រូបភាពប្រចាំសប្តាហ៍៖ ស្វាគមន៍មកកាន់ក្រុងអង្គរនាពេលព្រឹកព្រលឹម

ផ្សាយនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរា បញ្ចប់គម្រោងជួសជុលខឿនបាកាណប៉ែកអាគ្នេយ៍ នៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរាដែលជួសជុលខឿនបាកាណ ប៉ែកអាគ្នេយ៍ នៃប្រាសាទអង្គរវត្ត ដំណាក់កាលទី៣ បញ្ចប់ជាស្ថាពរ។

ការជួសជុលខឿនបាកាណប៉ែកអាគ្នេយ៍នៃប្រាសាទអង្គរវត្ត ដំណាក់កាលទី៣នេះ បានចាប់ផ្តើមជួសជុលតាំងពីដើមខែមករា ឆ្នាំ២០២៣មក។ មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោក ឃាម មុនី ឱ្យដឹងថា ក្នុងគម្រោងជួសជុលខឿនបាកាណ ប៉ែកអាគ្នេយ៍ នៃប្រាសាទអង្គរវត្ត គឺក្រុមការងារបានជួសជុលថ្មបែកបាក់ចំនួន២៩២ដុំ ដែលរុះរើពីតាមផ្នែកនៃជ្រុងនីមួយៗឱ្យល្អរឹងមាំរួចហើយរៀបចំទៅតាមកន្លែងដើមឡើងវិញ។

លោក ឃាម មុនី ឱ្យដឹងទៀតថា បន្ថែមពីលើការជួសជុលថ្មបែកបាក់ពីតាមផ្នែកនៃជ្រុងនីមួយៗឱ្យរឹងមាំរួចហើយរៀបចំទៅតាមកន្លែងដើមឡើងវិញនោះ ក្រុមការងារបច្ចេកទេសក៏បានជួយសង្គ្រោះការខូចខាតជាច្រើនកន្លែងផ្សេងទៀតឱ្យប្រសើរឡើងវិញដែរ ដូចជា រុញថ្មដែលញែកចេញពីគ្នាឱ្យចូលគ្នា ពង្រឹងរចនាសម្ព័ន្ធរបស់ប្រាសាទទាំងមូលឱ្យរឹងមាំឡើងវិញដែរ។







ខឿនបាកាណ ប៉ែកអាគ្នេយ៍ នៃប្រាសាទអង្គរវត្តដែលមានអាយុកាលនៃសំណង់យូរលង់មកហើយ បានរងការខូចខាតដោយសារតែដើមឈើដុះចាក់ឫសចូលតាមថ្នេរថ្មខឿន និងចូលទៅក្នុងគ្រឹះធ្វើឱ្យថ្មរហែកញែកចេញពីគ្នា រួមផ្សំនិងកត្តាទឹកភ្លៀងហូរចូលតាមចន្លោះថ្មទៅក្នុងគ្រឹះផងបណ្តាលឱ្យគ្រឹះខ្សោយនិងស្រុត។

ក្រុមអ្នកបច្ចេកទេសរំពឹងថា ក្រោយពីបញ្ចប់ការជួសជុលខឿនបាកាណរបស់ប្រាសាទអង្គរវត្ត គឺជាទីតាំងសំខាន់ដែលធ្វើឱ្យភ្ញៀវទេសចរឆ្លងកាត់ឥតដាច់ ដូច្នេះហើយបានជាអ្នកជំនាញត្រូវយកចិត្តទុកដាក់ថែរក្សាបេតិកភណ្ឌដ៏មហស្ចារ្យមួយនេះឱ្យបានល្អដើម្បីរួមចំណែកក្នុងការលើកតម្លៃក្នុងតំបន់នេះផង និងអាចបង្កើនកន្លែងទស្សនាដល់ទេសចរឱ្យកាន់តែមានជម្រើសច្រើនផង៕







ការងារជួសជុលបង្គាន់ដៃនាគប្រវែង២៤ម៉ែត្រ នៅជ្រុងឦសានខាងក្នុងរោងទងទី១ នៃប្រាសាទបន្ទាយសំរែបានបញ្ចប់ហើយ

ផ្សាយនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤



ក្រុមអភិរក្សថ្ម(SCU)នៃអាជ្ញាធរជាតិអប្សរាបានជួសជុលបង្គាន់ដៃនាគប្រវែង២៤ម៉ែត្រ នៅជ្រុងឦសានខាងក្នុងរោងទងទី១នៃប្រាសាទបន្ទាយសំរែ បញ្ចប់ជាស្ថាពរហើយកាលពីចុងឆ្នាំ២០២៣កន្លងទៅ។ គម្រោងនេះមានរយៈពេលប្រមាណ៦ខែ ដោយបានចាប់ផ្តើមតាំងពីពាក់កណ្តាលខែមិថុនាឆ្នាំ២០២៣មក។

ប្រធានក្រុមការងារអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោក ឡុង ណារី បានឱ្យដឹងថា ការងារជួសជុលបង្គាន់ដៃនាគ ប្រវែង២៤ម៉ែត្រ នៅជ្រុងឦសានខាងក្នុងរោងទងទី១របស់ប្រាសាទបន្ទាយសំរែបានបញ្ចប់កាលពីចុងឆ្នាំ២០២៣កន្លងទៅ។ លោក ឡុង ណារីបន្តថា រចនាសម្ពន្ធបង្គាន់ដៃនាគរបស់ប្រាសាទបន្ទាយសំរែ បានរងការខូចខាតធ្ងន់ធ្ងរដោយរលំបាក់បែកជាច្រើនបំណែក កន្លែងខ្លះធ្លាក់លើដីនិងខ្លះទៀតផ្ទៀងទ្រេតមិនមានលំនឹងធ្លាក់ថ្មមកលើកម្រាលជាដើម។





លោក ឡុង ណារី ឱ្យដឹងទៀតថា រយៈពេល៦ខែ ក្រុមការងារបានប្រឹងប្រែងប្រមូលបំណែកថ្មបង្កាន់ដៃនាគ ដែលមាននៅនិងកន្លែង និងស្វែងរកបំណែកខ្លះទៀត ដែលចល័តទៅទីតាំងផ្សេងៗ យកមករៀបចំផ្គុំឡើងវិញ ទៅតាមលទ្ធភាពដែលអាចរកឃើញ។ រីឯ ទីតាំងមួយចំនួន ដែលមិនអាចរកឃើញ គឺបានបន្ថែមថ្មថ្មីដំនួសដើម្បីឱ្យ បង្កាន់ដៃនាគរក្សាបាននូវទម្រង់ដើម និងមានភាពរឹងមាំជាថ្មីម្តងទៀត។

ក្រោយពីក្រុមអ្នកជំនាញបានបញ្ចប់ការងារជួសជុល បង្កាន់ដៃនាគនេះ បានជួយលើកសោភ័ណភាពនៃប្រាសាទនេះឡើងវិញ ព្រមទាំងមានសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរដែលទស្សនានៅប្រាសាទបន្ទាយសំរ៉ែដែរ។ ជាមួយគ្នានេះ ក្រុមអ្នកជំនាញក៏សំណូមពរដល់ភ្ញៀវទេសចរគ្រប់រូប សូមកុំអង្គុយឬផ្អែកលើសំណង់បុរាណដែលចាស់ទ្រុឌទ្រោមនេះ ដើម្បីរួមគ្នាថែរក្សាបន្តទៅមុខទៀត ប្រយោជន៍សម្រាប់ភាពគង់វង្សយូរអង្វែងនូវមរតកដូនតារបស់យើងទាំងអស់គ្នា៕



ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលមកទស្សនាប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៩ ខែមករា ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរាសហការជាមួយអង្គការមរតកវប្បធម៌ខ្មែរ បើកកម្មវិធីអប់រំបេតិកភណ្ឌ នៅសាលាបឋមសិក្សាក្របីរៀល

ផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤

នាព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា សហការជាមួយអង្គការមរតកវប្បធម៌ខ្មែរ (Khmer Heritage Organization) បានបើកកម្មវិធីអប់រំបេតិកភណ្ឌ នៅសាលាបឋមសិក្សាក្របីរៀល ក្រោមអធិបតី **ឯកឧត្តម ឡុច កុសល** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា។



កម្មវិធីអប់រំបេតិកភណ្ឌនៅសាលាបឋមសិក្សាក្របីរៀលនេះ បានដំណើរការតាំងពីឆ្នាំ២០២០ដែលមានសិស្សានុសិស្សចូលរួមសរុបប្រមាណជាង៧០០នាក់ ដែលក្នុង១ឆ្នាំៗមានសិស្សប្រមាណ២០០នាក់មកពីថ្នាក់ទី៥ និងទី៦។ ជាទូទៅ កម្មវិធីអប់រំបេតិកភណ្ឌមានរយៈពេល៩ខែក្នុង១ឆ្នាំ។

នាឱកាសបើកកម្មវិធីអប់រំបេតិកភណ្ឌ **ឯកឧត្តម ឡុច កុសល** មានមតិសំណេះសំណាលទាក់ទងនឹងការរស់នៅរបស់អ្នកស្រុក កុមារ និងសិស្សានុសិស្សដែលមានកព្វសំណាងដែលបានកើត សិក្សារៀនសូត្រ និងរស់នៅក្នុងតំបន់ដែនដីដ៏ពិសិដ្ឋនៃអង្គរ ព្រមទាំងលើកទឹកចិត្តកោតសរសើរដល់លោកគ្រូ អ្នកគ្រូដែលបានចូលរួម និងសហការល្អក្នុងការដឹកនាំ និងជំរុញសិស្សានុសិស្សឱ្យសិក្សា និងអនុវត្តតាមកម្មវិធី។

មិនតែប៉ុណ្ណោះ **ឯកឧត្តម ឡុច កុសល** បានណែនាំសិស្សានុសិស្សឱ្យយកចិត្តទុកដាក់សិក្សារៀនសូត្រក្នុងកម្មវិធីអប់រំនេះ ដែលនឹងអាចផ្តល់ប្រយោជន៍សំខាន់សម្រាប់ការងារអនាគត។ ជាពិសេស សិស្សានុសិស្សទាំងនេះ នឹងអាចជាអ្នកបន្តវេន និងជាអ្នកដឹកនាំដ៏ល្អលើវិស័យថែរក្សាការពារ និងគ្រប់គ្រងកេរមរតកវប្បធម៌ក្នុងសហគមន៍របស់ខ្លួន៕





អាជ្ញាធរជាតិអប្សរា កំពុងរៀបចំផ្តុំប្រាសាទជមឡើងវិញ

ផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉ែ(KOICA) តាមរយៈមូលនិធិបេតិកភណ្ឌកូរ៉ែ(KCHF)កំពុងជួសជុលប្រាសាទជមដែលទទួលរងការខូចខាតធ្ងន់ធ្ងរឱ្យរឹងមាំឡើងវិញតាមបច្ចេកទេសអាណាស្ទីឡូស(Anastylosis)រុះរើតួរបស់ប្រាសាទដើម្បីជួសជុលពង្រឹងគ្រឹះ ពង្រឹងរចនាសម្ពន្ធពាក់ព័ន្ធផ្នែកខាងក្រោម ព្រមទាំងជួសជុលថ្មដែលបាក់ខូច និងរៀបផ្តុំតួប្រាសាទជាថ្មីឡើងវិញ ដោយរក្សាឱ្យបាននូវទម្រង់ដើមទាំងស្រុង។

ស្ថាបត្យករនៃអាជ្ញាធរជាតិអប្សរាលោកថៃយ៉ាម៉ង់ ឱ្យដឹងថាគម្រោងជួសជុលប្រាសាទជម បានចាប់ផ្តើមនៅឆ្នាំ២០១៩ ដោយជំហានដំបូងបានធ្វើកំណាយស្រាវជ្រាវ វាយតម្លៃការខូចខាត ធ្វើសម្រង់ប្លង់និងស្វែងរកឯកសារ និងរូបភាពចាស់ៗសម័យបារាំង ព្រមទាំងរុះរើថ្មតាមបច្ចេកទេសអាណាស្ទីឡូស ដោយបែងចែកជា២ដំណាក់កាល។ ថ្មដែលរើមានចំនួន៣៥ស្រទាប់ ដោយថ្មភក់ចំនួន៣៥៨០ដុំ និងថ្មបាយក្រៀមមាន៤១០០ដុំ។ លោក យ៉ាម៉ង់ ឱ្យដឹងទៀតថា ចំពោះការពង្រឹងគ្រឹះដែលស្រុតឱ្យរឹងមាំឡើងវិញ នៅតាមកន្លែងខូចខាតនានាត្រូវផ្លាស់ប្តូរថ្មបាយក្រៀមថ្មី និងបច្ចុប្បន្ននេះ កំពុងរៀបសាកល្បងកម្រាល ដើម្បីឈានទៅដល់ការរៀបផ្តុំខឿនរបស់ប្រាសាទទាំងមូលឡើងវិញ។





ស្ថាបត្យករូបនេះបញ្ជាក់ទៀតថា ថ្មដែលរលុះធ្លាក់ផ្នែកខាងលើបានរកឃើញប្រមាណ៣០ភាគរយ ហើយថ្មមួយចំនួនបានរងការខូចខាតដែលទាមទារការជួសជុលនិងព្យាបាលដោយយកចិត្តទុកដាក់។ ជាមួយគ្នានេះដែរ ការស្វែងរកថ្មនៅប្រាសាទជម មានការលំបាកក្នុងការផ្គុំឡើងវិញ ដោយសារគំនរថ្មខ្លះមានលាយឡំគ្នាជាមួយថ្មប្រាសាទផ្សេងទៀតដែលនៅជុំវិញ។

ស្ថានភាពរបស់ប្រាសាទជម ផ្នែកកំពូលនៃប្រាសាទត្រូវបានរលុះធ្លាក់ កន្លែងខ្លះទៀតហែកក្រៀក ថ្មស្ទើរតែបាត់បង់រូបរាងដើម បណ្តាលមកពីអាយុកាលនៃសំណង់ កត្តាសង្គ្រាម កត្តាកង្វះការថែទាំយូរអង្វែង និងកត្តាធម្មជាតិ ដូចជាឫសឈើចាក់បំបែករចនាសម្ព័ន្ធរបស់ប្រាសាទរហូតទៅដល់ដីគ្រឹះ ធ្វើឱ្យទឹកភ្លៀងហូរចូល នាំឱ្យដីគ្រឹះចុះខ្សោយនិងធ្វើឱ្យស្រុតចុះ ថែមទាំងទ្រេតចំនួន៦ដីរក្រេ។ ក្រុមការងារពឹងថាគម្រោងជួសជុលប្រាសាទជម អាចនឹងបញ្ចប់នៅឆ្នាំ២០២៥ខាងមុខ៕







ស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ បណ្តុះពូជឈើលេខ១ និងលេខ២

ផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤





ស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ ជាស្ថានីយមួយក្នុងចំណោមស្ថានីយទាំង១០របស់អាជ្ញាធរជាតិអប្សរា ដែលបណ្តុះកូនឈើច្រើនប្រភេទសម្រាប់ដាំក្នុងតំបន់រមណីយដ្ឋានអង្គរ និងសម្រាប់ចែកចាយ។ ស្ថានីយនេះបណ្តុះប្រភេទពូជឈើលេខ១ និងប្រភេទឈើលេខ២។

អ្នកស្រី ព្រំ ស៊ីណា អ្នកមើលការខុសត្រូវនៅក្នុងស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ បានឱ្យដឹងថា នារដូវប្រាំងនេះ ក្រុមការងារមានភាពមមាញឹកបន្តិច ដែលត្រូវសម្រុកវាយដី លាយដី ច្រកថង់ ត្រៀមស្ទូងកូនឈើ។ អ្នកស្រីបន្តថា នៅកំឡុងខែ មីនា និងមេសា គ្រាប់ដើមឈើនឹងអាចប្រមូលផលបានច្រើន ខណៈដែលបច្ចុប្បន្ននេះវាកំពុងចេញផ្តែ ដែលឈើទាំងនោះរួមមាន ឈើទាល គគីរ ត្រាច និងផ្តេកជាដើម។ល។

តាមការបញ្ជាក់ពីអ្នកស្រី ព្រំ ស៊ីណា ស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវមានបណ្តុះពូជឈើសរុប ១៥មុខ ដែលជាប្រភេទឈើលេខ១ និងលេខ២។ ហើយនារដូវប្រាំងនេះ ការមើលថែទាំកូនឈើមានភាពលំបាកបន្តិច ដោយសារត្រូវស្រោចទឹក និងដាក់ជីបំប៉នបន្ថែម ដែលខុសពីរដូវវស្សាមានភ្លៀងធ្លាក់គ្រប់គ្រាន់ និងមិនពិបាកមើលថែច្រើន។

តាមការបញ្ជាក់ពីអ្នកស្រី ព្រំ ស៊ីណា ស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ ដូចស្ថានីយផ្សេងៗទៀតដែរគឺបណ្តុះដើម្បីដាំដុះក្នុងតំបន់រមណីយដ្ឋានអង្គរ និងសម្រាប់ចែកចាយដល់បងប្អូនប្រជាពលរដ្ឋ ដែលស្នើសុំទៅដាំនៅតាមតំបន់ ឬខេត្ត ក្រុងនានានៅក្នុងប្រទេសកម្ពុជា។



នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានជួសជុលកែសម្រួលផ្លូវ សម្តេចវិបុលបញ្ញា សុខ អាន ដែលខូចខាតក្នុងរដូវវស្សា ដើម្បីយានយន្តចរាចរបានជាយស្រួលឡើងវិញ

ផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤



ក្រុមការងារភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទអង្គរវត្ត បានប្រទះឃើញកាមេរ៉ា ១គ្រឿង ដែលភ្ជៀវជនជាតិ Guatemala បានភ្លេចនៅចំណុចមាត់ស្រះទឹកខាងលិចឆៀងខាងត្បូងគោលដៅព្រះពន់

រីឯ គោលដៅប្រាសាទបាយ័ន បានប្រទះឃើញកាបូបស្ពាយចំហៀងមួយដែលភ្ជៀវជនជាតិអាល្លឺម៉ង់ បានភ្លេចនៅក្បែរជណ្តើរឡើងលើរួតទី៧ នៃប្រាសាទបាយ័ន ភ្លាមៗនោះ ក្រុមការងារបានប្រគល់ជូនគាត់វិញ

ផ្សាយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤













សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ទទឹងតាំងពិព័រណ៌បញ្ចាញវត្ថុសិល្បៈក្វាតចំនួន៦៩៥៦គ្រាប់

ផ្សាយនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ គ្រោងនឹងតាំងពិព័រណ៌វត្ថុសិល្បៈក្វាតចំនួន៦៩៥៦គ្រាប់ ដែលបានពីកំណាយស្រាវជ្រាវ ដើម្បីឱ្យសាធារណជនបានស្គាល់ និងទស្សនាចាប់ពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤តទៅ។

ក្រុមអ្នកស្រាវជ្រាវ នៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញវត្ថុសិល្បៈបុរាណក្វាត ចំនួន៦៩៥៦គ្រាប់នេះនៅឯប្រាសាទកណ្តាលស្រះស្រង់ កាលពីឆ្នាំ២០២០កន្លងទៅ។មគ្គទេសក៍សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ លោក គុន ផល្លី មានប្រសាសន៍ថា វត្ថុសិល្បៈបុរាណក្វាត ចំនួន៦៩៥៦គ្រាប់នេះនឹងដាក់តាំងពិពរណ៌ជាអចិន្ត្រៃយ៍ក្នុងសាលពិព័រណ៌សារមន្ទីរ។ វត្ថុសិល្បៈនេះ មានបីប្រភេទគឺពណ៌ស្វាយ (កែវណាហ្វាន)Amethyst ពណ៌លឿង(ស៊ីទ្រីន)Citine និងពណ៌សថ្លា(គ្រីស្តាល់)Crystal។ ក្រៅពីការដាក់តាំងក្វាតនេះ ក៏មានការដាក់តាំងបង្ហាញនូវវត្ថុមួយចំនួនទៀតដែលបានមកពីកន្លែងតែមួយនៅប្រាសាទកណ្តាលស្រះស្រង់ដែរដូចជា រូបអណ្តើកថ្ម អាវុធត្រីសូល៍ អាវុធបញ្ចសូល៍ និងចតុសូល៍ជាដើម។

លោក គុន ផល្លី ឱ្យដឹងទៀតថា ការតាំងបង្ហាញពិព័រណ៌ជាអចិន្ត្រៃយ៍នេះក្នុងគោលបំណងបង្ហាញជូនសាធារណជនជាតិ អន្តរជាតិ អ្នកស្រាវជ្រាវ និងសិស្សានុសិស្សឱ្យមកទស្សនាសិក្សាស្វែងយល់អំពីវត្ថុសិល្បៈ វត្ថុសក្ការៈសម្រាប់



បញ្ចុះនៅគ្រឹះប្រាសាទកាលពីសម័យបុរាណ ព្រមទាំងដឹងពីប្រវត្តិសាស្ត្រ វប្បធម៌ សាសនា និងទំនៀមទម្លាប់របស់ជាតិខ្មែរផងដែរ។

ជារៀងរាល់ថ្ងៃសៅរ៍ដើមខែនីមួយៗ សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរតែងតែបើកឱ្យភ្ញៀវជាតិ អន្តរជាតិចូលទស្សនាដោយមិនគិតថ្លៃ ដែលនេះ គឺជាចំណុចមួយដ៏ពិសេសសម្រាប់លើកទឹកចិត្តដល់ភ្ញៀវជាតិ អន្តរជាតិ សាធារណជន អ្នកស្រាវជ្រាវ និងសិស្សានុសិស្ស ចូលទស្សនាសារមន្ទីរឱ្យបានកាន់តែច្រើន៕

សេចក្តីប្រកាសព័ត៌មាន

ផ្សាយនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៣២/អ.ប.ស.ហ
២៤

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ នៅរសៀលថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ គណនីមួយនៃបណ្តាញទំនាក់ទំនងសង្គមFacebook បានផ្សព្វផ្សាយនូវវីដេអូដែលក្នុងនោះបានបង្ហាញអំពីការប្រើប្រាស់ហិង្សារបស់បុគ្គលិកសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា ទៅលើកុមារដើរលក់កូនសត្វអណ្តើកចល័ត នៅបរិវេណកសិន្នុអង្គរវត្ត។ ពាក់ព័ន្ធនឹងករណីនេះ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនសាធារណជនទាំងអស់ មេត្តាជ្រាបដូចខាងក្រោម៖

១- ក្រោយពីបានទទួលព័ត៌មាននេះ ថ្នាក់ដឹកនាំពាក់ព័ន្ធនៃអាជ្ញាធរជាតិអប្សរា បានរៀបចំកិច្ចប្រជុំមួយជាបន្ទាន់ ដោយបានហៅបុគ្គលិកនោះ មកស្នរនាំអំពីមូលហេតុពិតប្រាកដ នៃការឈានទៅដល់ការប្រើប្រាស់នូវសកម្មភាពមិនសមរម្យខាងលើ។ តាមរយៈនេះ អាជ្ញាធរជាតិអប្សរា បានសម្រេចដាក់ពិន័យរដ្ឋបាល និងតម្រូវឱ្យចុះហត្ថលេខាលើកិច្ចសន្យាទទួលស្គាល់កំហុស និងបញ្ឈប់នូវរាល់សកម្មភាពហិង្សាបែបនេះ នាពេលអនាគត។ ក្នុងករណីមិនរាងចាល នឹងត្រូវបណ្តេញចេញពីការងារ និងទទួលរងទណ្ឌកម្មតាមផ្លូវច្បាប់ជាធរមាននានា។ ដោយឡែក អាជ្ញាធរជាតិអប្សរា ក៏បានណែនាំឱ្យបុគ្គលិករូបនេះ ទៅសុំទោសឪពុកម្តាយ និងកុមាររូបនេះដោយផ្ទាល់ផងដែរ។

២- ថ្នាក់ដឹកនាំពាក់ព័ន្ធនៃអាជ្ញាធរជាតិអប្សរា ជានិច្ចកាលតែងតែបានណែនាំដល់មន្ត្រី បុគ្គលិកភ្នាក់ងារ ពលករ និងឆ្មាំ នៃអាជ្ញាធរជាតិអប្សរា ឱ្យប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងចៀសវាងឱ្យបានជាដាច់ខាត នូវការប្រើប្រាស់អំពើហិង្សាក្នុងការដោះស្រាយបញ្ហានានា។

៣- អាជ្ញាធរជាតិអប្សរាមិនគាំទ្រ និងមិនអាចទទួលយកបានជាដាច់ខាត នូវរាល់ការប្រើប្រាស់អំពើហិង្សាក្នុងការអនុវត្តការងារ ដែលធ្វើឱ្យប៉ះពាល់ដល់វិន័យ សីលធម៌ និងគុណធម៌ដែលមានជាធរមានក្នុងលក្ខន្តិកៈរបស់មន្ត្រីរាជការស៊ីវិល-បុគ្គលិកសាធារណៈ។

៤- ដោយឡែក អាជ្ញាធរជាតិអប្សរា សូមអំពាវនាវសារជាថ្មីម្តងទៀត ដល់សាធារណជនទាំងអស់ មេត្តាកុំលក់ ឬយកសត្វគ្រប់ប្រភេទទៅលែងក្នុងកសិន្នុនានា នៃរមណីយដ្ឋានអង្គរដោយមិនមានការអនុញ្ញាត ដើម្បីចៀសវាងការប៉ះពាល់ដល់សត្ត និងរុក្ខជាតិដែលមានប្រភពដើមនៅទីនោះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាត់ ឃុំអំពិល
ស្រុកប្រាសាទបាគង់ ខេត្តសៀមរាប

អាជ្ញាធរដឹកនាំការពារមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

សូមអញ្ជើញទស្សនារូបភាពដ៏ស្រស់ត្រកាលនៃរមណីយដ្ឋានអង្គរ នារាត្រីថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ដើម្បីត្រៀមរៀបចំព្រឹត្តិការណ៍ឆប្បធម៌ចម្រុះ នៃព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋប្រជាមានិតចិន អបអរសាទរឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជន កម្ពុជា-ចិន ២០២៤ ដែលនឹងប្រព្រឹត្តទៅនៅព្រះលានជល់ដំរី ក្រុងអង្គរធំ នាល្ងាចថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤













រូបភាពប្រចាំសប្តាហ៍៖ អង្គរវត្ត ពេលថ្ងៃរៀបចិចបញ្ចេញពន្លឺពណ៌មាសលើចម្លាក់ឆានា ជាពិសេសស្រមោលចម្រឹងបង្ហួចនៅតាមជញ្ជាំងចេញជារូបកំពូលប្រាសាទអង្គរវត្ត គួរជាទីចាប់អារម្មណ៍

ផ្សាយនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៤











រូបភាពប្រចាំសប្តាហ៍÷ ខ្លោចទ្វារគោកវ ពេលស្ងរិយារៀបអស្តង្គត

ផ្សាយនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរាជួសជុលខឿនព្រះលានជល់ដំរី តាមរយៈមូលនិធិបេតិកភណ្ឌកូរ៉េខាងត្បូង

ផ្សាយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាដែលសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) តាមរយៈមូលនិធិបេតិកភណ្ឌកូរ៉េ(KCHF) កំពុងដំណើរការជួសជុលរចនាសម្ព័ន្ធមួយចំនួនរបស់ព្រះលានជល់ដំរី ដែលរងការខូចខាតឱ្យប្រសើរឡើងវិញ។



អ្នកគ្រប់គ្រងគម្រោងមូលនិធិបេតិកភណ្ឌកូរ៉េ លោក PARK JIMIN មានប្រសាសន៍ថា ការជួសជុលព្រះលានជល់ដំរីកំពុងធ្វើនៅទីតាំងចំនួន២ផ្សេងគ្នា គឺមួយស្ថិតនៅផ្នែកខាងជើង ប្រវែង២០ម៉ែត្រ និងមួយទៀត នៅផ្នែកខាងត្បូង ប្រវែង១៥ម៉ែត្រ។ ក្នុងដំណើរការជួសជុល

ក្រុមអ្នកបច្ចេកទេសផ្តោតការអនុវត្តលើការងារសំខាន់ៗមួយចំនួនដូចជា ពង្រឹងគ្រឹះ ពង្រឹងរចនាសម្ព័ន្ធពាក់ព័ន្ធផ្នែកខាងក្នុង និងខាងក្រោម ព្រមទាំងរៀបផ្គុំជញ្ជាំងនៃខឿនដែលទ្រេត និងថ្មពុកផុយឱ្យល្អឡើងវិញទៅតាមទម្រង់ដើម។

លោក PARK JIMIN បានឱ្យដឹងទៀតថា តាមការរកឃើញនៅទីតាំងទាំងពីរនេះ មានសភាពប្រហាក់ប្រហែលគ្នា គឺផ្នែជញ្ជាំងបានទ្រេតខ្លាំង អាចនឹងរលំ ព្រមទាំងថ្មបាយក្រៀម និងថ្មកក់ខ្លះបានពុកផុយបណ្តាលមកពីអាយុកាល និងទឹកភ្លៀងហូរច្រោះខាងក្រោមធ្វើឱ្យគ្រឹះខាងក្រោមបាតបង់លំនឹង។





លោក ព្រំ ទិត្យឆពណ្ណាទ្ធ ស្ថាបត្យករ និងជាក្រុមការងារបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាមានប្រសាសន៍ថាមូលហេតុសំខាន់ៗមួយចំនួនដែលធ្វើឱ្យគ្រឹះជញ្ជាំងស្រុត និងទ្រេតខ្លាំងដោយសារតែគ្រឹះខាងក្រោមមានកន្លែងខ្លះស្រុត បណ្តាលមកពីឫសឈើដុះចាក់ចូលទៅក្នុងរចនាសម្ព័ន្ធធ្វើឱ្យថ្មមួយចំនួនរំកិលចេញពីទីតាំងដើមបង្កើតបានជាប្រហោងនៅតាមចន្លោះថ្ម ជាហេតុធ្វើឱ្យទឹកហូរច្រោះចូលទៅតាមប្រហោងថ្មនាំល្បាយដីខ្សាច់ចេញមកក្រៅជាដើម។

ជាច្រើនខែមកនេះ ក្រុមអ្នកជំនាញបានរើថ្មកម្រាល និងជញ្ជាំងខឿនមួយផ្នែកដែលក្រៀកចេញ ដើម្បីពិនិត្យមើលស្ថានភាពជញ្ជាំងថ្មបាយក្រៀម និងរៀបថ្មកក់ ថ្មបាយក្រៀមទាំងនោះទៅតាមកន្លែងដើមឡើងវិញ ហើយចំពោះកន្លែងខ្លះដែលថ្មខូច គឺព្យាយាមជួសជុល ប៉ុន្តែបើនៅតែមិនអាចជួសជុលបានទេ គឺត្រូវដាក់ថ្មថ្មីតិចតួចដើម្បីជំនួស៕

ក្រុមភ្នាក់ងារទេសចរណ៍ប្រចាំការនៅគោលដៅក្នុងអង្គរធំ បានជួយសង្គ្រោះភ្ញៀវទេសចរ មានអាការៈឈឺតមុខ នៅរួតទី២ខាងត្បូងនៃប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤



នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ១០:៣០នាទី មានភ្ញៀវទេសចរជនជាតិខ្មែរម្នាក់ ភេទប្រុស អាយុ៦១ឆ្នាំ បានខ្សល់ចាប់ និងឈឺតមុខ ខណៈកំពុងទស្សនាប្រាសាទ នៅរួតទី២ ខាងត្បូងប្រាសាទបាយ័ន ភ្លាមៗនោះ ភ្នាក់ងារទេសចរណ៍ប្រចាំការនៅទីនោះ បានជួយសង្គ្រោះបឋមជូនដល់គាត់ និងបន្ទាប់ពីបានធូរស្បើយភ្ញៀវទេសចររូបនោះ បានត្រលប់ទៅគេហដ្ឋានវិញ៕



ភ្នាក់ងារទេសចរណ៍ប្រាសាទបន្ទាយសំរែ និងភ្ញៀវកម្សាន្តបានប្រទះឃើញកាមួយពណ៌ខ្មៅលាយទឹកដោះគោមួយ នៅចំណុចតួបមកណ្តាលប្រាសាទបន្ទាយសំរែ ក្នុងកាមួយនោះ មានសំបុត្រទស្សនាវមណីយដ្ឋានអង្គរចំនួន០២ ថវិកាមួយចំនួន និងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួន ភ្នាមៗនោះ ភ្នាក់ងារទេសចរណ៍បានប្រគល់ជូនភ្ញៀវវិញ ជាជនជាតិចារ៉ាំង

ផ្សាយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤







ក្រុមភ្នាក់ងារទេសចរណ៍គោលដៅប្រាសាទតាព្រហ្ម បានជួយសង្គ្រោះបឋមជន់ភ្ញៀវទេសចរជនជាតិចារ៉ាំង តេទស្រី ដែលបានដួលក្រិចកជើងខាងឆ្វេង នៅចំណុចរានហាលខាងលិច និងបានជួយជីកគាត់ទៅកាន់រុំម៉ករបស់គាត់ ដើម្បីបញ្ជូនគាត់ទៅកាន់មន្ទីពេទ្យ

ផ្សាយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរា ស្វែងរកម្ចាស់សម្ភារដែលបាត់ស្នេច នៅគោលដៅប្រាសាទអង្គរវត្ត និងប្រាសាទតាព្រហ្ម ដែលស្ថាក់ចារទេសចរណ៍ប្រទះឃើញសម្ភារមួយចំនួន មានដូចជា កាបូបដៃ ពណ៌ខ្មៅមួយ ទូរសព្ទដៃមួយគ្រឿង ម៉ាកHUAWEI មួយគ្រឿង និង ipad មួយគ្រឿង ស្ថាក់ចារទេសចរណ៍បានធ្វើការប្រគល់ជូនតំណាងទេសចរណ៍ដើម្បីរង់ចាំម្ចាស់មកទទួលយកវិញ

ផ្សាយនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤













ស្ពានផ្លូវកង់ប្រាសាទតាកែវបង្កើតបរិយាកាសថ្មីសម្រាប់អ្នកជិះកង់

ផ្សាយនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរាបានសាងសង់ស្ពានផ្លូវកង់ស្របតាមស្ពានប្រាសាទតាកែវ ដើម្បីសម្រួលដល់ការជិះកង់របស់ភ្ញៀវទេសចរក្នុងរមណីយដ្ឋានអង្គរឱ្យកាន់តែងាយស្រួល។

លោក សុខ សូសិលា អនុប្រធាននាយកដ្ឋានទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា អាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមសង់ផ្លូវកង់ក្នុងរមណីយដ្ឋានអង្គរនៅឆ្នាំ២០២០ ដើម្បីសម្រួលដល់ភ្ញៀវទេសចរដែលនិយមជិះកង់កម្សាន្ត។ ផ្លូវកង់ក្នុងរមណីយដ្ឋានអង្គរប្រវែងសរុបជាង ២៣គីឡូម៉ែត្រ ហើយក្នុងនោះក៏មានឆ្លងស្ទឹងចំនួន៤ទីតាំងផងដែរ។



ស្ពានផ្លូវកង់ប្រាសាទតាកែវ គឺជាទីតាំងមួយក្នុងចំណោម៤ទីតាំងខាងលើ ដែលអាជ្ញាធរជាតិអប្សរា សាងសង់សម្រួលដល់អ្នកជិះកង់ ដោយចង់បែងចែកឱ្យដាច់រវាងផ្លូវឬស្ពានធ្វើដំណើរទូទៅ និងផ្លូវកង់។ ស្ពាននេះមានទទឹង ២.៥ម៉ែត្រ និងបណ្តោយ៦៥ម៉ែត្រ។ ចំណែកស្ពានកង់៣ទីតាំងទៀត រួមមាន ស្ពានអង្គរ ស្ពានក្រាំងក្រូច និងស្ពាននាគព័ន្ធ។ ក្រៅពីនេះ ក៏មានស្ពានខ្នាតតូចឆ្លងកាត់ ២ទីតាំងទៀត ដូចជាកសិន្នុយសោធរ និងអតីតទ្វារទឹកនាគព័ន្ធ។





គោលបំណងសំខាន់នៃការបង្កើតផ្លូវកង់ក្នុងរមណីយដ្ឋានអង្គរ គឺការចង់បែងចែកឱ្យដាក់ពីគ្នារវាងផ្លូវចរាចរណ៍ធម្មតា និងផ្លូវកង់ ដើម្បីលើកកម្ពស់កីឡាជិះកង់ ការកាត់បន្ថយគ្រោះថ្នាក់នៅលើដងផ្លូវរវាងអ្នកជិះយានយន្ត និងអ្នកជិះកង់ ពិសេសកាត់បន្ថយផ្សែងយានយន្តដែលប៉ះពាល់ដល់ថ្មប្រាសាទ។

ចំពោះរចនាបថនៃការសង់ស្ពានកង់នេះ លោកបញ្ជាក់ថា បានជ្រើសរើសការរៀបចំបែបសាមញ្ញស្រដៀងនឹងធម្មជាតិ



ជុំវិញ ដោយមិនបង្កើតអ្វីដែលថ្មីលេចធ្លោពេកទេ គឺស្របតាមគោលគំនិតរបស់ថ្នាក់ដឹកនាំថា ការអភិរក្សដើរស្របនឹងការអភិវឌ្ឍ។

ជាមួយគ្នានេះ លោក សុខ សូសិលា សំណូមពរឱ្យភ្ញៀវទេសចរ ចូលរួមលើកតម្កើងការជិះកង់ ឱ្យបានកាន់តែច្រើននៅក្នុងតំបន់រមណីយដ្ឋានអង្គរ ក្នុងបំណងដើម្បីសុខភាព ប្តូរបរិយាកាសថ្មី ព្រោះថាការជិះកង់ធ្វើឱ្យយើងមានពេលគ្រប់គ្រាន់សម្រាប់ការទស្សនា ឬសិក្សាពីធម្មជាតិនៅជុំវិញ ពិសេសលុបបំបាត់ផ្សែងពុលដែលបង្កគ្រោះថ្នាក់ដល់ការអភិរក្សប្រាសាទ៕





អាជ្ញាធរជាតិអប្សរាសូមអំពាវនាវដល់អ្នកបើកបរយានយន្តដឹកភ្ញៀវទេសចរ ចូលរួមរក្សាសណ្តាប់ធ្នាប់ចតយានយន្តនៅក្នុងចំណតត្រឹមត្រូវ

ផ្សាយនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤





ពេលបច្ចុប្បន្ននេះ អ្នកបើករថយន្តគ្រប់ធុន និងរ៉ឺម៉ក ដឹកភ្ញៀវទេសចរខ្លះមិនព្រមចូលទៅចតយានយន្តតាមការណែនាំរបស់ភ្នាក់ងារសណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរាដែលប្រចាំការនៅទីនោះ ឱ្យបានត្រឹមត្រូវឡើយ បែរជាទៅចតនៅតាមចិញ្ចើមផ្លូវដើម្បីចាំទទួលភ្ញៀវនិងចតខុសកន្លែងជាដើម។

បញ្ហានេះ វាមិនត្រឹមតែធ្វើឱ្យមានគំរូអាក្រក់ប៉ុណ្ណោះទេ ក៏ប៉ុន្តែ វាក៏បានធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ គ្មានរបៀបរៀបរយ ព្រមទាំងបង្កឱ្យមានភាពកកស្ទះចរាចរណ៍នៅតាមដងផ្លូវ នឹងក៏អាចបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ផងដែរ។

អនុប្រធានក្រុមសណ្តាប់ធ្នាប់ប្រចាំតំបន់អង្គរកញ្ញា នៅចិន្តា បានឱ្យដឹងថា បច្ចុប្បន្ន បើទោះបីជាអ្នកបើកបររថយន្ត និងរ៉ឺម៉កដឹកភ្ញៀវទេសចរជាច្រើនបានយល់ដឹង និងធ្វើតាមការណែនាំរបស់បុគ្គលិកដោយចូលចតរថយន្តនៅក្នុងចំណតបានត្រឹមត្រូវក្តី ក៏ប៉ុន្តែ អ្នកបើករថយន្តជាពិសេស គឺរ៉ឺម៉កដឹកភ្ញៀវខ្លះ នៅតែមិនព្រមសហការជាមួយអាជ្ញាធរក្នុងការជួយរក្សាសណ្តាប់ធ្នាប់សារធារណៈនៅឡើយទេ។ ក្រុមអ្នកបើករ៉ឺម៉កខ្លះ នៅតែចតរ៉ឺម៉កនៅលើចិញ្ចើមផ្លូវដែលជាកន្លែងហាមឃាត់ ដើម្បីចាំទទួលយកភ្ញៀវដែលចេញពីទស្សនាអង្គរ និងមួយចំនួនទៀត បានចតរថយន្តឬរ៉ឺម៉កនៅចំផ្លូវចេញ-ចូលរំខានដល់គេឯងជាដើម។







កញ្ញា នៅ ចិន្តា មានប្រសាសន៍ទៀតថា បញ្ហាមួយចំនួនទៀត គឺមានអ្នកលក់អីវ៉ាន់នៅក្នុងចំណតរថយន្តខ្លះតែងតែទៅចោមរោមភ្ញៀវ និងបង្ខំឱ្យទិញសម្ភាររបស់ខ្លួន ប៉ុន្តែ នៅពេលដែលភ្ញៀវមិនទិញគឺបានប្រើពាក្យសម្តីមិនសមរម្យដាក់ភ្ញៀវថែមទៀតផង។ បញ្ហានេះ គឺជាទង្វើគ្មានសុជីវធម៌ដែលធ្វើឱ្យអ្នកទេសចរជាតិ និងអន្តរជាតិមិនសប្បាយចិត្ត។

អាជ្ញាធរជាតិអប្សរា សំណូមពរដល់ក្រុមអ្នកបើកបរយានយន្ត ឬរ៉ឺម៉កដឹកភ្ញៀវទេសចរទាំងឡាយដែលមិនទាន់បានគោរពតាមគោលការណ៍ណែនាំឱ្យបានត្រឹមត្រូវទាំងអស់ សូមមេត្តាយោគយល់ និងសហការជាមួយបុគ្គលិកដែលប្រចាំការនៅទីនោះ ធ្វើយ៉ាងណាចតយានយន្តនៅក្នុងចំណត ឱ្យបានត្រឹមត្រូវនិងមានរបៀបរៀបរយ ដើម្បីរួមគ្នារក្សាសណ្តាប់ធ្នាប់សាធារណៈឱ្យបានប្រសើរ ព្រមទាំងជាការជួយលើកតម្លៃនៃជនជាតិខ្មែរ ព្រមទាំងអង្គររបស់ខ្មែរឱ្យបានស័ក្តិសមសម្បត្តិបេតិកភណ្ឌ ដែលល្បីល្បាញបំផុតនៅក្នុងពិភពលោកនេះផង។ ហើយសូមភ្ញៀវទេសចរជាតិទាំងអស់ ដែលបាននាំគ្រួសារមកលេងអង្គរ មាននំចំណីអាហារយកមកទទួលទាននៅតាមតំបន់ឧទ្យានអង្គរ សូមជួយរក្សាបរិស្ថានឱ្យបានស្អាត ដោយពិសាររួចហើយសូមកុំបោះសំរាម ឬក៏ចង់ប្លាស្ទិកចោលរាយប៉ាយនៅតាមទីសាធារណៈ និងឧទ្យានអង្គរ។ សូមរួមគ្នាសម្អាតបរិស្ថានដើម្បីភាពស្រស់បំព្រងនៃសម្រស់អង្គរ ព្រមទាំងមោទនភាពនៃជាតិខ្មែរ៕



ក្រុមការងារសម្អាតរុក្ខជាតិលើប្រាសាទ នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា បានចុះសម្អាតរុក្ខជាតិ នៅប្រាសាទប្រែរូប

ផ្សាយនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤







ភ្នាក់ងារទេសចរណ៍ប្រចាំគោលដៅប្រាសាទអង្គរវត្ត បានសម្អាតជាងស្មោតនៅវាលស្មៅក្បែរស្រះទឹកខាងត្បូងដែលចាប់ និងធ្លាក់សំយោក ដើម្បីកុំឱ្យបាំងសម្រស់ទេសភាពនៃប្រាសាទ ធ្វើឱ្យភ្ញៀវទេសចរជាតិ និងអន្តរជាតិ អាចគយគន់ទេសភាព និងថតផ្តិតរូបភាពប្រាសាទអង្គរវត្តបានស្រស់ស្អាត

ផ្សាយនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤





ភ្នាក់ងារទេសចរណ៍ប្រចាំការនៅគោលដៅប្រាសាទតាព្រហ្ម ប្រទះឃើញការបូបរបស់ភ្ញៀវដែលភ្លេច នឹងបានប្រគល់ជូនម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤



នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០២៤ វេលាម៉ោង ០៥:២០ នាទីល្ងាច ក្រុមការងារភ្នាក់ងារទេសចរណ៍ ប្រចាំការនៅប្រាសាទតាព្រហ្ម បានប្រទះឃើញកាបូបស្ពាយចំហៀងពណ៌ខ្មៅមួយ នៅចំនុចច្រកចូលសាលរបាំ។ នៅវេលាម៉ោង ០៥:៣០នាទីល្ងាច ក្រុមភ្នាក់ងារទេសចរណ៍បានប្រគល់កាបូបនោះ ជូននគរបាលការពារបេតិកភណ្ឌ ដើម្បីរក្សាទុកង់ចាំម្ចាស់មករកវិញ។ លុះនៅវេលាម៉ោង ០៦:០០នាទី ល្ងាចថ្ងៃដដែលនោះ ក្រុមភ្នាក់ងារទេសចរណ៍ សហការជាមួយនគរបាលបេតិកភណ្ឌ បានប្រគល់កាបូបស្ពាយនោះ ជូនភ្ញៀវជនជាតិ ហូឡង់ កេទស្រី ក្រោយពីបានពិនិត្យឃើញថាពិតជារបស់គាត់មែន នៅប៉ុស្តិ៍ប្រចាំរបស់នគរបាលបេតិកភណ្ឌ ៕







សកម្មភាពក្រុមការងារសណ្តាប់ធ្នាប់ ជួយសម្រួលសណ្តាប់ធ្នាប់នៃការចតយានយន្តនៅតាមដងផ្លូវ

ផ្សាយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤



ក្រុមការងារសណ្តាប់ធ្នាប់ប្រចាំការនៅក្នុងរមណីយដ្ឋានអង្គរ បានជួយសម្រួលសណ្តាប់ធ្នាប់នៃការចតម៉ូតូ រ៉ឺម៉ក និងរថយន្ត របស់ភ្ញៀវទេសចរ និងបងប្អូនអ្នកប្រកបរបរដឹកជញ្ជូនភ្ញៀវនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត។ ការរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅតាមដងផ្លូវទាំងនេះ ដោយធ្វើយ៉ាងណាជំរុញឱ្យយានយន្ត ដែលដឹកភ្ញៀវទេសចរមកទស្សនាប្រាសាទ ចូលទៅចតនៅតាមកន្លែងចំណតឱ្យបានត្រឹមត្រូវ៕





នៅព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរណ៍ និងក្រុមការងារភ្នាក់ងារសណ្ឋាប់ធ្នាប់ បានជួយសម្រួលឱ្យរុម៉កចូលមកយកភ្ញៀវជនជាតិអឺរ៉ុបចាស់ជរា ដែលមានជំងឺ ពិបាកក្នុងការដើរ នៅចំណុចខាងត្បូងស្រះទឹកខាងមុខនៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤











អាជ្ញាធរជាតិអប្សរាសហការជាមួយអង្គការមរតកវប្បធម៌ខ្មែរ បើកកម្មវិធីអប់រំបេតិកភណ្ឌដៅសាលាបឋមសិក្សាវត្តលលៃ

ផ្សាយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរាសហការជាមួយអង្គការមរតកវប្បធម៌ខ្មែរ (Khmer Heritage Organization) បានបើកកម្មវិធីអប់រំបេតិកភណ្ឌដល់កុមារសម្រាប់ឆ្នាំសិក្សាថ្មី ២០២៤ នៅសាលាបឋមសិក្សាវត្តលលៃ ស្ថិតនៅឃុំបាគង ស្រុកប្រាសាទបាគងខេត្តសៀមរាប។



នាឱកាសនោះ លោក អ៊ឹម សុខវិទ្ធី ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បានលើកឡើងពីគោលបំណងនៃកម្មវិធីអប់រំបេតិកភណ្ឌ ដើម្បីឱ្យកូនចៅអ្នករស់នៅតំបន់រមណីយដ្ឋានអង្គរយល់ពីតួនាទីរបស់ខ្លួនក្នុងនាមអ្នកស្នងតំណក្នុងការថែរក្សា និងអភិរក្សតម្លៃអង្គរជារហូតទៅកុំឱ្យបាត់បង់។ លោកបន្តថា ប្រជាពលរដ្ឋរស់នៅតំបន់រមណីយដ្ឋានអង្គរ គួរមានមោទនភាពលើខ្លួនឯងដែលបានកើតលើទឹកដីប្រាសាទបុរាណ ដែលអន្តរជាតិឱ្យតម្លៃ និងត្រូវបានលើកតម្កើងខ្ពស់ តួយ៉ាង រូបប្រាសាទអង្គរវត្តត្រូវបានដាក់នៅលើទង់ជាតិខ្មែរនាគ្រប់ដំនាន់។ ដូច្នេះ បច្ចុប្បន្ននេះ យើងជាម្ចាស់ស្រុក ម្ចាស់តំបន់ដ៏ពិសិដ្ឋនេះ ត្រូវមានឆន្ទៈប្រឹងប្រែងរៀនសូត្រ និងស្វែងយល់នូវវប្បធម៌ អារ្យធម៌របស់ខ្លួនឲ្យបានច្បាស់ ដើម្បីចូលរួមចំណែកថែរក្សាមរតកវប្បធម៌ឲ្យបានគង់វង្ស។ចំពោះសិស្សានុសិស្សនៅសាលាបឋមសិក្សាវត្តលលៃដែលនឹងចូលរួមក្នុងកម្មវិធីអប់រំបេតិកភណ្ឌនៅពេលនេះ មានសិស្សថ្នាក់ទី៤ និងទី៥ សរុប៦៩នាក់។

សូមបញ្ជាក់ថា កម្មវិធីអប់រំបេតិកភណ្ឌបាននឹងកំពុងដំណើរការនៅ២ទីតាំង ទី១សាលាបឋមសិក្សាវត្តលលៃ និងទី២ សាលាបឋមសិក្សាក្របីរៀល។ ជាទូទៅ កម្មវិធីអប់រំបេតិកភណ្ឌមានរយៈពេល៩ខែក្នុង១ឆ្នាំ៕



ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា និងកូរ៉េ រួមគ្នាជួសជុលថ្មប្រាសាទជម ដែលរងការខូចខាតប្រមាណជាង៧០០ដុំ

ផ្សាយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤



ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា តាមរយៈកិច្ចសហការរវាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA) តាមរយៈមូលនិធិបេតិកភណ្ឌកូរ៉េ(KCHF) រួមគ្នាជួសជុលពង្រឹងថ្មប្រាសាទជមដែលរងការខូចខាត ដូចជាបែកបាក់និងពុកផុយចំនួនជាង៧០០ដុំ ឱ្យមានភាពរឹងមាំអាចប្រើប្រាស់ឡើងវិញបាន មុននឹងយកដើម្បីយកទៅរៀបដាក់នៅទីតាំងដើម ខណៈនេះដែលក្រុមការងារទាំង២កំពុងជួសជុលយ៉ាងយកចិត្តទុកដាក់។



អ្នកស្រី នឿង ភីរ៉ា បុគ្គលិកបច្ចេកទេសទេសនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ចំនួនថ្មប្រាសាទជម ដែលរងការខូចខាតបាក់បែកត្រូវការតភ្ជាប់ថ្មថ្មី និងយកបំណែកថ្មដែលបាក់បែកមកផ្គុំតគ្នាឡើងវិញ និងមួយចំនួនទៀតត្រូវធ្វើការពង្រឹងទៅតាមបច្ចេកទេសដើម្បីយកទៅប្រើប្រាស់ឡើងវិញ សរុបមានចំនួនពី៦០០ដុំទៅ៧០០ដុំ។ មកដល់បច្ចុប្បន្ននេះក្រុមការងារបានជួសជុល តភ្ជាប់ ពង្រឹងថ្មឱ្យមានគុណភាពអាចប្រើការបានជាង៤៨៩ដុំហើយ និងយកទៅរក្សាទុកនៅឃ្លាំងនៅក្បែរការដ្ឋានជួសជុលប្រាសាទជម ដើម្បីឱ្យក្រុមអ្នកជួសជុលយកទៅប្រើប្រាស់រៀបដាក់ទីតាំងដើមជាបន្តបន្ទាប់។







អ្នកស្រី ភីរ៉ា ឱ្យដឹងទៀតថា ដំណាក់កាលដំបូង មុននឹងយកថ្មមកជួសជុល គឺត្រូវត្រួតពិនិត្យការខូចខាតនៃថ្មដើម្បីរៀបចំជាឯកសារបច្ចេកទេស និងថតរូប។ ដំណាក់កាលទី២ យកថ្មទាំងនោះមកសម្អាតជាមួយនិងទឹកគ្មានជាតិរ៉ែនូវផ្នែដែលត្រូវតភ្ជាប់។ ក្រោយពីសម្អាតរួចរាល់ ប្រើម៉ាស៊ីន Ultrasonic Pulse Velocity Measurement Instrments ពិនិត្យមើលគុណភាពថ្ម ដើម្បីដឹងពីគុណភាព ដែលអាចប្រើចំនួន និងទំហំនៃដែកឬពន្លូញពេលជួសជុលតភ្ជាប់គ្នា។ ដំណាក់កាលទី៣ បំពេញថ្មថ្មីនៅកន្លែងដែលបាក់បែកបាត់បង់ថ្មនៃផ្នែកណាដែលចាំបាច់។ ដំណាក់កាលទី៤ បិទបំពេញបាយអរជុំវិញថ្មដែលបានតភ្ជាប់។

អ្នកជំនាញរូបនេះ បន្តថា ការងារនេះមានការពិបាកជាខ្លាំង ត្រូវការអត់ធ្មត់ និងផ្ចិតផ្ចង់ធ្វើយ៉ាងណា កុំឱ្យប៉ះពាល់ខូចខាតដល់ថ្មចាស់ទៅថ្ងៃក្រោយទៀត។ ក្នុងនោះដែរ អ្នកស្រី នឿង ភីរ៉ា បញ្ជាក់ថា ក្រៅពីថ្មជួសជុលប្រាសាទជម្រាប់រយដុំ គឺក្រុមការងារបានជួសជុលថ្មមកពីការដ្ឋានជួសជុលនៅលានដល់ដំរីចំនួន២ទីតាំងថែមទៀតផង។ បើទោះបីយ៉ាងនេះក្តី ក៏ក្រុមការងារមានការសប្បាយ និងមោទនភាពដែលបានធ្វើការជាមួយបេតិកភណ្ឌពិភពលោកមានតម្លៃមិនអាចកាត់ថ្លៃបាន៕



ភ្នាក់ងារទេសចរណ៍ប្រចាំការនៅតាមគោលដៅនានា តែងតែប្រទះឃើញសម្ភារផ្សេងៗ របស់ភ្ជៀវដែលបានភ្លេច និងប្រគល់ជូនម្ចាស់ដើមវិញ

ផ្សាយនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ក្រុមភ្នាក់ងារទេសចរណ៍ប្រចាំគោលដៅប្រាសាទតាព្រហ្ម បានប្រទះឃើញកាបូបស្ពាយពីក្រោយមួយពណ៌ខ្មៅ នៅចំនុចត្រឡែងកែងខាងលិចឈៀងខាងត្បូងនៃតួរប៉មកណ្តាល។ ភ្លាមៗនោះ ភ្ជៀវជនជាតិអៀរឡង់ ភេទប្រុស បានមករកវិញ ដោយបានពិនិត្យឃើញថា ជារបស់គាត់ពិតមែន ក្រុមភ្នាក់ងារទេសចរណ៍បានប្រគល់កាបូបជូនគាត់វិញ។



ចំណែកឯ ក្រុមការងារប្រចាំការនៅអតីតរាជធានីក្រុងអង្គរធំវិញ នៅថ្ងៃដដែល វេលាម៉ោង១២:១៧នាទីថ្ងៃត្រង់ ភ្នាក់ងារទេសចរណ៍បានរើសបានកាបូបស្ពាយក្រោយពណ៌ខ្មៅមួយ ដែលភ្ជៀវទេសចរបានភ្លេចនៅរួតទី១ ខាងត្បូង នៃប្រាសាទបាភួន។

នៅពេលថ្ងៃត្រង់ មានភ្ជៀវទេសចរ ភេទប្រុស ជនជាតិបារាំងម្នាក់ បានមកសួរនាំភ្នាក់ងារដែលប្រចាំការនៅទីនេះ ក្រោយភ្ជៀវត្រួតពិនិត្យឃើញថា មិនមានបាត់បង់របស់អ្វី និងពិតជារបស់គាត់ពិតប្រាដកមែន ភ្នាក់ងារទេសចរណ៍ ប្រគល់ជូនការបូបទៅគាត់វិញ។





អាជ្ញាធរជាតិអប្សរាបានឆិងកំពុងទម្លាក់ទឹកពីបារាយណ៍ទឹកថ្លាចុះទៅក្រោម សម្រាប់ការស្រោចស្រពស្រែប្រាំងរបស់ប្រជាពលរដ្ឋ

ផ្សាយនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤

ក្រៅពីជាអាងស្តុកទឹកដ៏ធំជាងគេនៅរមណីយដ្ឋានអង្គរ សម្រាប់ជួយកិច្ចការងារអភិរក្សប្រាសាទ បារាយណ៍ទឹកថ្លា ឬបារាយណ៍ខាងលិច ក៏ជាប្រភពទឹកដ៏សំខាន់សម្រាប់ការស្រោចស្រពស្រែប្រាំងរបស់ពលរដ្ឋនៅប៉ែកខាងក្រោម ដែលសរុបមានជិតៗពាន់គ្រួសារ។



លោក យុត យ៉ែម មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានទឹកព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា អាជ្ញាធរបានចាប់ផ្តើមបើកទឹកទម្លាក់ជូនប្រជាពលរដ្ឋដើម្បី ស្រោចស្រពស្រែប្រាំងចាប់ពីខែធ្នូ ឆ្នាំ២០២៣ និងបន្តរហូតដល់បច្ចុប្បន្ន។ លោកបន្តថា ការងារនេះ គឺអាជ្ញាធរជាតិអប្សរាក្នុងនាមអ្នកគ្រប់គ្រងទឹកបារាយណ៍ទឹកថ្លា តែងតែយកចិត្តទុកដាក់ និងមិនដែលឱ្យមានការរាំងស្ទះទឹកជូនពលរដ្ឋឡើយ ក្នុងបំណងជួយឱ្យការបង្កបង្កើនផលស្រូវប្រាំង របស់ប្រជាពលរដ្ឋបានទិន្នផលល្អ។

ជាមួយនឹងការងារសម្រួលទឹកជូនពលរដ្ឋនេះដែរ លោក យុត យ៉ែម បន្ថែមថា ក្រុមការងារលោកតែងចុះជាប្រចាំដោយពេលខ្លះបានជួសជុលប្រឡាយបញ្ជូនទឹកដែលបែកបាក់ និងពិនិត្យទ្វារទឹកឱ្យដំណើរការល្អពេលបិទបើកជាដើម។

តំណាងក្រុមសហគមន៍កសិករប្រើប្រាស់ទឹកបារាយណ៍ទឹកថ្លា លោក ហួត ហាយ បានឱ្យដឹងថា ការប្រើប្រាស់ទឹកនៅឆ្នាំនេះរបស់កសិករគឺមានភាពល្អប្រសើរ។ ក្នុងនាមកសិករមួយរូប លោកក៏សូមថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា ដែលតែងតែយកចិត្តទុកដាក់ការងារគ្រប់គ្រងទឹក និងទម្លាក់ទឹកជូនពលរដ្ឋប្រើប្រាស់គ្រប់គ្រាន់ និងទាន់ពេលវេលា។ លោកបន្ថែមថា ស្រែប្រាំងរបស់ប្រជាពលរដ្ឋគឺពឹងមួយផ្នែកធំលើទឹកបារាយណ៍ ក្រៅពីទាញទឹកពីទំនប់៧៨ និងទឹកពីបឹងទន្លេសាប។

សូមបញ្ជាក់ថា សហគមន៍ដែលកំពុងប្រើប្រាស់ទឹកបារាយណ៍សរុបមានចំនួន ៩ឃុំ-សង្កាត់ មាន៦៥ភូមិ និង៦៨១៨គ្រួសារ ស្មើនឹងផ្ទៃដីសរុប ៧៨៥០ហិកតា។



ប្រជាពលរដ្ឋសប្បាយរីករាយ ក្រោយពេលអាជ្ញាធរជាតិអប្សរា ធ្វើការសម្អាត និងអភិរក្សនៅទីតាំងទួលប្រាសាទគោកបល្ល័ង្កឡើងវិញ

ផ្សាយនៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៤

កាលពីអំឡុងដើមខែមករា ឆ្នាំ២០២៤ថ្មីៗនេះ អាជ្ញាធរជាតិអប្សរា ដោយមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះសម្អាតព្រៃជុំវិញទីតាំងបុរាណដ្ឋាន ប្រាសាទគោកបល្ល័ង្ក បន្ទាប់មកកាយយកអាចម៍ដីដែលចាក់លុប ចេញពីទីតាំងកសិន្ទ ស្ថិតនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប ដើម្បីកិច្ចការងារអភិរក្ស ការងារនេះធ្វើឱ្យបងប្អូនប្រជាពលរដ្ឋរស់នៅជុំវិញនោះបង្ហាញការគាំទ្រ និងសប្បាយរីករាយជាខ្លាំង។

លោកឈុន ឈឿន ប្រជាការពារក្នុងភូមិបឹង បានឱ្យដឹងថា លោកសូមគាំទ្រ និងចូលរួមជួយគ្រប់សកម្មភាពដែលអាជ្ញាធរជាតិអប្សរា បានចុះមកធ្វើការសម្អាតព្រៃ និងស្តារកសិន្ទទឹក នៅទីតាំងបុរាណដ្ឋាននៃប្រាសាទគោកបល្ល័ង្កនេះ។ លោកថា កាលដើមឡើយធ្លាប់បានឮការដំណាលរបស់ឪពុកម្តាយអំពីទីទួលប្រាសាទនេះនៅមានរូបរាងខ្លះៗ ប៉ុន្តែជាបន្តបន្ទាប់មក បានរងការខូចខាតទ្រុឌទ្រោមស្ទើរតែបាត់បង់រូបរាងអស់ជាច្រើនឆ្នាំមកហើយ ដោយកត្តាផ្សេងៗជាច្រើន។ ក្នុងនាមប្រជាពលរដ្ឋមួយរូប លោក ឈុន ឈឿន ពិតជាសប្បាយរីករាយណាស់នៅពេលបានឃើញអាជ្ញាធរជាតិអប្សរា គិតគូរខ្ពស់ទៅលើទីទួលបុរាណដ្ឋាន ដោយបានមកសម្អាត កាប់ឆ្ការព្រៃ ដែលដុះស៊ុបទ្រុប និងបានកាយយកអាចម៍ដីដែលប្រជាពលរដ្ឋចាក់លុបទៅលើកសិន្ទ ព្រមទាំងការស្តារកសិន្ទទឹកឡើងវិញ ដើម្បីកិច្ចការងារអភិរក្សទីទួលបុរាណរបស់ពលរដ្ឋគោរពបូជាចៀសវាងបាត់បង់កេរដំណែលដូនតាខ្មែរដែលបានបន្សល់ទុក។ ក្រោយពេលស្តារកសិន្ទទឹក និងសម្អាតបានស្អាតហើយនោះ លោកឈុន ឈឿន បានសំណូមពរដល់បងប្អូនប្រជាពលរដ្ឋរស់នៅជុំវិញនោះ សូមចូលរួមថែរក្សា ដោយមិនត្រូវយកសំរាមមកចាក់ចោល នៅទីទួលបុរាណនេះតទៅទៀតឡើយ។





ចំណែកលោក ចេង ណារ៉ូស ប្រជាពលរដ្ឋខ្មែរស្នាក់នៅលើទឹកដីសហរដ្ឋអាមេរិកជាយូរឆ្នាំ និងមានលំនៅឋានបច្ចុប្បន្នក្បែរទីទួលបុរាណដ្ឋាននៃប្រាសាទគោកបល្ល័ង្គបានឱ្យដឹងថា លោកពិតជាសប្បាយរីករាយណាស់ នៅពេលបានឃើញអាជ្ញាធរជាតិអប្សរា ធ្វើការអភិរក្សនៅលើទីតាំងបុរាណដ្ឋាននៃប្រាសាទគោកបល្ល័ង្គ ដើម្បីទុកជាកេរដំណែលឱ្យកូនខ្មែរជំនាន់ក្រោយបានស្គាល់ទីតាំងបុរាណដ្ឋានមួយនេះ។ លោកបន្តថា ក្នុងនាមលោកជាប្រជាពលរដ្ឋមួយរូបសូមធ្វើការគាំទ្រចំពោះការងារនេះ។



សូមជម្រាបថា ចាប់តាំងពីថ្ងៃទី០២ ខែមករា ឆ្នាំ២០២៤ មក ក្រុមការងារ នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បានចុះមកកាន់ទួលប្រាសាទគោកបល្ល័ង្គ បន្ទាប់ពីមានកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្បែរៗនោះ បានរាយការណ៍អំពីការរំលោភបំពាន ដោយចាក់ដីលុបទៅលើកសិន្ទុទឹកជាប់នឹងទួលនៃប្រាសាទ។ ក្រុមការងារដែលមានសមាជិកជាង២០នាក់ បានត្រួសឆ្ការព្រៃដុះស៊ុបទ្រុបសម្អាតនៅជុំវិញទីតាំងទួលបុរាណ កាយយកអាចម៍ដីដែលចាក់លុបចេញពីទីតាំងកសិន្ទ ព្រមទាំងបានស្តារកសិន្ទុទឹកឡើងវិញ ដើម្បីកិច្ចការងារអភិរក្ស ចៀសវាងបាត់បង់កេរដំណែលដូនតាខ្មែរដែលបានបន្សល់ទុក សម្រាប់កូនចៅជំនាន់ក្រោយ៕





រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទភ្នំក្រោម

ផ្សាយនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤









នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ ក្រុមការងារត្នាក់ងារទេសចរណ៍ គោលដៅប្រាសាទព្រះខ័ន ប្រាសាទប្រី និងប្រាសាទបន្ទាយប្រី រួមទាំងនគរបាលការពារបេតិកភណ្ឌ បានជួយសម្រួលជល់ត្នៀវអឺរុប ស្ត្រីវ័យចំណាស់ម្នាក់ ដែលគាត់ឈឺក្បាលជង្គង់ពិបាកដើរ ដោយបានជូនគាត់មកជល់ចំណតឡានទិសខាងជើង

ផ្សាយនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍ ខេមបូឌា គីអិលស៊ី
បានរៀបចំពិធីផ្លាស់ប្តូរកិច្ចព្រមព្រៀង និងសម្ពោធជាផ្លូវការគម្រោង «ឧទ្យានសហគមន៍អង្គរ-មេនូឡាយហ្វ៍»

ផ្សាយនៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤





រសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា សហការជាមួយក្រុមហ៊ុនមេនូឡាយហ្វ៍ ខេមបូឌា គីអិលស៊ី បានរៀបចំពិធីផ្លាស់ប្តូរកិច្ចព្រមព្រៀង និងសម្ពោធជាផ្លូវការគម្រោង «ឧទ្យានសហគមន៍អង្គរ-មេនូឡាយហ្វ៍» ដែលជាគម្រោងដាំកូនឈើចំនួនជាង១០ ០០០ដើម មានដូចជាដើមធ្នង់ គគីរ និងដើមបេង លើផ្ទៃដី៥.៥ហិកតា ដែលមានការអញ្ជើញចូលរួមជាអធិបតី**លោកជំទាវបណ្ឌិតសភាចារ្យ គឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: និងជាប្រធានក្រុមប្រឹក្សាភិបាល អាជ្ញាធរជាតិអប្សរា នៅទីតាំងខាងជើងបរិវេណប្រាសាទបន្ទាយប្រី ដោយមានការចូលរួមពីតំណាងថ្នាក់ដឹកនាំក្រសួងបរិស្ថាន រដ្ឋបាលខេត្តសៀមរាប មន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសិស្សានុសិស្សប្រមាណ៣០០នាក់។

ថ្លែងក្នុងពិធីប្រគល់កិច្ចព្រមព្រៀង និងសម្ពោធគម្រោង **លោកជំទាវ បណ្ឌិតសភាចារ្យ គឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: និងជាប្រធានក្រុមប្រឹក្សាភិបាល នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ដើមឈើរាប់លានដើម ទាំងក្នុងគម្រោងរបស់ក្រុមហ៊ុនមេនូឡាយហ្វ៍ រួមទាំងវិស័យឯកជននានា ដែលបានសហការជាមួយអាជ្ញាធរជាតិអប្សរា ដាំដុះជាបន្តបន្ទាប់នៅក្នុងឧទ្យានអង្គរ។ នេះជាភារកិច្ចថ្មីមួយទៀត បន្ថែមលើកិច្ចការដែលយើងជាកូនខ្មែរត្រូវថែរក្សាបរិស្ថាន។ ហេតុអ្វី? ដោយសារនៅលើទឹកដីនេះ មានប្រាសាទរាប់រយ ដែលប្រាសាទ គឺជាចំណងមួយរវាងប្រាសាទ ធម្មជាតិ និងមនុស្ស។ អ្វីទាំងអស់នោះ បើសិនជាគ្មានព្រៃឈើជួយទេ បញ្ហាវានឹងកកើតឡើងដូចជា ភាពរាំងស្ងួត ហើយបរិស្ថានបៃតងជួយច្រើនលើសុខុមាលភាពរបស់មនុស្ស។



លោកជំទាវបណ្ឌិតសភាចារ្យ បានសម្តែងសេចក្តីរីករាយ ដែលរាជដ្ឋាភិបាល យកចិត្តទុកដាក់លើការបង្កើនគម្របព្រៃឈើ ហើយសកម្មភាពនេះ កាន់តែផុសផលច្រើនឡើង ពិសេសក្នុងចំណោមយុវជន។ **លោកជំទាវបណ្ឌិតសភាចារ្យ** មានប្រសាសន៍បន្តថា អ្នកជំនាន់ក្រោយរស់នៅបានដោយសារសមិទ្ធផលរបស់អ្នកមុននេះជាបំណងយើងទាំងអស់គ្នាបានទទួលនូវភោគផលដែលដូនតាយើងបន្សល់ទុកមក មានប្រាង្គប្រាសាទមានសម្បត្តិធម្មជាតិ។ ដូច្នេះ ជាការកិច្ចរបស់យើងថែរក្សាក៏មានការកិច្ចនឹងបន្តបង្កើតនូវអ្វីសម្រាប់ទុកឱ្យអ្នកជំនាន់ក្រោយដែរ។

លោកចាន់ដ្ឋោអគ្គនាយកក្រុមហ៊ុនមេនូឡាយហ្វ៍ខេមបូឌាកីអិលស៊ី មានប្រសាសន៍ថា ថ្ងៃនេះ គឺជាពេលវេលាដ៏វិសេសវិសាលណាស់ ដែលក្រុមហ៊ុនមេនូឡាយហ្វ៍ មានកិត្តិយស និងមោទកភាពដោយទទួលបានការអនុញ្ញាត និងគាំទ្រពីអាជ្ញាធរជាតិអប្សរា លើគម្រោងសហប្រតិបត្តិការ «ឧទ្យានសហគមន៍អង្គរ-មេនូឡាយហ្វ៍»។ តាមរយៈគម្រោងនេះ និងការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិអប្សរា នឹងចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការពារបេតិកភណ្ឌវប្បធម៌ជាតិដ៏មានតម្លៃសម្រាប់មនុស្សជាតិ ក៏ដូចជាកូនចៅជំនាន់ក្រោយ។ ស្របពេលជាមួយគ្នានេះ ក៏រួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមតាមរយៈការបង្កើតប្រាក់ចំណូល និងឱកាសការងារសម្រាប់សហគមន៍មូលដ្ឋាន ជាពិសេស ប្រជាពលរដ្ឋដែលកំពុងរស់នៅ និងប្រកបការងារនៅទីនេះផ្ទាល់តែម្តង។ ទិសដៅនេះបានដើរស្របគ្នាយ៉ាងល្អឥតខ្ចោះទៅនឹងយុទ្ធនាការរបស់ក្រុមហ៊ុន មេនូឡាយហ្វ៍ ជាសកល (Manulife Impact Agenda) ក្នុងការកសាងជីវិតប្រកបដោយសុខភាពល្អ ភាពរឹងមាំយូរអង្វែង និងកាន់តែប្រសើរជូនប្រជាជននៅទូទាំងពិភពលោកដែលយើងមានប្រតិបត្តិការអាជីវកម្ម រួមទាំងប្រទេសកម្ពុជាផងដែរ៕





បេក្ខជនជាង៧០០អង្គ/នាក់ ចូលរួមប្រឡងសរសេរតាមអាន «សំណោរអង្គរ» លើកទីមួយ

ផ្សាយនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤

លោកជំទាវបណ្ឌិតសភាចារ្យ គឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានចូលរួមជាអធិបតីភាព កម្មវិធីប្រឡងសរសេរតាមអាន «សំណោអង្គរ» លើកទីមួយ នៅលើស្ពានហាលខាងលិចប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២៤ ដែលមានបេក្ខជនចូលរួមជាង៧០០ អង្គ/នាក់។ ពិធីខាងលើនេះដែរក៏មានការចូលរួមពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ថ្នាក់ដឹកនាំខេត្ត ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងមន្ត្រីរាជការជាច្រើនរូបទៀត។

លោកជំទាវបណ្ឌិតសភាចារ្យ គឿង សកុណា បានអានអត្ថបទប្រឡងទៅកាន់បេក្ខជនក្នុងរយៈពេលមួយម៉ោង ដែលអត្ថបទទាក់ទងនឹងរមណីយដ្ឋានអង្គរ ជាការរៀបចំសម្រិតសម្រាំងទុកដោ**យ៦ក៧ត្តម៧បនាយករដ្ឋមន្ត្រី ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រោមចំណងជើងថា «អង្គរ អាណាចក្រនៃអរិយធម៌ខ្មែរ»។

សូមបញ្ជាក់ថា កម្មវិធីសំណោរអង្គរ ជាកម្មវិធីថ្មីដែលបង្កើតឡើងក្នុងបំណងលើកកម្ពស់អក្សរសាស្ត្រខ្មែរ តាមរយៈការប្រឡងប្រជែងសរសេរតាមអាន។ កម្មវិធីនេះក៏អាចនឹងក្លាយជាព្រឹត្តិការណ៍ថ្នាក់ជាតិជាប្រចាំឆ្នាំផងដែរនាពេលអនាគត។







នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ កាត់ក្រឹមែកឈើដែលប៉ះពាល់ដល់សំណង់ផ្សេងៗក្នុងវត្តតាំងតុ

ផ្សាយនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

ក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានរៀបចំដំឡើងរន្ទាសម្រាប់កាត់ក្រឹមែកឈើមួយចំនួន នៅក្នុងបរិវេណវត្តតាំងតុ កាលពីថ្ងៃថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤ ប្រយោជន៍ដើម្បីការពារកុំឱ្យប៉ះពាល់ដល់សំណង់ផ្សេងៗក្នុងវត្ត ព្រមទាំងការពារគ្រោះថ្នាក់នានាផង។

មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ លោក គង់ សុវណ្ណារិទ្ធ ឱ្យដឹងថា ដើមឈើទាល ដើមពង្រ និងដើមស្លែង ដែលដុះជាប់នឹងបរិវេណវត្តតាំងតុ មានអាយុកាលច្រើនឆ្នាំមកហើយ កំពុងតែមានសភាពពុកផុយដោយអន្លើ។ ក្រុមការងារគ្រប់គ្រងព្រៃឈើ នៃអាជ្ញាធរជាតិអប្សរា បានដំឡើងរន្ទាដៃកដើម្បីកាត់ក្រឹមែកឈើទាំងនោះមួយចំនួនចេញ ដើម្បីបញ្ចៀសការបាក់ធ្លាក់ដែលអាចនឹងបង្កឱ្យមានគ្រោះថ្នាក់និងការប៉ះពាល់ដល់សំណង់ផ្សេងៗក្នុងវត្ត។

លោក គង់ សុវណ្ណារិទ្ធ បញ្ជាក់ទៀតថា ថ្វីត្បិតតែមានការព្រួយបារម្ភអំពីគ្រោះថ្នាក់ដែលអាចបង្កឡើងពីមែកឈើបាក់ធ្លាក់ ក៏ប៉ុន្តែ ព្រៃឈើក្នុងតំបន់រមណីយដ្ឋានអង្គរ ក៏ជារបាំងសម្រាប់ការពារខ្យល់បក់ បាំងប្រាសាទ ជាម្លប់ ជាប្រភពទាក់ទាញទឹកភ្លៀង និងជាសោភ័ណភាពទាក់ទាញភ្ញៀវទេសចរដែរ។ ដូច្នេះ ដើមឈើដែលក្រុមការងារកាត់ក្រឹមែកចេញលុះត្រាតែដើមឈើនោះងាប់ ពុកគល់ ឬក៏ពុកមែក។ ក្រៅពីការងារជួសជុលថែរក្សាប្រាសាទ ការងារគ្រប់គ្រងព្រៃឈើក្នុងរមណីយដ្ឋានអង្គរ ក៏ជាកិច្ចការចាំបាច់របស់អាជ្ញាធរជាតិអប្សរាដែរ។

អាជ្ញាធរជាតិអប្សរា តែងបន្តធ្វើការកាត់ក្រឹមែកឈើនៅតំបន់រមណីយដ្ឋានអង្គរជាប្រចាំ ដើម្បីការពារគ្រោះថ្នាក់ដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ ប្រាសាទនិងថែរក្សាទេសភាពវប្បធម៌នៅតំបន់អង្គរ៕





អ្នកសារព័ត៌មានជាង២០រូបអញ្ជើញមកពីរាជធានីភ្នំពេញធ្វើទស្សនកិច្ចសិក្សា នៅសារមន្ទីរចំនួនពីរក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤





នៅព្រឹកថ្ងៃទី២២ខែមករាឆ្នាំ២០២៤នេះអ្នកសារព័ត៌មានចំនួន២២រូប មកពីស្ថាប័នផ្សេងៗបានធ្វើដំណើរពីរាជធានីភ្នំពេញ ធ្វើទស្សនកិច្ចសិក្សានៅក្នុងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ និងសារមន្ទីរវាយនកណ្ឌាប្រពៃណីអាស៊ី ដើម្បីសិក្សាស្វែងយល់ការងារអភិរក្សនៅក្នុងសារមន្ទីរ និងធ្វើការផ្សព្វផ្សាយបន្ត។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយឯកឧត្តម អគ្គនាយករង បានអញ្ជើញទទួលស្វាគមន៍ និងឆ្លៀតផ្តល់កិច្ចសម្ភាសដល់ក្រុមអ្នកសារព័ត៌មាន អំពីកិច្ចការងារអភិរក្ស និងអភិវឌ្ឍន៍ក្នុងតំបន់រមណីយដ្ឋានអង្គរ៕





កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ មានភ្ញៀវជនជាតិបារាំងម្នាក់ តេទប្រុស អាយុ៣៦ឆ្នាំ បានដើរដំពប់ជើងដួលនៅខាងកើតសាលរបាំ នៃប្រាសាទតាព្រហ្ម ស្លាមៗនោះ ក្រុមស្នាក់ការទេសចរប្រចាំតំបន់ប្រាសាទតាព្រហ្ម បានជួយសង្គ្រោះបឋមជូនភ្ញៀវ

ផ្សាយនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា គ្រោងធ្វើឱ្យប្រាសាទបាយ័នមានស្រះទឹកដូចពីសម័យបុរាណឡើងវិញ

ផ្សាយនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤





ក្រុមអ្នកបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា កំពុងតែធ្វើកំណាយស្រាវជ្រាវនៅផ្នែកទិសអាគ្នេយ៍ ជាប់ប្រាសាទបាយ័នដែលគេជឿថា ពីមុន គឺជារចនាសម្ព័ន្ធរបស់ស្រះទឹកបុរាណ ដើម្បីសិក្សាអំពីកំណកដី និងទំហំស្រះនោះ ដើម្បីឈានទៅរកការស្តារស្រះស្តុកទឹកឱ្យមានឡើងវិញដូចកាលពីសម័យបុរាណ។

បុរាណវិទូ លោក ខៀវ ច័ន្ទ មានប្រសាសន៍ថា កំណាយដែលក្រុមការងារកំពុងធ្វើនោះ គឺជាកំណាយសង្គ្រោះដែលជាគម្រោងរបស់នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់សិក្សា ដើម្បីចង់ដឹងឱ្យប្រាកដថាតើរចនាសម្ព័ន្ធរបស់ស្រះកាលពីសម័យបុរាណមានទំហំប៉ុណ្ណា? តើមានអ្វីខ្លះនៅតាមច្រាំង និងមាត់ស្រះ? ហើយ តើអាចម៍ដីដែលលុបស្រះនេះ គឺជាដីដែលហូរច្រោះមកតាមទឹកឬក៏ជាអាចម៍ដីដែលគេចាក់លុបនៅក្រោយពេលដែលអង្គរត្រូវគេបោះបង់ហាន:ជារាជធានី?។

លោក ខៀវ ច័ន្ទ ឱ្យដឹងទៀតថា ការធ្វើកំណាយស្រាវជ្រាវនេះ ក្នុងគោលបំណងសិក្សាអំពីទំនាក់ទំនងរវាងស្រះទឹកនិងកំពែងបុរាណ ដើម្បីឱ្យប្រាកដថាតើរចនាសម្ព័ន្ធរបស់ស្រះទឹកសម័យបុរាណនោះ មានទំហំត្រឹមណាឱ្យពិតប្រាកដ?។

ក្រុមអ្នកបុរាណវិទូឱ្យដឹងថា នៅពេលណាដែលអ្នកជំនាញបានសិក្សាស្រាវជ្រាវពីទំហំស្រះ មាត់ច្រាំងស្រះ និងជម្រៅស្រះបុរាណទៅតាមប្រវត្តិសាស្ត្ររួចរាល់ហើយនោះ គឺក្រុមការងារនឹងស្តារស្រះបុរាណដើម្បីឱ្យស្តុកទឹកមាននៅប្រាសាទបុរាណបាយ័នឱ្យដូចសម័យកាលបុរាណឡើងវិញ៕



ខឿនជាន់ទីមួយ នៅប្រាសាទបាយ័ននៃជ្រុងខាងកើតឆៀងខាងត្បូង ប្រវែងជាង១០ម៉ែត្រ កំពុងជួសជុលឱ្យប្រសើរឡើងវិញ

ផ្សាយនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤





ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា របស់អាជ្ញាធរជាតិអប្សរា កំពុងរៀបចំជួសជុលពង្រឹងខឿន រួតទី១របស់ប្រាសាទបាយ័ន នាជ្រុងខាងកើតឆៀង ខាងត្បូង ដោយសារតែខឿននោះ បានរំកិលស្រុត ថ្មកម្រាលហែកក្រៀកមិនមានលំនឹងជាដើម។

បុគ្គលិកបច្ចេកទេស នៃនាយកដ្ឋានអភិរក្សប្រាសាទ និង បុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា លោក លឹម ហាក់ ឱ្យដឹងថា ការជួសជុលពង្រឹងខឿនប្រវែងជាង១០ម៉ែត្រ ចាប់ផ្តើមតាំងពីចុងខែវិច្ឆិកា ឆ្នាំ២០២៣។

ផ្នែកខ្លះរបស់ខឿនបានរំកិល និងស្រុត កម្រាលថ្មកក់មាន សភាពរំកិលខុសពីទីតាំងដើមហើបខ្ពស់ទាបមិនស្មើគ្នា បាត់បង់សោភ័ណភាព។

ក្រុមការងារនឹងត្រូវចំណាយពេលជាច្រើនខែ ដើម្បី ជួសជុលខឿនរបស់ប្រាសាទបាយ័ននៅចំណុចជ្រុង ខាងត្បូងឈៀងខាងកើតនេះ ឱ្យមានភាពរឹងមាំ និង សោភ័ណភាពឡើងវិញ ព្រមទាំងអាចជួយសម្រួលដល់ ដំណើរភ្ញៀវទេសចរជាតិ និងអន្តរជាតិឱ្យងាយស្រួលដើរ ឆ្លងកាត់ និងមានសុវត្ថិភាពផង៕

ក្រុមការងារគ្រប់គ្រងហានិភ័យដើមឈើ នៃនាយកដ្ឋានធឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានធ្វើកំណត់ហេតុ និងឈានដល់ការកំណត់ដើមឈើហានិភ័យ សរុប២៣ដើម នៅប្រាសាទបាគង។ បច្ចុប្បន្ន ក្រុមការងារបានរិងកំពុងចុះកាត់ក្រី និងដកដើមឈើហានិភ័យទាំងនោះ ក្នុងបំណងបញ្ជៀសហានិភ័យនានា និងបិទបាំងទេសភាពនៅជុំវិញប្រាសាទ

ផ្សាយនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤











អ្នកបច្ចេកទេស អាជ្ញាធរជាតិអប្សរា ធ្វើការជួសជុលពង្រឹងតួប្រាសាទឥដ្ឋ ក្នុងបរិវេណកសិន្ធុទី២ ប្រាសាទបាគង

ផ្សាយនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤



អ្នកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យាអាជ្ញាធរជាតិអប្សរា កំពុងធ្វើការជួសជុលពង្រឹងតួប្រាសាទឥដ្ឋចំនួន២(តួទី១៣នៅទិសអាគ្នេយ៍ និងតួទី២២នៅខាងត្បូង) ក្នុងបិវេណកសិន្ធុទី២របស់ប្រាសាទបាគង ដែលមានសភាពទ្រុឌទ្រោមខ្លាំង។



ការងារជួសជុលនេះ ក្រុមអ្នកបច្ចេកទេស បានប្រមូលបំណែកឥដ្ឋដែលបាក់បែក និងពុកផុយ មករៀបផ្ទុំពង្រឹងឡើងវិញ ព្រមទាំងបិទបាយអតាមចន្លោះប្រហោងដើម្បីការពារជម្រាបទឹក និងធ្វើការចងក្រៀក ទល់ទ្រ ផ្នែកដែលប្រេះហែកចេញពីគ្នាឱ្យមានលំនឹងឡើងវិញ។



នេះគឺជាផ្នែកមួយនៃកិច្ចការអភិរក្ស ដែលអាជ្ញាធរជាតិអប្សរា អនុវត្តន៍ជាប្រចាំ ដើម្បីថែរក្សាប្រាសាទជាទីសក្តារៈ ដែលមានអាយុកាលជាង១០០០ឆ្នាំទាំងនេះ ឱ្យនៅឈរវឹងមាំយូរអង្វែងបន្តទៀត។



អាជ្ញាធរជាតិអប្សរា
បានបញ្ចប់ការងារជួសជុលប្រាង្គកណ្តាលប្រាសាទតាព្រហ្មកិលជាស្ថាពរ

ផ្សាយនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤





បន្ទាប់ពីបានចំណាយពេលវេលាជួសជុលអស់រយៈពេលជាច្រើនខែមក នាចុងឆ្នាំ២០២៣កន្លងទៅថ្មីៗនេះ អាជ្ញាធរជាតិអប្សរា បានបញ្ចប់រួចរាល់ការជួសជុលប្រាសាទតាព្រហ្មកិល ឱ្យងើបឈរបង្ហាញរូបរាងជាថ្មីឡើងវិញ ដើម្បីទុកជាប្រយោជន៍សម្រាប់មនុស្សជាតិជំនាន់ក្រោយ។

លោក ម៉ៅ សុខនី ប្រធានការដ្ឋានជួសជុលប្រាសាទតាព្រហ្មកិល និងជាស្ថាបត្យករ នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបានឱ្យដឹងថា នៅក្នុងដំណើរការជួសជុលប្រាសាទតាព្រហ្មកិល បានចែកចេញជាពីរដំណាក់កាល ដោយដំណាក់កាលទីមួយគឺការសិក្សាស្រាវជ្រាវ គូសប្លង់ និងកំណាយស្រាវជ្រាវ។ ដំណាក់កាលទីពីរ បានចាប់ផ្តើមតាំងពីអំឡុងខែមីនាមកដល់ខែធ្នូ ឆ្នាំ២០២៣ថ្មីៗនេះ បានបញ្ចប់ការងារជួសជុល ធ្វើឱ្យរចនាសម្ព័ន្ធរបស់ប្រាសាទបានរឹងមាំជាងពេលមុន ដែលធ្លាប់តែទ្រេត បាក់ធ្លាក់ និងទល់ទ្រជាញឹកញាប់។



ប្រធានការដ្ឋានជួសជុលប្រាសាទតាព្រហ្មកិល បានបញ្ជាក់ថា ប្រាសាទនេះបានរងការខូចខាតទ្រុឌទ្រោមខ្លាំង ដោយសារថ្មខ្លះបានធ្លាក់កប់ដី នៅរាយប៉ាយ ហើយតួរប៉មកណ្តាល បានបាក់រលុះអស់មួយចំហៀង នៅជ្រុងខាងត្បូង និងខាងលិច។ ដូច្នេះចំពោះការងារជួសជុលគឺពង្រឹងរចនាសម្ព័ន្ធនៃជ្រុងដែលបាក់ធ្លាក់ឱ្យរឹងមាំឡើងវិញ ដោយមានជំនួសនូវថ្មថ្មីខ្លះៗ។

លោកម៉ៅ សុខនី បន្ថែមថា មកដល់ពេលនេះ ក្រុមការងារកំពុងរៀបចំជាវង់ទស្សនាសម្រាប់ភ្ញៀវ សម្អាតប្រព័ន្ធលូទឹក ដើម្បីឱ្យហូរចូលទៅក្នុងស្រះផ្នែកខាងជើង និងរៀបចំទីធ្លាប្រាសាទឱ្យមានសណ្តាប់ធ្នាប់ឡើងវិញ ដើម្បីងាយស្រួលភ្ញៀវដើរទស្សនាប្រាសាទ។





សូមជម្រាបថា ប្រាសាទតាព្រហ្មកិល មានតួនាទីជាហោសម្រាប់មនុស្សបន់ស្រន់ នៅក្នុងមន្ទីរពេទ្យមួយ ក្នុងចំណោមមន្ទីរពេទ្យទាំង៤ជុំវិញក្រុងអង្គរធំ។ កសាងឡើងក្នុងរាជកាលព្រះបាទជ័យវរ្ម័នទី៧ នាចុងសតវត្សទី១២ នៃគ្រីស្តរាជ។ ប្រាសាទនេះ មានទីតាំងនៅផ្នែកខាងលិចឈៀងខាងជើងនៃប្រាសាទអង្គរវត្ត៕





ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ឡើងទស្សនារួតបាកាណានៃប្រាសាទអង្គរវត្ត នារសៀលថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤





ការយកចិត្តទុកដាក់របស់ក្រុមភ្នាក់ងារទេសចរណ៍ចំពោះភ្ញៀវទេសចរក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤

នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា ប្រចាំគោលដៅប្រាសាទអង្គរវត្ត បានសហការណ៍ជាមួយក្រុមការងារសណ្តាប់ធ្នាប់ សម្របសម្រួលឱ្យរ៉ឺម៉កចូលមកដឹកភ្ញៀវជនជាតិកូរ៉េ ដែលមានបញ្ហាឈឺជើងដើរមិនរួច នៅចំណុចរួតទី១ នៃច្រកតាពេជ្រ។

ដោយឡែក ក្រុមការងារភ្នាក់ងារទេសចរណ៍ ប្រចាំគោលដៅប្រាសាទតាព្រហ្ម បានជួយសង្គ្រោះបឋម ក្មេងប្រុសជនជាតិខ្មែរ ដែលដួលបណ្តាលអោយគ្រិចដៃ នៅត្រង់ចំនុចគក់ទ្រូង៕







អាជ្ញាធរជាតិអប្សរា កំពុងបន្តសិក្សាកំណាយស្រាវជ្រាវរចនាសម្ព័ន្ធសំណង់ជាបន្តទៀត នៅបរិវេណប្រាសាទតាព្រហ្មកិល

ផ្សាយនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤





បន្ទាប់ពីបានបញ្ចប់ការងារជួសជុលប្រាង្គកណ្តាលប្រាសាទតាព្រហ្មកិលជាស្ថាពរ នាចុងឆ្នាំ២០២៣កន្លងទៅក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាកំពុងបន្តការធ្វើកំណាយស្រាវជ្រាវ នៅបរិវេណប្រាសាទតាព្រហ្មកិលបន្តទៀត ដើម្បីធ្វើឱ្យសំណង់ប្រាសាទ ដែលមានតួនាទីជាកន្លែងសម្រាប់មនុស្សបន់ស្រន់ នៅក្នុងមន្ទីរពេទ្យមួយ ក្នុងចំណោមមន្ទីរពេទ្យទាំង៤ជុំវិញក្រុងអង្គរធំមួយនេះ មានគ្រប់រចនាសម្ព័ន្ធទាំងខ្លោងទ្វារ កំពែង និងស្រះទឹកជាដើម។

លោក ម៉ៅ សុខនី ប្រធានការដ្ឋានជួសជុលប្រាសាទតាព្រហ្មកិល និងជាស្ថាបត្យករ នៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យាបានឱ្យដឹងថា នៅពេលបញ្ចប់ការជួសជុលប្រាង្គកណ្តាលនៃប្រាសាទតាព្រហ្មកិល ក្រុមអ្នកជំនាញមិនបានបញ្ឈប់សកម្មភាពនៅទីនេះឡើយ ពោលគឺកំពុងសិក្សាទៅលើគម្រោងជួសជុលពង្រឹងខ្លោងទ្វារខាងកើតរបស់ប្រាសាទតាព្រហ្មកិលបន្តទៀត ជួសជុលពង្រឹងខឿនបណ្ណាល័យ ផ្នែកខាងត្បូង នៃជ្រុងអាគ្នេយ៍ និងរៀបចំស្រះទឹកនៅជ្រុងឦសានឱ្យមានរូបរាងឡើងវិញ។

បន្ទាប់ពីផែនការជួសជុល និងរៀបចំ នៅតាមផ្នែកនីមួយៗ រួចរាល់ហើយ អ្នកជំនាញរំពឹងថា នឹងមានភ្ញៀវទេសចរចូលមកទស្សនាប្រាសាទតាព្រហ្មកិលកាន់តែច្រើន ព្រោះទីនេះមានទីតាំងមិនឆ្ងាយប៉ុន្មានពីប្រាសាទអង្គរវត្តឡើយ។



និស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញចំនួន៣៦០រូប ចូលរួមស្តាប់បាឋកថាស្តីពី " ចំណេះដឹង និងការសិក្សាស្រាវជ្រាវថ្មីៗនៅតំបន់អង្គរ"

ផ្សាយនៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤



នារសៀលថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤នេះ បាឋកថាស្តីពី " ចំណេះដឹង និងការសិក្សាស្រាវជ្រាវថ្មីៗនៅតំបន់អង្គរ" នៅសាលសន្និសីទអង្គរនៃអាជ្ញាធរជាតិអប្សរា ដោយ លោក អ៊ឹម សុខរិទ្ធិ ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា។ ក្នុងគោលបំណងចូលរួមផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងប្រវត្តិសាស្ត្រ និងរបកគំហើញនៃការស្រាវជ្រាវថ្មីៗ នៅក្នុងតំបន់អង្គរ ជូននិស្សិតប្រវត្តិវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញចំនួន៣៦០រូប និងមន្ត្រី-បុគ្គលិករបស់អាជ្ញាធរជាតិអប្សរាជាច្រើនរូបទៀត៕





នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤នេះ ភ្នាក់ងារសណ្តាប់ធ្នាប់ សហការណ៍ជាមួយភ្នាក់ងារទេសចរណ៍ នគរបាលការពារបេតិកភណ្ឌ នគរបាលទេសចរណ៍ បានប្រគល់ទូរស័ព្ទម៉ាក Iphone 7 ឱ្យភ្ញៀវទេសចរ ជនជាតិអាមេរិកម្នាក់ គេទស្រី អាយុ៧៣ឆ្នាំវិញ នៅវេលាម៉ោង ១១ និង ៥៩នាទីថ្ងៃត្រង់ នៅត្រង់ចំណុចរោងJASA ក្រោយគាត់បានភ្លេចទូរស័ព្ទ នៅត្រង់ចំណុចខាងត្បូងប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៤









រូបភាពប្រចាំសប្តាហ៍÷ " ទិដ្ឋភាពប្រាសាទសួរព្រ័ត្រពីលើអាកាស "

ផ្សាយនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៤





អង្គការមូលនិធិប្រាសាទពិភពលោកបានប្រគល់ការដ្ឋានអតិរក្ស និងជួសជុលចំនួន៣ ក្នុងរមណីយដ្ឋានអង្គរ ជូនអាជ្ញាធរជាតិអប្សរាគ្រប់គ្រងវិញ បន្ទាប់ពីជួសជុលរួចរាល់

ផ្សាយនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៤

អង្គការមូលនិធិប្រាសាទពិភពលោក(World Monument Fund)របស់សហរដ្ឋអាមេរិក បានធ្វើពិធីរំលឹកខួបលើកទី ៣៥ឆ្នាំ នៃបេសកកម្មរបស់ខ្លួនព្រមទាំងពិធីប្រគល់ និងទទួលជួសជុលការដ្ឋានប្រាសាទចំនួន៣ ក្នុងរមណីយដ្ឋានអង្គរ ជូនអាជ្ញាធរជាតិអប្សរាគ្រប់គ្រងវិញ កាលពីរសៀលថ្ងៃទី២៦ ខែមករាឆ្នាំ២០២៤។

ពិធីប្រគល់ការដ្ឋានជួសជុលចំនួន៣នោះ មានប្រាសាទតាសោម ប្រាសាទព្រះខ័ន និងរោងទងនៃចម្លាក់សមុទ្រកូទឹកដោះ របស់ប្រាសាទអង្គរវត្ត ក្រោមអធិបតីភាពរបស់**ឯកឧត្តមបណ្ឌិតសភាចារ្យ សឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយក នៃអាជ្ញាធរជាតិអប្សរា និងមន្ត្រីជាច្រើនរូប ព្រមទាំងដៃគូនៃកិច្ចសហប្រតិបត្តិការក្នុងការជួសជុល និងអភិរក្សប្រាសាទបុរាណជាច្រើនស្ថាប័នទៀត។





លោកជំទាវ បណ្ឌិតសភាចារ្យ គឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: បានថ្លែងនៅក្នុងពិធីប្រគល់ការដ្ឋានជួសជុលចំនួន៣មកឱ្យអាជ្ញាធរជាតិអប្សរាគ្រប់គ្រងវិញនោះថា អាជ្ញាធរជាតិអប្សរា នឹងបន្តថែរក្សាប្រាសាទទាំង៣នេះ ហើយកម្ពុជានឹងចងចាំជារៀងរហូតចំពោះការរួមចំណែករបស់មូលនិធិប្រាសាទពិភពលោក(World Monument Fund)ក្នុងការជួយការពារបេតិកភណ្ឌជាតិរបស់កម្ពុជា ហើយកម្ពុជាក៏រង់ចាំបន្តធ្វើការជាមួយអង្គការមូលនិធិប្រាសាទពិភពលោកក្នុងវិស័យទូលំទូលាយដូចជា ការផ្លាស់ប្តូរជំនាញស្តីពី ការអភិរក្ស វេទិកាយុវជនសម្រាប់ការគ្រប់គ្រងបេតិកភណ្ឌ ការស្រាវជ្រាវផ្នែកបុរាណវិទ្យា និងសិក្ខាសាលារួមគ្នាដើម្បីចែករំលែកបទពិសោធន៍ជាដើម។

ចំណែកប្រធាន និងជានាយកប្រតិបត្តិរបស់អង្គការមូលនិធិប្រាសាទពិភពលោករបស់សហរដ្ឋអាមេរិកអ្នកស្រី Benedicte De Montlaur បានថ្លែងថា ការចូលរួមរបស់(World Monument Fund)ក្នុងការងារជួសជុលប្រាសាទនៅរមណីដ្ឋានអង្គរបានចាប់ផ្តើមតាំងពីឆ្នាំ១៩៨៩ ជាមួយនឹងបេសកកម្មចុះវាល ដើម្បីវាយតម្លៃស្ថានភាពនៃប្រាសាទ ដើម្បីឆ្លើយតបតាមការស្នើសុំរបស់អតីតព្រះមហាក្សត្រព្រះបាទនរោត្តម សីហនុ ហើយបន្ទាប់មកអង្គការមូលនិធិប្រាសាទពិភពលោកក៏បានបង្កើតកម្មវិធីអភិរក្ស និងបណ្តុះបណ្តាលដ៏ទូលំទូលាយ ដោយជួយបំពេញបន្ថែមទៅលើកិច្ចខិតខំប្រឹងប្រែងរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្ប:(RUFA) ដែលទើបនឹងបើកឡើងវិញនាពេលនោះ។





រូបភាពប្រចាំសប្តាហ៍៖ ព្រះលានស្តេចគម្លង់

ផ្សាយនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤









នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤ ក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទបាយ័ន បានសម្របសម្រួលជួយសង្គ្រោះភ្ញៀវទេសចរជនជាតិអង់គ្លេសម្នាក់ វ័យ៥៥ឆ្នាំ ដែលមានបញ្ហាសុខភាព។ ក្រុមការងារបានសម្របសម្រួលជួយសង្គ្រោះបឋម និងដូនគាត់ឡើងរថយន្តដើម្បីឱ្យគាត់បានទៅសម្រាកនៅសណ្ឋាគារដែលគាត់ស្នាក់នៅ

ផ្សាយនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤









ក្រុមភ្នាក់ងារទេសចរ បានប្រទះ និងប្រគល់សម្ភារជូនទេសចរវិញ ក្រោយពួកគេបានភ្លេចអំឡុងពេលដើរទស្សនានៅតំបន់ប្រាសាទ

ផ្សាយនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ១រសៀល ក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទអង្គរវត្ត និងអង្គភាពពាក់ព័ន្ធ បានប្រគល់កាបូបយួរពណ៌ខ្មៅជូនម្ចាស់ដើមវិញ ដែលគាត់បានភ្លេចនៅខាងលិចស្ពានបណ្តែតទឹក។ នៅថ្ងៃដដែល កាបូបលុយពណ៌ខ្មៅមួយទៀត បានប្រគល់ជូនជនជាតិអាឡឺម៉ង់ ដែលជាម្ចាស់វិញ បន្ទាប់ពីក្រុមការងារប្រទះឃើញនៅចំនុចមុខជណ្តើរ ឡើងរួតបាកាណាប្រាសាទអង្គរវត្ត។





ដោយឡែកនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ បានប្រគល់ទូរសព្ទ IPhone8 មួយគ្រឿងជូនម្ចាស់ដើមវិញ បន្ទាប់ប្រទះឃើញនៅប្រាសាទមេបុណ្យខាងកើត៕







ខឿនរួតទី៣ ជ្រុងនិរតីប្រាសាទបាយ័នបានបញ្ចប់ការជួសជុលជាស្ថាពរហើយ

ផ្សាយនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

ក្រុមការងារជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់ដោយជោគជ័យលើការងារជួសជុលខឿនជ្រុងនិរតី រួតទី៣នៃប្រាសាទបាយ័នជាស្ថាពរហើយនៅដើមឆ្នាំ២០២៤នេះ។

ស្ថាបត្យករ និងជាអ្នកគ្រប់គ្រងការដ្ឋានជួសជុលខឿនរួតទី៣ប្រាសាទបាយ័នកញ្ញា ម៉េង សុវណ្ណលីលីន ឱ្យដឹងថា ការងារជួសជុលសម្រេចបានដោយជោគជ័យនៅខឿនជ្រុងនិរតីនៃប្រាសាទបាយ័ន មានដូចជា រៀបចំថ្មខឿនដែលរំកិលហែកក្រៀកឱ្យចូលទីតាំងដើមវិញ បុកបង្ហាប់ដីគ្រឹះ រៀបថ្កម្រាល រំដោះទឹកហូរតាមប្រព័ន្ធទឹកបុរាណឡើងវិញ ជួសជុលបង្កាន់ដៃនាគប្រវែងប្រហែល១២ម៉ែត្រ ដែលក្នុងការងារទាំងនេះកន្លែងខ្លះត្រូវបន្ថែមថ្មថ្មីដែលចាំបាច់។ ការងារនេះ បានចាប់ផ្តើមតាំងពីដើមឆ្នាំ២០២៣ មកនោះ បានឈានដល់ការសម្រេចជាស្ថាពរហើយ គឺនៅសល់តែការងារតិចតួច ដូចជា ការដាប់សម្អាតថ្មថ្មី និងបិទបាយអបំពេញនៅតាមមុខដំណរថ្មតែប៉ុណ្ណោះ។

កញ្ញា ម៉េង សុវណ្ណលីលីន ឱ្យដឹងទៀតថា ខឿនជ្រុងខាងត្បូងផ្នែកខាងលិចរបស់រួតទី៣នៃប្រាសាទបាយ័នដែលរងខូចខាតខ្លាំងដោយសារតែមូលហេតុដូចជា ឫសឈើបានដុះចាក់ចូលទៅក្នុងរចនាសម្ព័ន្ធធ្វើឱ្យថ្មមួយចំនួនរំកិលចេញពីទីតាំងដើម និងបង្កើតបានជាប្រហោងនៅតាម



ចន្លោះថ្ម។ ទឹកហូរច្រោះចូលទៅតាមប្រហោងថ្មដោយនាំល្បាយដីខ្សាច់ចេញមកក្រៅបណ្តាលឱ្យខឿននេះហែកក្រៀកមួយចំនួន។ ម្យ៉ាងទៀត បារាំងធ្លាប់បានជួសជុលដោយប្រើបាយអស៊ីម៉ងត៍ទៅបិទបំពេញនៅតាមចន្លោះថ្កម្រាល។ ប៉ុន្តែ មកដល់បច្ចុប្បន្នបាយអនោះអស់គុណភាព ហើយបានធ្វើឱ្យខឿនរួតទី៣របស់ប្រាសាទបាយ័ននៅតែប្រឈមនិងហានិភ័យជាថ្មី៕





នៅរសៀលថ្ងៃទី៣០ ខែមករាឆ្នាំ២០២៤ ក្រុមភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទបាយ័ន
បានជួយសង្រ្គោះស្ត្រីភ្ជៀវទេសចរជនជាតិបារាំងម្នាក់ ដែលបានជួលសន្លប់ នៅត្រង់ជណ្តើរឈើឡើងប្រាសាទ

ផ្សាយនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤

ក្រោយពីជួយសម្រួល និងរុំរបួសបន្តិចក្រោយមក ជនរងគ្រោះ
មានស្ថានភាពស្រួលខ្លួនឡើងវិញ ហើយក្រុមភ្នាក់ងារ
ទេសចរណ៍ ក៏បានជួយជូនគាត់ឡើងរថយន្ត ដើម្បីគាត់
ទៅបន្តសម្រាកនៅសណ្ឋាគារ។







ដំបូលខ្លោងទ្វារខាងកើតរបស់ប្រាសាទអង្គរវត្ត ត្រូវការជួសជុលសង្គ្រោះបន្ទាន់ ដើម្បីឱ្យមានភាពរឹងមាំឡើងវិញ

ផ្សាយនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា បានធ្វើពិធីសែនព្រេនតាមបែបជំនឿសាសនា ដើម្បីសុំសេចក្តីសុខ ក្នុងការរុះរើថ្មដំបូលខ្លោងទ្វារខាងកើតរបស់ប្រាសាទអង្គរវត្ត ដើម្បីជួសជុលឡើងវិញ។

មន្ត្រីបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា លោក ឃាម មុនី មានប្រសាសន៍ថា ក្រុមការងារចាប់ផ្តើមរុះរើថ្មដំបូលកណ្តាលខ្លោងទ្វារខាងកើតនៃប្រាសាទអង្គរវត្តនេះ ដោយសារតែថ្មនៅទិសឦសានបែកជាច្រើនបំណែក និងបាក់ធ្លាក់ដោយអន្លើ។ ដំបូលនេះ គឺជាអ័ក្សខ្វែងនៃដំបូលទាំងមូល ដែលត្រូវទ្រទ្រង់រចនាសម្ព័ន្ធរបស់ដំបូលទាំងអស់ បើកាលណាធ្លាក់បាក់ គឺមានបញ្ហា មិនអាចឱ្យជួសជុលដំបូលទាំងអស់បានទេ ហើយក៏អាចធ្វើឱ្យប៉ះពាល់ដល់ជ្រុងឬជញ្ជាំងដទៃទៀតដែលនៅជុំវិញដែរ។

លោក ឃាម មុនី ឱ្យដឹងទៀតថា ដោយសារតែអាយុកាលនៃសំណង់បានធ្វើឱ្យថ្មមួយចំនួននៅជ្រុងឦសានពុកផុយ និងមានការខូចខាតនូវរចនាសម្ព័ន្ធរបស់ដំបូល ដោយដុំថ្មខ្លះក្រៀកចេញពីគ្នា និងមានប្រហោង។ ក្នុងលក្ខណៈដូចនេះ គឺរើថ្មដំបូលដូរថ្មថ្មី១ដុំ និងប៉ះថ្មបែកមួយចំនួន រួចរៀបបញ្ចូលពង្រឹងជ្រុងឦសានឡើងវិញ ទើបអាចបើកឱ្យភ្ញៀវឆ្លងកាត់បាន។

ខ្លោងទ្វារខាងកើតរបស់ប្រាសាទអង្គរវត្ត គឺជាច្រកដ៏សំខាន់មួយដែលភ្ញៀវទេសចរតែងតែមកទស្សនាជារៀងរាល់ថ្ងៃ ហើយវាក៏ជំណាងឱ្យច្រកទាំង៤របស់ប្រាសាទអង្គរវត្តដែរ៕







ខ្លោងទ្វារខាងលិចនៃប្រាសាទបន្ទាយក្តី បានបញ្ចប់ការជួសជុលជាស្ថាពរហើយ

ផ្សាយនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤





តាមរយៈក្រុមអ្នកជំនាញនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់ជាស្ថាពរនូវការងារជួសជុលខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី ដោយបានរៀបផ្តុំថ្មទៅតាមលំនាំរូបរាងដើមនៃខ្លោងទ្វារឡើងវិញ ដើម្បីលើកតម្លៃសំណង់បុរាណ។

លោកស្រី នេត ស៊ីមន បុរាណវិទូ និងជាអ្នកមើលការខុសត្រូវនៅការដ្ឋានជួសជុលខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី បានឱ្យដឹងថា ការងារជួសជុលនៅខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តីនេះ ត្រូវបានអនុវត្តចំនួនពីរដំណាក់កាល។ ដំណាក់កាលទីមួយ នៅក្នុងឆ្នាំ២០២០ ដោយចាប់ផ្តើមប្រមូលឯកសារ សិក្សាអំពីរូបរាង សម្រង់ប្លង់ សិក្សាអំពីហានិភ័យរបស់ខ្លោងទ្វារ និងចុះបញ្ជីថ្មនៅរាយប៉ាយជុំវិញខ្លោងទ្វារ។ដំណាក់កាលទីពីរ ចាប់ផ្តើមពីឆ្នាំ២០២២មក អនុវត្តគម្រោងជួសជុលពង្រឹងតែម្តង មានការងាររុះរើថ្មទាំងអស់ ចាប់ពីគ្រឹះរហូតដល់កំពូលខាងលើ ទើបរៀបចំពង្រឹងគ្រឹះផ្តុំទៅតាមលំនាំដើមវិញ និងបានបញ្ចប់ការជួសជុលជាស្ថាពរនាចុងឆ្នាំ២០២៣។ លោកស្រីថា បញ្ហាប្រឈមជាច្រើននៅក្នុងពេលរៀបផ្តុំថ្មឡើងវិញ ដោយសារថ្មបុរាណតែងមានល្បាក់។







ក្រោយបញ្ចប់ការងារជួសជុលជាស្តាពរ អ្នកជំនាញរំពឹងថា ខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី និងរឹងមាំឡើងវិញ ជានាសុវត្ថិភាពសម្រាប់ទេសចរឆ្លងកាត់ និងចូលមកផ្តិតយករូបភាពដ៏ស្រស់ស្អាតនៅទីនេះ។ ជាពិសេសបានលើកតម្លៃសំណង់បុរាណ រក្សាស្នាដៃទុកជាមរតកសម្រាប់មនុស្សជំនាន់ក្រោយ។

សូមរំឭកថា ដោយសារកត្តាអាយុកាលនៃសំណង់ ធម្មជាតិ និងមនុស្ស បានធ្វើឱ្យខ្លោងទ្វារខាងលិចរបស់ប្រាសាទបន្ទាយក្តីមុនការងារជួសជុលឡើងវិញ មានស្ថានភាពទ្រុឌទ្រោមខ្លាំង តួប៉មខាងលើនៃប្រាង្គកណ្តាលបានរលុះអស់នៅសល់តែមុខព្រហ្មចំនួនពីរប៉ុណ្ណោះ។

ចំណែកស្លាបសងខាង នៃថ្មដំបូលបានរលុះធ្លាក់អស់មួយចំនួន ហើយថ្មជញ្ជាំងបានក្រៀកហែកស្ទើរតែរលុះធ្លាក់មួយភាគធំទៅហើយ។ បន្ទាប់ពីការយកចិត្តទុកដាក់របស់អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ធ្វើឱ្យខ្លោងទ្វារដែលមានសភាពទ្រុឌទ្រោមមួយនេះ ប្រែមកជារឹងមាំ ស្រស់ស្អាត អាចឱ្យភ្ញៀវទេសចរធ្វើដំណើរឆ្លងកាត់ចូលទស្សនាប្រាសាទបន្ទាយក្តីតាមច្រកខាងលិចឡើងវិញ៕

សេចក្តីជូនដំណឹង ស្តីពីការបិទជាបណ្តោះអាសន្នផ្លូវទស្សនាក្នុងរោងទន្លីទី១ ផ្នែកខាងត្បូងឆៀងខាងលិចនៃប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ: ៦៦២/រជប សជណ
២៤

សេចក្តីជូនដំណឹង
ស្តីពី
ការបិទជាបណ្តោះអាសន្នផ្លូវទស្សនា
ក្នុងរោងទន្លីទី១ ផ្នែកខាងត្បូងឆៀងខាងលិចនៃប្រាសាទបាយ័ន

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់មេត្តាជ្រាបថា អាជ្ញាធរជាតិអប្សរា នឹងបិទជាបណ្តោះអាសន្ននូវផ្លូវទស្សនាត្រង់ច្រកចេញ-ចូលរោងទន្លីទី១ ផ្នែកខាងត្បូងឆៀងខាងលិចនៃប្រាសាទបាយ័នចំនួន០២ទីតាំង ដើម្បីអនុញ្ញាតឱ្យក្រុមការងារបច្ចេកទេសអាជ្ញាធរជាតិអប្សរាជួសជុលកម្រាលស្រុត និងរៀបចំប្រព័ន្ធបង្ហូរទឹកG5 នៅប្រាសាទបាយ័ន ដោយគិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់គម្រោងត្រូវបានជួសជុលរួចរាល់ជាស្ថាពរ។ ក្នុងអំឡុងពេលនៃដំណើរការជួសជុលនេះ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនអាចចេញ-ចូលទស្សនាប្រាសាទបាយ័ន តាមទិសដៅទស្សនាថ្មី ដូចមានផែនទីជូនភ្ជាប់មកជាមួយ។

សេចក្តីជូនដំណឹងបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ-អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ៍ ៨កើត ខែ ហ្វុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

ប្លង់បន្ទាញផ្ទូវបើក-បិទសម្សនា និងតីតាំងការដ្ឋានជូសជុលកម្រាលស្រុតនៅផ្លែកខាងកុងកេងនងតី១ ខាងត្បូងឆៀងខាងលិច និងរៀបចំប្រព័ន្ធបន្ទូតើកG5 នៅប្រាសាទបាយ័ន



ប្លង់បន្ទាញផ្ទូវបើក-បិទនសម្សនា និងបរិវេណតីតាំងការដ្ឋានជូសជុលកម្រាលស្រុតនៅផ្លែកខាងកុងកេងនងតី១ ខាងត្បូងឆៀងខាងលិច និងរៀបចំប្រព័ន្ធបន្ទូតើកG5 នៅប្រាសាទបាយ័ន





អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមរើគំនរថ្ម និងរៀបចំជួសជុលប្រព័ន្ធបង្ហូរទឹកបុរាណឡើងវិញ នៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

ក្រុមអ្នកជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានរើគំនរផ្នាំងថ្មជាច្រើនរយដុំ ដែលអ្នកអភិរក្សជំនាន់បារាំងនាដើមសតវត្សទី២០ ដើម្បីជួសជុលកម្រាលដែលស្រុត ព្រមទាំងរៀបចំប្រព័ន្ធបង្ហូរទឹកបុរាណឡើងវិញ នៅរោងទងទី១ ផ្នែកខាងត្បូងឆៀងខាងលិចរបស់ប្រាសាទបាយ័ន។

ស្ថាបត្យករ និងជាអ្នកគ្រប់គ្រងការដ្ឋានប្រាសាទបាយ័ន កញ្ញា ម៉ែង សុវណ្ណលីលីន ឱ្យដឹងថា បច្ចុប្បន្ន កម្រាលថ្មរបស់រោងទងទី១ ផ្នែកខាងត្បូងឆៀងខាងលិច នៃប្រាសាទបាយ័នបានស្រុត ហើយទាមទារឱ្យក្រុមការងារត្រូវតែរុះរើផ្នាំងថ្មចេញសិន ទើបយកមកផ្គុំសាកល្បងឡើងវិញដើម្បីជួសជុល។

ចំណែក ប្រព័ន្ធបង្ហូរទឹកបុរាណវិញ មិនដំណើរការយូរឆ្នាំមកហើយ។ ក្នុងកំឡុងពេលមានភ្លៀងធ្លាក់ម្តងៗ គឺមានស្នះទឹក ទើបក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរាធ្វើការជួសជុលឡើងវិញ ដើម្បីឱ្យមានដំណើរការរំដោះទឹកចេញពីប្រាសាទបាយ័នទៅខាងក្រៅ។







កញ្ញា ម៉ែង សុវណ្ណលីលីន ឱ្យដឹងទៀតថា ការរើថ្មកម្រាលរោងទងទី១ និងជួសជុលប្រព័ន្ធបង្ហូរទឹកនេះគឺមានសារសំខាន់ ដើម្បីរកវិធីបញ្ចៀសទឹកភ្លៀងចេញពីខាងលើរួតទី៣ដែលហូរធ្លាក់មកក្រោយប្រាសាទឱ្យកាន់តែលឿន និងកាត់បន្ថយបរិមាណទឹកភ្លៀងហូរចូលទៅក្នុងគ្រឹះប្រាសាទ។

អ្នកជំនាញពន្យល់ថា កាលណា បរិមាណទឹកភ្លៀងហូរចូលទៅក្នុងគ្រឹះប្រាសាទច្រើន វាអាចនាំឱ្យដីល្បាប់ខ្សាច់ហូរចេញទៅតាមទឹកភ្លៀង។ កាលណាដីល្បាប់ខ្សាច់ហូរចេញពីប្រាសាទច្រើនគឺវានឹងធ្វើឱ្យគ្រឹះប្រាសាទខ្សោយ៕



នៅព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤ នៅវេលាម៉ោង៨:៥០នាទី ក្រុមការងារគ្រប់គ្រងព្រៃឈើ បានប្រទះឃើញកាបូបលុយ ពណ៌ទឹកប៊ិចចំនួន១ របស់ទេសចរជនជាតិភូមៀ ស្ថិតក្នុងព្រៃខាងត្បូង ផ្លូវដីខាងលិចប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

ករណីមួយទៀត នៅវេលាម៉ោង ៩:១៨នាទី ក្រុមភ្នាក់ងារទេសចរ នគរបាលទេចរ និងនគរបាលបេតិកភណ្ឌ បានប្រទះឃើញកាបូបលុយពណ៌សូកូឡាចំនួន ១ របស់ភ្ញៀវស្រី ជនជាតិភូមគី សៀតទុកចោលក្នុងគំនរថ្ម នៅក្នុងប្រាសាទតាព្រហ្ម នៅចំនុចរោងទងទីពីរទិសខាងលិច ។ ករណីខាងលើ ក្រុមការងារបានសហការគ្នា ប្រគល់សម្ភារជូននគរបាលទេសចរណ៍ដើម្បីរក្សាទុក និងស្វែងរកម្ចាស់កាបូបវិញ។









ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកុម្ភៈ

ក្រុមការងារសណ្តាប់ធ្នាប់បានជួយសម្រួលរៀបចំសណ្តាប់ធ្នាប់តាមជងផ្លូវ ណែនាំឱ្យរថយន្តចូលចតតាមចំណតឱ្យបានត្រឹមត្រូវ ក៏ជួចជាជួយសម្រួលចរាចរណ៍ ជល់ទេសចរឆ្លងកាត់ផ្លូវ កំឡុងពេលចូលទស្សនានៅតាមប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤









នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤នេះ ក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទអង្គរវត្ត បានសហការសម្រួលឱ្យរុំម៉ែកកង់បីចូលយកភ្ញៀវទេសចរជនជាតិអឺរ៉ុបម្ខាក់ ដែលមានអាការៈមិនស្រួលខ្លួន ដើម្បីជូនគាត់ទៅព្យាបាលជំងឺនៅមន្ទីរពេទ្យ

ផ្សាយនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤









ស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI) បានប្រគល់រូបចម្លាក់ចំនួន៥ ជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក

ផ្សាយនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤





នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា ដែលកំពុងអភិរក្ស និងជួសជុលប្រាសាទតាព្រហ្ម បានប្រគល់រូបចម្លាក់ចំនួន៥ដែលបានរកឃើញកាលពីចុងឆ្នាំ២០២៣ ក្នុងអំឡុងពេលរើគំនរថ្មខ្លោងទ្វារខាងត្បូងប្រាសាទតាព្រហ្ម ដែលរលុះធ្លាក់អស់កាលដ៏យូរមកហើយ មកអាជ្ញាធរជាតិអប្សរា ដើម្បីរក្សាទុក។

លោកស្រី នេត ស៊ីមន បុរាណវិទូនៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា រូបចម្លាក់បដិមាទាំង៥ ដែលប្រគល់ជូនអាជ្ញាធរជាតិអប្សរា រួមមាន រូបចម្លាក់ព្រះពុទ្ធទ្រង់ភ្នែនប្រក់នាគចំនួន២ រូបលោកកេស្វរៈចំនួន១ រូបព្រះពុទ្ធទ្រង់ភ្នែនប្រក់នាគក្នុងទម្រង់សមាធិ បាត់ព្រះកេស និងបាត់ព្រះហស្តទាំងសងចំនួន២។

លោកស្រី បានបញ្ជាក់ទៀតថា ក្រោយពីប្រទះឃើញចម្លាក់ចំនួន៦ ក្រុមការងារបានសម្អាត រៀបចំឯកសារ និងសង្កេតឃើញថា ចម្លាក់បដិមាទាំង៥នេះ ពុំពាក់ព័ន្ធនឹងរចនាសម្ពន្ធខ្លោងទ្វារខាងត្បូងនេះទេ លើកលែងតែថ្មកំពូលហោជាង ដែលមានចម្លាក់រូបព្រះពុទ្ធគង់ភ្នែន មានទេពទ្រពីក្រោម១ផ្ទាំងដែលត្រូវដាក់នៅទីតាំងដើមរបស់ខ្លោងទ្វារឡើងវិញ លើកលែងតែរូបចម្លាក់ទាំង៥ខាងលើនេះ ដែលត្រូវជូនអាជ្ញាធរជាតិអប្សរា ដើម្បីជួសជុល និងរក្សាទុក។



អាជ្ញាធរជាតិអប្សរដួសជុលពង្រឹងតួខាងត្បូងប្រាសាទព្រះគោ

ផ្សាយនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤



ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា សហការជាមួយគម្រោងអភិរក្សទេពអប្សររបស់អាល្លឺម៉ង ហៅកាត់ថា (G.A.C.P)របស់ប្រទេសអាល្លឺម៉ង កំពុងធ្វើការដួសជុលពង្រឹងតួប៉មឥដ្ឋខាងត្បូងរបស់ប្រាសាទព្រះគោ ដែលទទួលរងការខូចខាតធ្ងន់ធ្ងរ។



ការដួសជុលនេះ មានការលំបាកយ៉ាងខ្លាំង ដោយរចនាសម្ព័ន្ធសំណង់មានភាពស្មុគស្មាញថ្មរបស់ប្រាសាទ និងក្បាច់ចម្លាក់មួយចំនួន មានការពុកផុយរបេះធ្លាក់ និងបាត់បង់។ ដែលទាមទារការយកចិត្តទុកដាក់ខ្ពស់ ពិសេសបច្ចេកទេសធ្វើការពង្រឹងនៅតាមផ្នែកទ្រទម្ងន់ និងទប់ដំហរប្រាសាទឱ្យមានលំនឹងឡើងវិញ។ នេះគឺជាផ្នែកមួយនៃកិច្ចការអភិរក្ស ដែលអាជ្ញាធរជាតិអប្សរាតែងធ្វើជាប្រចាំ ដើម្បីថែរក្សា និងលើកតម្លៃប្រាសាទជាទីសក្ការៈដែលមានអាយុកាលជាង ១១៣៩ឆ្នាំនេះ នៅឈរឆ្ងាំយូរអង្វែងបន្តទៀត៕



អាជ្ញាធរជាតិអប្សរាធ្វើពិធីបួងសួង តាមបែបសាសនា ក្រោយបញ្ចប់ការជ្ឋាននៅប្រាសាទគោកបល្ល័ង្ក

ផ្សាយនៅថ្ងៃទី០២ ខែកុម្ភ: ឆ្នាំ២០២៤



នៅរសៀលថ្ងៃទី០១ ខែកុម្ភ: ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា រួមជាមួយអាជ្ញាធរមូលដ្ឋាន បងប្អូនប្រជាពលរដ្ឋរស់នៅជុំវិញនោះ ប្រារព្ធធ្វើពិធីបួងសួងសុំសេចក្តីសុខ បន្ទាប់ពីបានបញ្ចប់ការសម្អាតទីទួល កាប់ឆ្ការព្រៃ និងស្តារកសិន្ទុទឹក នៅប្រាសាទគោកបល្ល័ង្ក ដើម្បីអភិរក្សទីទួលបុរាណដ្ឋានមួយនេះ ចៀសវាងការបាត់បង់ ទុកជាកេរដំណែលដូនតាខ្មែរបានបន្សល់ទុក សម្រាប់កូនចៅគោរពបូជា។

ក្រោយការងារសម្អាត រៀបចំរួចរាល់នៅលើទីទួលនៃប្រាសាទគោកបល្ល័ង្កនេះ នឹងមិនក្លាយជាទីកន្លែងចោលសំរាម និងគំនរបាក់បែកផ្សេងៗដែលប្រជាពលរដ្ឋឈប់ប្រើប្រាស់ មកបោះចោលនៅទីនេះទៀតឡើយ។ សូមជម្រាបថា ប្រាសាទគោកបល្ល័ង្ក មានទីតាំងស្ថិតនៅភូមិបឹង សង្កាត់ជ្រាវ ក្រុងសៀមរាប។ ក្រោយមានការរាយការណ៍ អំពីការរំលោភបំពាន ដោយចាក់ដីលុបទៅលើកសិន្ទុទឹកជាប់នឹងទួលនៃប្រាសាទ អាជ្ញាធរជាតិអប្សរា ដោយមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះសម្អាតព្រៃជុំវិញទីតាំងបុរាណដ្ឋាន ដោយបានធ្វើកំណាយរៀបចំវត្ថុដែលនៅសេសសល់មួយចំនួនរក្សាទុកនៅទីតាំងដើម ដើម្បីកិច្ចការងារអភិរក្ស និងជាការគោរពបូជាពីសំណាក់ប្រជាពលរដ្ឋ។





ស្ថាប័នក្រុមអភិរក្សប្រាសាទអង្គរនៃរដ្ឋាភិបាលចិន-កម្ពុជា (CCSA) បានប្រគល់វត្ថុបុរាណមកអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក

ផ្សាយនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៤

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្ថាប័នក្រុមអភិរក្សប្រាសាទអង្គរនៃរដ្ឋាភិបាលចិន-កម្ពុជា បានប្រគល់វត្ថុបុរាណចំនួន២៧៧កេស ដែលរកឃើញក្នុងអំឡុងពេលស្រាវជ្រាវ និងជួសជុលប្រាសាទចៅសាយទេវតា ពីឆ្នាំ១៩៩៨-១៩៩៩ និងក្នុងឆ្នាំ២០១២ និងប្រាសាទតាកែវ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ មកអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក។

វត្ថុបុរាណទាំងនោះភាគច្រើនជាអំបែងភាជន៍ និងបំណែកចម្លាក់ពីថ្មភក់មួយចំនួន ដោយក្នុងនោះវត្ថុបុរាណមកពីប្រាសាទចៅសាយទេវតាមានចំនួន៣៥កេស មានវត្ថុចំនួន ២៩២។ ចំណែកវត្ថុមកពីប្រាសាទតាកែវមានចំនួន៩៥កេស មានវត្ថុចំនួន៨០៨។ ដោយឡែកវត្ថុបុរាណចំនួន ១៤៧កេសទៀតមកពីប្រាសាទចៅសាយទេវតា និងប្រាសាទតាកែវ ប៉ុន្តែសុទ្ធតែជាអំបែងភាជន៍ដែលមានទំហំតូចៗ ដែលមិនអាចកំណត់រូបរាងបាន។







រូបភាពប្រចាំសប្តាហ៍÷ប្រាសាទបន្ទាយសំរែ ជម្រើសទស្សនាល្អសម្រាប់ភ្ញៀវទេសចរ ដែលចូលចិត្តភាពស្ងប់ស្ងាត់ មិនគួរមើលរំលង

ផ្សាយនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៤





ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារឆ្លាក់ចារទេសចរនៃអាជ្ញាធរជាតិអប្សរា គោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញភ្ញៀវទេសចរជាជនជាតិរុស្សី២នាក់ប្តីប្រពន្ធវិញ ក្រោយពិនិត្យឃើញថាពិតជារបស់គាត់ពិតប្រាកដមែន

ផ្សាយនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៤









រូបភាពប្រចាំសប្តាហ៍៖
ទិដ្ឋភាពភ្នៀវទេសចរទេស្សនាថ្ងៃលិចនៅប្រាសាទភ្នំបាខែងមើលពីលើអាកាស

ផ្សាយនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៤









ថ្មជាង៤០០ដុំ គរនៅទីតាំងខាងត្បូងឆៀងខាងលិចប្រាសាទបាយ័ន ត្រូវបានកំណត់អត្តសញ្ញាណ និងស្គាល់ទីតាំងដើម

ផ្សាយនៅថ្ងៃទី០៥ ខែកុម្ភ: ឆ្នាំ២០២៤



ក្រុមអ្នកជំនាញជួសជុលនៅខឿនរួតទី១របស់ប្រាសាទបាយ័ន ឱ្យដឹងថា ក្នុងចំណោមថ្មចំនួនប្រមាណ២០០០ដុំ គរនៅទីតាំងខាងត្បូងឆៀងខាងលិចប្រាសាទបាយ័ន ដែលចាប់ផ្តើមរើតាំងពីពាក់កណ្តាលខែមករា ឆ្នាំ២០២៤ ត្រូវបានរកឃើញចំនួនជាង៤០០ដុំ ដែលអាចកំណត់អត្តសញ្ញាណបានថា គឺជាថ្មធ្លាក់មកពីថែវទី២ និងកំពូលព្រហ្មមុខបួននៅជ្រុងនិរតីនៃប្រាសាទបាយ័ន។ ប៉ុន្តែ ចំពោះថ្មជាច្រើនទៀត គេមិនទាន់ដឹងថា មានប្រភពមកពីណានៅឡើយ។



បុគ្គលិកជួសជុលប្រាសាទរបស់អាជ្ញាធរជាតិអប្សរា និងជាអ្នកជំនាញរកថ្ម លោក ញ៉ុក ឡូ ឱ្យដឹងថា ក្នុងការរើគំនរថ្មទិសខាងត្បូងប៉ែកខាងលិចរបស់ប្រាសាទបាយ័ន នៅជំហានដំបូងនេះ បានរកឃើញថ្ម និងអាចកំណត់អត្តសញ្ញាណជាច្រើនប្រភេទដូចជា ថ្មផ្តែរ ថ្មចិញ្ចើមព្រហ្ម ថ្មទងត្រចៀករបស់ព្រហ្មមុខបួន ថ្មសរសរពេជ្រ ថ្មហោជាង និងដំបូលរបស់ប្រាសាទបាយ័ន។ ដោយឡែក ថ្មមានចម្លាក់ជាទងត្រចៀក បបេមាត់ទាំងនោះ បានជ្រុះធ្លាក់ពីកំពូលមុខព្រហ្មលេខ២៧ រួមទាំងធ្លាក់ពីថែវទី២ ដែលនៅទល់មុខនិងគំនរថ្មនេះតែម្តង។ អ្នកជំនាញរូបនេះ បញ្ជាក់ទៀតថា ចំពោះដុំថ្មដែលអាចកំណត់អត្តសញ្ញាណបាន គឺត្រូវរៀបទុកមួយផ្នែកសម្រាប់យកមកផ្គុំគ្នាឡើងវិញ។ រីឯថ្មមួយចំនួនទៀត មិនទាន់អាចកំណត់អត្តសញ្ញាណបានត្រូវទុកដាច់ដោយឡែកជាបណ្តោះអាសន្នសិន។



ស្ថាបត្យករ និងជាអ្នកគ្រប់គ្រងការដ្ឋានជួសជុលខឿនរួតទី១ប្រាសាទបាយ័ន កញ្ញា ម៉ែង សុវណ្ណលីលីន ឱ្យដឹងថា មុននឹងឈានដល់ការជួសជុលថ្មកម្រាលដែលស្រុត និងជួសជុលប្រព័ន្ធបង្ហូរនៅទិសខាងត្បូងឆៀងខាងលិចនៅរួតទី១នៃប្រាសាទបាយ័នឡើងវិញ ជាដំបូង ក្រុមការងារត្រូវរើគំនរថ្មដែលនៅខាងក្រោយជញ្ជាំងរោងទងនៃទីតាំងជួសជុលជាចាំបាច់។ ការងារដំហានទី១ គឺត្រូវចុះបញ្ជីថ្មនីមួយៗ និងរើម្តងមួយៗ បែងចែកទៅតាមប្រភេទថ្ម ដើម្បីងាយស្រួលរកតួនាទី និងទីតាំងរបស់វា លើកលែងតែថ្មដំបូលទាំងអស់ហ្នឹងត្រូវយកចេញទៅខាងក្រៅ រៀបគរលើគ្នាឱ្យមានសណ្តាប់ធ្នាប់ អ្វីដែលយើងចង់បាន គឺរកឃើញផ្នែកខាងលើបំផុតនៃតួប្រាង្គមុខបួន។

កញ្ញា ម៉ែង សុវណ្ណលីលីន ឱ្យដឹងទៀតថា ជាផែនការក្រុមការងារនឹងព្យាយាមរុករកទីតាំងដើមរបស់គំនរថ្មនីមួយៗ ហើយបើសិនមានលទ្ធភាពនឹងរៀបចំថ្មដែលរកឃើញទាំងអស់នោះទៅទីតាំងដើមវិញនាពេលអនាគត៕





ពិធី«ឡើងមាយ»

ផ្សាយនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤



ពិធី«ឡើងមាយ»ជាពិធី ឡើងអ្នកតា ដែលអ្នកស្រុកអង្គរតែងតែធ្វើនៅក្នុងខែមាយ ជាពិសេស ថ្ងៃ៣កើត ខែមាយ ទោះបីបច្ចុប្បន្នស្រុកទេសមានការរីកចម្រើនក៏ដោយ ក៏អ្នកស្រុកអង្គរនៅតែបន្តថែរក្សាប្រពៃណី និងទំនៀមទម្លាប់បែបបុរាណបានយ៉ាងខ្ជាប់ខ្ជួន ដោយនាំគ្នាធ្វើពិធីឡើងមាយឬឡើងអ្នកតានៅតាមខ្នមអ្នកតា ឬសាលាឆាន់ក្នុងភូមិរបស់ពួកគេ។







ឡើងមាយនៅភូមិគោកស្នោត



ឡើងមាយនៅប្រាសាទវត្តអាជ្ញារ

ខែមាយ ជាខែដែលប្រមូលផលស្រូវបានរួចរាល់ទាំងស្រុង ពោល គឺជាការបិទបញ្ចប់ វដ្តស្រូវនៃឆ្នាំនោះ។ ជាទូទៅ ភូមិជាច្រើននៅតំបន់អង្គរ ដូចជា ភូមិរលួស និងភូមិដូននំ របស់ឃុំបាគង ភូមិគីរីមានន្ទ និងភូមិស្នោត របស់ឃុំអំពិល នៃស្រុកប្រាសាទបាគង ភូមិនគរក្រៅ ភូមិគោកស្នោត គោកបេង របស់សង្កាត់គោកចក ភូមិក្រវ៉ាន់ របស់សង្កាត់នគរធំ ភូមិក្រសាំងរលើង របស់សង្កាត់សៀមរាប ភូមិភ្នំក្រោម របស់សង្កាត់ចុងឃ្នៀស នៃក្រុងសៀមរាប ភូមិប្រដាក ភូមិថ្នល់ត្រង់ របស់ឃុំព្រះដាក់ ភូមិសាលាក្រវ៉ាន់ របស់ឃុំរំចេក ភូមិស្រែចង្ហូត របស់ឃុំរុនតាឯក នៃស្រុកបន្ទាយស្រី ភូមិដូនឪ ភូមិតាប្រុក និងភូមិលាងដៃ របស់ឃុំលាងដៃ នៃស្រុកនគរធំជាដើម តែងធ្វើពិធីឡើងមាយនៅខួមអ្នកតាតែមួយល្ងាចប៉ុណ្ណោះ។ ចំណែកឯភូមិខ្លះទៀត ធ្វើរយៈពេលមួយយប់មួយថ្ងៃក៏មាន។

នៅឆ្នាំនេះ ភូមិបង្គោងនឹងរៀបចំពិធី«ឡើងមាយ»នៅថ្ងៃអាទិត្យ ២កើត ខែមាយ ត្រូវនឹងថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ ដោយធ្វើពិធីចាប់ត្រីសម្រាប់ធ្វើម្ហូបថ្ងៃឡើងមាយ នៅត្រពាំងបឹង វេលាម៉ោង៦ព្រឹក។ ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប៕







សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ីតាំងបង្ហាញហូល ផាមួងដែលជាស្នាដៃអ្នកស្រុកព្រៃកប្បាស ខេត្តតាកែវ ដូនសាធារណជនបានសិក្សាស្វែងយល់

ផ្សាយនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៤

សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី នឹងរៀបចំពិធីតាំងពិព័រណ៌មិនអចិន្ត្រៃយ៍រយៈពេល៦ខែ ដើម្បីឱ្យសាធារណជន និងភ្ញៀវទេសចរ បានចូលទស្សនា ក៏ដូចជាសិក្សាស្វែងយល់ពីហូល ផាមួងខ្មែរ ចាស់ៗដែលជាស្នាដៃរបស់អ្នកស្រុកព្រៃកប្បាស ខេត្តតាកែវ។

លោក សែន គឹមស៊ុន នាយករងស្តីទីនៃសារមន្ទីរវាយណាភណ្ឌប្រពៃណីអាស៊ី នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ពិព័រណ៌ខាងលើនេះ នឹងមានសមុច្ច័យជាហូល ផាមួង អាវប៉ាក់សរុបចំនួន២១សម្រាប់តាំងបង្ហាញ។លោកបន្តថា ពិព័រណ៌នេះនឹងចាប់ផ្តើមពីថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៤ ដែលមានរយៈពេល៦ខែ។

សមុច្ច័យខាងលើ គឺសារមន្ទីរបានមកពីការបរិច្ចាគរបស់ពលរដ្ឋស្រុកព្រៃកប្បាស ខេត្តតាកែវ សរុបមានចំនួន៥១ ដែលក្នុងនោះមានសំពត់ផាមួង អាវ និងក្រណាត់ហូលជាដើម។ ក្រុមការងារសារមន្ទីរបានទៅទទួល សមុច្ច័យទាំងនោះនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ បន្ទាប់មកមានការចុះបញ្ជីរៀបចំអភិរក្ស សម្អាត និងជួសជុល មុននឹងរៀបចំឱ្យមានពិព័រណ៌បង្ហាញដល់សាធារណជនបានទស្សនា។ ក្រណាត់ហូល ផាមួងខ្លះមានអាយុកាលចន្លោះពី៤០ទៅ៦០ឆ្នាំ ដែលពលរដ្ឋបានថែទាំយ៉ាងយកចិត្តទុកដាក់ មុននិងក្នុងសម័យខ្មែរក្រហម។



នេះជាដំណាក់កាលទី១នៃការរៀបចំពិព័រណ៌ដែល លោក សែន គឹមស៊ុន ពន្យល់ថា សារមន្ទីរបានរើស សមុច្ច័យចំនួន២១ក្នុងចំណោម៥១ ហើយនិងមានការបង្ហាញនៅដំណាក់កាលក្រោយៗទៀត។ លោក សែន គឹមស៊ុន អំពាវនាវឱ្យសាធារណចូលទស្សនាក្នុងពិព័រណ៌ដ៏មានសារសំខាន់នេះ ដែលជាផ្នែកមួយក្នុងការឱ្យតម្លៃ និងសិក្សាស្វែងយល់ពីស្នាដៃសិល្បៈនៃហូល ផាមួងរបស់អ្នកស្រុកព្រៃកប្បាស ខេត្តតាកែវ៕



ខឿនឧបោសថាគារប្រាសាទតុបខាងលិច កំពុងទទួលបានការជួសជុល

ផ្សាយនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤





អ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា សហការជាមួយវិទ្យាស្ថានជាតិណារ៉ាប្រទេសជប៉ុន កំពុងបន្តធ្វើការជួសជុលខឿននៃឧបោសថាគារ មុខប្រាសាទតុបខាងលិច ដែលទទួលរងការខូចខាតធ្ងន់ធ្ងរ បន្ទាប់ពីធ្វើការជួសជុលប្រាង្គកណ្តាលរបស់ប្រាសាទនេះបានចប់រួចរាល់។

ខឿននៃឧបោសថាគារ ដែលដើមឡើយ មានរោងធ្វើពីឈើប្រក់ក្បឿង (បច្ចុប្បន្ន ពុកផុយដួលរលំអស់ហើយ នៅសល់តែស្លាកស្នាមប៉ុណ្ណោះ) មានទទឹង៧,៥០ម៉ែត្រ និងបណ្តោយ១៧,៥០ម៉ែត្រ នេះគឺជាទីតាំងនៃព្រះវិហារព្រះពុទ្ធសាសនា បន្ទាប់ពីប្រាសាទនេះ បានប្រែក្លាយជាប្រាសាទសម្រាប់ឧទ្ទិសដល់ព្រះពុទ្ធសាសនា តាំងពីសម័យកណ្តាលមក។

បើតាមការបញ្ជាក់របស់លោក ឡាំ សុភ័គ្រ អ្នកទទួលខុសត្រូវការងារជួសជុល បានឱ្យដឹងថា ក្នុងការជួសជុលនេះ គឺយើងនឹងធ្វើការរើតួខឿនទាំងមូលចេញ ដើម្បីធ្វើការពង្រឹងគ្រឹះ និងរចនាសម្ព័ន្ធផ្នែកខាងក្រោម ទើបរៀបផ្គុំតួខឿននៃឧបោសថាគារទាំងមូលឡើងវិញ ទៅតាមលំនាំដើម ហើយការងារជួសជុលនេះ គ្រោងនឹងបញ្ចប់នាពេល៣ខែខាងមុខ៕



សវនករស្ថាប័នធានាគុណភាពជប៉ុន ធ្វើសវនកម្មផ្ទៃក្រៅ លើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤



នាព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បានរៀបចំបើកសវនកម្មផ្ទៃក្រៅលើប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ បស់អាជ្ញាធរជាតិអប្សរា ដែលមានការចូលរួមវាយតម្លៃដោយស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance ហៅកាត់ថា (JQA) ក្នុងរយៈពេលបីថ្ងៃចាប់ពីថ្ងៃទី៦ ដល់៨ ខែកុម្ភៈ ឆ្នាំ២០២៤។

គោលបំណង នៃសវនកម្មផ្ទៃក្រៅនេះ ធ្វើឡើងដើម្បីបន្តវិញ្ញាបនបត្រជាថ្មីដល់ស្ថាប័នអាជ្ញាធរជាតិអប្សរា ក្នុងការបំពេញបេសកកម្មថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រ នៃតំបន់សៀមរាប- អង្គរ។ ដោយនៅក្នុងនោះ មានពិនិត្យលើឯកសារ ជួបសម្ភាសជាមួយបុគ្គលិកទូទៅ និងចុះទៅពិនិត្យផ្ទាល់នៅតាមការដ្ឋាននានាក្នុងរមណីយដ្ឋានអង្គរ។

អញ្ជើញចូលរួមបើកសវនកម្មផ្ទៃក្រៅ ក្រោមវត្តមាន **ឯកឧត្តម ឡុង កុសល** អគ្គនាយករង តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោក ម៉ាម៉ូរុ យ៉ាម៉ាដា (Mamoru YAMADA) តំណាងស្ថាប័ន JQA និងជាសវនករ **ឯកឧត្តម សុខ លក្ខិណា** ប្រធានអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា ប្រធាន-អនុប្រធាននាយកដ្ឋាន និងអង្គភាពគ្រប់គ្រងបរិស្ថានអង្គរ ព្រមទាំងមន្ត្រី-បុគ្គលិកជាអ្នកជំរុញបរិស្ថាននៅតាមនាយកដ្ឋាននីមួយៗ។



ក្រុមការងារអាជ្ញាធរជាតិអប្សរា កំពុងដំឡើងស្លាកកញ្ចក់តាមផ្លូវកែងមួយចំនួន នៅតំបន់រមណីយដ្ឋានអង្គរ ស្លាកកញ្ចក់ទាំងអស់មានចំនួន២១បង្គោល ស្មើនឹង២១ទីតាំង ដែលជាការឧបត្ថម្ភដោយធនាគារអម្រឹត

ផ្សាយនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤













ឯកឧត្តម អគ្គនាយកអាជ្ញាធរជាតិអប្សរា ចុះពិនិត្យការងារក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយ អគ្គនាយករង ប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញពាក់ព័ន្ធ ចុះពិនិត្យការងារតាមការដ្ឋាននានា ដើម្បីសិក្សាជាមួយអ្នកជំនាញរបស់ខ្លួន ក្នុងការលើកគម្រោងកិច្ចការអភិរក្សប្រកបដោយចីរភាពរបស់ប្រាសាទមួយចំនួននៅក្នុងតំបន់រមណីយដ្ឋានអង្គរ៕











កំណាយស្រាវជ្រាវនៅខ្លោងទ្វារខាងត្បូងប្រាសាទតាព្រហ្ម បានរកឃើញថ្មបាយក្រៀមជាបន្តបន្ទាប់ និង កំណត់អត្តសញ្ញាណស្ថានភាពគ្រឹះខាងក្រោមរបស់ខ្លោងទ្វារ

ផ្សាយនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា សហការជាមួយស្ថាប័នASI របស់ឥណ្ឌា កំពុងធ្វើកំណាយជួសជុលឡើងវិញខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្ម ដែលបានរងការខូចខាតទ្រុឌទ្រោមខ្លាំង ដើម្បីលើកតម្លៃសំណង់បុរាណឱ្យមានរូបរាងឡើងវិញ។

លោកស្រី នេត ស៊ីមន បុរាណវិទូ នាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា មុនពេលចាប់ផ្តើមការងារជួសជុល ស្ថាប័នស្រាវជ្រាវបុរាណវិទ្យាឥណ្ឌា (ASI)ក៏បានសិក្សា ប្រមូលព័ត៌មានមុននិងឈានទៅដល់ការរុះរើជួសជុលខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្ម។ លោកស្រីថា នេះគឺជាដំណាក់កាលនៃការជួសជុលហើយ ដូច្នេះក្រុមការងារបានរើថ្មនៅផ្នែខាងលើទាំងអស់ ដើម្បីចុះបញ្ជីថ្ម ត្រៀមជួសជុលពង្រឹងឡើងវិញ។

លោកស្រីថា ការងារកំណាយស្រាវជ្រាវ មានគោលបំណងសំខាន់ៗដូចជា៖
១. ស្វែងរកថ្មដែលបានបាត់បង់
២.សិក្សាអំពីស្ថានភាពគ្រឹះខ្លោងទ្វារ ស្វែងរកមូលហេតុដែលធ្វើឱ្យខ្លោងទ្វារបាក់រលុះទ្រុឌទ្រោម និង៣. ដើម្បីសិក្សាអំពីបច្ចេកទេសនៃការសាងសង់របស់ចាស់បុរាណ ពីរចនាសម្ពន្ធគ្រឹះខាងក្រោមរបស់ខ្លោងទ្វារ។







លោកស្រី នេត ស៊ីមន បុរាណវិទូបន្តថា ការងារធ្វើកំណាយស្រាវជ្រាវ បានចាប់ផ្តើមតាំងពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០២៣ មកដល់រយៈពេលជិតពីរខែមកនេះ ក្រុមការងារជីករណ្តៅបានចំនួន៥នៅជុំវិញខឿនរបស់ខ្លោងទ្វារ។ ដោយបានជីករណ្តៅខ្លះមានជម្រៅចន្លោះពី៦០ទៅ៧០សង់ទីម៉ែត្រ ដើម្បីស្វែងរកថ្ម។ លទ្ធផលនៃកំណាយបានរកឃើញថ្មបាយក្រៀមជិត១០០ដុំហើយ។ ប៉ុន្តែអ្នកជំនាញនៅមិនទាន់សន្និដ្ឋានអំពីចំនួនថ្មពិតប្រាកដបាននៅឡើយ ដោយត្រូវរង់ចាំការធ្វើកំណាយឱ្យរួចរាល់សិន ដោយគ្រោងចំណាយពេលប្រហែល៣ខែទើបចប់។ មួយវិញទៀត បានកំណត់អត្តសញ្ញាណស្ថានភាពគ្រឹះខាងក្រោមរបស់ខ្លោងទ្វារ ដែលមានសភាពស្រុតខ្លាំង ដោយសារដីធូរ មិនហាប់រឹងមាំ ដូចនៅខ្លោងទ្វារខាងកើតនៃប្រាសាទតាព្រហ្ម និងខ្លោងទ្វារខាងលិចនៃប្រាសាទបន្ទាយក្តីឡើយ។ និងបញ្ហាឫសឈើចាក់ចូលទៅកាន់តែជ្រៅទៅក្នុងគ្រឹះខាងក្រោមនៃខ្លោងទ្វារ។

អ្នកជំនាញមានក្តីសង្ឃឹមថា នឹងអាចរកឃើញថ្មបន្ថែមទៀតនៅពេលធ្វើកំណាយរួចរាល់ ដើម្បីយកថ្មទាំងនោះមកប្រើប្រាស់គ្រប់ចំនួន ក្នុងការងារជួសជុលពង្រឹងខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្មនេះ៕



នៅព្រឹកថ្ងៃទី០៨ ខែកុម្ភ: ឆ្នាំ ២០២៤នេះ
ភ្នាក់ងារទេសចរប្រចាំគោលដៅប្រាសាទបាគង ប្រាសាទព្រៃមន្ទីរ ប្រាសាទត្រពាំងផុងនិងប្រាសាទទទឹងថ្ងៃ បានធ្វើការបោសសំអាតដី តាមកាំជណ្តើរបរិវេណក្លោងទ្វារចូលខាងត្បូងនៃប្រាសាទបាគង និងជូតសំអាតស្លាកសញ្ញា ដើម្បីលើកកម្ពស់សោភ័ណភាពប្រាសាទ

ផ្សាយនៅថ្ងៃទី០៨ ខែកុម្ភ: ឆ្នាំ២០២៤









ក្រុមការងារភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា សង្គ្រោះបឋមជំងឺភ្ញៀវទេសចរដែលមានអាការៈខ្យល់គរនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤

នៅត្រង់ចំណុចរួតទី២ខាងក្នុង ខាងកើតឈៀងខាងជើង នៃប្រាសាទបាយ័ន។ ភ្លាមៗនោះ ភ្នាក់ងារទេសចរ នៃអាជ្ញាធរជាតិអប្សរា និងកម្លាំងអង្គភាពនគរបាល ការពារបេតិកភណ្ឌប្រចាំនៅក្រុងអង្គរធំ សហការណ៍គ្នា ជួយសង្គ្រោះបឋមបានទាន់ពេលវេលា និងបន្ទាប់ពីបាន ធូរស្បើយខ្លះ បន្តជួនគាត់ឡើងឡានដើម្បីទៅសម្រាកនៅ សណ្ឋាគារវិញ។





ករណីដូចគ្នានេះដែរ ភ្នាក់ងារទេសចរគោលដៅ ប្រាសាទអង្គរវត្ត បានជួយសង្គ្រោះបឋមជូនភ្ញៀវអឺរ៉ុបម្នាក់ អាយុ៣៥ឆ្នាំ ជនជាតិហូឡង់ ដែលមានការៈខ្យល់គរ ព្រមទាំងបានសម្រួលឱ្យរថយន្តចូលមកយកគាត់ទៅ ព្យាបាលបន្តនៅមន្ទីរពេទ្យដែរ៕





អាជ្ញាធរជាតិអប្សរា ព្យាយាមកាត់បន្ថយការប្រើប្រាស់ផ្លាស្ទិកមួយដំហានម្តងៗ នៅក្នុងរមណីយដ្ឋានអង្គរដើម្បីរួមចំណែកក្នុងការថយដល់បរិស្ថានឱ្យកាន់តែប្រសើរ

ផ្សាយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤



បច្ចុប្បន្ននេះ ក្រុមការងារ នៃអាជ្ញាធរជាតិអប្សរា កំពុងងាកមកប្រើប្រាស់វត្ថុធាតុដើមធម្មជាតិដូចជា ឫស្សី ដែលនឹងផ្តល់ការងារកាន់តែច្រើនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងធ្វើឱ្យបរិស្ថាននៅតាមការដ្ឋានក្នុងឧទ្យានអង្គរកាន់តែប្រសើរឡើង។



អាជ្ញាធរជាតិអប្សរា បានកែសម្រួលរោង និងរបងហ៊ុមព័ទ្ធនៅតាមការដ្ឋានជួសជុលនានាក្នុងតំបន់អង្គរ ដោយកាត់បន្ថយការប្រើប្រាស់ផ្លាស្ទិកជាតង់ ឬស្បែមួយដំហានម្តងៗ ដោយប្រើប្រាស់វត្ថុធាតុដើមធម្មជាតិដូចជា ឫស្សីជំនួសវិញ៕







អាជ្ញាធរជាតិអប្សរា រៀបចំដំឡើងបង្កាន់ដៃជណ្តើរឈើចំនួនពកន្លែង នៅប្រាសាទអង្គរវត្ត ដើម្បីសម្រួលការឡើង-ចុះ និងសុវត្ថិភាពភ្ញៀវទេសចរ

ផ្សាយនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៤



ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍(TSC) របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធជាតិអប្សរា បានដំឡើងបង្កាន់ដៃជណ្តើរឈើចំនួនបីទីតាំង នៅប្រាសាទអង្គរវត្តក្នុងគោលបំណង ជួយសម្រួលដល់ការឡើងចុះរបស់ភ្ញៀវទេសចរឱ្យងាយស្រួល និងសុវត្ថិភាពផង។ កន្លែងទាំងបី ដែលក្រុមការងារដំឡើងបង្កាន់ដៃជណ្តើរនោះ គឺនៅរួតព្រះពាន់ នៅចំណុចកណ្តាល និងនៅអមសងខាង នៃរួតព្រះពាន់ឡើង-ចុះរួតបាកាណ (កំពូលកណ្តាល)របស់ប្រាសាទអង្គរវត្ត។

ប្រធានក្រុមការងារពលករនៅនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ លោក ប៊ូ ផានេត ឱ្យដឹងថាការដំឡើងបង្កាន់ដៃជណ្តើរឈើទាំងនេះ ក្នុងគោលបំណងជួយសម្រួលដល់ការឡើងចុះរបស់ភ្ញៀវទេសចរផង និងក៏ជួយការពារគ្រោះថ្នាក់ដល់ភ្ញៀវទេសចរ ដែលអាចនឹងកើតឡើងជាយថាហេតុណាមួយផង។ ប្រការទី២ គឺជួយបង្ការកុំឱ្យភ្ញៀវទេសចរចាប់តោង ឬក៏ប៉ះផ្ទាល់ទៅលើថ្មប្រាសាទ ដែលអាចនាំឱ្យសឹករឹករិលក្បាច់ចម្លាក់ជាដើមជាពិសេសជួយសម្រួលបានច្រើនដល់ភ្ញៀវទេសចរនៅរដូវធ្លាក់ភ្លៀងបង្ការកុំឱ្យរអិលទៀតផង។





លោក ផានេត បន្ថែមទៀតថា ការដំឡើងបង្កាន់ដៃនេះ បានប្រើឆ្នឹងដៃកស្រោបឈើលើដើម្បីការពារកុំឱ្យច្រេះ និងមិនឱ្យប៉ះពាល់ដល់សោភ័ណភាពនៃប្រាសាទនោះទេ។ ក្រុមទេសចរចម្រុះជាតិសាសន៍ ព្រមទាំងមគ្គទេសក៍ទេសចរណ៍ជាច្រើន បានសម្តែងការសប្បាយចិត្តនៅពេលឃើញអាជ្ញាធរជាតិអប្សរាដំឡើងបង្កាន់ដៃជណ្តើរទាំងនេះ។

មគ្គទេសក៍ទេសចរណ៍ ភាសាជប៉ុន លោក យ៉ែម រ៉ូហ្សា បានបង្ហាញក្តីរំភើប នៅពេលដែលរូបលោកបាននាំភ្ញៀវមកទស្សនាប្រាសាទអង្គរវត្ត ចំពេលដែលក្រុមការងារ នៃអាជ្ញាធរជាតិអប្សរាបានរៀបចំដំឡើងបង្កាន់ដៃជណ្តើរនេះរួចរាល់ហើយ។ មគ្គទេសក៍រូបនេះនិយាយថា កាលពីមុនជណ្តើរទាំងនោះ ពិបាកឡើងចុះ ហើយនៅកន្លែងខ្លះដែលងងឹតបន្តិចផងនោះ តែងធ្វើឱ្យភ្ញៀវទេសចរមួយចំនួនដែលមានវ័យចាស់ៗ ពិតជាពិបាកឡើងចុះ ប៉ុន្តែពេលនេះវាពិតមានភាពងាយស្រួលជាងកាលពីមុនឆ្ងាយណាស់។ លោក យ៉ែម រ៉ូហ្សា គិតថា នេះជាគំនិតល្អ ដែលអាជ្ញាធរជាតិអប្សរាបានគិតគូរដល់សុវត្ថិភាពរបស់ភ្ញៀវទេសចរជាចម្បង ពីព្រោះតែប្រាសាទខ្ពស់ៗ ជណ្តើរក៏ច្រើនហើយកន្លែងខ្លះក៏ងងឹតថែមទៀតនោះ៕



រូបភាពប្រចាំសប្តាហ៍៖ ចម្លាក់នានាក្នុងស្រះកណ្តាល នៃប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៤











រូបភាពប្រចាំសប្តាហ៍៖ ចម្លាក់ក្រុឌនៅតាមកំពែងប្រាសាទព្រះខ័ន សត្វក្រុឌត្រូវបានគេជឿថា ជានិមិត្តរូបនៃភាពអង់អាចក្លាហាន

ផ្សាយនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤







អ្នកភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ចាប់ត្រីត្រៀមឡើងមាយតាមទំនៀមបុរាណមិនដែលខកខាន

ផ្សាយនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤

រមណីយដ្ឋានអង្គរ ប្រមូលផ្តុំទៅដោយបេតិកភណ្ឌរស់ដែលសម្បូរទាំងមរតកអរូបី និងរូបីជាច្រើន ហើយត្រូវបានអ្នកស្រុកអង្គរបន្តប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនរហូតមកដល់បច្ចុប្បន្ន។ ជាក់ស្តែងជារៀងរាល់ឆ្នាំ ក្រោយពេលប្រមូលផលស្រូវរួចរាល់ ឱ្យតែមកដល់ខែមាយ ប្រជាពលរដ្ឋរស់នៅក្នុងភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប តែងតែនាំគ្នាប្រារព្ធពិធីចាប់ត្រីរួមមិនដែលខកខានជាលក្ខណៈសហគមន៍ គឺសម្រាប់តែសមាជិកក្នុងភូមិបង្កោងតែប៉ុណ្ណោះ ដើម្បីត្រៀមរៀបចំពិធីឡើងមាយ ឬឡើងអ្នកតានៅថ្ងៃបន្ទាប់ តាមទំនៀមទម្លាប់ពីបុរាណមក។





ការចាប់ត្រីរួមគ្នាធ្វើឡើងនៅត្រពាំងធំមួយដែលជាត្រពាំងបុរាណ មានទឹកខ្ជូបប្រាំងខ្ជូបវស្សា អ្នកភូមិបានអភិរក្សទុកការពារមិនអនុញ្ញាតឱ្យនរណាម្នាក់ចូលមកនេសាទផ្តេសផ្តាស់ខុសពីខែមាឃនេះឡើយ លុះត្រាតែមានការសម្រេចគ្នាពីគណៈកម្មការរៀបចំបុណ្យជាមុន ហើយកំណត់ថ្ងៃនេសាទរួម ទើបអ្នកភូមិអាចទៅរកចាប់បាន។ ប៉ុន្តែត្រូវតែប្រើឧបករណ៍នេសាទបុរាណ រួមមានសំណាញ់ អង្រែត ឈ្នាង ជាដើម។

លោក ពេជ្រ យិន មេភូមិបង្កោងមានប្រសាសន៍ថា ត្រីដែលចាប់បាននោះ មួយផ្នែកទុករួមសម្រាប់ធ្វើម្ហូបជាលក្ខណៈគ្រួសាររៀងៗខ្លួន មួយផ្នែកទៀតទុកសម្រាប់ធ្វើទឹកនំបញ្ចុក ម្ហូបអាហារ និងចង្ហាន់ជាដើម សម្រាប់ប្រគេនព្រះសង្ឃ នៅថ្ងៃធ្វើកិច្ចពិធីឡើងមាឃ ឬបុណ្យឡើងអ្នកតានៅសាលាឆាន់ក្នុងភូមិតាមទំនៀមបុរាណមិនដែលខកខាន។





សកម្មភាពថែទាំ ដកស្មៅ និងកូនឈើ នៅប្រាសាទព្រះខ័ន ប្រាសាទបន្ទាយប្រី និងប្រាសាទប្រី

ផ្សាយនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារផ្នែកសម្អាតរុក្ខជាតិលើប្រាសាទ បានចុះធ្វើសកម្មភាព ដកស្មៅនឹងកាត់កូនឈើតូចៗ នៅត្រង់ចំណុចតួប៉មកណ្តាលតម្កល់ចេតិយនៃប្រាសាទព្រះខ័ន។

សកម្មភាពដកស្មៅ និងរុក្ខជាតិតូចធំជាច្រើន តែងតែដុះនៅលើប្រាសាទ មិនថារដូវប្រាំងឬវស្សាទាំងនេះ ក្នុងន័យធ្វើយ៉ាងណា ថែរក្សាសោភ័ណភាព ការពារកុំឱ្យស្មៅដុះព្រោះរុក្ខជាតិទាំងនោះ បានបំផ្លាញភាពស្រស់ស្អាតនៃប្រាសាទ៕







ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារឆ្មាក់ចារទេសចរណ៍ ប្រចាំតោលដៅប្រាសាទអង្គរវត្តបានប្រទះឃើញទូរស័ព្ទ ម៉ាក IPhone ១៤ pro max ពណ៌ខ្មៅមួយគ្រឿង ដែលភ្ញៀវទេសចរបានភ្លេចនៅចំណុចកៅអីឈើក្រកខាងកើតនៃប្រាសាទអង្គរវត្ត

នៅថ្ងៃដដែល ក្រុមការងារឆ្មាក់ចារទេសចរណ៍បានប្រគល់ជូនម្ចាស់ដើមវិញ ក្រោយពីពិនិត្យឃើញថា ពិតជាម្ចាស់ពិតប្រាកដមែន

ផ្សាយនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤









មូលនិធិប្រាសាទពិភពលោកកំពុងបន្តគម្រោងជួសជុលជណ្តើរ និងជញ្ជាំងផ្នែកខាងត្បូង របស់ប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤



មូលនិធិប្រាសាទពិភពលោក(World Monument Fund) របស់សហរដ្ឋអាមេរិកក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា កំពុងបន្តជួសជុលជណ្តើរ និងជញ្ជាំងផ្នែកខាងត្បូងរបស់ប្រាសាទភ្នំបាខែងបន្ថែមទៀត បន្ទាប់ពីបានបញ្ចប់ការជួសជុលរចនាសម្ព័ន្ធជណ្តើរ និងជញ្ជាំងផ្នែកខាងកើត និងខាងជើងរួចរាល់មក។

ស្ថាបត្យករ និងជាអ្នកសម្របសម្រួលគម្រោងរបស់មូលនិធិប្រាសាទពិភពលោក អ្នកស្រី ជាម ផល្លី មានប្រសាសន៍ថា ការជួសជុលរចនាសម្ព័ន្ធជណ្តើរ និងជញ្ជាំងផ្នែកខាងត្បូងរបស់ប្រាសាទភ្នំបាខែងនេះ សម្រេចបានចំនួន៥០%ហើយ ដែលគ្រោងនឹងបញ្ចប់នៅខែធ្នូ ឆ្នាំ២០២៧ខាងមុខ។











អ្នកស្រី ផល្លី ឱ្យដឹងទៀតថា ប្រាសាទភ្នំបាខែង មិនខុសពីប្រាសាទដទៃទៀតទេ គឺរងការខូចខាតដោយសារកត្តាអាយុកាល ឫសឈើដុះចាក់ អាកាសធាតុ និងទឹកហូរច្រោះបណ្តាលឱ្យរចនាសម្ព័ន្ធប្រាសាទខូចខាត ទ្រេត និងរលំ។ ជណ្តើរខាងត្បូង និងជញ្ជាំងរួតផ្នែកខាងលិចនៅផ្នែកពាក់កណ្តាលពីរ៉ាមីតនៃប្រាសាទភ្នំបាខែង ក៏កំពុងតែក្រៀកថ្ម រលោះ និងហែកទាំងក្បាលជណ្តើរ កាំជណ្តើរ និងជញ្ជាំង។

ក្រុមបច្ចេកទេស កំពុងតែរុះរើជណ្តើរ រួចបុកបង្ហាប់ បន្ថែមគ្រឹះថ្មី ដើម្បីរៀបចំជួសជុលវាឡើងវិញ ចំណែកឯជញ្ជាំងត្រូវពង្រឹងឱ្យរឹងមាំឱ្យស្របតាមធម្មនុញ្ញអង្គរ ដែលបានកំណត់ដោយគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ។

ប្រាសាទភ្នំបាខែងកសាងឡើងពីការកាត់ថ្មភ្នំធម្មជាតិ ធ្វើឱ្យទៅរាងពីរ៉ាមីត ដោយបន្ថែមថ្មបាយក្រៀម ថ្មភក់ ដី និងរូបចម្លាក់ផ្សេងៗ ដើម្បីកសាងជាប្រាសាទភ្នំ។ ប្រាសាទនេះស្ថិតនៅចំកណ្តាលទីក្រុងយសោធរបុរៈ នាឆ្នាំ៩០៧ នៃគ្រឹស្តសករាជ ក្នុងរាជកាលព្រះបាទយសោវរ្ម័នទី១ នៅចន្លោះប្រាសាទបាយ័ន និងប្រាសាទអង្គរវត្ត៕



បុណ្យចូលឆ្នាំចិន-វៀតណាម ភ្ញៀវទេសចរជិត១៤ម៉ឺននាក់ ដើរកម្សាន្តរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤



នាឱកាសបុណ្យចូលឆ្នាំចិន-វៀតណាមរយៈពេល៣ថ្ងៃ ពីថ្ងៃទី៩ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៤ ភ្ញៀវទេសចរជាតិ-អន្តរជាតិមកទស្សនារមណីយដ្ឋានអង្គរសរុបមានចំនួន ១៣៧,៦៩០នាក់។



តាមរបាយការណ៍សកម្មភាព និងចំនួនទេសចរដើរកម្សាន្ត តាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ នៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌បានបង្ហាញថា នៅថ្ងៃទី៩ ទេសចរជាតិ-អន្តរជាតិដើរកម្សាន្តតាមប្រាសាទសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ មានចំនួន ២៨,៩១៥នាក់ ចំណែកថ្ងៃទី១០ មានចំនួន៤៦,៣៧១នាក់ និងថ្ងៃទី១១ មានចំនួន ៦២,៤០៤នាក់។ ក្នុងនោះ ប្រាសាទអង្គរវត្ត បាយ័ន តាព្រហ្ម និងបន្ទាយស្រីដែលមានទេសចរទៅកម្សាន្តច្រើនជាងគេ៕





បុណ្យដាក់ដំណាក់ទឹកស្រក

ផ្សាយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤

នៅកំពង់ភ្លុក មានធ្វើបុណ្យដាក់ដំណាក់ពីរដងក្នុងមួយឆ្នាំ ពោលគឺ«បុណ្យដាក់ដំណាក់ទឹកស្រក»ធ្វើពេលខែទឹកទន្លេស្រក និង«បុណ្យដាក់ដំណាក់ទឹកឡើង»ធ្វើនៅខែទន្លេទឹកឡើង។

គេអាចធ្វើនៅខែខ្នើត ឬខែរនោចក៏បាន ឱ្យតែថ្ងៃឡើងរោង ប៉ះចំថ្ងៃសុក្រ និងបញ្ចូននៅថ្ងៃសៅរ៍។ កាលបើរើសថ្ងៃសម្រាប់ពិធីដាក់ដំណាក់ខែមាឃ(ដាក់ដំណាក់ខែទឹកស្រក)ត្រូវនឹងខែកុម្ភៈបានហើយ គេនឹងរើសយកថ្ងៃឆាន់ភូមិនៅថ្ងៃនោះតែម្តង ដោយមានរយៈពេលពីរថ្ងៃ។ អ្នកស្រុក ក៏បានបញ្ចូលបុណ្យឡើងមាឃ នៅក្នុងថ្ងៃនេះដែរ ប៉ុន្តែ រយៈពេល ៣ឆ្នាំ ទើបគេរៀបចំពិធីនេះម្តង។

បុណ្យដាក់ដំណាក់ដែលធ្វើក្នុងពេលខាងលើនេះ ពាក់ព័ន្ធនឹងកម្ពស់ទឹកទន្លេសាប បរិស្ថានធម្មជាតិ ទិន្នផលត្រី និងការបញ្ចៀសជំងឺរាតត្បាតក្នុងភូមិ។ ពោល គឺនៅខែបុស្ស-មាឃជាពេលកំពុងពេញរកត្រី ខែចេត្រ ជាពេលទឹកទន្លេស្រកខ្លាំង។ ពិធីនេះ ដើរស្របនឹងវដ្តជីវិតត្រីផង និងវដ្តនៃការនេសាទផង។ ក្នុងឆ្នាំនេះ អ្នកភូមិដីក្រហម ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង នឹងរៀបចំធ្វើពិធីបុណ្យដាក់ដំណាក់ទឹកស្រក នៅរសៀលថ្ងៃទី១៥ នឹងឆ្លងនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤៕







អ្នកភូមិក្នុងតំបន់អង្គរប្រារព្ធពិធីឡើងមាយនាថ្ងៃពាកើតដែលជាទំនៀមពីបុរាណ

ផ្សាយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤

រាល់ថ្ងៃពាកើត ខែមាយ អ្នកភូមិរស់នៅតំបន់រមណីយដ្ឋានអង្គរ តែងប្រារព្ធពិធីឡើងមាយ ឬឡើងអ្នកតា ដែលជាទំនៀមពីបុរាណកាលមក។

ពិធីឡើងមាយឬឡើងអ្នកតានៅឆ្នាំនេះ ធ្វើឡើងនៅថ្ងៃចន្ទ ពាកើត ខែមាយ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ដែលត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៤។ អ្នកភូមិរស់នៅក្នុងតំបន់អង្គរ ដូចជាភូមិបង្កោង ឃុំអំពិល, ភូមិសំរោង ឃុំលាងដៃ, ភូមិក្រវ៉ាន់ សង្កាត់នគរធំ, ភូមិក្រសាំងរំលើង សង្កាត់សៀមរាប។ល។ នៅតែបន្តប្រារព្ធពិធីដែលជាទំនៀមពីបុរាណមិនដាច់។





ពិធីឡើងមាឃឬពិធីឡើងអ្នកតាតែងធ្វើឡើងនៅក្រោយពេលបញ្ចប់រដូវច្រូតកាត់ និងត្រៀមរដូវកាលធ្វើស្រែចម្ការក្នុងឆ្នាំថ្មី ក្នុងនោះក៏ដើម្បីសុំសេចក្តីសុខចម្រើនដល់ភូមិឋានទាំងមូល ធ្វើស្រែចម្ការទទួលបានភោគផលច្រើន និងចៀសផុតពីជំងឺចង្រៃផ្សេងៗ។ អ្នកភូមិដែលចូលរួមក្នុងពិធីនេះ បាននាំយកម្ហូបអាហារ បាយសម្ល កេសជ្ជៈ ផ្លែឈើជាដើម ដើម្បីធ្វើពិធីសែន និងថ្វាយនៅតាមរោងអ្នកតា ឬរូបសំណាកដែលអ្នកភូមិគោរព។ អ្វីដែលមិនអាចខ្វះបាននោះ គឺនំបញ្ចុក។ ក្រៅពីនោះក៏មានស្លាធម៌ បាយសី មានគ្រឿងសំណែន ទៀន ធូប បារី ខោ អាវផងដែរ។





នៅតំបន់ខ្លះដូចជាគោកតារាជមានរៀបចំភ្លេងបុរាណថ្វាយ និងរៀបចំរៀងអធិកអធម តែតំបន់ខ្លះទៀត ដូចជាភូមិសំរោង អ្នកភូមិរៀបចំតូចតាច មានអាហារដាក់ក្នុងថាសតូចៗ សែនថ្វាយមុខខ្នមអ្នកតា ដោយពុំមានភ្លេងប្រគំកំដរអ្វីឡើយ៕





ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ (TSC) ជួសជុលជណ្តើរឈើនៅរួតទី២ នៃជណ្តើរជ្រុងខាងត្បូង និងជ្រុងខាងជើងរបស់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤



ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ (TSC) របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានបន្តជួសជុលជណ្តើរឈើនៅរួតទី២ នៃជណ្តើរជ្រុងខាងត្បូង និងជ្រុងខាងជើងរបស់ប្រាសាទអង្គរវត្ត ដែលមានប្រវែងទទឹង២.៧០ម៉ែត្រ និងមានកម្ពស់១១ម៉ែត្រ។

ការងារជួសជុលជណ្តើរឈើនៅរួតទី២របស់ប្រាសាទអង្គរនេះ លោក ប៊ូ ផានេត ប្រធានក្រុមការងារជួសជុលជណ្តើរឈើនៅប្រាសាទអង្គរវត្ត (TSC) បានឱ្យដឹងថា ក្រុមការងារបានផ្លាស់ប្តូរឈើថ្មី ដូចជាកូនគីង្គក់ដែលទ្រកាំជណ្តើរមួយចំនួនដែលបានពុកផុយ និងពង្រឹងគ្រប់កាំទាំងអស់នៃជណ្តើរឱ្យរឹងមាំឡើងវិញ។

លោក ប៊ូ ផានេត បញ្ជាក់ថា គោលបំណងសំខាន់នៃការជួសជុលពង្រឹងជណ្តើរឈើនេះ ក៏នឹងធ្វើឱ្យជណ្តើរមានភាពរឹងមាំ ផ្តល់នូវសុខសុវត្ថិភាពរបស់ភ្ញៀវទេសចរដែលដើរឡើងចុះទៅទស្សនានៅរួតបាកាណ ដោយហេតុថាទីតាំងនេះមានចំណោទខ្ពស់ផង និងដើម្បីអាចឈានទៅដល់ការដំឡើងបង្ការន់ដៃនាពេលខាងមុខផង។







ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិឡើងទស្សនារួតបាកាណនៃប្រាសាទអង្គរវត្ត នារសៀលថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤











អាជ្ញាធរជាតិអប្សរា និងរដ្ឋបាលព្រៃឈើ សហការគ្នារៀបចំកែលម្អស្ថានីយបណ្តុះកូនឈើស្ថានអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៤





តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិង **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានណែនាំឱ្យអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលព្រៃឈើ សហការគ្នាកែលម្អ និងរៀបចំប្រែក្លាយស្ថានីយបណ្តុះកូនឈើស្ថានអង្គរឱ្យទៅជាស្ថានីយបណ្តុះកូនឈើដ៏ធំមួយនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីអភិរក្ស និងបង្កើនពូជរុក្ខជាតិកម្រ ដែលកំពុងប្រឈមនឹងការបាត់បង់ ក្នុងគោលបំណងចែកជូនក្រសួង/ស្ថាប័ន និងសាធារណជនយកទៅដាំនៅសៀមរាប-អង្គរ និងតាមបណ្តាខេត្តផ្សេងៗទៀតទូទាំងប្រទេសដោយឥតបង់ថ្លៃ។

គម្រោងសហការនេះសំដៅលើការរៀបចំប្តង់និងផែនការមេការលើកកម្ពស់ទេសភាពវប្បធម៌ដោយរុះរើសំណង់មិនរៀបរយចេញ រៀបចំថ្នាលបណ្តុះកូនឈើ ជួសជុលរហាត់ទឹកឱ្យដំណើរការឡើងវិញ កែលម្អសោភ័ណភាពអនាម័យ បរិស្ថាន និងសម្បទាចាំបាច់សម្រាប់គាំទ្រដល់ការដាក់ឱ្យដំណើរការស្ថានីយនេះទាំងមូលនាពេលឆាប់ៗខាងមុខនេះផងដែរ។



ក្រុមកម្មករជួសជុលប្រាសាទបុរាណ បានបង្ហាញនូវទឹកចិត្តរីករាយ បន្ទាប់ពីបានបញ្ចប់ការជួសជុលប្រាង្គកណ្តាលនៃប្រាសាទតាព្រហ្មកិលរួចរាល់

ផ្សាយនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤

ប្រាសាទតាព្រហ្មកិល ដែលជាអតីតមន្ទីរពេទ្យបុរាណសម័យអង្គរធ្លាប់តែរងការខូចខាតធ្ងន់ធ្ងរដោយរូមកហើយ។ ប៉ុន្តែពេលនេះ បានវិលត្រឡប់មករកស្ថានភាពរឹងមាំ និងមានរូបរាងស្ទើរតែពេញលេញដូចកាលពីសម័យដើមឡើងវិញហើយ។ ក្រុមកម្មករជួសជុលប្រាសាទបុរាណ បានបង្ហាញនូវទឹកចិត្តរីករាយបន្ទាប់ពីបានបញ្ចប់ការជួសជុលប្រាង្គកណ្តាលដែលជាហោរបន់ស្រន់របស់ប្រាសាទនេះរួចមក។

រស់នៅភូមិតាត្រៃ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ដែលបម្រើការងារជាកម្មករជួសជុលនៅប្រាសាទតាព្រហ្មកិល លោកតា សេង ស៊ន់ អាយុ៦៩ឆ្នាំ ឱ្យដឹងថា ស្ថានភាពប្រាសាទតាព្រហ្មកិលកាលពីមុនពេលជួសជុល មានការធ្លាក់រលុះឬ ប្រាសាទមិនមានលំនឹងព្រមទាំងមានសភាពទ្រុឌទ្រោមខ្លាំង ដោយមានការទល់ទ្រស្ទើរតែគ្រប់កន្លែង។

លោកតា សេង ស៊ន់ បានចូលរួមជួសជុលប្រាសាទតាព្រហ្មកិលនេះ ដោយមានតួនាទីជាអ្នកជាប់ឆ្លាក់ទាំងថ្មកក់ និងថ្មបាយក្រៀមបានបង្ហាញក្តីរំភើបថា រូបលោកមិនខ្វិលឡើយចំពោះការងារជួសជុលប្រាសាទ។ លោកចូលចិត្ត ដោយមិននឿយហត់ ហើយមួយថ្ងៃៗចង់តែមក ចង់តែឃើញ និងនៅតែចង់ធ្វើការងារជួសជុលប្រាសាទបុរាណ។ ប្រសិនបើលោកនៅតែមានសុខភាពល្អ គឺលោកនឹងនៅតែមកចូលរួមធ្វើការងារជួសជុលប្រាសាទបុរាណបន្តទៀត។

អ្នកភូមិវាល ឃុំគោកចក ក្រុងសៀមរាបលោកតា ឡែ ឡន អាយុ៦០ឆ្នាំ ជាអ្នកជាប់ឆ្លាក់ថ្មនៅការដ្ឋានជួសជុលប្រាសាទតាព្រហ្មកិលម្នាក់ទៀត មានប្រសាសន៍ថា លោកពិតជាសប្បាយចិត្តដែលបានចូលរួមជួសជុលប្រាសាទបុរាណរបស់ដូនតាខ្មែរ។ លោកយល់ថា ការជួសជុលឡើងវិញនេះ នឹងធ្វើឱ្យប្រាសាទរបស់ដូនតាខ្មែរមានសភាពរឹងមាំបន្តទៀត ដើម្បីបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយបានឃើញ និងស្គាល់យូរអង្វែង។ ថ្វីត្បិតតែការងារជួសជុលអភិរក្ស និងថែរក្សាប្រាសាទបុរាណ ឱ្យបានរឹងមាំគង់នៅយូរអង្វែងបន្តទៅទៀត គឺជាតួនាទីនិងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ក៏ប៉ុន្តែនៅក្នុងនោះ ក៏ត្រូវការប្រជាពលរដ្ឋជាច្រើនបានចូលរួមនៅក្នុងការងារជាច្រើនផ្នែកដែរ។

លោក សេង ស៊ន់ និងលោក ឡែ ឡន សំណូមពរដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ ទាំងឡាយសូមជួយចូលរួមថែរក្សា អភិរក្សប្រាសាទបុរាណរបស់ដូនតាខ្មែរ តាមគ្រប់រូបភាព ចៀសវាងការប្រើសកម្មភាពណាមួយមិនសមរម្យចំពោះប្រាង្គប្រាសាទ នាំឱ្យខូចខាតដល់ថ្មប្រាសាទ និងធ្វើឱ្យបាត់បង់តម្លៃរបស់សម្បត្តិបេតិកភណ្ឌដែលមិនអាចកាត់ថ្លៃបាននេះ៕



ក្រុមការងារប្រចាំនៅគោលដៅក្រុងអង្គរធំ និងបារាយណ៍ទឹកថ្លា ប្រគល់ជូនម៉ាស៊ីនថតមួយគ្រឿង ដល់ភ្ញៀវដែលបានភ្លេច

ផ្សាយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង០៩ និង៤៥ នាទីព្រឹក ក្រុមការងារសណ្តាប់ធ្នាប់ បានចូលរួមជាមួយ នគរបាលសទេសចរណ៍ នគរបាលបេតិកភណ្ឌ នៃប៉ុស្តិ៍ការពារទី១០ និងភ្នាក់ងារទេសចរ ប្រគល់ជូនម៉ាស៊ីនថតមួយគ្រឿង ដល់ភ្ញៀវទេសចរជនជាតិចិនម្នាក់ អាយុ៥៥ឆ្នាំ ដែលបានភ្លេច នៅខាងលិចធៀងខាងត្បូងនៃប្រាសាទបាយ័ន។







អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យការដ្ឋានការងារមួយចំនួនក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៤







នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារ ចុះពិនិត្យការដ្ឋានការងារមួយចំនួននៅតំបន់រមណីយដ្ឋានអង្គរ។ ការងារនេះធ្វើឡើងដើម្បីពិនិត្យតាមដានការងារ ក៏ដូចជាផ្តល់អនុសាសន៍ក្នុងការអនុវត្តជាបន្តបន្ទាប់ទៀត៕





ភ្នាក់ងារទេសចរ នៃអាជ្ញាធរជាតិអប្សរា មានតួនាទីសំខាន់ក្នុងការសង្គ្រោះភ្ញៀវទេសចរ កំឡុងទស្សនាប្រាសាទ

ផ្សាយនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤





ព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ មានភ្ញៀវជនជាតិកាណាដា ភេទប្រុស អាយុ៦០ឆ្នាំ បានដើរដួលនៅជណ្តើរឡើង ទិសខាងលិចប្រាសាទបាយ័ន បណ្តាលឱ្យរងរបួសស្រាលនៅត្រង់ដៃ និងជង្គង់។ ភ្លាមៗនោះ ក្រុមការងារភ្នាក់ងារទេសចរនៃអាជ្ញាធរជតិអប្សរាគោលដៅអតីតរាជធានីក្រុងអង្គរធំ បានជួយសង្គ្រោះបឋមបានធូរស្បើយឡើងវិញ និងអាចបន្តការទស្សនាជាធម្មតា។

ករណីដូចគ្នានេះដែរ ក្រុមភ្នាក់ងារទេសចរប្រចាំគោលដៅប្រាសាទតាព្រហ្ម បានសង្គ្រោះបឋមដល់ភ្ញៀវទេសចរជនជាតិវៀតណាម ភេទប្រុស ដែលមិនប្រយ័ត្នបានប៉ះក្បាលនឹងស៊ុមទ្វារប្រាសាទ។ ក្រោយទទួលបានការសង្គ្រោះបឋមរួចហើយ គាត់អាចដើរទស្សនាប្រាសាទធម្មតាវិញ៕



អាជ្ញាធរជាតិអប្សរាធ្វើការជួសជុលខ្លោចទ្វារទី២ ចូលពីខាងកើតប្រាសាទប្រែរូប

ផ្សាយនៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤



ក្រុមអ្នកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា អាជ្ញាធរជាតិអប្សរាកំពុងធ្វើការជួសជុលពង្រឹងខ្លោងទ្វារទី២ ខាងកើតប្រាសាទប្រែរូប ដែលទ្រុឌទ្រោមខ្លាំង។

ការងារជួសជុលនេះ ក្រុមអ្នកបច្ចេកទេសបានអនុវត្តការងារសំខាន់ចំនួនពីរគឺជួសជុលពង្រឹងឡើងវិញតួប៉មឥដ្ឋដែលមានសភាពពុកផុយ ធ្វើការពង្រឹងរចនាសម្ព័ន្ធថ្មកក់និងថ្មបាយក្រៀមផ្នែកខាងក្រោម ព្រមទាំងបិទបាយអតាមស្នាមប្រេះ និងចន្លោះប្រហោងការពារជម្រាបទឹកផងដែរ។ នេះគឺជាផ្នែកមួយនៃកិច្ចការអភិរក្ស ដែលអាជ្ញាធរជាតិអប្សរាបានអនុវត្តជាប្រចាំ ក្នុងគោលគំនិតដើម្បីថែរក្សាលើកតម្លៃប្រាសាទផង និងដើម្បីរក្សាសុខសុវត្ថិភាពដល់ភ្ញៀវទេសចរផង។

សូមបញ្ជាក់ថា ប្រាសាទប្រែរូបត្រូវបានកសាងឡើងនាចុងសតវត្សរ៍ទី១០ក្នុងគ.ស.៩៦១ ដោយ ព្រះបាទរាជេន្ទ្រវរ្ម័នទី២ បច្ឆាមរណៈ ព្រះនាម "សិវលោក" ដើម្បីឧទ្ទិសថ្វាយចំពោះលទ្ធិព្រហ្មញ្ញសាសនា។







រូបភាពប្រចាំសប្តាហ៍ ៖ ប្រាសាទវត្តអធ្វា កសាងឡើងអំពីថ្មតក់បែរមុខទៅទិសខាងលិច ជូចប្រាសាទអង្គរវត្តដែរ ក្នុងរាជ្យព្រះបាទសូរ្យវរ្មន៍ទី២ នៅចុងសតវត្សរ៍ទី១២

ផ្សាយនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរា ដំឡើងបង្កាន់ដៃជណ្តើរឈើចំនួន២ទីតាំងបន្ថែមទៀត នៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៤

ក្រុមការងារត្រួតពិនិត្យសោភកម្មទេសចរណ៍របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានបន្តសកម្មភាពការងាររបស់ខ្លួនយ៉ាងមមាញឹកក្នុងការដំឡើងបង្កាន់ដៃជណ្តើរឈើចំនួន២ទីតាំងបន្ថែមទៀត របស់ប្រាសាទអង្គរវត្ត នៅត្រង់ចំណុចរួតទី២ ជណ្តើរទិសខាងត្បូង និងខាងជើងឡើង-ចុះរួតបាកាណ។

លោក ប៊ូ ផានេត ប្រធានក្រុមការងារជួសជុលជណ្តើរឈើនៅប្រាសាទអង្គរវត្ត បានឱ្យដឹងថា ការបន្តដំឡើងបង្កាន់ដៃទាំង២ទីតាំងនេះ គឺក្នុងគោលបំណង ជួយសម្រួលដល់ការឡើង-ចុះ របស់ភ្ញៀវទេសចរទៅកាន់រួតបាកាណ។

ពិសេសការពារកុំឱ្យរអិលនៅរដូវភ្លៀងធ្លាក់ ផ្តល់នូវសុខសុវត្ថិភាពភ្ញៀវទេសចរគ្រប់ៗរូប ការពារគ្រោះថ្នាក់ផ្សេងៗ ដូចជាពេលវិលមុខ អស់កម្លាំង ខ្យល់គរ ញ័ររបេះដូងជាដើម។ ព្រោះថានៅទីតាំងនេះមានសភាពចោទ និងមានកម្ពស់ខ្ពស់រហូតដល់ជាង១០ម៉ែត្រ។

លោក ប៊ូ ផានេត បន្តថា អាជ្ញាធរជាតិអប្សរា បន្តជួសជុលជណ្តើរឈើដែលរងការខូចខាត និងដំឡើងបង្កាន់ដៃនៅទីតាំងប្រឈមនិងហានិភ័យផ្សេងៗ ដើម្បីបង្ការគ្រោះថ្នាក់ដោយយថាហេតុ ដោយគិតគូរពីសុវត្ថិភាពរបស់ភ្ញៀវទេសចរ ហើយក៏កាត់បន្ថយការប៉ះផ្ទាល់ទៅលើថ្មប្រាសាទ៕







រូបភាពប្រចាំសប្តាហ៍៖ សម្រស់ភ្លឺមឥដ្ឋ នៃប្រាសាទបាគង ដែលអ្នកទស្សនាមិនគួរមើលរំលង

ផ្សាយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤







ប្រាសាទភ្នំក្រោម ស្ថិតនៅលើកំពូលភ្នំក្រោម មានចម្ងាយប្រហែល១២គីឡូម៉ែត្រ ខាងត្បូងក្រុងសៀមរាប និងខាងជើងបឹងទន្លេសាប

ផ្សាយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៤











អតីតអ្នកឃុសម្នាក់ រស់នៅតំបន់រមណីយដ្ឋានអង្គរ បង្រៀនយុវជនខ្មែរឱ្យចេះជំនាញចារសាស្ត្រាស្លឹករឹត

ផ្សាយនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤



នៅក្នុងតំបន់រមណីយដ្ឋានអង្គរ លោក ព្រាន ជ្រូក រស់នៅភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប បានយកទីតាំងផ្ទះរបស់គាត់ធ្វើជាកន្លែងបង្រៀនយុវជនខ្មែរជំនាន់ក្រោយ ឱ្យចេះជំនាញចារគម្ពីរសាស្ត្រាស្លឹករឹត ក្នុងបំណងរក្សាវប្បធម៌និងសិល្បៈមួយនេះឱ្យមានអ្នកបន្តវេនយូរអង្វែងតទៅទៀត។



លោក ព្រាន ជ្រូក អាយុ២៧ឆ្នាំ ឱ្យដឹងថា លោកបានចេះជំនាញចារសាស្ត្រាស្លឹករឹតក្នុងពេលដែលរូបលោកបានបួស និងរៀននៅវត្ត «នាមរូប» ក្នុងស្រុកពួក។ បច្ចុប្បន្ន លោកកំពុងប្រឹងប្រែងបង្ហាត់បង្រៀនចារសាស្ត្រាស្លឹករឹតដល់យុវជន យុវតី នៅក្នុងភូមិដោយឥតគិតថ្លៃ ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយ បានឃើញ និងស្គាល់ពីតម្លៃរបស់សាស្ត្រា ដែលបុព្វបុរសខ្មែរបានប្រើប្រាស់ ចារជាគម្ពីរប្រវត្តិសាស្ត្រ និងក្បួនច្បាប់ផ្សេងៗជាច្រើនជាយូរលង់មកហើយ។ ការខិតខំបង្រៀនជំនាញចារសាស្ត្រាស្លឹករឹតដល់យុវជនខ្មែរជំនាញក្រោយឱ្យមានចំណេះបន្ត ដោយសារតែបច្ចុប្បន្ន ជំនាញចារសាស្ត្រាស្លឹករឹតបានបាត់បង់ទៅៗ ស្ទើរតែទាំងស្រុងនៅក្នុងសង្គមខ្មែរសម័យថ្មី។

លោក ព្រាន ជ្រូក បញ្ជាក់ថា ជំនាញចារសាស្ត្រាស្លឹករឹត គឺត្រូវមានចិត្តអត់ធ្មត់ ធ្វើអារម្មណ៍យើងឱ្យនឹង ស្រលាញ់និងផ្តោតការយកចិត្តទុកដាក់ខ្លាំង។ ដូច្នេះអ្នកដែលចង់សិក្សារៀនសូត្រ ពីជំនាញចារសាស្ត្រាស្លឹករឹតទាល់តែមានចិត្តស្រលាញ់ ចង់ចេះ ចង់ដឹងច្បាស់លាស់ទើបអាចធ្វើបាន។ បច្ចុប្បន្ននេះមានយុវតីនិងយុវជនចំនួន៥ ទៅ៦នាក់ប៉ុណ្ណោះ ដែលចាប់អារម្មណ៍និងជំនាញចារសាស្ត្រាស្លឹករឹតនេះនៅក្នុងចំណោមយុវជនជាច្រើន។ នៅក្នុងភូមិត្នោតជ្រុំ ក៏មានអ្នកចេះចារសាស្ត្រាស្លឹករឹត២ទៅ៣នាក់ដែរ ហើយសុទ្ធតែអ្នកធ្លាប់បួសរៀននៅវត្តដូចគ្នា៕



ស្រះស្រង់ទឹកឆ្លុះទស្សនាថ្ងៃរះ និងថ្ងៃលិចដ៏ស្រស់ស្អាត

ផ្សាយនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤









ពិធីលៀងមេមត់នៅភូមិស្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក

ផ្សាយនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤

លៀងមេមត់ ជាជំនឿដែលខ្មែរគោរពតាំងពីយូរមកហើយ និងនៅតែបន្តប្រតិបត្តិរហូតដល់សព្វថ្ងៃ ជាពិសេស អ្នករស់នៅក្នុងតំបន់អង្គរ។ ការគោរពអមនុស្សមានដូចជា ព្រលឹងដូនតា អារក្ស អ្នកតាម្ចាស់ទឹក ម្ចាស់ដីជាដើម គឺជាការដឹងគុណ ដែលអមនុស្សអាចជួយឱ្យពួកគាត់បានសេចក្តីសុខចម្រើន និងរួចផុតពីជំងឺនានា។

លោកតា ឱន ហាន ដែលជាអ្នកស្នងរូប បានរៀបចំពិធីលៀងមេមត់នៅផ្ទះរបស់គាត់ស្ថិតនៅភូមិស្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក មានប្រសាសន៍ថា ពិធីលៀងមេមត់ ធ្វើឡើងដើម្បីលាបំណន់ និងលាមាត់ដែលបានបន់ស្រន់ ក្រោយពីអ្នកជំងឺបានជាសះស្បើយ និងដើម្បីសុំសេចក្តីសុខ និងសេចក្តីចម្រើនឱ្យព្រលឹងដូនតាដែលជាគ្រូកំណើតឱ្យបានសប្បាយផង និងឱ្យអ្នកស្នងរូបបានជាពីជំងឺផ្សេងៗព្រមទាំងការបង្ហាញនូវការនឹកគុណដល់ខ្មោចជីដូនជីតា ដែលបានថែរក្សាក្រុមគ្រួសារឱ្យសុខសប្បាយកន្លងមក។

លោកតា ឱន ហាន ឱ្យដឹងទៀតថា បន្ទាប់ពីបន់ស្រន់រួចហើយ បើសិនអ្នកជំងឺបានជាសះស្បើយហើយ យើងត្រូវរៀបចំពិធីលៀងមេមត់ទៅតាមថ្ងៃខែដែលបានសន្យាជាមួយគ្រូ។ តាមជំនឿ គេធ្វើពិធីលៀងមេមត់ឱ្យចំថ្ងៃព្រហស្បតិ៍ចំថ្ងៃពេញបូណ៌មីខែមាឃ។លោកតាបន្តទៀតថា មុនដល់ពិធីលៀងមេមត់នេះ យើងត្រូវធ្វើពិធីឡើងអ្នកតានៅថ្ងៃ៣កើត ខែមាឃ ហើយបន្ទាប់ពីពិធីឡើងអ្នកតា គឺមានកិច្ចពិធីសំពះគ្រូ ដោយធ្វើឱ្យចំខែពេញបូណ៌មី។ ផុតពីនោះ បើគ្រូណាចង់លៀង គឺស្រេចតែគ្រូ តែគ្រូនេះ ២ទៅ៣ឆ្នាំទើបធ្វើម្តង មិនកំណត់ថា ធ្វើជារៀងរាល់ឆ្នាំទេ គឺអាស្រ័យលើការសន្យាជាមួយគ្រូ និងរយៈពេលប៉ុន្មានឆ្នាំត្រូវលៀងមេមត់ជូនគ្រូ។ ពិធីលៀងមេមត់នេះ ត្រូវលេងភ្លេងមេមត់ ទើបអាចបញ្ចូលរូបបាន។









រីឯគ្រឿងរណ្តាប់ សំណែនក្នុងពិធីលៀងមេមត់ មានដូចជា គ្រូកំណើត កន្លងគ្រូកំណើត ពែបាយព្រាយ សំណែនគ្រូកំណើត គ្រែព្រះធម៌ បាយសី ជម ពិតាន តោក ជមព្រះភូមិ ក្បាលជ្រូក ម្ជូ ស្លា បារី ធូប ទៀន សម្លបាយ នំអន្សម ចេកណាំវ៉ា ផ្លែឈើគ្រប់មុខ។ គ្រឿងរណ្តាប់ទាំងអស់នេះ ត្រូវបានរៀបចំដោយអ្នកត្រូវស្នងរូបនីមួយៗផ្សេងគ្នាទៅតាម គ្រូបាអាចារ្យកាន់រៀងខ្លួនៗ មានចំនួនច្រើនមិនក្រោម១០រូប នោះឡើយ មានប្រុសស្រី ចាស់ ក្មេង និងរៀបចំនៅក្នុង

រោងមួយយ៉ាងសមរម្យសម្រាប់ធ្វើកិច្ចពិធី ហើយមានក្រុម វង់ភ្លេងអារក្សផង។ ក្នុងកម្មវិធីនេះដែរ ឃើញមានអ្នកភូមិ ផង បានយកអង្ករ និងបច្ច័យមកចូលរួមតាមសទ្ធាផង។

តាមការសង្កេត ពិធីលៀងមេមត់ គឺពិតជាសំខាន់ខ្លាំងណាស់ សម្រាប់មនុស្សខ្មែរតំបន់អង្គរ ព្រោះជាផ្នែកមួយនៃការរស់នៅ របស់ពួកគាត់ទាក់ទងនឹងជំនឿ ដែលផ្តាច់មិនបាន។ បន្ថែមពីនេះ វាក៏បង្ហាញពីការដឹងគុណចំពោះបុព្វបុរសជា គ្រូបាអាចារ្យ ជាឪពុកម្តាយដែលបានចែកឋានទៅហើយ ផង។ ការជឿជាក់ និងការឃើញរឿង ហេតុការណ៍នៅក្នុង ពិធីជាអ្វីដែលធ្វើឱ្យអ្នកស្រុកអង្គរយល់ថា វត្ថុស័ក្តិសិទ្ធិ និង បារមីនៅតែមានជីវិតរស់នៅលើដែនដីអង្គរមិនសាបសូន្យ ទៅណា។ ការគោរពប្រតិបត្តិទាំងនេះ ជាការរួមចំណែក មួយក្នុងការថែរក្សាមរតក ជំនឿឱ្យនៅតែមានជីវិតគ្រប់ ជំនាន់របស់ជាតិខ្មែរ។



នៅថ្ងៃទី ១៩ ខែកុម្ភ: ឆ្នាំ២០២៤ វេលាម៉ោង១រសៀល ស្ត្រីជាភ្ញៀវទេសចរជនជាតិអឺរ៉ុបម្ហាក់ បានរើសកាបូបស្ពាយចង្ពេះពណ៌ខ្មៅតូចមួយ ស្ថិតនៅក្នុងប្រាសាទប្រាសាទតាព្រហ្ម និងបានយកមកជូនក្រុមការងារគ្រឹះស្ថានអង្គរ ដែលប្រចាំការនៅទីនោះ

ក្រោយសាកសួរព័ត៌មានជាក់លាក់រួចមក កាបូបនេះបានប្រគល់ជូនម្ចាស់ដើមវិញ ដែលជាទេសចរជនជាតិ អ៊ីតាលី

ផ្សាយនៅថ្ងៃទី១៩ ខែកុម្ភ: ឆ្នាំ២០២៤





ពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា លើវិស័យបេតិកភណ្ឌវប្បធម៌ រវាងរដ្ឋបាលបេតិកភណ្ឌវប្បធម៌ នៃសាធារណរដ្ឋកូរ៉េ និងអាជ្ញាធរជាតិអប្សរនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤

នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ នាទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងឯកឧត្តមបណ្ឌិត Choi Eung-Chon ប្រធានរដ្ឋបាលបេតិកភណ្ឌវប្បធម៌ បានចុះអនុស្សរណៈនៃការយោគយល់គ្នា លើវិស័យបេតិកភណ្ឌវប្បធម៌ រវាងរដ្ឋបាលបេតិកភណ្ឌវប្បធម៌ នៃសាធារណៈរដ្ឋកូរ៉េ និងអាជ្ញាធរជាតិអប្សរា នៃព្រះរាជាណាចក្រកម្ពុជា អនុស្សរណៈនេះផ្តោតសំខាន់ទៅលើកិច្ចការងារអភិរក្ស និងជួសជុល រួតបាកាណ នៃប្រាសាទអង្គរវត្ត ដែលមានរយៈពេល៣ឆ្នាំ។ ក្រៅពីការជួសជុលរួតបាកាណ នៃប្រាសាទអង្គរវត្ត ដែលមានសារៈសំខាន់ជាងគេ របស់ប្រទេសកម្ពុជាហើយនោះ កិច្ចសហប្រតិបត្តិការណ៍នេះ ក៏មានការបណ្តុះបណ្តាល និងការផ្លាស់ប្តូរនូវចំណេះដឹងទាក់ទងនិងបច្ចេកវិទ្យាថ្មីៗ ក្នុងការបង្ហាញទៅកាន់ភ្ញៀវជាតិ និងអន្តរជាតិផងដែរ៕







លៀងមេមត់

ផ្សាយនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤

លៀងមេមត់របស់អ្នកភូមិរស់នៅក្នុងតំបន់អង្គរ ដូចជា៖ ភូមិនគរក្រៅ, (សង្កាត់គោកចក), ភូមិអារក្សស្វាយ (សង្កាត់នគរធំ), ភូមិក្រសាំងរលើង, ភូមិទ្រៀក (សង្កាត់សៀមរាប) ភូមិភូមិថ្ម(ល់បាក់ (ឃុំអំពិល), ភូមិភ្លង់ (ឃុំលាងដៃ), ភូមិក្បាលដំរី (ឃុំរមាស) និងភូមិស្នាសង្គ្រាម (ស្រុកបន្ទាយស្រី)។ល។ គេចំណាំធ្វើនៅខែមាឃ ឬអាចធ្វើក្នុងបរិបទពិសេសណាមួយនៅពេលមានរូបមេមត់ ឬ «សម្បក» ឈឺធ្ងន់ដោយសារអមនុស្សធ្វើឱ្យរូបស្នងនោះឈឺ។ ហេតុនេះ ដើម្បីដោះស្រាយ និងជៀសវាងកុំឱ្យឈឺ ត្រូវលៀងមេមត់ក្នុងមួយឆ្នាំ ឬពីរឆ្នាំម្តង។ ជាទូទៅ ស្រុក ឬតំបន់ខ្លះ គេហៅថា «អារក្ស» ក៏ប៉ុន្តែនៅតំបន់អង្គរ គេនិយមហៅ «មេមត់» មិនសូវឮប្រើពាក្យអារក្សទេ។ ដូច្នេះហើយបានជាគេច្រើនហៅថា «ភ្លេងមេមត់ » «រូបមេមត់» និង «លៀងមេមត់»។

មេមត់ គឺជាខ្មោចជួរចំបួរប្រចាំត្រកូល ហើយមាន "រូបស្នង" ដែលភាគច្រើនជាមនុស្សស្រី។ «រូបស្នង» ដើរតួនាទីសំខាន់ក្នុងកិច្ចជាន់មេមត់រកមើលហេតុនៃវិបត្តិតូច ធំដែលកើតឡើងផ្ទាល់ខ្លួន, ក្នុងគ្រួសារ ឬតាមការពឹងពាក់ពីអ្នកស្រុកជិតឆ្ងាយឱ្យជួយព្យាបាល ដោយស្តោះផ្តុំ ឬពេលបាត់បង់វត្ថុអីមួយ។ល។ លុះបានផល ឬជាពីជម្ងឺដោយធ្វើតាមពាក្យខ្មោចប្រាប់ យើងត្រូវលៀងកំសាន្តឱ្យអមនុស្សជាការដឹងគុណដែលប្រាប់ពីហេតុផល និងខំមើលយើងជា។ ពិធីលៀងនេះ គេហៅ «លៀងមេមត់»។ ក្នុងពិធីលៀងមេមត់នេះភ្លេងគឺជាគ្រឿងរណ្តាប់មួយយ៉ាងសំខាន់ដែលមិនអាចខ្វះបាន ត្បិតត្រូវលេងឱ្យមេមត់រាំលេងសប្បាយ។

កិច្ចពិធីលៀងមេមត់ មានរបៀបពីរយ៉ាង៖ ទី១ កិច្ចពិធីលៀងជាលក្ខណៈឯកជន ដោយមានរៀបចំសំណែនជាមួយអាហារ ព្រមទាំងមានភ្លេងមេមត់ផង ដើម្បីជាការដឹងគុណដល់ខ្មោច ឬចំបួរ ដែលខំមើលជម្ងឺជា ឬរកវត្ថុអ្វីមួយដែលបានបាត់បង់ទៅហើយឃើញមកវិញ។ កិច្ចពិធីនេះ ច្រើនចាប់ធ្វើនៅពេលថ្ងៃត្រង់ ឬក៏រសៀល។ ចំណែកកិច្ចពិធីទី២ គឺលៀងមេមត់មានលក្ខណៈជាសហគមន៍ ដែលធ្វើរៀងរាល់ឆ្នាំ ឬអ្នកខ្លះ ភូមិខ្លះទាល់តែពីរ ឬបីឆ្នាំម្តង ទោះជាឈឺ ឬមិនឈឺអីក៏ដោយ គឺត្រូវតែធ្វើពិធីលៀងមេមត់។ ក្នុងពិធីលៀងនេះដែរ រូបស្នងក៏បញ្ជាន់មេមត់ដែលជាគ្រូកំណើត ឬចំបួររបស់ខ្លួនឡើងរាំតាមចង្វាក់ភ្លេង ហើយអ្នកខ្លះគេឆ្លៀតមករកមើលពីវិបត្តិតូច ធំផ្ទាល់ខ្លួន ឬគ្រួសារ ហើយជួនកាលមេមត់ហ្នឹងក៏ព្យាបាលអ្នកជម្ងឺ ដោយស្តោះព្រួសក្នុងពេលលៀងនោះទៀតផង។

នៅថ្ងៃព្រហស្បតិ៍ ១៣ កើត ខែមាឃ ត្រូវនឹងថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ និងនៅថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤នេះ នៅភូមិនគរក្រៅ នឹងមានរៀបចំពិធីលៀងមេមត់នៅផ្ទះយាយគង់ និងនៅផ្ទះយាយអុល៕



ក្រុមការងារសម្អាតបរិស្ថានអាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់ជាប្រចាំ

ផ្សាយនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤

ជារៀងរាល់ថ្ងៃក្រុមការងារសម្អាតបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា បានកាត់សម្អាតស្មៅ បោសសម្អាតធូលីដី នៅតាមប្រាសាទ ដោយពួកគាត់បានបែងចែកជាក្រុមៗ បំពេញការងារទាំងក្នុង និងក្រៅបរិវេណប្រាសាទគ្រប់ពេលវេលា ដែលការងារនេះរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យតំបន់ប្រាសាទមានសោភ័ណភាពស្រស់ស្អាត។ ក្រៅពីកិច្ចការអភិរក្សដែលអាជ្ញាធរជាតិអប្សរា បាននិងកំពុងធ្វើជាប្រចាំ ហើយកិច្ចការទាំងនេះមិនអាចខ្វះបានចូលរួមពីសាធារណជន ក៏ដូចជាភ្ញៀវទេសចរបានទេ។





យើងទាំងអស់គ្នា ចូលរួមលើកកម្ពស់បរិស្ថានក្នុងរមណីយដ្ឋានអង្គរ ដើម្បីភាពស្រស់ស្អាត និងតម្លៃបេតិកភណ្ឌពិភពលោក៕





អាជ្ញាធរជាតិអប្សរាធ្វើការជួសជុលខ្លោងទ្វារខាងកើត ប្រាសាទមេបុណ្យខាងកើត

ផ្សាយនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤





អ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា កំពុងធ្វើការជួសជុលពង្រឹងតួខ្លោងទ្វារខាងកើត ប្រាសាទមេបុណ្យខាងកើត ដែលមានសភាពទ្រុឌទ្រោមខ្លាំង ។

ការជួសជុលនេះ បានផ្តោតលើការងារសំខាន់ៗមួយចំនួន ដូចជា ធ្វើការពង្រឹងរចនាសម្ព័ន្ធថ្មភក់និងថ្មបាយក្រៀម ផ្នែកខាងក្រោម ជួសជុលពង្រឹងឡើងវិញរចនាសម្ព័ន្ធឥដ្ឋ ផ្នែកខាងលើដែលមានសភាពពុកផុយ បិទបាយអតាម ស្នាមប្រេះការពារជម្រាបទឹក ព្រមទាំងធ្វើការទល់ទ្រ ដើម្បីទប់លំនឹងតួខ្លោងទ្វារទាំងមូលផងដែរ។

នេះគឺជាផ្នែកមួយនៃកិច្ចការអភិរក្ស ដែលអាជ្ញាធរជាតិអប្សរាបានអនុវត្តជាប្រចាំ ក្នុងគោលគំនិតដើម្បីថែរក្សាលើកតម្លៃប្រាសាទផង និងដើម្បីរក្សាសុខសុវត្ថិភាពដល់ភ្ញៀវទេសចរផង។

សូមបញ្ជាក់ថា ប្រាសាទមេបុណ្យខាងកើតត្រូវបានកសាងឡើងនាពាក់កណ្តាលសតវត្សរ៍ទី១០ ក្នុងរាជព្រះបាទរាជេន្ទ្រវរ្មន៍ទី១ ដើម្បីឧទ្ទិសថ្វាយចំពោះព្រះឥសូរ ក្នុងព្រហ្មញ្ញសាសនា។



អាជ្ញាធរជាតិអប្សរា កំពុងធ្វើការបង់លេខថ្ម ដែលរាយប៉ាយនៅកំពែងខាងក្រៅ របស់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤





ក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងរៀបចំចុះលេខបញ្ជីថ្មចំនួន ១៦៥៦ដុំ ដែលកំពុងតែនៅរាយប៉ាយជាប់កំពែងខាងក្រៅ ផ្នែកខាងត្បូង និងខាងជើង នៃខ្លោងទ្វារខាងលិចរបស់ ប្រាសាទអង្គរវត្ត ដើម្បីឱ្យដឹងច្បាស់ពីទីតាំង និងប្រភព របស់វាថា ជាថ្មដំបូល? ឬក៏ជាថ្មតួប៉មណាមួយឱ្យប្រាកដ។

បុរាណវិទូ នៃអាជ្ញាធរជាតិអប្សរា លោក អន សុភាព ឱ្យ ដឹងថា តាមការសង្កេតឃើញថា ថ្មមួយចំនួនប្រហែលជា រចនាសម្ពន្ធរបស់តួប៉មទាំង៣ នៃខ្លោងទ្វារខាងលិចរបស់ ប្រាសាទអង្គរវត្ត។ មួយចំនួនអាចជាកំពូលខាងលើ ដោយសារ តែមានរាងរង្វង់មូលជាត្របកឈូក ក្រៅពីនោះ បំណែក មួយចំនួនទៀតអាចជា ដំបូលរបស់រោងទង ជាខឿនក្រោម ព្រមទាំងបំណែករូបចម្លាក់ ដូចជា គោ ប្រអប់ជើង និង ជើងទម្រជាដើម។ល។ជំនាន់បារាំងធ្លាប់បានយកមក រក្សាទុក ក្រុមការងារបានថតរូបដោយដ្រូនពីលើ ចាប់ផ្តើម បង់លេខសម្គាល់ទីតាំង និងជាឯកសារស្ថានភាពរបស់ថ្ម។

បុរាណវិទូ ឱ្យដឹងទៀតថា បន្ទាប់ពីចុះលេខចប់ ក្រុមការងារ នឹងសាកល្បងផ្គុំថ្មទាំងនោះ ដើម្បីរកទីតាំងដើម និងប្រភព របស់វា។ បើទោះបីជាយ៉ាងណាការរើថ្មនេះ មានភាពស្មុគ ស្មាញខ្លះៗ ពីព្រោះវារលំគរចម្រុះគ្នាច្រើនទីតាំង ចំណែក ឯថ្មខ្លះទៀត ធ្លាប់បានគេចល័តចេញពីកន្លែងដើមម្តងហើយ ដែលធ្វើឱ្យមានការលំបាកស្វែងរកទីតាំងនិងប្រភពដើម៕



អាជ្ញាធរជាតិអប្សរា រៀបចំសិក្ខាសាលាស្តីពី ដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ

ផ្សាយនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤

នៅទីស្នាក់ការរបស់អាជ្ញាធរជាតិអប្សរា រៀបចំសិក្ខាសាលាផ្ទៃក្នុង ស្តីពីដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ ក្នុងគោលបំណងទី១: ផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់សៀវភៅប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ទី២: ស្វែងយល់ និងចូលរួមការពារបរិស្ថានក្នុងតំបន់អង្គរ បង្កើនប្រសិទ្ធភាពការងារ និងកែលម្អប្រព័ន្ធគ្រប់គ្រងបរិស្ថាន ដល់មន្ត្រី-បុគ្គលិកសរុបចំនួន១០០នាក់ នាព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤។ ក្រោមអធិបតីភាព **ឯកឧត្តម សុខ លក្ខិណា** ទីប្រឹក្សា និងតំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយក នៃអាជ្ញាធរជាតិអប្សរា។

សិក្ខាសាលានាឱកាសនេះ មានធ្វើបទបង្ហាញចំនួន៣ សំខាន់ៗ ទី១: បទបង្ហាញស្តីពី អង្គរ និងបរិស្ថាន ទី២:បទបង្ហាញស្តីពីការបង្កើតគម្របព្រៃឈើ និងចែកចាយកូនឈើ ទី៣: បទបង្ហាញស្តីពីមន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរា និងសាធារណជនជាតិ អន្តរជាតិយល់ដឹងពីការងារអាជ្ញាធរជាតិអប្សរា ប្រវត្តិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ និងការពារបរិស្ថាន រួមទាំងសំណួរ-ចម្លើយ និងមតិសំណូមពរផ្សេងៗ ដែលសិក្ខាកាមអាចលើកឡើងដែរ ដើម្បីឱ្យសិក្ខាសាលាកាន់តែមានភាពស្និទ្ធស្នាល និងប្រសិទ្ធភាព៕







កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង១៦:៤៥ ភ្នាក់ងារទេសចរ និងនគរបាលការពារបេតិកភណ្ឌ បានប្រទះឃើញទូរស័ព្ទមួយគ្រឿងម៉ាក Iphone7 នៅមុខផ្ទះខាងកើតប្រាសាទមេបុណ្យ និងបានប្រគល់ជូនម្ចាស់ដើមវិញ ដែលជាភ្ញៀវទេសចរជនជាតិជប៉ុន នៅថ្ងៃដដែល

ផ្សាយនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរា បានរៀបចំធ្វើជណ្តើរឈើ នៅទិសឦសានៃប្រាសាទបាពួន

ផ្សាយនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤

ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍នៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌របស់អាជ្ញាធរជាតិអប្សរា បានរៀបចំធ្វើជណ្តើរឈើចំនួន១ នៅទីតាំងទិសឦសាននៃប្រាសាទបាពួន ដើម្បីជួយបង្វែរទិសដៅភ្ញៀវទេសចរនៅជណ្តើរទិសខាងលិចដោយសារជណ្តើរជ្រុងខាងជើងឆៀងខាងលិចកំពុងធ្វើការជួសជុល។

ការដំឡើងជណ្តើរឈើនេះដែរ ក៏ដើម្បីសម្រួលឱ្យភ្ញៀវទេសចរចូលទស្សនាក្នុងរាជវាំងចាស់បានស្រួល ការពារការដើរទាក់ជើងនិងឫសឈើ ក៏ដូចជាជួយការពារឫសឈើ និងកាត់បន្ថយការដើរជាន់ដុំថ្ម ព្រមទាំងរូបចម្លាក់ផ្សេងៗនៅលើកំពែងនេះផង៕







អគ្គនាយកអាជ្ញាធរជាតិអប្សរាធ្វើបទបង្ហាញពីការអភិរក្ស និងអភិវឌ្ឍន៍តំបន់បេតិកភណ្ឌពិភពលោកអង្គរ ដល់រដ្ឋបាលបេតិកភណ្ឌវប្បធម៌នៃសាធារណរដ្ឋកូរ៉ែ

ផ្សាយនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

ឆ្លៀតក្នុងឱកាសនៃការបំពេញការកិច្ចនៅសាធារណរដ្ឋកូរ៉ែ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានធ្វើបទបង្ហាញស្តីពីការងារអភិរក្ស ការជួសជុលរួតបាកាណនៃប្រាសាទអង្គរវត្ត និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ជូនដល់ថ្នាក់ដឹកនាំ និងបុគ្គលិករដ្ឋបាលបេតិកភណ្ឌវប្បធម៌នៃសាធារណរដ្ឋកូរ៉ែ ដើម្បីឈ្វេងយល់ពីកិច្ចការងាររបស់អាជ្ញាធរជាតិអប្សរា និងទិសដៅអនាគត។









អាជ្ញាធរជាតិអប្សរាបន្ត បើកវគ្គបណ្តុះបណ្តាលស្តីពីៈ អប់រំបេតិកភណ្ឌដល់សិស្សានុសិស្សនៅវិទ្យាល័យហ៊ុនសែនប្រាសាទបាគង ក្នុងឆ្នាំ២០២៤នេះ

ផ្សាយនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

នៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា ដោយមានកិច្ចសហការជាមួយអង្គការមរតកវប្បធម៌ខ្មែរ អាជ្ញាធរមូលដ្ឋាន បានបើកវគ្គបណ្តុះបណ្តាល កម្មវិធីបើកវគ្គអប់រំបេតិកភណ្ឌ ដល់សិស្សានុសិស្សនៃវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង ខេត្តសៀមរាប។ អញ្ជើញចូលរួមបើកវគ្គបណ្តុះបណ្តាលនោះមាន លោកអ៊ឹម សុខវិទ្ធិ ប្រធាននាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា លោកអ៊ុន មណីនីតា ប្រធានអង្គការមរតកវប្បធម៌ខ្មែរ លោក ប្រម ប្រេម នាយកវិទ្យាល័យហ៊ុន សែន ប្រាសាទបាគង តំណាងអាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ចំនួន៥៦នាក់ និងមានចែកសម្ភារៈសិក្សាដល់សិស្សានុសិស្សផងដែរ។

សូមជម្រាបថា ជារៀងរាល់ឆ្នាំអាជ្ញាធរជាតិអប្សរា អង្គការមរតកវប្បធម៌ និងអាជ្ញាធរក្នុងតំបន់មួយចំនួននៃរមណីយដ្ឋានអង្គរ បានបើកវគ្គបណ្តុះបណ្តាលស្តីពីៈ កម្មវិធីអប់រំបេតិកភណ្ឌ។ កម្មវិធីនេះមានសារសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលរស់នៅក្នុងតំបន់បេតិកភណ្ឌ ជាពិសេសសម្រាប់យុវជនជំនាន់ក្រោយ បានយល់ដឹង អំពីតម្លៃបេតិកភណ្ឌ និងផ្តល់ឱកាសដល់យុវជន បានយល់ដឹងនូវតម្លៃមរតកវប្បធម៌ បេតិកភណ្ឌ បណ្តុះគំនិតជាមួយនឹងបេតិកភណ្ឌ ឱ្យពួកគាត់ចេះស្រឡាញ់ និងចូលរួមថែរក្សាការពារ ជាពិសេសយល់ដឹងអំពីតួនាទីភារកិច្ច នៃការការពារ អភិរក្ស និងការងារគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា និងអាចធ្វើជាគំរូដល់សហគមន៍របស់ខ្លួនថែមទៀតផង៕





រូបភាពប្រចាំសប្តាហ៍៖ ចម្លាក់ព្រះពុទ្ធរូបនៅប្រាសាទតុបខាងលិច ក្នុងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៤











រូបភាពប្រចាំសប្តាហ៍÷ ទន្លេស្វតគឺជាប្រាសាទសាចពីថ្មតាក់នៅចុងសតវត្សរ៍ទី១២ ដែលជា «ហោបង់ស្រង់» របស់មន្ទីរព្យាបាលរោគមួយក្នុងចំណោមបួននៅជុំវិញក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤





នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ១០:២០នាទី ក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទតាព្រហ្ម បានជួយសង្គ្រោះបឋមក្មេងស្រីជនជាតិចិនម្នាក់ ដែលបានដើរដួលបណ្តាលឱ្យរបួសជើង នៅចំណុចខាងលិចសាលរចាំ

ផ្សាយនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤





នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ នៅវេលាម៉ោង១០:៥៦នាទីព្រឹក ក្រុមការងារសណ្តាប់ធ្នាប់ បានចូលរួមជាមួយកម្លាំងនគរបាល បេតិកភណ្ឌ ប៉ុស្តិ៍ការពារទី១០ និង ភ្នាក់ងារទេសចរ បានប្រគល់ទូរសព្ទដៃ ម៉ាក Samsung Galaxy A៥៣ ៥G ពណ៌ខ្មៅ ទៅជនជាតិអ៊ីតាលី ដែលបានភ្លេចនៅជណ្តើរខាងត្បូង ស្ពានហាល នៃប្រាសាទបាពួន ក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤











អាជ្ញាធរជាតិអប្សរា ជួសជុលសង្រ្គោះចម្រឹងបង្ហួចចំនួន២នៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤

អ្នកជំនាញអភិរក្សថ្មរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានរៀបចំជួសជុលចម្រឹងបង្ហួចចំនួន២ ដែលប្រឈមនិងហានិភ័យខ្ពស់ ឱ្យរឹងមាំឡើងវិញ។ ចម្រឹងបង្ហួចទាំង២នោះ មួយនៅរួតព្រះពាន់ផ្នែកខាងក្រៅនាទិសឦសាន បានបាក់ជាពីរកំណាត់ និងមួយទៀត នៅខ្លោងទ្វារចូលខាងមុខប្រាសាទអង្គរ ចំណុចផ្លូវដំរីទិសខាងជើង ដែលបាក់ជាបួនកំណាត់ និងមានស្នាមប្រេះដោយអន្លើ ថែមទាំងបែកមួយចំហៀងនៃសាច់ថ្មរបស់ចម្រឹងបង្ហួច។

អ្នកជំនាញអភិរក្សថ្មនៅប្រាសាទអង្គរវត្ត លោក សយ សុភារិន្ទ មានប្រសាសន៍ថា ក្រោយពីពិនិត្យឃើញថា ស្ថានភាពចម្រឹងបង្ហួចទាំងនោះ មានសភាពទ្រុឌទ្រោមខ្លាំង និងមិនមានលំនឹង ក្រុមការងារក៏បានចាត់វិធានការសង្រ្គោះបឋមដោយចងក្រៀកជាមួយនិងឈើទប់លំនឹង ជាបណ្តោះអាសន្ន ដើម្បីកុំឱ្យធ្លាក់ នៅមុនពេលជួសជុល។







លោក សយ សុការិន្ទ បន្តថា ចម្រឹងបង្អួចទី១ ដែលនៅខ្លោងទ្វារចូល នៅចំណុចផ្លូវដំរីមានគុណភាពល្អ គ្រាន់តែបាក់មួយកំណាត់ផ្នែកគល់ ទាមទារការជួសជុល និងព្យាបាលតាមដំណាក់ដូចជា សម្អាតស្ងួត សម្អាតសើម ដកជាតិអំបិល តភ្ជាប់ដោយដាក់ស្នូល និងបិតការភ្ជាប់សាច់ថ្ម បិតកំបោរបាយអ តាមមុខដំណរការពារដើម្បីកុំឱ្យជ្រាបទឹក និងបន្ថែមថ្មថ្មីតាមកន្លែងដែលបាត់សាច់ថ្ម ដើម្បីជួយទ្រតួចម្រឹងទាំងមូលឡើងវិញ។ រីឯចម្រឹងបង្អួចទី២ ដែលយកមកពីផ្នែកខាងក្រៅជ្រុងឦសាននៃថែវទី២វិញ មានសភាពទ្រុឌទ្រោម និងចុះខ្សោយខ្លាំង ដោយសារតែបាត់ថ្មមួយចំហៀង ធ្វើឱ្យក្រុមការងារព្យាយាមជួសជុលពង្រឹងព្យាបាលតភ្ជាប់ និងបន្ថែមថ្មថ្មីត្រង់កន្លែង ដែលបាត់ ដើម្បីឱ្យរឹងមាំនិងមានលំនឹងដូចដើមឡើងវិញ។



ការខូចខាតចម្រឹងបង្អួចទាំង២ បណ្តាលមកពីអាយុកាលនៃថ្ម អាកាសធាតុ ក្តៅ សើម ពិសេសសំណើម ដែលធ្វើឱ្យមានទឹកជ្រាបចូលតាមថ្នេរថ្ម ឬស្នាមប្រេះរបស់ថ្ម បណ្តាលឱ្យថ្មឆាប់ពុកផុយ។ អ្នកជំនាញរូបនេះ សំណូមពរចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលទៅទស្សនាប្រាសាទអង្គរវត្ត សូមចៀសវាង កុំចាប់តោងចម្រឹងបង្អួច ព្រោះចម្រឹងទាំងនោះមិនរឹងមាំទេ ដោយសារចម្រឹងបង្អួចមិនមែនជារចនាសម្ពន្ធអាចទ្រទម្ងន់ឡើយ គឺវាគ្រាន់តែជាគ្រឿងលម្អប៉ុណ្ណោះ៕





អាជ្ញាធរជាតិអប្សរាសហការរៀបចំសិក្ខាសាលាស្តីពីប្រវត្តិ ការគ្រប់គ្រង និងវិស័យទេសចរណ៍ ព្រះវិហារគ្រឹស្តសាសនាបុរាណ Cologne Cathedral and Freiburg Minster នៅប្រទេសអាល្លឺម៉ង់

ផ្សាយនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា បានសហការជាមួយស្ថាប័នអាល្លឺមង់ GACP បានរៀបចំសិក្ខាសាលាស្តីពីប្រវត្តិ ការគ្រប់គ្រង និងវិស័យទេសចរណ៍នៅសំណង់ព្រះវិហារគ្រឹស្តសាសនាបុរាណឈ្មោះថា Cologne Cathedral និង Freiburg Minster នៃប្រទេស អាល្លឺម៉ង់។ សិក្ខាសាលានេះ ធ្វើបទបង្ហាញដោយអគ្គនាយកអភិរក្សសំណង់បុរាណនៃព្រះវិហារគ្រឹស្តសាសនាទាំងពីរខាងលើ។

វាគ្មិនបណ្ឌិត Peter Fussenich បានធ្វើបទបង្ហាញពីប្រវត្តិត្រួសៗនៃអគារព្រះវិហារសាសនាគ្រិស្ត Cologne Cathedral សិល្បៈសំណង់ស្ថាបត្យកម្ម គំនូរចម្រុះលើកញ្ចក់ជាដើម។ ចំណុចសំខាន់គឺផ្តោតលើការងាររោងជាងរបស់ព្រះវិហារ ដែលមានអ្នកជំនាញចម្រុះវិស័យបំពេញការងារលើកិច្ចការពារ ការអភិរក្ស និងវិធានបង្ការ ការចែករំលែកបទពិសោធន៍ការងារនៅព្រះវិហារ Cologne Cathedral ។ ការងាររបស់រោងជាងសព្វថ្ងៃបានក្លាយគោលដៅទេសចរណ៍រហូតដល់មានអ្នកចូលទស្សនាការងារជួសជុលចំនួន៦,៥០០,០០០នាក់ក្នុងមួយឆ្នាំ។ Cologne Cathedral ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១២៤៨ មានកម្ពស់១៥៧ម៉ែត្រ។ អគារនេះត្រូវបានចុះក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្តូ នៅឆ្នាំ១៩៩៦។





ចំពោះបទបង្ហាញទី២ ដោយលោកស្រីបណ្ឌិត Anne Christine BREHM ជាអគ្គនាយិកា បានបង្ហាញបទពិសោធន៍ការងាររបស់រោងជាង នៃព្រះវិហារ Freiburg Minster ដែលជាព្រះវិហារនេះបានកសាងនៅសម័យកណ្តាលនៅអឺរ៉ុប។ ដូចគ្នានឹងព្រះវិហារខាងលើ មានចំនួនភ្ញៀវច្រើនលាននាក់បានមកទស្សនារោងជាងការងារអភិរក្សនៅព្រះវិហារ Freiburg Minster ដែរ។ ការងាររបស់រោងជាងទាំងពីរខាងលើ បានទទួលចំណាត់ថ្នាក់បេតិកភណ្ឌអរូបីពិភពលោកនៅឆ្នាំ២០២០ (Unesco Intangible World Heritage: Craft Techniques and Customary Practices of Cathedral Workshops)។



បាឋកថានេះធ្វើជាភាសាអង់គ្លេស ដោយមានការប្រែសម្រួលជាភាសាខ្មែរដោយលោក អ៊ឹម សុខរិទ្ធិ ប្រធាននាយកដ្ឋាន ស្រាវជ្រាវនិងបណ្តុះបណ្តាល។

ឯកឧត្តម ឡុច កុសល អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានចាត់ទុកសិក្ខាសាលាដែលរៀបចំនៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២៤នេះ ថាពិតជាសារប្រយោជន៍ជាខ្លាំងដល់អ្នកជំនាញខ្មែរ លើការអភិរក្សថ្ម ចម្លាក់ ក៏ដូចជាផ្នែកទេសចរណ៍ជាដើម។ ឯកឧត្តមរំពឹងថាក្រោយសិក្ខាសាលានេះចប់ មន្ត្រី-បុគ្គលិក និងអ្នកពាក់ព័ន្ធទាំងអស់ ដែលកំពុងបម្រើការនៅរមណីយដ្ឋានអង្គរ នឹងយល់ពីការងារសំខាន់ៗ ក្នុងន័យថែរក្សា ការពារ និងអភិរក្សតំបន់បេតិកភណ្ឌមួយនេះឱ្យកាន់តែល្អប្រសើរ៕

ខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា សូមថ្វាយនូវមហារាជកុសល និងសម្តែងនូវការចូលរួមមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុតចំពោះការយាងចូលទិវង្គត របស់សម្តេចព្រះអគ្គមហាសង្ឃរាជរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖ ✓

លិខិតរំលែកមរណទុក្ខ

សូមក្រាបបង្គំទូលថ្វាយ
សម្តេចព្រះគណៈសង្ឃនាយក គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

ជាទីសក្តារៈដ៏ខ្ពង់ខ្ពស់ !

ខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា ដែលជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា មានសេចក្តីរន្ធត់ក្តុកក្តួលរំជួលចិត្តឥតឧបមា និងពោរពេញដោយទុក្ខក្រៀមក្រំ បន្ទាប់ពីបានទទួលដំណឹងថា សម្តេច ព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ព្រះអង្គទ្រង់យាងចូលទិវង្គត នៅថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង១៧:៤០ នាទី ក្នុងព្រះជន្មាយុ ៩៣ ព្រះវស្សា ដោយព្រះជរាពាធ។

ក្នុងឱកាសដ៏សែនវិយោគរកទីបំផុតគ្មានន្រះ ខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសមានទុក្ខ អាឡោះអាល័យ និងសេចក្តីសង្វេគជាពន្លឹក ចំពោះព្រះដំណើរអនិច្ចធម្មនៃសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ដែលជាការបាត់បង់មហាវីរសង្ឃមួយព្រះអង្គ ក្នុងការលើកកម្ពស់ការរស់ឡើងវិញនូវព្រះពុទ្ធសាសនា ក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីថ្ងៃរំដោះ ៧ មករា ១៩៧៩ រហូតដល់ថ្ងៃអស់ព្រះជន្ម។ លើសពីនេះទៅទៀត ព្រះអង្គបានបូជាកម្លាំងព្រះកាយពល និងព្រះបញ្ញាញាណ ថ្វាយ **ជាតិ សាសនា ព្រះមហាក្សត្រ** ជាពិសេស ព្រះអង្គបានស្តាបនានូវស្នាព្រះហស្តយ៉ាងច្រើន ក្នុងវិស័យពុទ្ធចក្រ និងអាណាចក្រ ទុកសម្រាប់បច្ចាជនប្រើប្រាស់ជាធនធានក្នុងការរួមចំណែកអភិវឌ្ឍសង្គមជាតិទាំងក្នុងពេលបច្ចុប្បន្ន និងតទៅថ្ងៃអនាគត។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា សូមវន្ទាឧទ្ទិសបួងសួងដល់ដួងព្រះវិញ្ញាណក្ខន្ធរបស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **ទេព វង្ស** សូមបានយាងទៅកាន់ទីឋានសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចព្រះគណៈសង្ឃនាយក គណៈមហានិកាយ** ជាទីសក្តារៈដ៏ខ្ពង់ខ្ពស់ ទ្រង់ព្រះមេត្តាទទួលនូវ មនោសញ្ចេតនារំលែកមរណទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំព្រះករុណាយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ អង្គារ ៣៣៤ ខែ ឆាយ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០២៤

អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបឆ្នាំង ឃុំគំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរជាតិអប្សរា
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune,
Prasat Bakong District, Siem Reap Province

សកម្មភាពថែទាំ ដកស្មៅ និងកូនរុក្ខជាតិផ្សេងៗនៅបរិវេណប្រាសាទសួរព្រ័ត្រខាងជើង

ផ្សាយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤



នៅព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារផ្នែកសម្អាតរុក្ខជាតិលើប្រាសាទ បានចុះធ្វើសកម្មភាព ដកស្មៅ និងកាត់កូនឈើតូចៗ ដែលដុះនៅខាងលើ ប្រាសាទសួព្រ័ត្រខាងជើង នៃរាជធានីអង្គរធំ។ ស្មៅ និងកូនរុក្ខជាតិទាំងនោះ តែងតែដុះជាប្រចាំ មិនថា រដូវប្រាំងឬរដូវវស្សាឡើយ។ ដូច្នេះ សកម្មភាពថែទាំនិងដកហូត ក៏ត្រូវយកចិត្តទុកដាក់ ជាប្រចាំ៕





អាជ្ញាធរជាតិអប្សរកំពុងធ្វើការសម្អាតនិងចុះបញ្ជីថ្មនៅប្រាសាទអ្នកតាវាំង

ផ្សាយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤



ប្រាសាទអ្នកតាវាំង ឬអ្នកស្រុកហៅប្រាសាទគោកតាវាំង ជាប្រាសាទតូចមួយ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប។ ប្រាសាទនេះ បានបែកបាក់បាត់បង់រូបរាងស្ទើរទាំងស្រុងទៅហើយ ដោយសារកត្តាជាច្រើន មានធម្មជាតិ អាយុកាល និងកត្តាមនុស្សជាដើម។ ដើម្បីកិច្ចការងារអភិរក្សសំណង់បុរាណ អាជ្ញាធរជាតិអប្សរា កំពុងធ្វើសម្រង់ថ្ម ដែលធ្លាក់រាយប៉ាយនៅជុំវិញនោះ ដើម្បីស្វែងរកថ្ម រួចធ្វើការសម្អាត និងអាចរៀបផ្គុំប្រាសាទឱ្យមានរូបរាងឡើងវិញ។



លោក រស់ វិសុទ្ធ មន្ត្រីអភិរក្សប្រាសាទភ្នំក្រោម នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ដោយមានការអនុញ្ញាតពីថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា រយៈពេលជាងមួយខែកន្លងមកហើយ ដែលក្រុមការងារនៃនាយកដ្ឋានលោក បានចុះមកកាន់ទីតាំងប្រាសាទអ្នកតាវាំងនេះ ពិនិត្យមើលកិច្ចការងារមួយចំនួន ដើម្បីអភិរក្សប្រាសាទ ដែលរងការខូចខាតទ្រុឌទ្រោម នៅសល់តែគ្រឹះខាងក្រោម ថ្មធ្លាក់រាយប៉ាយ និងមានការរំលោភបំពានពីសំណាក់ពលរដ្ឋរស់នៅក្បែរៗនោះ ដោយបានចាក់ដីលុប និងសាងសង់សំណង់ថ្មីពីលើ។



លោកថាក្រៅពីការងាររបោសសម្អាត នៅជុំវិញបរិវេណប្រាសាទ ក្រុមការងារកំពុងធ្វើបច្ចុប្បន្នភាពទៅលើថ្មដែលនៅរាយប៉ាយ ធ្វើការសម្អាតថ្ម បង់លេខថ្ម ទើបចុះបញ្ជី ដើម្បីបានដឹងថា ថ្មមានក្បាច់ចំនួនប៉ុន្មានដុំ ថ្មជញ្ជាំងចំនួនប៉ុន្មានដុំ ថ្មសរសៃបនិងថ្មសសរពេជ្រចំនួនប៉ុន្មាន និងចំនួនថ្មផ្សេងៗទៀត ដោយត្រូវធ្វើសម្រង់ថ្មឡើងវិញទាំងអស់។ ប៉ុន្តែជំហានដំបូងត្រូវធ្វើសម្រង់ថ្មណា ដែលមានក្បាច់រចនាឬរូបរាងគ្រប់គ្រាន់។ លោកបន្តថា បន្ទាប់ពីការសម្រង់និងចុះបញ្ជីថ្មរួចរាល់ហើយ ទើបចាប់ផ្តើមការដួសជុលឬរៀបផ្គុំថ្មសាកល្បងឡើងវិញទៅតាមក្រុមថ្មនីមួយៗ ទើបស្នើសុំគោលការណ៍ថ្នាក់ដឹកនាំ ដើម្បីសិក្សាគម្រោងដួសជុលរៀបផ្គុំប្រាសាទអ្នកតាវាំងនេះឱ្យមានរូបរាងឡើងវិញ។

តាមរយៈឯកសារសាលាបារាំងចុងបូព៌ាបញ្ជាក់ថា ក្នុងអំឡុងឆ្នាំ ១៩៧២ បារាំងធ្លាប់បានមកធ្វើកំណាយស្រាវជ្រាវនៅលើទីតាំងនេះ ម្តងរួចមកហើយ កាលនោះនៅកំពូលខាងលើប្រាសាទ មានសំណង់ប្រក់ក្បឿងសម្រាប់គោរពបូជាអ្នកតា។

អាជ្ញាធរជាតិអប្សរាសំណូមពរដល់អាជ្ញាធរដែនដី និងបងប្អូនប្រជាពលរដ្ឋរស់នៅតំបន់ក្បែរៗប្រាសាទទាំងអស់ សូមចូលរួមថែរក្សាការពារ និងអភិរក្ស មិនថាប្រាសាទនោះ តូចឬធំឡើយ ត្រូវឈ្វេងយល់ និងផ្តល់តម្លៃដល់សំណង់បុរាណទាំងអស់ ដើម្បីបន្តថែរក្សាកេរដំណែលដូនតាខ្មែរបានបន្សល់ទុក៕







ក្រុមការងារស្នាក់ការទេសចរអាជ្ញាធរជាតិអប្សរា រៀបចំរបាថ្មថ្មីនៅទិសខាងលិចភ្នំក្រោម

ផ្សាយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤



នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារស្នាក់ការទេសចរបស់អាជ្ញាធរជាតិអប្សរា ប្រចាំគោលដៅប្រាសាទវត្តអង្គារ និងប្រាសាទភ្នំក្រោម បានរៀបចំដោះដូររបាថ្មថ្មី ជំនួសរបាចាស់ ដែលបានបាក់នៅទិសខាងលិចនៃប្រាសាទភ្នំក្រោម ដើម្បីឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព រួមទាំងជៀសវាងភ្ញៀវដើរឆ្លងកាត់នាំឱ្យមានគ្រោះថ្នាក់ផ្សេងៗ។





ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនកុះករ ចូលមកទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤











ក្រុមការងារសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា បាននិងកំពុងបំរុញឱ្យត្រៀវទេសចរ ក៏ជួចជាអ្នកប្រកបរបរ ជឹកជញ្ជូនទាំងអស់ ឱ្យចតយានយន្តនៅក្នុងចំណតឱ្យបានត្រឹមត្រូវ

ការណ៍នេះជាផ្នែកមួយនៃការរៀបចំ សណ្តាប់ធ្នាប់ និងបរិស្ថាន នៅតំបន់រមណីយដ្ឋានអង្គរឱ្យមានរបៀបរៀបរយ

ផ្សាយនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤





អបអរសាទរ ព្រះរាជាណាចក្រកម្ពុជា ដែលបានឈ្នះពានរង្វាន់ ជាគោលដៅទេសចរណ៍វប្បធម៌ ឈានមុខគេនៅអាស៊ី ពី World Travel Awards

ផ្សាយនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា ផ្តល់សម្ភារ និងកម្លាំងកម្មករ ជល់អង្គការមូលនិធិប្រាសាទពិភពលោក ក្នុងកិច្ចការជួសជុលប្រាសាទ

ផ្សាយនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា ផ្តល់សម្ភារ និងកម្លាំងកម្មករជំនាញ ជល់អង្គការមូលនិធិប្រាសាទពិភពលោក(world Monument Fund)ដើម្បីជួយធ្វើការជាប្រចាំថ្ងៃនៅការដ្ឋានជួសជុលប្រាសាទភ្នំបាខែង។

កម្លាំងមនុស្ស ដែលអាជ្ញាធរជាតិអប្សរាផ្តល់ទៅជួយការងារអង្គការ(WMF)នោះ គឺសុទ្ធតែអ្នកជំនាញខាងគូរប្លង់រកថ្ម ជួសជុលថ្ម រើថ្ម រៀបថ្ម ឆ្លាក់ក្បាច់ អ្នកជំនាញផ្នែកជួសជុលពង្រឹងគ្រឹះ និងអ្នកជំនាញការពារប្រព័ន្ធទឹក ដែលយល់ដឹងពីផលបះពាល់នៃការជម្រាបទឹក ដែលម្នាក់ៗមានបទពិសោធន៍ និងជំនាញ យ៉ាងហោចណាស់ក៏ជាង១០ឆ្នាំដែរ។ស្ថាបត្យករ និងជាអ្នកសម្របសម្រួលគម្រោងរបស់មូលនិធិប្រាសាទពិភពលោក អ្នកស្រីជាម ផល្លី មានប្រសាសន៍ថា អាជ្ញាធរជាតិអប្សរានឹងបន្តផ្តល់សម្ភារ ដូចជា ថ្មបាយក្រៀម ថ្មភក់ និងកម្លាំងកម្មករ ក្នុងន័យជួយគ្នាលើគម្រោងជួយជុល និងអភិរក្សប្រាសាទបុរាណនេះ(WMF)ពិតជារីករាយ និងស្វាគមន៍ហើយថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិអប្សរាយ៉ាងជ្រាលជ្រៅ។ អាជ្ញាធរជាតិអប្សរា និងអង្គការមូលនិធិប្រាសាទពិភពលោក(WMF) គឺជាដៃគូសហប្រតិបត្តិការយ៉ាងល្អក្នុងកិច្ចការអភិរក្ស និងជួសជុលប្រាសាទបុរាណរយៈពេល៣៥ឆ្នាំមកហើយ។



អ្នកស្រី ជាម ផល្លី ឱ្យដឹងថា រយៈពេល៣៥ឆ្នាំមកនេះ អង្គការមូលនិធិប្រាសាទពិភពលោក បានចូលរួមកិច្ចការអភិរក្ស បេតិកភណ្ឌនៅតំបន់អង្គរ ដោយជួសជុលប្រាសាទចំនួន៥ដូចជា ប្រាសាទព្រះខ័ន ប្រាសាទតាសោម ប្រាសាទអង្គរវត្ត ប្រាសាទក្នុបាខែង។ រីឯប្រាសាទនាគព័ន្ធស្ថិតក្នុងគម្រោងថែទាំ សម្អាតស្មៅនៅជុំវិញស្រះ អស់រយៈពេលជាង១០ឆ្នាំមកដែរ។



បន្ថែមលើនេះ ក្នុងអំឡុងពេល៣៥ឆ្នាំ អង្គការមូលនិធិប្រាសាទពិភពលោក (WMF) ក៏បានចូលរួមកិច្ចការអភិរក្ស បេតិកភណ្ឌនៅប្រទេសកម្ពុជា ដូចជា ការបណ្តុះបណ្តាលធនធានមនុស្សនិស្សិត កម្មករ មេជាង ឱ្យក្លាយទៅជាអ្នកជំនាញពិតប្រាកដ ធ្វើការដោយខ្លួនឯងដោយមិនពឹងផ្អែកលើអ្នកជំនាញអន្តរជាតិ។ ជួយចងក្រងឯកសារបេតិកភណ្ឌស្ថាបត្យកម្មដ៏សម្បូរបែបរបស់កម្ពុជា ហើយក៏បានធ្វើឱ្យមានស្ថិរភាព និងអភិរក្សប្រាសាទសំខាន់ៗជាដើម៕



ព្រឹកថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរ គោលដៅប្រាសាទអង្គរវត្ត បានសហការជាមួយក្រុមការងារភ្នាក់ងារសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា ជួយសម្របសម្រួលឱ្យរថយន្តចូលមកយកភ្ញៀវទេសចរអ៊ីរ៉ុប ដែលមានអាការៈមិនស្រួលខ្លួន ដើម្បីយកទៅសង្គ្រោះនៅមន្ទីរពេទ្យ

ផ្សាយនៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤











ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមីនា



ជំនួបការងារអោយឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា និងមន្ត្រីជាន់ខ្ពស់ ក្រសួងការបរទេស និងពាណិជ្ជកម្ម ប្រទេសនូវែលហ្សឺឡង់

ផ្សាយនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤

នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលជួបជាមួយលោកស្រី Gabrielle ISAAK មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកគោលនយោបាយអាស៊ាន នៃក្រសួងការបរទេស និងពាណិជ្ជកម្មប្រទេសនូវែលហ្សឺឡង់ដើម្បីពិភាក្សាលើវឌ្ឍនភាពការងារ និងទស្សនកិច្ចទីតាំងអនុវត្តគម្រោង«គ្រប់គ្រងទឹកអង្គរដោយប្រសិទ្ធភាព និងចីរភាពដើម្បីភាពធន់ និងការប្រែប្រួលអាកាសធាតុ និងសង្គម-សេដ្ឋកិច្ច»។



គម្រោងដែលជាជំនួយរបស់រដ្ឋាភិបាលនូវែលហ្សឺឡង់នេះផ្តោតជាសំខាន់លើការជួសជុលប្រឡាយនិងទំនប់បុរាណ សាងសង់ទ្វារទឹក តាមដានកម្រិតទឹកក្រោមដីដោយស្វ័យប្រវត្តិ លើកកម្ពស់ជីវភាពប្រជាជនតាមរយៈកសិកម្ម ស្ថានីយបណ្តុះកូនឈើ និងជីធម្មជាតិ ការចូលរួមរបស់ព្រះសង្ឃសម្រាប់បេតិកភណ្ឌជាដើម៕







អាជ្ញាធរជាតិអប្សរា រៀបចំដាក់ស្លាកសញ្ញាបង្ហាញទីតាំង ដែលត្រូវប្រុងប្រយ័ត្ន មុននិងដើរឆ្លងកាត់នៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤

ជាតិអប្សរា បានរៀបចំដាក់ស្លាកសញ្ញាមួយចំនួន ដើម្បីប្រាប់ពីទីតាំងខ្លះៗដល់ភ្ញៀវទេសចរឱ្យមានការប្រុងប្រយ័ត្នមុននិងដើរឆ្លងកាត់ នៅតាមទិសដៅវង់ទស្សនាប្រាសាទបាយ័ន។

លោក ប៊ូ ផានេត ប្រធានក្រុមការងាររៀបចំស្លាកសញ្ញាហានិភ័យ ឱ្យដឹងថា ក្រុមការងារបានចុះទៅពិនិត្យទីតាំងមួយចំនួន ដែលអាចនឹងធ្វើឱ្យភ្ញៀវទេសចរគ្រោះថ្នាក់ដូចជា ដើរដួល ដើរផុតឬ ដើរចូលកន្លែងទាបជាដើម។ ដើម្បីបញ្ចៀសនូវគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ ទើបក្រុមការងាររៀបចំដាក់ស្លាកសញ្ញានៅតាមចំណុចហានិភ័យខ្ពស់ទាំងនោះ បំណងប្រាប់ដល់ភ្ញៀវជាតិ-អន្តរជាតិ ឱ្យបានដឹងជាមុន និងប្រុងប្រយ័ត្នខ្ពស់ក្នុងពេលកំពុងដើរទស្សនា។





លោក ប៊ូ ផានេត បន្ថែមថា ស្លាកសញ្ញាប្រាប់ដំណឹងដល់ភ្ញៀវទេសចរនេះ មានទំហំតូចល្មម មិនប៉ះពាល់ដល់ទេសភាព សោភ័ណភាពប្រាសាទនោះឡើយ ដែលអាចធ្វើឱ្យភ្ញៀវទេសចរបានឃើញ និងយកចិត្តទុកដាក់ទីតាំងដែលពួកគាត់ឆ្លងកាត់។

អាជ្ញាធរជាតិអប្សរា សូមសំណូមពរដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មេត្តាចូលរួមគោរពតាមការណែនាំតាមស្លាកសញ្ញាផ្សេងៗដែលបានរៀបចំនៅគ្រប់ប្រាសាទទាំងអស់ ដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗ ក្នុងពេលទស្សនាប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ៕



រូបភាពប្រចាំសប្តាហ៍៖
ទាលស្មៅខៀវខ្ចីជុំវិញប្រាសាទអង្គរវត្តត្រូវទទួលការថែទាំជាប្រចាំដោយអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៤







នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៤ ក្រុមការងារឆ្លាក់ថារទេសចរ សហការជាមួយក្រុមការងារ ឆ្លាក់ថារសណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា គោលដៅប្រាសាទបន្ទាយក្តី និងស្រះស្រង់ បានសម្អាតបរិស្ថាន មានស្លឹកឈើ និងស្មៅជាដើម នៅបរិវេណបន្ទប់ទឹក ប្រាសាទបន្ទាយក្តី ដើម្បីលើកកម្ពស់សោភ័ណភាព កាន់តែប្រសើរឡើង

ផ្សាយនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៤









ក្រុមការងារភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា បានប្រគល់របស់របរដែលភ្ញៀវទេសចរភ្លេចចំនួន២ករណី

ផ្សាយនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៤



នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៤ ភ្ញៀវទេសចរជនជាតិអាហ្សង់ទីន បានភ្លេចទូរស័ព្ទដៃមួយគ្រឿងនៅក្នុងបន្ទប់ទឹករបស់បរិវេណបដិសណ្ឋារកិច្ចនៃប្រាសាទបន្ទាយស្រី។ បន្ទាប់មកក្រុមការងារភ្នាក់ងារទេសចរគោលដៅប្រាសាទបន្ទាយស្រី ក្រុមការងារអនាម័យ នៃគ្រឹះស្ថានអង្គរ ក្រុមការងារភ្នាក់ងារសណ្តាប់ធ្នាប់ រួមសហការជាមួយនគរបាលការពារបេតិកណ្ឌ រក្សាទុកដើម្បីរង់ចាំម្ចាស់មកយក និងបានប្រគល់ទូរសព្ទទៅម្ចាស់ដើមវិញ ក្រោយពីពិនិត្យឃើញថា គាត់ពិតជាម្ចាស់ពិតប្រាកដមែន។



ករណីដូចគ្នានេះដែរ ក្រុមការងារភ្នាក់ងារទេសចរគោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញកាបូបស្ពាយចំនួនមួយនៅចំណុចបរិវេណមាត់កសិន្ទុខាងជើងស្ពានហាល។ បន្ទាប់មក ក្រុមការងារបានសហការជាមួយនគរការពារបេតិកភណ្ឌ ប្រគល់ជូនទៅម្ចាស់ដើម ជាភ្ញៀវទេសចរអន្តរជាតិមកពីប្រទេសអង់គ្លេស ក្រោយពីពិនិត្យឃើញថាពិតជាម្ចាស់ពិតប្រាកដមែន៕





រូបភាពប្រចាំសប្តាហ៍៖ស្ថាបត្យកម្ម នាចុងសតវត្សរ៍ទី១២ នៅតែឈរយ៉ាងរឹងមាំ និងនៅតែបន្តឱ្យភ្ញៀវទេសចរធ្វើដំណើរឆ្លងកាត់មកដល់បច្ចុប្បន្ន នោះគឺខ្លោងទ្វារទន្លេអ៊ុំ

ផ្សាយនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៤









កម្មករជំនាញ សប្បាយចិត្តដែលបានចូលរួមជួសជុលប្រាសាទភ្នំបាខែង ជាមួយអង្គការមូលនិធិប្រាសាទពិភពលោក

ផ្សាយនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២៤



កម្មករជំនាញជួសជុលប្រាសាទជាច្រើនរូប ដែលអាជ្ញាធរជាតិអប្សរាផ្តល់ឱ្យទៅចូលរួមជួសជុលប្រាសាទភ្នំបាខែង ក្រោមកិច្ចសហការជាមួយអង្គការមូលនិធិប្រាសាទពិភពលោក (World Monument Fund) បានបង្ហាញការសប្បាយចិត្តនៅក្នុងកន្លែងការងារថ្មី។



លោក សូ នៅ ជាអ្នកភូមិស្រះស្រង់ខាងត្បូង អាយុ៥៤ឆ្នាំ ដែលមានជំនាញផ្នែកដាប់ ឆ្លាក់ និងរៀបថ្មអស់រយៈពេលជាង១០ឆ្នាំ នៅក្នុងស្ថាប័នអាជ្ញាធរជាតិអប្សរាមកហើយ មានប្រសាសន៍ថា លោកសប្បាយចិត្ត និងធ្វើការងារជួសជុលប្រាសាទបុរាណភ្នំបាខែង ទោះបីជា លោកត្រូវឡើងចុះភ្នំខុសពីការងារដែលលោកធ្លាប់ធ្វើក៏ដោយ។ លោកបន្តថា នៅការដ្ឋានជួសជុលប្រាសាទលើភ្នំបាខែង គឺក្រុមការងារបានទទួលស្វាគមន៍រូបលោកយ៉ាងកក់ក្តៅ។ ចំណែក ការងារក៏បំពេញទៅតាមជំនាញរបស់ខ្លួនមានកន្លងមក ដែលមិនមានការលំបាកអ្វីនោះឡើយ។





ដូចគ្នានេះដែរ លោក សុខ សារ៉ែត ជាអ្នកភូមិស្រះស្រង់ខាងត្បូងម្នាក់ទៀត ដែលបានបម្រើការងារជួសជុលប្រាសាទតាំងពីឆ្នាំ២០០៤ បានឱ្យដឹងដែរថា ការងារជួសជុលប្រាសាទភ្នំបាខែង មិនសូវខុសគ្នាពីការជួសជុលប្រាសាទបុរាណដទៃទៀតឡើយ។លោកសារ៉ែតបញ្ជាក់ថា ការទទួលស្គាគមន៍យ៉ាងកក់ក្តៅពីក្រុមការងារប្រចាំនៅការដ្ឋានលើភ្នំបាខែង គឺមានភាពស្និទ្ធស្នាល និងចេះជួយគ្នាទៅវិញទៅមក ដើម្បីរួមគ្នាជួសជុលអភិរក្សប្រាសាទភ្នំបាខែងបានកាន់តែប្រសើរឡើង។



លោក សូ នៅ និងលោក សុខ សារ៉ែត បានថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា ដែលផ្តល់ទំនុកចិត្ត និងផ្តល់ឱកាសសម្រាប់រូបលោក ក៏ដូចជា ក្រុមការងារទៅជួសជុលប្រាសាទភ្នំបាខែង និងជាលើកទី១ ដែលរូបលោក និងក្រុមការងារបានទៅជួសជុលនៅភ្នំបាខែង។ ពិសេសអង្គការមូលនិធិប្រាសាទពិភពលោក បានស្វាគមន៍យ៉ាងកក់ក្តៅគួរឱ្យមោទនភាព៕



អ្នកជំនាញការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យ និងសិក្សាពីការជ្ឋានប្រាសាទមេបុណ្យខាងលិច

ផ្សាយនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤ អ្នកជំនាញការអាជ្ញាធរនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក លោកស្រី សាស្ត្រាចារ្យ INABA Nobuki រួមទាំងអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ដើម្បីសិក្សាស្វែងយល់វាយតម្លៃលើការងារយៈពេលកន្លងមក។









អ្នកជំនាញការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យការងារតាមការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤





អ្នកជំនាញការអាជ្ញាធរនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ ចុះពិនិត្យការងារតាមការដ្ឋានមួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរ រួមមាន ស្ពានហាលខាងលិចមុខប្រាសាទអង្គរវត្ត ច្រាំងកសិន្ទខាងជើងឆៀងខាងកើត ខ្លោងទ្វារខាងកើត បង្គាន់ដៃនាគខាងត្បូងរួតទី២ប៉មខាងជើងឆៀងខាងកើត ស្រះទឹកខាងត្បូង ប្រាសាទតាព្រហ្មកិល និងប្រាសាទភ្នំបាខែង។

ការចុះពិនិត្យនេះ ធ្វើឡើងដើម្បីពិភាក្សាស្វែងយល់អំពីដំណើរការជួសជុល អភិរក្សនានា និងផ្តល់អនុសាសន៍ដល់ក្រុមការងារជំនាញខ្មែរអំពីកិច្ចការផ្សេងៗដែលកំពុងធ្វើ និងត្រៀមទៅពេលអនាគត៕

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប សហការជាមួយអាជ្ញាធរជាតិអប្សរា ស៊ើបអង្កេតលើជនខិលខូចមួយក្រុម បានយាយីធ្វើឱ្យរបួសសត្វស្វានៅតំបន់រមណីយដ្ឋានអង្គរ ដើម្បីអនុវត្តនីតិវិធីច្បាប់

ផ្សាយនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤

នាពេលថ្មីៗនេះ មានជនខិលខូចមួយក្រុមតូចបានយាយីធ្វើឱ្យរបួសសត្វស្វា យកដើងទាត់ និងគ្រវែងសត្វស្វាចូលក្នុងទឹក ដើម្បីថតរូបក្នុងគោលដៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួននៅតំបន់រមណីយដ្ឋានអង្គរខេត្តសៀមរាប។

ដើម្បីទប់ស្កាត់សកម្មភាពទាំងនេះ បច្ចុប្បន្នមន្ទីរកសិកម្មខេត្តកំពុងសហការជាមួយអាជ្ញាធរជាតិអប្សរា នឹងធ្វើការស៊ើបអង្កេតលើករណីជនខិលខូចមួយក្រុមតូចទាំងនោះ។ យោងតាមច្បាប់ស្តីពីព្រៃឈើមាត្រា ៤៨ ចែងថា៖ ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាទ្រព្យរួមមាន ពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ផលជលិកសត្វ បាណកសត្វ និងសត្វ ឥតឆ្អឹងកងផ្សេងៗទៀតព្រមទាំងពងកូនរបស់វា និងមាត្រា ៩៩ចែងថា: ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី៣ ដែលត្រូវជាប់ពន្ធនាគារពី ០១ខែទៅ ០១ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១លានទៅ ១០លានរៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសយាយីធ្វើឱ្យរបួស ប្រមូលពងកូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយកម្រឬបំផ្លាញជម្រករបស់វា។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត
សៀមរាប

ថ្ងៃសាត្យ ទីដប់ពីរ ខែ.គាស ឆ្នាំថោះបញ្ចស័ក ព.ស២៥៦៧
សៀមរាប,ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០២៤

សេចក្តីជូនដំណឹង
ស្តីពី
ការយាយីធ្វើឱ្យរបួសសត្វស្វានៅតំបន់រមណីយដ្ឋានអង្គរខេត្តសៀមរាប

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាបមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា: នាពេលថ្មីៗកន្លងមកនេះ មានជនខិលខូចមួយក្រុមតូច បានយាយីធ្វើឱ្យរបួសសត្វស្វាជូចជាយកដើងទាត់និងគ្រវែងសត្វស្វាចូលក្នុងកណ្ឋិណទឹកដើម្បីថតរូប កម្សាន្ត ក្នុងគោលដៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន នៅតំបន់រមណីយដ្ឋានអង្គរខេត្តសៀមរាប ។

យោងតាមច្បាប់ស្តីពីព្រៃឈើមាត្រា ៤៨ ចែងថា:ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាទ្រព្យសម្បត្តិរបស់រដ្ឋនិងជាសមាសភាគនៃធនធានព្រៃឈើរួមមាន ពួកថនិកសត្វ បក្សីសត្វ ឧរង្គសត្វ ផលជលិកសត្វ បាណកសត្វ និងសត្វ ឥតឆ្អឹងកងផ្សេងៗទៀតព្រមទាំងពងកូនរបស់វា និងមាត្រា ៩៩ចែងថា: ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី៣ ដែលត្រូវជាប់ពន្ធនាគារពី ០១ខែទៅ ០១ឆ្នាំ ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១លានទៅ ១០លានរៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសយាយីធ្វើឱ្យរបួស ប្រមូលពងកូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬក្រុមមានដោយកម្រឬបំផ្លាញជម្រករបស់វា ។

ទង្វើអសីលធ៌មក្នុងការយាយី ការធ្វើទារុណកម្ម ធ្វើឱ្យរបួសសត្វស្វាជាអំពើខុសច្បាប់ដែលត្រូវផ្តន្ទាទោសតាមច្បាប់ស្តីពីព្រៃឈើ។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត សហការជាមួយអាជ្ញាធរជាតិអប្សារានឹងធ្វើការស៊ើបអង្កេតលើករណីជនខិលខូចមួយក្រុមតូច បានយាយីធ្វើឱ្យរបួសសត្វស្វានៅតំបន់រមណីយដ្ឋានអង្គរដើម្បីអនុវត្តតាមនីតិវិធីច្បាប់ ។

អាស្រ័យហេតុនេះសូមសាធារណជនមេត្តាជ្រាបជាសេចក្តីជូនដំណឹងតាមការគួរ។

ប្រធានមន្ទីរ
ឧា.គីមសុទ្ធ

Siem Reap Provincial Department of Agriculture Forestry and Fisheries, 60m Street(Pyong yang), Boeng Dorpa Village, Slorkram Commune, Siem Reap Municipality, Siem Reap Province, E-mail : pda.sr.adm@gmail.com Telegram: 012 915 560, 012 820 806



ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចូលគោរពព្រះវិញ្ញាណក្ខន្ធ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស សម្តេចព្រះសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៤





នៅព្រឹកថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងក្រុមការងារ បានសម្តែងនូវការគោរពចំពោះព្រះវិញ្ញាណក្ខន្ធ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសមាណទុក្ខដ៏មហាក្រៀមក្រំ សោកស្តាយស្រណោះអាឡោះអាល័យស្ទើរគ្មានទីបំផុតគ្មាន ចំពោះការយាងចូលព្រះទិវង្គតរបស់ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។ ការយាងចូលព្រះទិវង្គតរបស់សម្តេច គឺជាការបាត់បង់មហាវីរសង្ឃកំពូល ដែលជាកុលបុត្រដ៏ឧត្តុង្គឧត្តម ធ្លាប់រួមចលនាតស៊ូរំដោះជាតិប្រជាជន លើសពីនេះ ព្រះអង្គបានបូជាធ្វើពលិកម្មដ៏ខ្ពង់ខ្ពស់បំផុត លះបង់ព្រះកាយថ្វាយ ជាតិ សាសនា ព្រះមហាក្សត។ បន្ថែមលើសពីនេះទៀត ព្រះអង្គក៏បានជួយជ្រោមជ្រែងលើកិច្ចការអភិរក្សនៅប្រាសាទលលៃ និងព្រះវិហារវត្តលលៃ ឱ្យសក្តិសមជាបេតិកភណ្ឌពិភពលោក។

យើងខ្ញុំ សូមវន្ទាឧទ្ទិសដល់ដួងព្រះវិញ្ញាណក្ខន្ធ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សូមយាងទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ៕





ស្នាក់ការទេសចររបស់អាជ្ញាធរជាតិអប្សរា ប្រគល់របស់ដែលភ្លៀវទេសចរភ្លេចចំនួន២ករណី

ផ្សាយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៤

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរ របស់អាជ្ញាធរជាតិអប្សរាគោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញទូរស័ព្ទដៃចំនួនមួយ នៅចំណុចជណ្តើរចូលទីតាំងអុជធូបគោលដៅរូតព្រះពាន់។ ក្រុមការងារទេសចរ សហការជាមួយនគរបាលការពារបេតិកភណ្ឌ នគរបាលទេសចរណ៍ប្រគល់ទៅម្ចាស់ដើមវិញ ដែលជាភ្ញៀវទេសចរជនជាតិថៃ ក្រោយពីពិនិត្យឃើញថាជាម្ចាស់ពិតប្រាកដមែន។

ករណីដូចគ្នានេះដែរ ក្រុមការងារភ្នាក់ងារទេសចររបស់អាជ្ញាធរជាតិអប្សរាគោលដៅប្រាសាទតាព្រហ្ម សហការជាមួយនគរបាលការពារបេតិកភណ្ឌ នគរបាលទេសចរណ៍ បានប្រគល់កាបូបស្ពាយចំនួនមួយ ជូនភ្ញៀវទេសចរដែលបានភ្លេចនៅចំណុចស្ពានដើមច័ន្ទ ក្រោយពីពិនិត្យឃើញថា ពិតជារបស់ភ្ញៀវទេសចរដែលបានភ្លេចជាម្ចាស់ដើមវិញពិតប្រាកដ៕







អ្នកជំនាញការអាយស៊ីស៊ី-អង្គរ បន្តចុះពិនិត្យការងារតាមការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៤

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៤ ក្រុមអ្នកជំនាញការអាជីហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក បានបន្ត ចុះពិនិត្យការងារតាមការដ្ឋានមួយចំនួនក្នុងតំបន់រមណីយ ដ្ឋានអង្គរ រួមមាន ប្រាសាទតុបខាងលិច ប្រាសាទបាយ័ន ព្រះលានដល់ដំរី ក្រុមប្រាសាទព្រះពិធូរ ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយក្តី ប្រាសាទក្តីសូរ និងប្រាសាទតានែ។



ការចុះពិនិត្យនេះ ធ្វើឡើងដើម្បីពិភាក្សាស្វែងយល់អំពី ដំណើរការជួសជុល អភិរក្សនានា និងផ្តល់អនុសាសន៍ ដល់ក្រុមការងារជំនាញខ្មែរអំពីកិច្ចការផ្សេងៗដែលកំពុងធ្វើ និងត្រៀមទៅពេលអនាគត៕







រូបភាពប្រចាំសប្តាហ៍៖ ថ្មគោលព្រះពុទ្ធ នៅអមសងខាងផ្លូវចូលប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៤









ថ្ងៃទី០៩ មីនា ឆ្នាំ២០២៤នេះ អ្នកជំនាញការអាយស៊ីស៊ី-អង្គរ ចុះពិនិត្យការងារតាមការដ្ឋានចំនួន៩ ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២៤

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៤នេះ ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក និងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដែលដឹកនាំដោយ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានបន្តចុះពិនិត្យការងារតាមការដ្ឋានមួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរ មានដូចជាៈ ប្រាសាទបាគង ប្រាសាទបន្ទាយសំរែ និងចុះពិនិត្យទីតាំងមជ្ឈមណ្ឌលបដិសណ្ឋារកិច្ច ចំណតនៅប្រាសាទតាសោម និងទន្លេស្ងួត។



ការចុះពិនិត្យនេះ ធ្វើឡើងដើម្បីពិភាក្សាស្វែងយល់អំពីដំណើរការជួសជុល អភិរក្សនានា និងផ្តល់អនុសាសន៍ដល់ក្រុមការងារជំនាញខ្មែរអំពីកិច្ចការផ្សេងៗដែលកំពុងធ្វើ នឹងត្រៀមទៅពេលអនាគត៕





រូបភាពប្រចាំសប្តាហ៍÷
ទិដ្ឋភាពថ្ងៃរះពេលព្រឹកព្រលឹមនៅប្រាសាទអង្គរវត្ត មើលពីលើអាកាស

ផ្សាយនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤









អ្នកជំនាញការអាយស៊ីស៊ី-អង្គរ បន្តចុះពិនិត្យការងារតាមការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤



ក្នុងគោលបំណងស្វែងយល់អំពីដំណើរការជួសជុល អភិរក្ស និងផ្តល់អនុសាសន៍ដល់ក្រុមការងារជំនាញខ្មែរអំពីកិច្ចការផ្សេងៗដែលកំពុងធ្វើ នឹងត្រៀមទៅពេលអនាគតនៅតាមការដ្ឋាននានា ក្រុមអ្នកជំនាញការអាជីហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក និងអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា បានបន្តចុះពិនិត្យការងារតាមការដ្ឋានមួយចំនួនទៀតនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដូចជា ព្រះលានដល់ដំរី ក្រុមប្រាសាទព្រះពិធូរ និងប្រាសាទមេបុណ្យខាងលិច នារសៀលថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤៕







ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ យ៉ាងច្រើនកុះករ បានមករង់ចាំទស្សនាថ្ងៃរះនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤



ស្ទើរតែជារៀងរាល់ព្រឹក ពុំមានលុះមួយថ្ងៃណាមួយឡើយ ភ្ញៀវទេសចរជាតិ និងអន្តរជាតិតែងតែក្រោកមកតាំងពីព្រលឹមស្រាងៗ ដើម្បីរង់ចាំគយគនទិដ្ឋភាពថ្ងៃរះនៅខាងមុខប្រាសាទអង្គរវត្ត។ ព្រោះថា ថ្ងៃរះនៅប្រាសាទអង្គរវត្ត ជាផ្ទាំងទស្សនីយភាពដ៏ទាក់ទាញមួយសម្រាប់ភ្ញៀវទេសចរ ពួកគេមានខ្លះឈរ និងខ្លះអង្គុយ នៅជុំវិញស្រះទឹក ដើម្បីរង់ចាំមើលថ្ងៃរះដ៏ស្រស់ត្រកាល នាព្រឹកព្រហៀម និងផ្តិតយករូបភាពទាំងនោះទុកអនុស្សាវរីយ៍។



ជាក់ស្តែងនៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤នេះចាប់តាំងពីម៉ោង៥ព្រឹកមកម្ល៉េះ ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចំនួនប្រមាណ ១,៥០០នាក់ បានមករង់ចាំទស្សនាទិដ្ឋភាពដ៏ស្រស់ស្អាតនេះ នៅខាងមុខប្រាសាទអង្គរវត្ត៕







ក្រុមការងារសម្អាតបរិស្ថានអាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ជាប្រចាំគ្រប់រដូវកាល ដើម្បីលើកតម្កើរមណីយដ្ឋានអង្គរកាន់តែប្រសើរ

ផ្សាយនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤





គណៈកម្មាធិការអន្តរជាតិ សម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍ រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក នឹងបើកកិច្ចប្រជុំ រយៈពេល២ថ្ងៃ ក្រោមអធិបតីភាព លោកជំទាវ បណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ផ្សាយនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

គណៈកម្មាធិការអន្តរជាតិ សម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក នឹងបើកកិច្ចប្រជុំបច្ចេកទេសលើកទី៣៨ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ នៅឯខេត្តសៀមរាប។

កិច្ចប្រជុំបច្ចេកទេសលើកទី៣៨នេះ នឹងដឹកនាំដោយ លោក TANINAI Ichitomo ជាអនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុន និងលោក Pierre VINCENT ទីប្រឹក្សាទទួលបន្ទុកផ្នែកវប្បធម៌របស់ស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា។នៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកទី៣៨នេះ ក្រុមអ្នកជំនាញអន្តរជាតិ នឹងពិនិត្យទៅលើការងារមួយចំនួននៅតាមការដ្ឋានការងារជាតិ និងអន្តរជាតិ ដែលកំពុងតែដំណើរការក្នុងការជួសជុល និងអភិរក្សប្រាសាទបុរាណនានា។ ជាមួយគ្នានេះដែរ ក្រុមអ្នកជំនាញអន្តរជាតិ ក៏នឹងធ្វើការតាមដាននិងផ្តល់យោបល់បច្ចេកទេស ព្រមទាំងអនុសាសន៍ថ្មីៗបន្ថែមទៀត ដើម្បីឱ្យតាមការដ្ឋានយកទៅអនុវត្តន៍ស្របតាមកិច្ចការដែលកំពុងតែបំពេញនោះ។

ចំណែក នៅថ្ងៃទី១៥ ខែមីនា សម័យប្រជុំពេញអង្គលើកទី៣០ នឹងដឹកនាំដោយ ឯកឧត្តម Jacque PELLET ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។ប្រធានបទសំខាន់នៃសម័យប្រជុំពេញអង្គលើកទី៣០ នឹងពិភាក្សាទៅលើសេចក្តីប្រកាសរួមរបស់អន្តរដ្ឋាភិបាល ដែលបានប្រព្រឹត្តទៅនៅទីស្នាក់ការរបស់អង្គការUNESCO ក្នុងទីក្រុងប៉ារីស កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣កន្លងទៅ ស្តីពី រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក។

កិច្ចប្រជុំពេញអង្គនេះ ក៏នឹងពិភាក្សា ព្រមទាំងពិនិត្យទៅលើគម្រោងថ្មីៗរបស់កិច្ចការអភិរក្ស ការងារអភិវឌ្ឍន៍ កិច្ចការស្រាវជ្រាវ ការងារបុរាណវិទ្យា បណ្តុះបណ្តាល ព្រមទាំងកិច្ចការអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងតំបន់រមណីយដ្ឋានអង្គរ ក៏ដូចជា សំបូរព្រៃគុកដែរ៕



ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ជួសជុលជណ្តើរឈើ ដែលរងការខូចខាតឱ្យល្អប្រសើរឡើងវិញ នៅតាមប្រាសាទនានា នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីលើកសោភ័ណភាព និងមានសុវត្ថិភាពដល់ភ្ញៀវទេសចរជាយស្រួល ក្នុងការចេញ-ចូល ឡើង-ចុះទស្សនាប្រាសាទ

ផ្សាយនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤











និស្សិតសាកលវិទ្យាល័យអាមេរិកាំង-ភ្នំពេញ មកស្វែងយល់ប្រព័ន្ធធារាសាស្ត្របុរាណក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

និស្សិតផ្នែកវិទ្យាសាស្ត្របរិស្ថាន នៃសាកលវិទ្យាល័យអាមេរិកាំង-ភ្នំពេញចំនួន៨០នាក់ មកស្វែងយល់ពីសារសំខាន់ និងការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្របុរាណក្នុងតំបន់អង្គរ តាមរយៈទស្សនកិច្ចសិក្សាកាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៤។ ទស្សនកិច្ចនេះ អាជ្ញាធរជាតិអប្សរា ផ្តល់នូវអ្នកជំនាញ ដើម្បីធ្វើបទបង្ហាញ ព្រមទាំងបានដឹកនាំចុះទៅតាមកន្លែង និងទីតាំងជាក់ស្តែងផង។



លោក ឡៃ ប៉ូទី អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានធ្វើបទបង្ហាញជូនដល់និស្សិតទាំងនោះ អំពីកិច្ចការងារគ្រប់គ្រងក្នុងតំបន់អង្គរ អំពីប្រវត្តិនៃការរីកចម្រើននៃសំណង់ធារាសាស្ត្របុរាណ សារសំខាន់នៃការគ្រប់គ្រងទឹកនិងប្រើប្រាស់ទឹក ផលប៉ះពាល់កើតមានឡើងក្នុងតំបន់អង្គរកំឡុងពេលគ្មានការជួសជុលថែទាំ ព្រមទាំងជួសជុលប្រព័ន្ធធារាសាស្ត្របុរាណ ឱ្យមានដំណើរការឡើងវិញ ដោយអាជ្ញាធរជាតិអប្សរា និងសមិទ្ធផលដែលទទួលបានពីការងារគ្រប់គ្រងទឹកក្នុងតំបន់អង្គរជាដើម។



បន្ទាប់ពីបញ្ចប់បទបង្ហាញរួចមក អ្នកជំនាញរបស់នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានដឹកនាំនិស្សិតចុះពិនិត្យតាមទីតាំងសំណង់គ្រប់គ្រងទឹកសំខាន់ៗជាច្រើនកន្លែង ថែមទាំងពន្យល់លម្អិតពីការងារចាត់ចែងគ្រប់គ្រងទឹកមុខងារនៃសំណង់ធារាស្ត្រនីមួយៗ ការភ្ជាប់ទំនាក់ទំនងគ្នានៃប្រព័ន្ធទឹកក្រោមដី រួមទាំងឆ្លើយតបនិងសំណួររបស់និស្សិត ដើម្បីផ្តល់ចំណេះដឹងឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតផង៕



អ្នកជំនាញការអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក ចុះពិនិត្យការរៀបចំ និងអភិវឌ្ឍន៍តំបន់ពាក់ស្នែង និងរុនតាឯក

ផ្សាយនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤





នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ក្រុមអ្នកជំនាញការអាដហុក នៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ និងសំបូរព្រៃគុក ហៅកាត់ថា អាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក បានចុះទៅពិនិត្យការរៀបចំ និងកិច្ចអភិវឌ្ឍន៍នៅតំបន់ពាក់ស្នែង និងរុនតាឯក។ ក្នុងដំណើរទស្សនកិច្ច ដែលដឹកនាំដោយ លេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ, ឯកឧត្តមអគ្គនាយក-អគ្គនាយករង អាជ្ញាធរជាតិអប្សរា ព្រមទាំងមន្ត្រីពាក់ព័ន្ធ ជាច្រើនរូប។

នៅតំបន់រុនតាឯក ក្រុមការងារបានចុះទស្សនកិច្ចសិក្សា នៅមណ្ឌលសុខភាព ចម្ការបង្ហាញ និងផ្ទះកសិករគំរូដែល ទទួលបានការគាំទ្របច្ចេកទេសដោយអ្នកជំនាញកសិកម្ម របស់ អាជ្ញាធរជាតិអប្សរា។ល។





មកដល់ទៀតហើយ ព្រឹត្តិការណ៍ដ៏អស្ចារ្យនៅអង្គរវត្តក្នុងខែមីនានេះ

ផ្សាយនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤

ពេលវេលាដែលអ្នកទេសចរទាំងអស់តែងតែទន្ទឹងរង់ចាំបានមកដល់ទៀតហើយ នោះគឺព្រះអាទិត្យនឹងរះឡើងចំកំពូលប្រាសាទកណ្តាលនៃអង្គរវត្ត ឬសមរាត្រី ដែលនឹងកើតឡើងនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ខាងមុខនេះ។

ព្រឹត្តិការណ៍មហស្ចារ្យនៅអង្គរវត្តនេះ តែងតែបានទាក់ទាញចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិយ៉ាងច្រើនរាប់ពាន់នាក់ ដែលចង់ឃើញហេតុការណ៍ និងចង់ផ្តិតយករូបភាពនេះទុកជាអនុស្សាវរីយ៍។អ្នកស្រាវជ្រាវបានហៅព្រឹត្តិការណ៍នេះថា សមរាត្រី (Equinox) ដែលមានសរសេរលើសិលាចារឹកបុរាណថា «វិសុវ» គឺជាពេលដែលយប់និងថ្ងៃមានរយៈពេលស្មើគ្នា។





សូមអញ្ជើញភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលមកទស្សនាព្រឹត្តិការណ៍សមរាត្រី នាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ឱ្យបានច្រើនកុះករ។សូមបញ្ជាក់ដែរថា ជារៀងរាល់ឆ្នាំ ព្រឹត្តិការណ៍សមរាត្រី (Equinox) តែងតែកើតមាន២ដង គឺនៅរដូវប្រាំង (Vernal Equinox) កើតឡើងនៅខែមីនា និងសមរាត្រីរដូវវស្សា (Autumnal Equinox) កើតឡើងនៅខែកញ្ញា៕





កិច្ចប្រជុំបច្ចេកទេសលើកទី៣៨ នៃគណៈកម្មាធិការអាយស៊ីស៊ី-អន្តរ និងសំបូរព្រៃគុក ចាប់ផ្តើមជំណើរការ

ផ្សាយនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤



នៅព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៤ គណៈកម្មាធិការអន្តរជាតិ សម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក បានចាប់ផ្តើមកិច្ចប្រជុំបច្ចេកទេសលើកទី៣៨ដែលដឹកនាំដោយលោក TANINAI Ichitomo ជាអនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុន និងលោក Pierre VINCENT ទីប្រឹក្សាទទួលបន្ទុកផ្នែកវប្បធម៌របស់ស្ថានទូតបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា។



ជាកិច្ចចាប់ផ្តើមសន្ទរកថាដោយលោក TANINAI Ichitomo ជាអនុប្រធានបេសកកម្មនៃស្ថានទូតជប៉ុន លោកបានរំឲ្យកពីការងារមួយចំនួនដែលជប៉ុនបានចូលរួម ក្នុងរមណីយដ្ឋានអង្គរជាង៣០ឆ្នាំមកនេះ។ លោកបន្តថា ពីឆ្នាំ១៩៩៤មក ជប៉ុនបានសហការជាមួយអាជ្ញាធរជាតិអប្សរា ជួសជុលការដ្ឋានមួយចំនួនក្នុងរមណីយដ្ឋានអង្គរ។ សមិទ្ធផលដែលលេចធ្លោជាងគេ គឺការងារជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរវត្ត ដែលមាន២ដំណាក់កាល និងត្រូវបានដាក់សម្ពោធជាផ្លូវការនៅខែធ្នូ ឆ្នាំ២០២៣។



ជាមួយគ្នានោះលោក TANINAI Ichitomo ក៏បានវាយតម្លៃលើកិច្ចសហប្រតិបត្តិការនៅ រមណីយដ្ឋានសំបូរព្រៃគុក ផងដែរ ហើយលោកថាកិច្ចសហប្រតិបត្តិការនឹងបន្តជារហូត ក្នុងបុព្វហេតុរួមចំណែកអភិរក្សសម្បត្តិបេតិកភណ្ឌកម្ពុជា ឱ្យមាននិរន្តរភាព និងចីរភាព។



សូមបញ្ជាក់ថា ក្រៅពីកិច្ចប្រជុំបច្ចេកទេសលើកទី៣៨នេះ នៅថ្ងៃទី១៥ ខែមីនា ក៏នឹងមានកិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងសំបូរព្រៃគុក ដែលកិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តម Jacques PELLET ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។ មុននឹងមានកិច្ចប្រជុំផ្លូវការនេះឡើង ក្រុមអ្នកជំនាញការចំពោះកិច្ចខាងផ្នែកអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព បានចុះទៅតាមការដ្ឋានមួយចំនួនក្នុងរមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក ដើម្បីត្រួតពិនិត្យការងារ តាមដាន និងផ្តល់អនុសាសន៍លើការងារទាំងនោះ ឱ្យស្របតាមគោលការណ៍ជារួមក្នុងធម្មនុញ្ញអង្គរ៕





គណៈកម្មាធិការអន្តរជាតិ សម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុកបើកកិច្ចប្រជុំពេញអង្គ លើកទី៣០នៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤



គណៈកម្មាធិការអន្តរជាតិ សម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក បានបើកកិច្ចប្រជុំពេញអង្គ លើកទី៣០នៅខេត្តសៀមរាប នាព្រឹកថ្ងៃទី១៥ខែមីនាឆ្នាំ២០២៤ នេះ។



កិច្ចប្រជុំពេញអង្គនេះ ដឹកនាំដោយសហប្រធាន ឯកឧត្តម Jacques PELLET ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងក៏មានការអញ្ជើញចូលរួមជាភ្ញៀវកិត្តិយស ដោយឯកឧត្តម KOMURA Masahiro អនុរដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន ស្ថិតក្រោមអធិបតីភាព **លោកជំទាវបណ្ឌិតសភាចារ្យ ឡើង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាកិបាលនៃអាជ្ញាធរជាតិអប្សរា។





រូបភាពប្រចាំសប្តាហ៍៖ ចម្លាក់តូចៗល្អវិចិត្របង្ហាញអំពីទេពកថា «រឿងក្អូរសមុទ្រទឹកដោះ» និងរូបទេពផ្សេងៗ នៅផ្នែកខាងលើផ្តែរប្រាសាទព្រះតន្ទ្រកោសីយ៍

ផ្សាយនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤





សូមបញ្ជាក់ដែរថា ប្រាសាទព្រះតន្ទ្រកោសីយ៍ កសាងនៅចុងសតវត្សរ៍ទី១០ មានទីតាំងស្ថិតនៅក្នុងវត្តព្រះតន្ទ្រកោសីយ៍ ក្រុងសៀមរាប។



លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា ទទួលជួបឯកឧត្តម Chang Won Sam ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ដើម្បីពង្រឹងទៅលើកិច្ចសហប្រតិបត្តិការវិស័យវប្បធម៌ និងបេតិកភណ្ឌ

ផ្សាយនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៤



សូមបញ្ជាក់ថា នាពេលកាលពីថ្មីៗនេះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយរដ្ឋបាលបេតិកភណ្ឌវប្បធម៌កូរ៉េ (The Cultural Heritage Administration of the Republic of Korea) ទៅលើកិច្ចការងារអភិរក្ស និងជួសជុល រួតបាកាន នៃប្រាសាទអង្គរវត្ត ដែលមានរយៈពេល៣ឆ្នាំ (២០២៤-២០២៦)។

ឆ្លៀតឱកាសនៅក្រៅកិច្ចប្រជុំពេញអង្គ លើកទី៣០ នៃគណៈកម្មាធិការអន្តរជាតិ សម្របសម្រួល កិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានអង្គរ និងសំបូរព្រៃគុក នៅខេត្តសៀមរាប នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានទទួលជួបជាមួយឯកឧត្តម Chang Won Sam ប្រធានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) នៃសាធារណរដ្ឋកូរ៉េ និងសហការីដើម្បីពង្រឹងទៅលើកិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ និងបេតិកភណ្ឌ ជាពិសេសកិច្ចការងារជួសជុលប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។







រូបភាពប្រចាំសប្តាហ៍៖
ខ្ពោចទ្វារទន្លេអុំ ទីតាំងភ្ជៀវទេសចរគយគន់ថ្ងៃលិចដ៏ស្រស់ស្អាត

ផ្សាយនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៤









សកម្មភាពក្រុមសម្អាតអនាម័យបន្តសម្អាតអនាម័យបរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤

ក្រុមការងារសម្អាតអនាម័យបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា បានបន្តសកម្មភាពជាប្រចាំ សម្អាតបរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរ។ ការងារនេះធ្វើឡើងក្នុងន័យដើម្បីថែរក្សាសោភ័ណភាព អនាម័យ បរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរឱ្យមានភាពស្រស់ស្អាត ទាក់ទាញភ្ញៀវទេសចរ និងស័ក្តិសមជាតំបន់បេតិកភណ្ឌដ៏ពេញនិយមសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ៕









ក្រុមការងារភ្នាក់ងារទេសចរ ប្រចាំគោលដៅប្រាសាទអង្គរវត្តសហការជាមួយនគរបាលទេសចរណ៍ និងនគរបាលបេតិកភណ្ឌ ធ្វើការប្រគល់កាបូបជូនភ្ញៀវដែលបានភ្លេច

ផ្សាយនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤



នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤នេះ នៅគោលដៅប្រាសាទអង្គរវត្ត មានមគ្គុទ្ទេសក៍ទេសចរណ៍ជនជាតិខ្មែរ ភេទប្រុស ឈ្មោះ ជា មាន រើសបានកាបូបស្តាយក្រោយពណ៌ខ្មៅមួយ មកប្រគល់ជូនភ្នាក់ងារទេសចរប្រចាំនៅជណ្តើរឡើងរួតបាណ។ លុះក្រោយមក ម្ចាស់កាបូបជនជាតិអឺរ៉ុបម្នាក់ ភេទប្រុស មកពីសាធារណរដ្ឋឆេក បានមករកវិញ ដោយពិនិត្យឃើញថា ជារបស់គាត់ពិតប្រាកដមែន ក្រុមភ្នាក់ងារទេសចរ បានសហការជាមួយនគរបាលទេសចរណ៍ និងនគរបាលបេតិកភណ្ឌ ធ្វើការប្រគល់ជូនម្ចាស់វិញនៅវេលាថ្ងៃដដែល។



អាជ្ញាធរជាតិអប្សរាសូមថ្លែងអំណរគុណចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ ក៏ដូចជាប្រជាពលរដ្ឋខ្មែរ ដែលតែងតែរក្សាបាននូវតម្លៃវប្បធម៌ដ៏ល្អផូរផង់មួយនេះ ហើយវប្បធម៌នេះគឺជាការបង្ហាញនៅទំនុកចិត្តសម្រាប់ភ្ញៀវទេសចរ ដែលបានអញ្ជើញមកទស្សនានៅក្នុងរមណីយដ្ឋានអង្គរ៕



ភ្ញៀវទេសចរជាង១ម៉ឺននាក់ បានមកទស្សនាព្រឹត្តការណ៍ថ្ងៃរះចំកំពូលកណ្តាលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤



នៅព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤នេះ ព្រឹត្តិការណ៍សមរាត្រី ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចំនួនជាង១ម៉ឺននាក់ បានក្រោកមកតាំងពីម៉ោង៥ព្រឹក ដើម្បីរង់ចាំទស្សនាព្រឹត្តិការណ៍ព្រះអាទិត្យរះឡើងកាត់តាមកំពូលកណ្តាលនៃប្រាសាទអង្គរវត្ត។

ដោយសារអាកាសធាតុនាព្រឹកព្រលឹមនេះ មានអំណោយផលល្អ ទេសចរអាចទស្សនា និងផ្តិតយកទិដ្ឋភាពថ្ងៃរះ គួរទីជាគយគនបានយ៉ាងរីករាយ។

សូមបញ្ជាក់ដែរថា ព្រឹត្តិការណ៍សមរាត្រី (Equinox) តែងតែកើតមាន២ដង ជារៀងរាល់ឆ្នាំ គឺនៅរដូវប្រាំង (Vernal Equinox) កើតឡើងនៅខែមីនា និងសមរាត្រីរដូវវស្សា (Autumnal Equinox) កើតឡើងនៅខែកញ្ញា។











អាជ្ញាធរជាតិអប្សរា ពង្រីកសួនរុក្ខជាតិអង្គរ ពីទំហំ១៥ហិកតា ទៅ១៥០ហិកតា ដើម្បីបម្រើឱ្យវិស័យទេសចរណ៍លក្ខណៈធម្មជាតិកាន់តែសម្បូរបែប

ផ្សាយនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤

សួនរុក្ខជាតិអង្គរមានទំហំផ្ទៃដីប្រមាណ១៥ហិកតា ដែលបានបើកដំណើរការជាផ្លូវការកាលពីឆ្នាំ២០២២កន្លងមក ឥឡូវនេះ អាជ្ញាធរជាតិអប្សរាកំពុងរៀបចំពង្រីកឱ្យធំជាងមុន ពីទំហំ១៥ហិកតា ទៅ១៥០ហិកតា ដើម្បីបម្រើឱ្យវិស័យទេសចរណ៍លក្ខណៈធម្មជាតិកាន់តែសម្បូរបែប។

អនុប្រធាននាយកដ្ឋានគ្រប់គ្រង ទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា លោក ឡៃ ប៉ូទី មានប្រសាសន៍កាលពីរសៀលថ្ងៃទី២១ ខែមីនា អាជ្ញាធរជាតិអប្សរាមានគម្រោងពង្រីក សួនរុក្ខជាតិអង្គរពីទំហំ១៥ហិកតារ ទៅ១៥០ហិកតា ដោយធ្វើរបងសម្រាប់ដោះលែងសត្វព្រៃ និងការពារព្រៃឈើ រៀបចំផ្លូវដើរ ស្ពានថ្មើរជើងសម្រាប់ទេសចរដើរកម្សាន្តក្នុងព្រៃធម្មជាតិ។



នៅក្នុងគម្រោងពង្រីកផ្ទៃដីសួនរុក្ខជាតិអង្គរនេះគឺអាជ្ញាធរជាតិអប្សរា បានដាំបង្គោលស៊ីម៉ង់ត៍ និងព័ទ្ធលួសសំណាញ់ប្រវែង៥៤៦៨ម៉ែត្រជុំវិញព្រៃ ចាប់ពីសួនរុក្ខជាតិអង្គររហូតទៅដល់កសិន្ទុអង្គរភាគខាងត្បូង បំណងធ្វើជាទីធ្លាសម្រាប់ព្រលែងសត្វព្រៃជាច្រើនប្រភេទឱ្យរស់នៅតាមលក្ខណៈធម្មជាតិរបស់វា ដែលទេសចរក៏អាចទស្សនាសត្វព្រៃទាំងនេះដោយផ្ទាល់តាមរយៈផ្លូវថ្មើរជើងក្នុងព្រៃ។

ទន្ទឹមនេះ អាជ្ញាធរជាតិអប្សរា ស្នើបញ្ឈប់ការផ្សព្វផ្សាយក្នុងបណ្តាញសង្គមដែលផ្ទុយពីការពិត ដែលបង្កជាការបំផ្លើសព័ត៌មានក្នុងន័យអវិជ្ជមាន ធ្វើឱ្យប៉ះពាល់ដល់កិត្តិយសស្ថាប័នជាតិ និងកិច្ចខិតខំប្រឹងប្រែងទាក់ទាញភ្ញៀវទេសចរមកទស្សនានៅរមណីយដ្ឋានអង្គរ។



ព្រះអាទិត្យរះចំកំពូលប្រាង្គកណ្តាលប្រាសាទអង្គរវត្តដ៏ស្រស់ស្អាតនាព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ ភ្ញៀវទេសចរជាតិ-អន្តរជាតិនៅតែមានចំនួនច្រើនកុះករក្នុងការមកទស្សនាព្រឹត្តិការណ៍ដ៏វិសេសវិសាលនេះ

ផ្សាយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤





សូមបញ្ជាក់ដែរថា ព្រឹត្តិការណ៍សមរាត្រី (Equinox) តែងតែកើតមាន២ដងជារៀងរាល់ឆ្នាំគឺនៅរដូវប្រាំង (Vernal Equinox) កើតឡើងនៅខែមីនា និងសមរាត្រីរដូវស្រូវ (Autumnal Equinox) កើតឡើងនៅខែកញ្ញា។





អគ្គនាយកអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាការងារជាមួយអនុប្រធាន រដ្ឋបាលបេតិកភណ្ឌវប្បធម៌នៃសាធារណរដ្ឋកូរ៉េ

ផ្សាយនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤នេះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយលោក YI Kyunghoon អនុប្រធាន រដ្ឋបាលបេតិកភណ្ឌវប្បធម៌នៃសាធារណរដ្ឋកូរ៉េ (The Cultural Heritage Administration of the Republic of Korea) នាមជ្ឈមណ្ឌលរបស់អាជ្ញាធរជាតិអប្សរា។ ក្រៅពីជំនួបសម្តែងការគួរសម ក៏បានពិភាក្សាការងារទៅលើ គម្រោងសហប្រតិបត្តិការទៅថ្ងៃអនាគត ជាពិសេសគម្រោងជួសជុលពង្រឹងគ្រឹះរួតបាកាននៃប្រាសាទអង្គរ និងកិច្ចសហប្រតិបត្តិការផ្សេងៗទៀត ដែលបាននឹងត្រូវអនុវត្តនៅក្នុងខ្លឹមសារដែលបានចុះអនុស្សរណៈយោគយល់ជាមួយគ្នានាពេលកន្លងមក។





សូមបញ្ជាក់ថា កាលពីខែកុម្ភៈ ឆ្នាំ២០២៤ថ្មីៗនេះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយរដ្ឋបាលបេតិកភណ្ឌវប្បធម៌កូរ៉េ (The Cultural Heritage Administration of the Republic of Korea) ទៅលើកិច្ចការងារអភិរក្ស និងជួសជុល រួតបាកាណ នៃប្រាសាទអង្គវត្ត ដែលមានរយៈពេល៣ឆ្នាំ (២០២៤-២០២៦)៕





រូបភាពប្រចាំសប្តាហ៍÷ ខ្លោចទ្វារតាកាវ ឬខ្លោចទ្វារខាងលិច នៃក្រុងអង្គរធំ នាពេលព្រះអាទិត្យរៀបអស្តង្គត

ផ្សាយនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤







រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទតេមានអកាស ដែលស្ថិតនៅក្នុងបរិវេណអតីតព្រះរាជវាំងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤













អាជ្ញាធរជាតិអប្សរា រៀបចំគំនូសបួងសួងស្ថាបត្យកម្មលក្ខណៈបែបប្រពៃណីខ្មែរ ជូនពលរដ្ឋចំនួន១១ករណី

ផ្សាយនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤

នៅសប្តាហ៍ទី៣នៃខែមីនា ឆ្នាំ២០២៤នេះ ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានជួយរៀបចំគំនូសបួងសួងស្ថាបត្យកម្មបែបប្រពៃណីខ្មែរ ជូនដល់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ទទួលបានការអនុញ្ញាតបានចំនួន ១១ករណី ក្នុងនោះរួមមាន៖

-១ ឈ្មោះ រឿន ធឿម រស់នៅភូមិគោកបេង សង្កាត់គោកចក ក្រុងសៀមរាប
-២ ឈ្មោះ សឹក សាភា រស់នៅភូមិប្រដាក ឃុំប្រដាក ស្រុកបន្ទាយស្រី
-៣ ឈ្មោះ ហ៊ា សុផល រស់នៅភូមិអូរទទឹង ឃុំប្រដាក ស្រុកបន្ទាយស្រី
-៤ ឈ្មោះ គិល គឹ រស់នៅភូមិតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី
-៥ ឈ្មោះ ឃេ ឃឿយ រស់នៅភូមិអន្តង្គន់ ឃុំដូនកែវ ស្រុកពួក
-៦ ឈ្មោះ ក្រាញ់ ឈូក រស់នៅភូមិបឹងខ្នារ ឃុំខ្នាត ស្រុកពួក
-៧ ឈ្មោះម៉ែន លុយ រស់នៅភូមិប្រាសាទចារ្យ ឃុំដូនកែវ ស្រុកពួក
-៨ ស្តើង ស៊ីវ៉ែន រស់នៅភូមិគោកស្នួល ឃុំខ្នាត ស្រុកពួក
-៩ ឈ្មោះ ហ៊ុម ព្រម រស់នៅភូមិល្បើក ឃុំដូនកែវ ស្រុកពួក
-១០ ឈ្មោះសុំ ស្រីមុំ រស់នៅភូមិស្នឹង ឃុំបាគង ស្រុកប្រាសាទបាគង
-១១ ឈ្មោះ អោម មៀន រស់នៅភូមិថ្នល់ត្រង់ ឃុំបាគង ស្រុកប្រាសាទបាគង។



អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើរហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោលគឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕





៣ខែដើមឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្នុងមណីយដ្ឋានអង្គរចំនួន២១៧ករណី

ផ្សាយនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤

ក្រុមការងារសហគមន៍នៃនាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍របស់អាជ្ញាធរជាតិអប្សរា បានចុះពិនិត្យការស្នើសុំជួសជុល និងអនុញ្ញាតជូនប្រជាពលរដ្ឋដែលរស់នៅក្នុង ០៥ក្រុង-ស្រុក បានចំនួន២១៧ករណី។



ការអនុញ្ញាតទាំងចំនួន២១៧ករណីនោះ មានដូចជា៖ ១) ស្រុកប្រាសាទបាគង អនុញ្ញាតចំនួន២៥ករណី ២) ស្រុកអង្គរធំ អនុញ្ញាតចំនួន២៩ករណី ៣) ស្រុកពួក អនុញ្ញាត៤២ករណី ៤) ក្រុងសៀមរាប អនុញ្ញាតចំនួន៥៨ករណី ៥) ស្រុកបន្ទាយស្រី អនុញ្ញត៥៩ករណី ៦) ទីតាំងក្រៅឧទ្យានរមណីយដ្ឋានអង្គរ អនុញ្ញាត៤ករណី។

ស្តែងចេញពីសកម្មភាពទាំងនេះ ក្រុមការងារសហគមន៍តែងតែចុះទៅតាមគោលដៅរបស់ខ្លួន ដល់ខ្នងផ្ទះប្រជាពលរដ្ឋជារៀងរាល់ថ្ងៃ ដើម្បីដោះស្រាយ បញ្ហាជូនពួកគាត់ ថែមទាំងបាននាំយកថវិកាមួយចំនួន ជូនដល់ចាស់ជរា គ្មានទីពឹងនៅតាមមូលដ្ឋានគោលដៅជាដើម។ ទន្ទឹមនិងនេះ អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់គ្រប់បញ្ហា ចំពោះប្រជាពលរដ្ឋទាំងសុខទុក្ខ ទាំងជីវភាពរស់នៅ សុខភាព និងការអប់រំ។



«ថ្មសោ» ជាគន្លឹះសម្រាប់រើថ្ម ជួសជុលសំណង់ប្រាសាទបុរាណ

ផ្សាយនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤

នៅគ្រប់សំណង់ប្រាសាទថ្មកក់របស់ជូនតាខ្មែរ ការសាងសង់រៀបថ្មពីមួយជុំទៅមួយជុំ តែងតែមានថ្មគន្លឹះ ឬហៅថា ថ្មសោ។ ថ្មសោនេះ ជាទូទៅមានផ្ទៃខាងលើធំជាងបាតខាងក្រោម ដើម្បីសម្រាប់រឹតបន្តឹងថ្ម ទប់លំនឹងថ្មឱ្យរឹងមាំ មិនឱ្យថ្មងាកទ្រេត ឬថ្មរំកិលចេញពីគ្នា។

ថ្មសោដំបូលខ្លោងទ្វារខាងកើតនៃប្រាសាទអង្គរវត្ត ជាឧទាហរណ៍។ នៅចំណុចមិនឆ្ងាយពីទីប្រសព្វនៃដំបូលដែលមានទិសទាំង៤ផ្គុំគ្នា ថ្មសោ ត្រូវបានយកមកប្រើដើម្បីខ្ទាស់ថ្មតម្រៀបក្រោយគេទាំងអស់។ ដូចនេះ ពេលរើគឺត្រូវរើថ្មសោមុនគេបង្អស់ ប្រៀបដូចជាការបើកសោ ដើម្បីអាចរើថ្មផ្សេងៗទៀតបាន។





ឯកឧត្តម គឹម សុធិន អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍បន្តថា ខ្មែរបុរាណ ពិតជាមានបច្ចេកទេសខ្ពស់ ដែលសំណង់នីមួយៗអាចនៅគង់វង្សរាប់រយឆ្នាំ។ លក្ខណៈពិសេសនេះ កម្រមានអ្នកចាប់អារម្មណ៍ ឬដឹងនោះឡើយ មានតែអ្នកធ្វើការផ្ទាល់ជាមួយប្រាសាទបុរាណ ទើបយល់ពីស្នាដៃដូនតា និងអាចសិក្សាយកបច្ចេកទេសនោះ ដើម្បីយកមកជួសជុល អភិរក្សរាល់សំណង់នោះឡើងវិញឱ្យបានគង់វង្សរាប់រយឆ្នាំជាបន្តទៀត៕







នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង១២ និង៥០នាទី ភ្នាក់ងារទេសចរប្រាសាទតាកែវ និងតារនៃជួយសង្គ្រោះ ភ្ញៀវទេសចរជនជាតិអាល្លឺម៉ង់ម្នាក់ ដែលបានចុះពីលើប្រាសាទ ហើយក្រិចកជើងនៅជាន់ទី១ ផ្នែកខាងកើត។

ភ្នាមៗក្រុមភ្នាក់ងារទេសចរ ដែលប្រចាំការនៅទីនោះបានជួយសង្គ្រោះ ដោយប្រើកញ្ចប់សង្គ្រោះបឋម បន្ទាប់មកទេសចរខាងលើក៏បានធូរស្រាល និងបន្តដំណើរទៅចំណតដោយខ្លួនឯង ។

ផ្សាយនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤









នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង១១ និង១០នាទី
ក្រុមភ្នាក់ងារទេសចរប្រចាំ ប្រាសាទបាយ័ន
បានប្រទះឃើញកាបូបស្ពាយខាងក្រោយពណ៌ប្រផេះមួយ
ដែលភ្ឿវទេសចរ បានភ្លេចនៅរួតទីមួយ។

យ៉ាងណាក្នុងរយៈពេល១០នាទីក្រោយមក ភ្ឿវទេសចរជនជាតិកូឡុំបឹ គេទប្រុស
រួមនិងមក្តុទ្ទេសក៏បានមកទទួលកាបូបនោះ និងបញ្ជាក់ថា
កាបូបនោះពិតជារបស់គាត់ ពិតមែន។ ភ្លាមៗនោះ ភ្នាក់ងារទេសចរក៏បានប្រគល់ជូន
គាត់វិញនៅនឹងកន្លែង។

ផ្សាយនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤





វត្តឥន្ទបត្តបុរី (វត្តអង្គរខាងត្បូង) នឹងមានសោភ័ណភាព ដោយការប្តេជ្ញាចិត្តរបស់ ព្រះគ្រូចៅអធិការវត្ត កែវ អាន

ផ្សាយនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤



អាជ្ញាធរជាតិអប្សរាបានកោតសរសើរ ចំពោះព្រះគ្រូឥន្ទបាលី កែវ អាន ព្រះវិន័យធរនៃសាលាអនុគណក្រុងសៀមរាប និងជាព្រះគ្រូចៅអធិការវត្តឥន្ទបត្តបុរីអង្គរខាងត្បូង ដែលមានទស្សនវិស័យវែងឆ្ងាយ និងបានសម្រេចព្រះទ័យក្នុងការកែប្រែបរិវេណវត្តឱ្យមានមុខមាត់ថ្មីប្រកបដោយសោភ័ណភាព។

នៅរសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ នៅវត្តរាជបូព៌ មានកិច្ចប្រជុំមួយ ក្រោមអធិបតីភាព សម្តេចព្រះព្រហ្មរតនមុនី ពិន សែម សិរីសុវណ្ណោ ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក និងជាសមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា ដោយមានការនិមន្តចូលរួមពីសំណាក់ព្រះសុមង្គលសិលាចារ្យ អាភាករោ ជុំ គឹមឡេង ជាព្រះមេគណខេត្តសៀមរាប និងជាប្រធានក្រុមប្រឹក្សាកិច្ចការវត្តអារាមនៅឧទ្យានអង្គរ (CoMAPA) ព្រមជាមួយវត្តមានព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម ក៏ដូចជាក្រុមការងារកិច្ចការវត្តអារាមរបស់អាជ្ញាធរជាតិអប្សរា។







ក្នុងកិច្ចប្រជុំមានការបង្ហាញអំពីប្លង់មេនៃវត្តឥន្ទបត្តបុរីអង្គរខាងត្បូង សម្រាប់ការរៀបចំសោភ័ណភាពក្នុងបរិវេណវត្តឡើងវិញ ក្នុងនោះព្រះគ្រូឥន្ទបាលី កែវ អាន ព្រះវិន័យធរនៃសាលាអនុគណក្រុងសៀមរាប និងជាព្រះគ្រូចៅអធិការវត្តឥន្ទបត្តបុរីអង្គរខាងត្បូង ក៏បានចុះហត្ថលេខាលើប្លង់មេដើម្បីបញ្ជាក់ពីគោលបំណងរបស់ថ្នាក់ដឹកនាំវត្តចំពោះមុខអង្គប្រជុំផងដែរ។

អាជ្ញាធរជាតិអប្សរាបានបង្ហាញការសាទរ និងកោតសរសើរ ចំពោះអំពើដ៏ល្អប្រពៃរបស់ព្រះគ្រូចៅអធិការវត្តឥន្ទបត្តបុរីអង្គរខាងត្បូង ដែលបានសម្រេចព្រះទ័យលើកតម្លៃអារាមព្រះពុទ្ធសាសនាដែលស្ថិតនៅកៀកប្រាសាទអង្គរវត្ត ហើយដែលសកម្មភាពនេះនឹងក្លាយជាគំរូដ៏ប្រសើរសម្រាប់វត្តដទៃទៀតក្នុងរមណីយដ្ឋានអង្គរ៕







អ្នកស្រុកអង្គរ នៅតែបំពេញភ្នួតនាទី ជាអ្នកថែរក្សា និងការពារអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤









មកដល់សព្វថ្ងៃ អ្នកស្រុកអង្គរ នៅតែបំពេញតួនាទីជាអ្នកថែរក្សា និងការពារអង្គរ តាមរយៈការចូលរួមជួសជុលប្រាសាទបុរាណនានា និងបានក្លាយជាកម្មករជំនាញតាមផ្នែកផ្សេងៗដូចជា ជាប់ឆ្លាក់ថ្ម រៀបផ្គុំថ្ម និងស្វែងរកថ្មជាដើម។ ជាក់ស្តែង លោក ព្រាន ដូរ អាយុ៣២ឆ្នាំ និងលោក តប់ តង អាយុ៥៨ឆ្នាំ ក្នុងចំណោមកម្មករជំនាញជាច្រើន កំពុងបំពេញតួនាទីរបស់ខ្លួនជាអ្នកស្វែងរកថ្មដែលរលុះធ្លាក់ចល័តខុសពីទីតាំងដើម នៅការដ្ឋានជួសជុលខ្លោងទ្វារខាងត្បូងនៃប្រាសាទតាព្រហ្ម ដែលទទួលរងការខូចខាត បាក់ស្រុតរលុះថ្មស្ទើរតែទាំងស្រុងជាយូរមកហើយឱ្យរឹងមាំឡើងវិញ។

លោក ព្រាន ដូរ ឱ្យដឹងថា នៅការដ្ឋានជួសជុលខ្លោងទ្វារខាងត្បូងរបស់ប្រាសាទតាព្រហ្ម មានចំនួន២នាក់ ហើយការស្វែងរកថ្មប្រាសាទដែលរលុះធ្លាក់ និងចល័តខុសពីទីតាំងដើមយកមករៀបផ្គុំឱ្យត្រូវឡើងវិញចួបការលំបាកច្រើន ដោយចំនួនថ្មនៃតួខ្លោងទ្វារមានរាប់រយដុំ ថ្មខ្លះបានបែកបាក់ និងនៅរាយប៉ាយ។ ការស្វែងរកថ្មដែលរលុះធ្លាក់ទាំងនោះបានទាល់តែមានចិត្តព្យាយាមរកឱ្យឃើញផ្នែកណាមួយជាមុនសិន ទើបមានមូលដ្ឋានស្វែងរកថ្មទៅតាមល្បាក់ជាបន្តបន្ទាប់។ លោក ព្រាន ដូរ បញ្ជាក់ថា ក្នុងចំណោមថ្មប្រាសាទដែលងាយស្រួលស្វែងរក គឺថ្មដែលមានក្បាច់។



ចំណែកលោក តប់ តង អាយុ៥៨ឆ្នាំ ជាកម្មករជំនាញស្វែងរកថ្មម្នាក់ទៀត ក៏បានលើកឡើងប្រហាក់ប្រហែលគ្នាថា ការរកថ្មសម្រាប់យកទៅជួសជុលប្រាសាទឱ្យត្រូវតាមទីតាំងដើម និងបានពេញទម្រង់ដើមឡើងវិញមានសារសំខាន់ណាស់ ដើម្បីរក្សាភាពដើមរបស់ប្រាសាទផង និងធ្វើឱ្យសំណង់រឹងមាំឡើងវិញផង។ លោក តប់ តង បង្ហាញឆន្ទៈមុតមាំថា ក្នុងនាមលោកជាអ្នកទទួលខុសត្រូវលើការងាររកថ្ម គឺលោកនឹងខិតខំប្រើជំនាញនិងទេពកោសល្យឱ្យអស់ពីកម្លាំងកាយចិត្ត ដើម្បីជួយសង្គ្រោះខ្លោងទ្វារខាងត្បូងរបស់ប្រាសាទតាព្រហ្ម ដែលកំពុងដួលបាក់បែកឱ្យឈរដូចដើមវិញនៅពេលខាងមុខ។





សូមបញ្ជាក់ថា ក្នុងចំណោមអ្នកស្រុកអង្គរដែលបានចូលរួមជួសជុលថែរក្សាប្រាសាទបុរាណកន្លងមក អ្នកខ្លះមានវង្សត្រកូលជាអ្នកជួសជុលអង្គរអស់ជាច្រើនជំនាន់មកហើយ ដោយបន្តតាំងពីជំនាន់ជីតា ដល់ឪពុក រហូតកូនៗ ហើយពួកគាត់សប្បាយចិត្ត នឹងការផ្ទេរចំណេះដឹងដល់អ្នកជំនាន់ក្រោយ ដើម្បីរួមគ្នាថែរក្សាកេរដូនតាឱ្យនៅគង់វង្សជាបន្តទៀតបន្តពីមួយជំនាន់ទៅមួយជំនាន់៕



អគ្គនាយកអាជ្ញាធរជាតិអប្សរា ទទួលជួបក្រុមការងារនៃស្ថាប័ន Smithsonianនៃសហរដ្ឋអាមេរិក

ផ្សាយនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤





នារសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៤ នៅប្រាសាទអង្គរវត្ត **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលជួបក្រុមការងារនៃស្ថាប័នSmithsonian នៃសហរដ្ឋអាមេរិកដែលមកបំពេញទស្សនកិច្ចស្វែងយល់អំពីកិច្ចការគ្រប់គ្រង ការពារ និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ។







អាជ្ញាធរជាតិអប្សរា កំពុងជួសជុលបដិមាធ្វើពីថ្មភក់មួយ នៅចំពីមុខបណ្ណាល័យខាងត្បូង នៃប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

អ្នកជំនាញអភិរក្សថ្មរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលរូបបដិមាមួយធ្វើពីថ្មភក់ ដែលស្ថិតនៅចំពីមុខបណ្ណាល័យខាងត្បូង នៃប្រាសាទភ្នំបាខែងឱ្យប្រសើរឡើងវិញ។



អ្នកជំនាញអភិរក្សថ្មនៅប្រាសាទភ្នំបាខែង លោក សយ សុការិន្ទ បានឱ្យដឹងថា រូបបដិមានោះ បានបាក់បែកធ្ងន់ធ្ងរជាច្រើនកន្លែង តាំងពីព្រះកេស ដៃសងខាង ព្រមទាំងជើងខាងស្តាំ ក៏បាក់ពាក់កណ្តាល ជាហេតុធ្វើឱ្យក្រុមអ្នកបច្ចេកទេសមិនអាចដឹងថា ជាបដិមាអ្វីច្បាស់លាស់ឡើយ។ ចំពោះពេលវេលា និងមូលហេតុដែលធ្វើឱ្យរូបបដិមានេះបាក់ធ្លាក់ យើងមិនទាន់ដឹងឱ្យប្រាកដ។

ក៏ប៉ុន្តែ ផ្អែកតាមស្លាកស្នាមស៊ីម៉ង់ត៍ដែលសេសសល់ យើងអាចដឹងថា កន្លងមក រូបបដិមានេះ ធ្លាប់មានការជួសជុលដោយសាលាបារាំងចុងបូព៌ាម្តងមកហើយ។



បច្ចុប្បន្ននេះ ក្រុមអ្នកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា កំពុងធ្វើការជួសជុលជាថ្មីម្តងទៀតជាច្រើនកន្លែងដូចជា សិក្សាអំពីគ្រឹះ ពិនិត្យមើលជើងទម្រ របស់រូប។ ជួសជុលជើងទម្រនៅផ្នែកខាងស្តាំដែលប្រេះ ដោយស្វានដាក់ស្នូលដែកអ៊ីណុកដើម្បីតភ្ជាប់ប្រអប់ជើងឡើងវិញជាដើម។ ក្នុងការជួសជួលបដិមាថ្មភក់បុរាណមួយនេះ ក្រុមអ្នកបច្ចេកទេស ក៏នឹងត្រូវធ្លាក់ថ្មថ្មីមកបំពេញជំនួសនៅតាមកន្លែងដែលបាត់៕



ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ ដំឡើងកម្រាលក្តារនៅចំណុចខឿនរួតទី២ ប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានរៀបចំដំឡើងកម្រាលក្តារនៅចំណុចខឿនរួតទី២ ទិសខាងកើតនៃប្រាសាទបាយ័ន នៅលើទីតាំងកម្រាលថ្មកក់មានសណ្ឋានមិនស្មើគ្នា។

ការដំឡើងកម្រាលក្តារនេះ ដើម្បីឱ្យភ្ញៀវទេសចរដើរឆ្លងកាត់ទស្សនាដោយសុវត្ថិភាព បញ្ចៀសនូវគ្រោះថ្នាក់ដោយយថាហេតុផ្សេងៗ៕









សូមអញ្ជើញកយកន់ទេសភាព ជុំវិញប្រាសាទភ្នំបាខែង ពេលព្រឹកព្រលឹម

ផ្សាយនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤











រូបភាពប្រចាំសប្តាហ៍៖ ថ្វីដ្បិតជាប្រាសាទតូច តែប្រាសាទធម្មនន្ទ មានក្បាច់ចម្លាក់ស្រស់ស្អាតជាច្រើន មិនចាញ់ប្រាសាទធំៗប៉ុន្មានឡើយ

ផ្សាយនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរាសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា រូបភាព Poster ដែលបានផ្សព្វផ្សាយក្នុងផេក ការពិត -Fact នេះ គឺជារូបភាពកាត់ត ក្លែងក្លាយ និងមានចេតនាញុះញុងឱ្យរើសអើងពូជសាសន៍។ អាជ្ញាធរជាតិអប្សរាសូមអំពាវនាវឱ្យសមត្ថកិច្ចធ្វើការស្រាវជ្រាវរកអ្នកដែលបានបង្កើតនូវរូបភាពកាត់តនេះ និងស្នើសុំបងប្អូនប្រជាពលរដ្ឋមេត្តាកុំនាំគ្នាចែកចាយបន្តនូវរូបភាពកាត់តក្លែងក្លាយ។ សូមអរគុណ!

https://www.facebook.com/share/ZJBqk1qKF235CbFj/?mibextid=WC7FNe

ផ្សាយនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤



សេចក្តីប្រកាសព័ត៌មាន

ផ្សាយនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់សាធារណជនទាំងអស់មេត្តា កុំចែករំលែកបន្តនូវរូបភាពកាត់ត ដែលមានចរិកលក្ខណៈអុជអាល និងជាន់ពន្លិចជាតិខ្លួនឯង។ទន្ទឹមនឹងនេះអាជ្ញាធរជាតិអប្សរានឹងសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធស្រាវជ្រាវស្វែងរកមុខអ្នកបង្កើតរូបភាពនេះឱ្យមកទទួលខុសត្រូវចំពោះមុខច្បាប់។





ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមេសា





អាជ្ញាធរជាតិអប្សរ ចុះពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដំណើរការសាងសង់លំនៅដ្ឋានជូនពលរដ្ឋរស់នៅក្នុង និងក្រៅតំបន់អង្គរ ចំនួន១៣៧ករណី

ផ្សាយនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤

ក្នុងសប្តាហ៍ទី៤ នៃខែមីនា ឆ្នាំ២០២៤ នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេសដោយពុំគិតប្រាក់កម្រៃ ក្នុងដំណើរការសាងសង់លំនៅដ្ឋាន ក៏ដូចជាសំណង់ឧបសម្ព័ន្ធផ្សេងៗទៀត ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុង និងក្រៅតំបន់រមណីយដ្ឋានអង្គរ បានចំនួន១៣៧ករណី ដូចជា:

១. ក្រុងសៀមរាប ចំនួន២៩ករណី
២. ស្រុកប្រាសាទបាគង ចំនួន២៤ករណី
៣. ស្រុកបន្ទាយស្រី ចំនួន៤១ករណី
៤. ស្រុកពួក ចំនួន១៦ករណី
៥. ស្រុកអង្គរធំ ចំនួន១៥ករណី
៦. ស្រុកស្វាយលើ ចំនួន១០ករណី
៧. ស្រុកសូទ្រនិគម ចំនួន២ករណី



អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើ រហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោលគឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕



សេចក្តីអំពាវនាវ

ផ្សាយនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០២៤



ដើម្បីត្រៀមទទួលអំណរឆ្នាំថ្មីប្រពៃណីជាតិ ដែលកាន់តែខិតចូលមកដល់ អាជ្ញាធរជាតិអប្សរាសូមធ្វើការអំពាវនាវដល់ភ្ញៀវទេសចរទាំងអស់ និងបងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងរមណីយដ្ឋានអង្គរ ជាពិសេសអាជីវករលក់ដូរគ្រប់ប្រភេទ មេត្តាចូលរួមកាត់បន្ថយការប្រើប្រាស់វាល់សារធាតុប្លាស្ទិកជាអតិបរមា និងទុកដាក់សំរាមនៃការប្រើប្រាស់ ឬលក់ដូរប្រចាំថ្ងៃតាមទីតាំងដែលបានកំណត់ជូនឱ្យបានល្អប្រសើរ។













នៅព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ អ្នកបើករ៉ឺម៉កមួយរូបឈ្មោះ ទូច ថន ភេទប្រុស រើសបានកាបូបតូចស្តាយមួយ របស់ភ្ញៀវទេសចរ និងបានប្រគល់ជូន ក្រុមការងារអាជ្ញាធរជាតិអប្សរា ព្រមទាំងកម្លាំងនគរបាលបេតិកភណ្ឌ ដែលប្រចាំការនៅប្រាសាទអង្គរវត្ត ដើម្បីទុកជូនភ្ញៀវទេសចរវិញ។

នេះជាឥរិយាបថដ៏ល្អផូរផង់ របស់ប្រជាពលរដ្ឋខ្មែរ ហើយឥរិយាបថនេះ ជាផ្នែកមួយសំខាន់ក្នុងការបង្កើនទំនុកចិត្ត ដល់ភ្ញៀវទេសចរ ក្នុងការមកកម្សាន្ត ខេត្តសៀមរាប ក៏ជូចជាកម្ពុជាទាំងមូល។

ផ្សាយនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤







នារសៀលថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរប្រចាំប្រាសាទអង្គរវត្ត បានសហការជាមួយក្រុមការងារសណ្តាប់ធ្នាប់ ជួយសម្រួលរុំ៉មកកង់បីមួយគ្រឿង ចូលដឹកភ្ញៀវទេសចរខ្មែរ ដែលមានវ័យជរា តាមផ្លូវវត្តអង្គរខាងត្បូង

ផ្សាយនៅថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៤









ឯកឧត្តមបណ្ឌិត ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ទទួលជួបពិភាក្សាការងារ ជាមួយអគ្គនាយកស្ថាប័នមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉ែ

ផ្សាយនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤នេះ នាមជ្ឈមណ្ឌលរបស់អាជ្ញាធរជាតិអប្សរា **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយក បានជួបពិភាក្សាការងារជាមួយឯកឧត្តម Na Jung Hee អគ្គនាយកស្ថាប័នមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉ែ។ គោលបំណងសំខាន់នៃជំនួបខាងលើ ដើម្បីពិភាក្សាលម្អិតទៅលើអនុស្សរណៈដែលបានចុះហត្ថលេខាកន្លងមក ដើម្បីឈានទៅអនុវត្តគម្រោងជួសជុលរួតបាកាននៃប្រាសាទអង្គរវត្ត និងផ្នែកផ្សេងទៀតនៃគម្រោង។





សូមបញ្ជាក់ថា កាលពីដើមឆ្នាំ២០២៤ថ្មីៗនេះ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយរដ្ឋបាលបេតិកភណ្ឌវប្បធម៌កូរ៉ែ (The Cultural Heritage Administration of the Republic of Korea) ទៅលើកិច្ចការងារអភិរក្ស និងជួសជុលរួតបាកាននៃប្រាសាទអង្គរវត្ត ដែលមានរយៈពេល៣ឆ្នាំ (២០២៤-២០២៦)៕









សប្តាហ៍ទី៤ នៃខែមីនា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតសំណើរសុំជួសជុលលំនៅដ្ឋានអ្នកស្រុកអង្គរ ចំនួន០៩ករណី

ផ្សាយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤

នៅកំឡុងសប្តាហ៍ទី៤ នៃខែមីនា ឆ្នាំ២០២៤កន្លងមកនេះ ក្រុមការងារបច្ចេកទេស នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកកណ្តាក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យទីតាំងស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ និងសំណង់សាធារណៈផ្សេងៗ និងអនុញ្ញាតជូនដល់ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ចំនួន០៩ករណី។ ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ទទួលបានការអនុញ្ញាតរួមមាន៖

- ស្រុកអង្គរធំ ចំនួន០២ករណី
១. លោក ជុំ ញឹក មានអាសយដ្ឋាននៅ ភូមិដូនឌី ឃុំលាងដៃ
២. លោក ខ្វែក សុខ មានអាសយដ្ឋាននៅ ភូមិដូនឌី ឃុំលាងដៃ
- ស្រុកបន្ទាយស្រី ចំនួន០៣ករណី
១. លោក ម៉ោញ ហោម មានអាសយដ្ឋាននៅ ភូមិរវៀងតាទុំ ឃុំរំចេក
២. អ្នកស្រី ឈឿន ខូន មានអាសយដ្ឋាននៅ ភូមិអូរទទឹង ឃុំព្រះដាក់
៣. លោក ប៉ុក ចាន់ធូ មានអាសយដ្ឋាននៅ ភូមិសាលាក្រវ៉ាន់ ឃុំរំចេក
- ស្រុកពួក ចំនួន២ករណី
១.អ្នកស្រី ខាត់ ណារិន មានអាសយដ្ឋាននៅ ភូមិខ្នាត ឃុំខ្នាត
២.អ្នកស្រី លុយ លីន មានអាសយដ្ឋាននៅ ភូមិអំពិលពាម ឃុំខ្នាត
- ក្រុងសៀមរាប ចំនួន១ករណី
១.អ្នកស្រី ហែម បឿយ មានអាសយដ្ឋាននៅ ភូមិបន្ទាយឈើ សង្កាត់ទឹកវិល
- ស្រុកប្រាសាទបាគង ចំនួន០១ករណី
១.អ្នកស្រី សាន សូល មានអាសយដ្ឋាននៅ ភូមិត្រាចដុំ ឃុំអំពិល

ចំពោះប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតខាងលើ ក្រុមការងារបច្ចេកទេសបានជួយរៀបចំគំនូសប្លង់ ដែលមានស្តាបត្យកម្មបែបប្រពៃណីជូនពួកគាត់ផងដែរ។ រាល់ការស្នើសុំច្បាប់ គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕





អាជ្ញាធរជាតិអប្សរាកំពុងបង្កើនការបណ្តុះកូនឈើដើម្បីទុកដាំនារដូវវស្សាខាងមុខ

ផ្សាយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤

ស្ថានីយបណ្តុះកូនឈើ៨ហិកតា ជាស្ថានីយមួយក្នុងចំណោមស្ថានីយទាំង១០ នៃអាជ្ញាធរជាតិអប្សរា។ ដូចទៅនឹងស្ថានីយដទៃទៀតដែរ ស្ថានីយនេះកំពុងបង្កើនសកម្មភាពបណ្តុះកូនឈើ ដើម្បីត្រៀមសម្រាប់ដាំនារដូវវស្សាខាងមុខ។

កញ្ញា ឆេង រុចនា អ្នកគ្រប់គ្រងស្ថានីយបណ្តុះកូនឈើ៨ហិកតា បានប្រាប់ថា ស្ថានីយនេះបណ្តុះប្រភេទឈើប្រណិត ចំនួន៤ប្រភេទ មានបេង ធ្នង់ គ្រញូង និងច្រេស។ ស្ថានីយនេះកំពុងមមាញឹកក្នុងការរៀបចំលាយដី សាបកូន បណ្តុះ និងថែទាំយ៉ាងយកចិត្តទុកដាក់ ដែលធានាថា កូនឈើទាំងអស់លូតលាស់បានល្អ។

ជាមួយគ្នានេះ បើតាមការបញ្ជាក់ពីអ្នកគ្រប់គ្រងស្ថានីយ កញ្ញា រុចនា ថា ក្នុងមួយឆ្នាំស្ថានីយអាចបណ្តុះកូនឈើបានប្រមាណ៣ម៉ឺនដើម សម្រាប់ទុកដាំក្នុងតំបន់រមណីយដ្ឋានអង្គរ ក៏ដូចជាសម្រាប់ចែកចាយទៅខាងក្រៅ។ បច្ចុប្បន្ននេះ ស្ថានីយមានកូនឈើសរុបប្រមាណ៦ម៉ឺនដើម គឺរាប់ចាប់ពីទើបបាចសាបក្នុងថ្នាល និងរហូតកូនឈើមានកម្ពស់២ម៉ែត្រ។

ក្នុងនាមអ្នកស្រឡាញ់បរិស្ថានមួយរូប កញ្ញា រុចនា សូមឱ្យសាធារណជនទូទៅ ជួយរួមគ្នាដាំកូនឈើ ឱ្យបានកាន់តែច្រើន ស្របពេលដែលពិភពលោកមានបម្រែបម្រួលអាកាសធាតុព្រោះថាការងារនេះ នឹងជួយបង្កើនគម្របព្រៃឈើ និងបង្កើតបរិយាកាសឱ្យបានកាន់តែល្អប្រសើរ។ បន្ថែមពីនេះ សូមសាធារណជន ជួយចូលរួមជាមួយអាជ្ញាធរជាតិអប្សរា ដាំកូនឈើដែលផ្តល់ជូនដោយឥតគិតថ្លៃ ឱ្យបានកាន់តែច្រើន។





សារលិខិតអបអរសាទរ របស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំនៃអាជ្ញាធរជាតិអប្សរា សូមគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ក្នុងឱកាសដែលសម្តេចតេជោ ត្រូវបានព្រឹទ្ធសភាបោះឆ្នោតគាំទ្រជ្រើសរើស ជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ នីតិកាលទី៥ ដោយមានសំឡេងគាំទ្រចំនួន៦២សំឡេងនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល នាថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤ ក្នុងសម័យប្រជុំដំបូងនៃនីតិកាលទី៥ របស់ព្រឹទ្ធសភា

ផ្សាយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សិរីមង្គលអបអរសាទរ

សូមគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា





អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលក្រុងសៀមរាប អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន សៀមរាប បើកយុទ្ធនាការសម្អាតសំរាមក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤





ប្រជាពលរដ្ឋទាំងអស់ ចូលរួមកាត់បន្ថយការប្រើប្រាស់សារធាតុប្លាស្ទិកជាអតិបរមា និងទុកដាក់សំរាមឱ្យបានល្អនៅក្នុងរមណីយដ្ឋានអង្គរ នាព្រឹកថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤នេះ អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងបងប្អូនប្រជាពលរដ្ឋប្រមាណ៣០០នាក់ បានចុះយុទ្ធនាការសម្អាតសំរាមនៅភូមិត្រពាំងសេស និងនៅតាមដងផ្លូវពីមុខប្រាសាទអង្គរវត្តទៅព្រលានយន្តហោះចាស់។ សកម្មភាពដ៏ល្អនេះ ពិតជាគំរូ និងបានឆ្លុះបញ្ចាំងពីការចូលរួមចំណែកយ៉ាងថ្លៃថ្លាពីមហាជនក្នុងការកាត់បន្ថយសំរាម ការទុកដាក់សំរាម និងការគ្រប់គ្រងសំរាមបានល្អ ដែលធ្វើឱ្យរមណីយដ្ឋានអង្គរ និងក្រុងសៀមរាបទាំងមូលកាន់តែស្អាត និងមានភាពទាក់ទាញបន្ថែមទៀត ហើយលើកកម្ពស់សុខភាពឱ្យកាន់តែល្អប្រសើរ។

អាជ្ញាធរជាតិអប្សរា សូមថ្លែងអំណរគុណដល់សាលាក្រុងសៀមរាប អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលបានចូលរួមសកម្មភាពសម្អាតសំរាមនៅក្នុងរមណីយដ្ឋានអង្គរ និងរួមចំណែកថែរក្សា លើកតម្លៃដល់សម្បត្តិបេតិកភណ្ឌជាតិ និងបង្ហាញពីការរស់នៅប្រកបដោយភាពថ្លៃថ្នូរនៃសង្គមជាតិយើង។









រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទលលៃ សំណង់ឥដ្ឋដ៏ល្អឯកមួយក្នុងចំណោម សំណង់ប្រាសាទជាច្រើនទៀតនៅក្នុងតំបន់រលួស

ផ្សាយនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៤





ក្រុមភ្នាក់ងារទេសចរ ជួយសង្គ្រោះភ្ញៀវទេសចរនៅតាមប្រាសាទ

ផ្សាយនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៤

នាព្រឹកថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៤នេះ ក្រុមភ្នាក់ងារទេសចរ សហការជាមួយភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំប្រាសាទអង្គរវត្ត បានជួយសង្គ្រោះបឋមដល់ទេសចរជនជាតិអឺរ៉ុបម្នាក់ ដែលក្រេចជើងដើរមិនរួច ដើម្បីនាំគាត់ទៅសម្រាកនៅសណ្ឋាគារ។

មួយករណីទៀតគឺនៅប្រាសាទតាព្រហ្ម ក្រុមភ្នាក់ងារទេសចរ បានជួយសង្គ្រោះបឋមដល់ទេសចរអឺរ៉ុបម្នាក់ ដែលមានអាការៈមិនស្រួលខ្លួននៅចំណុចតួរប៉មកណ្តាល និងរហូតដល់គាត់មានអាការៈធម្មតាវិញ៕







រូបភាពប្រចាំសប្តាហ៍÷ ប្រាសាទតានែ ទីតាំងបុរាណដ្ឋាន ដែលទេសចរនាគច្រើនទៅហួសមកហួស

ផ្សាយនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៤











អាជ្ញាធរជាតិអប្សរា បន្តរៀបចំកៅអីឈើ នៅក្រោមម្លប់ឈើតាមបរិវេណ ប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤





ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ នៃអាជ្ញាធរជាតិអប្សរា បានបន្តរៀបចំកៅអីឈើបន្ថែមទៀត ក្រោមម្លប់ឈើដ៏ត្រឈឹងត្រឈៃនៅតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។

លោក ប៊ូ ផានេត ប្រធានក្រុមការងាររៀបចំ បានឱ្យដឹងថា ដោយកំណើនភ្ញៀវទេសចរចូលចិត្តអង្គុយសម្រាក ក្រោមម្លប់ឈើ កំឡុងពេលទស្សនាប្រាសាទនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ពិសេសនៅក្នុងរដូវក្តៅនេះផង ទើប អាជ្ញាធរជាតិអប្សរា បានរៀបចំកៅអីឈើបន្ថែមក្រោមម្លប់ឈើត្រឈឹងត្រឈៃនៅតាមបរិវេណប្រាសាទនានា ក្នុងគោលបំណងជួយសម្រួលឱ្យភ្ញៀវទេសចរ ដែលដើរចេញឬចូលទស្សនា អាចអង្គុយសម្រាកពីការនឿយហត់។



លោក ប៊ូ ផានេត បន្តថា ទេសចរអាចអង្គុយគយគន់ទេសភាពប្រាសាទនៅក្រោមម្លប់ឈើ ពិសេសជួយសម្រួលដល់ភ្ញៀវទេសចរដែលមានវ័យចំណាស់។ មានកន្លែងអង្គុយសម្រាកនៅពេលរដូវក្តៅ អាចកាត់បន្ថយជំងឺខ្យល់គរ និងជំងឺផ្លូវដង្ហើម។ កាត់បន្ថយការឈប់សម្រាកនៅក្នុងប្រាសាទដែលនាំឱ្យកកស្ទះ ឬអង្គុយលើថ្មជាដើម។ ជាពិសេសនៅពេលចូលឆ្នាំខាងមុខមានភ្ញៀវជាតិ និងអន្តរជាតិច្រើន មានកន្លែងអង្គុយសម្រាកសម្រាប់ភ្ញៀវទេសចរចូលទស្សនាប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរ៕





ក្រុមការងារភ្លាក់ងារទេសចរ ប្រចាំគោលដៅប្រាសាទអង្គរវត្ត បានសម្អាតធាងត្លោតនៅក្នុងបរិវេណ ប្រាសាទអង្គរ ជែលងាប់ និងធ្លាក់សំយាក ដើម្បីបង្ការការធ្លាក់ជាយថាហេតុ និង កុំឱ្យបាំងសម្រស់ទេសភាពនៃប្រាសាទ ធ្វើឱ្យភ្ឿៀវទេសចរជាតិ និងអន្តរជាតិ អាចគយគន់ទេសភាព និងថតផ្តិតរូបភាព ប្រាសាទអង្គរវត្តបានកាន់តែស្រស់ស្អាត បន្ថែមទៀត

ផ្សាយនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤







ក្រុមការងារសម្អាតបានធ្វើការសម្អាតសារាយនៅក្នុងស្រះទឹកខាងត្បូងនៃប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរាប្រារព្ធពិធីសូត្រមន្តចម្រើនសិរីសួស្តី អបអរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

ផ្សាយនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤





នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា ប្រារព្ធពិធីសូត្រមន្តបង្សុកូល និងប្រគេនទេយ្យទានដល់ព្រះសង្ឃ។ ពិធីនេះបានរៀបចំឡើង នាពេលរសៀលថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៤ ក្រោមព្រះអធិបតីភាព **សម្តេចព្រះព្រហ្មរតនមុនី ពិន សែម សិរីសុវណ្ណោ** ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក និងជាសមាជិកថេរសភាព្រះពុទ្ធសាសនានៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយក អគ្គនាយករង ប្រធាន អនុប្រធាន នាយកដ្ឋាន និងមន្ត្រី បុគ្គលិកទាំងអស់នៃអាជ្ញាធរជាតិអប្សរា។

ពិធីដ៏មង្គលនេះ បានប្រារព្ធធ្វើឡើងដើម្បីលើកសិរីសួស្តីដល់ថ្នាក់ដឹកនាំ រួមទាំងមន្ត្រី បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ដែលនឹងចូលមកដល់នៅថ្ងៃសៅរ៍ ៥កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤ ខាងមុខនេះ។ ជាពិសេស ក៏ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់អតីតថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា អ្នកជំនាញការជាតិ-អន្តរជាតិ ដែលបានមរណភាពក្នុងបុព្វហេតុបម្រើអង្គរ រួមទាំងញាតិការដែលបានចែកឋានទៅកាន់បរលោក៕





ក្នុងសប្តាហ៍ទី១ នៃខែមេសា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា បានបន្តចុះពិនិត្យទីតាំងស្នើសុំជួសជុល និងសាងសង់តូចតាចរបស់ប្រជាពលរដ្ឋអ្នកស្រុកអង្គរ សរុបចំនួន៤៩ករណី

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤

កំឡុងសប្តាហ៍ទី១(ថ្ងៃទី០១ ដល់ ថ្ងៃទី០៥) នៃខែមេសា ក្រុមការងារសហគមន៍ នៃនាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍៖ បានបន្តចុះពិនិត្យទីតាំងស្នើសុំជួសជុល និងសាងសង់តូចតាច របស់ប្រជាពលរដ្ឋអ្នកស្រុកអង្គរ រស់នៅតាមក្រុង/ស្រុកទាំង៥ សរុបចំនួន៤៩ ករណី។ ដោយក្រុមការងារបានសម្រេចអនុញ្ញាតជួសជុលដូចជា៖ ប្តូរដំបូលផ្ទះ ប្តូរសសរពុកផុយមួយចំនួន ប្តូរជញ្ជាំងធ្លុះធ្លាយ និងសាងសង់តូចតាចដូចជា៖ ទ្រុងមាន់រោងគោ បង្គន់អនាម័យ និងទ្រុងជ្រូកជាដើម៖ ព្រោះថាជាទីតាំងដែល មានមនុស្ស រស់នៅជាប្រចាំថ្ងៃ និងមានតំរូវការចាំបាច់។



ចំពោះប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតខាងលើ ក្រុមការងារបច្ចេកទេសបានជួយរៀបចំគំនូសប្លង់ ដែលមានស្ថាបត្យកម្មបែបប្រពៃណីជូនពួកគាត់ផងដែរ។ រាល់ការស្នើសុំច្បាប់ គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឲ្យ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា។



សារលិខិតជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ ពលករ ឆ្នាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤





សារលិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤





សារលិខិតជូនពរ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤





សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤





សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤



ស្រាលិខិតថ្វាយព្រះពរ
សូមក្រាបបង្គំទូលថ្វាយ
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងឱកាសដ៏មហាទក្ខត្តឬក្សនៃថ្ងៃចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ
ដែលនឹងឈានមកដល់នៅថ្ងៃសៅរ៍ ៥រោត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧
ត្រូវនឹងថ្ងៃទី ១៣ ខែមេសា ត.ស ២០២៤

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមអភិវន្ទលើកហត្ថប្រណម្យបូងសូងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដូងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរត្រប់ព្រះអង្គ ជាពិសេសឬទ្ធិបារមីនៃដូងព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំ ព្រះសព្វសាធុការពរជ័យត្រប់ប្រការ ថ្វាយចំពោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចម៉ែ សូមព្រះអង្គទាំងទ្វេទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លៀតឡើយ ដើម្បីតង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុរាស្ត្រខ្មែរ ជានិច្ចនិរន្តរ៍ ។

សូមក្រាបថ្វាយបង្គំទូលថ្វាយពី
ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា
ព្រមនាំងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ត្នាក់ការ ពលករ និងឆ្នាំនាំងអស់



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ២៨៩/ ៨៩.លម៉ា
/ ២៤

ស្រាលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

ចពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្តារៈដ៏ខ្ពង់ខ្ពស់បំផុត!

ក្នុងឱកាសដ៏ទក្ខត្តឬក្សថ្ងៃថ្លានៃឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤ ខាងមុខនេះ ទូលព្រះបង្គំ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ក្នាក់ងារ ពលករ និងឆ្នាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត សម្តែងថ្វាយនូវកតញ្ញាតតវទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះមហាករុណាទិគុណ និងព្រះព្រហ្មវិហារធម៌របស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ក្នុងព្រះបរមនាមជាអង្គព្រះមហាក្សត្រ ប្រកបដោយទសពិធរាជធម៌ និងព្រះរាជតម្រិះតតិបណ្ឌិតដ៏ឈ្លាសវៃ ដែលព្រះអង្គតែងតែយកព្រះទ័យទុកដាក់អស់ពីកម្លាំងព្រះកាយពល និងព្រះបញ្ញាញាណបំពេញព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម បម្រើជាតិមាតុភូមិ និងប្រជារាស្ត្រជាទីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះអង្គ នៅត្រប់កាលៈទេសៈ។ ទន្ទឹមនឹងនេះ ទូលព្រះបង្គំយើងខ្ញុំសូមក្រាបបង្គំអភិវន្ទសម្តែងថ្វាយព្រះសព្វសាធុការពរជ័យ បវរសូស្តី សិរីវិឌ្ឍនា វិបុលសុខមហាប្រសើរត្រប់យ៉ាង ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចម៉ែ** សូមព្រះអង្គទាំងទ្វេទ្រង់ប្រកបដោយព្រះកាយពលរឹងមាំខ្ជាំងក្លា ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះបញ្ញាញាណក្ខីជ្ជាត្រចះត្រចង់ ព្រះជន្មាយុយឹនយូរជាងរយព្រះវស្សា ចាកផុតពីព្រះរោគាព្យាធិនានា ដើម្បីព្រះអង្គទ្រង់គង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ត្រជាក់ត្រជុំ សម្បូរសប្បាយ ថ្ពុំថ្ពៃងរុងរឿងរបស់ប្រជាពស្ត្ររបស់ព្រះអង្គ និងមាតុភូមិអង្គរជាទីស្នេហា។

ជាថ្មីម្តងទៀត ទូលព្រះបង្គំយើងខ្ញុំ សូមអភិវន្ទលើកហត្ថប្រណម្យបូងសូងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដូងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរត្រប់ព្រះអង្គ ជាពិសេសឬទ្ធិបារមីនៃដូងព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ និងទេវតាឆ្នាំថ្មី **ឆ្នាំរោង** ព្រះនាម មហោទរាទៀ សូមតាមជួយបីបាច់ថែរក្សាអភិបាលប្រោះព្រំ ព្រះសព្វសាធុការពរជ័យត្រប់ប្រការ ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចម៉ែ** សូមព្រះអង្គទាំងទ្វេទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាំតឡើយ ដើម្បីតង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជាពស្ត្រខ្មែរ ជានិច្ចនិរន្តរ៍។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្តារៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តា ទទួលនូវតាវកិច្ចភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្តារៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាប្រោស។

ថ្ងៃ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សូមក្រាបបង្គំទូលថ្វាយ [illegible] ១១ ខែ [illegible] ឆ្នាំ២០២៤
[illegible]

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាំង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរជាតិអប្សរា
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Koeng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ក្រុមការងារសម្ពាតបរិស្ថាន របស់អាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់សម្ពាតបរិស្ថាន នៅតាមបរិវេណប្រាសាទនានា និងទីតាំងផ្សេងៗនៅក្នុងរមណីយដ្ឋានអង្គរ ពិសេសសំរាមស្លឹកឈើនៅរដូវប្រាំង ដើម្បីលើកតម្លៃរមណីយដ្ឋានអង្គរ កាន់តែល្អប្រសើរគ្រប់ពេលវេលា

ផ្សាយនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤













បើទោះបីជារដូវប្រាំងក៏ស្មៅនៅមុខប្រាសាទអង្គរវត្តនៅតែមានពណ៌បៃតង

ផ្សាយនៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤

រដូវប្រាំងចូលមកដល់ បានធ្វើឱ្យស្មៅនិងរុក្ខជាតិមួយចំនួនក្រៀមស្វិតស្រពោននៅក្នុងតំបន់រមណីយដ្ឋានអង្គរ ប៉ុន្តែទោះជាយ៉ាងណា ក៏អាជ្ញាធរជាតិអប្សរាបានប្រឹងប្រែងថែទាំស្រោចស្រពស្មៅនៅតាមសួនកសិន្ទុប្រាសាទអង្គរវត្ត ឱ្យនៅតែមានពណ៌បៃតង។ ក្នុងនោះដែរ ចំពោះវាលស្មៅនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ក៏អាជ្ញាធរជាតិអប្សរាបានរៀបចំប្រព័ន្ធស្រោចស្រពវាលស្មៅទាំងនោះផងដែរ។

សូមបញ្ជាក់ថា សកម្មភាពដាំ និងថែទាំស្មៅមិនត្រឹមតែរៀបចំធ្វើនៅបរិវេណមុខប្រាសាទអង្គរវត្តប៉ុណ្ណោះទេ តែសកម្មភាពទាំងនេះ បានធ្វើនៅតាមប្រាសាទមួយចំនួនទៀតដូចជា ព្រះលានដល់ដំរី ប្រាសាទបាយ័ន្ត ប្រាសាទបន្ទាយក្តី ប្រាសាទតាព្រហ្ម និងទីកន្លែងជាច្រើនទៀតធ្វើយ៉ាងណាឱ្យរមណីយដ្ឋានអង្គរមានភាពបៃតងស្រស់ស្អាតទាំងខួបប្រាំង និងវស្សា៕





សួស្តីឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទប្រែរូប សំណង់ឥដ្ឋដ៏ធំស្កឹមស្កៃក្នុងសម័យអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤







សេចក្តីជូនដំណឹង ស្តីពីការជកហូតដើមឈើ និងកាត់ក្រីមែកឈើ មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៤



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៤២៧/ឧប.សដណ
២៤

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ជកហូតដើមឈើនិងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ជៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ជៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយ អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ក្រីដើមឈើចំនួន១៥ដើម (ស្គង់៦ដើម ចាន់១ដើម ស្នាយ១ដើម ចាមរី១ដើម ខ្នុរ២ដើម ឈើទាល៣ដើម ត្រាង១ដើម) ស្ថិតនៅបរិវេណប្រាសាទព្រះខ័ន។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន៣០ដើម (កាត់ដកហូតឈើទាល១ដើម និងខ្នារ១ដើម កាត់ក្រីចុងឈើទាល១៥ដើម ឈើទាល៩ដើម ចាមរី១ដើម ស្នាយ១ដើម គគីរ២ដើម) ស្ថិតនៅបរិវេណអភិរក្សដ្ឋានអង្គរ។
- កាត់ដកហូតដើមឈើចំនួន២ដើម (មៀនរស់១ដើម និងដើមអង្កាញ់ងាប់១ដើម) ស្ថិតនៅបរិវេណវត្តទេពប្រណម។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន២២ដើម (កាត់ដកហូតពភ្លា២ដើម ត្រាង១ដើម សង្កែ១ដើម ស្នូល១ដើម ស្នាយ១ដើម អំពិល១ដើម និងកាត់ក្រីត្រាង៤ដើម ស្គង់២ដើម ល្វា២ដើម អង្កោល២ដើម ល្ឿង១ដើម ម្ពេញព្រៃ២ដើម ចំបក់១ដើម បេង១ដើម) ស្ថិតនៅបរិវេណប្រាសាទបេងមាលា និងប្រាសាទកន្សែង។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១០ដើម (កាត់ដកហូតល្វា១ដើម ល្ឿង១ដើម កន្សែង១ដើម ជន្លូស១ដើម ដកព១ដើម ពភ្លា១ដើម បេង១ដើម កាត់ក្រីក្រឡាញ់១ដើម បេង១ដើម និងស្រឡៅ១ដើម) ស្ថិតនៅបរិវេណប្រាសាទជ្រៃ។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន១២ដើម (កាត់ដកហូតក្រឡាញ់៤ដើម ឈើទាល១ដើម រំដួល១ដើម ត្រយឹង១ដើម ត្រាងដំរី១ដើម ត្រៀក១ដើម ជន្លូស១ដើម កាត់ក្រីក្រឡាញ់១ដើម និងស្រឡៅ១ដើម) ស្ថិតនៅបរិវេណប្រាសាទគងភ្នុក។
- កាត់ដកហូតដើមឈើទាល១ដើម ស្ថិតនៅបរិវេណមុខខាងជើងប្រាសាទបាយ័ន។
- កាត់ដកហូតដើមឈើទាលងាប់១ដើម ស្ថិតនៅខាងជើងទន្លេសូតជិតដល់ទ្វារទឹកខាងលើអូរខ្លូត។
- កាត់ដកហូត និងកាត់ក្រីដើមឈើចំនួន៩ដើម (កាត់ដកហូតពភ្លា៣ដើម ស្នាយព្រៃ១ដើម កន្សែង១ដើម ស្នាយ១ដើម ស្រឡៅ១ដើម ស្នាយគគីត១ដើម កាត់ក្រីខ្នុរព្រៃ១ដើម) ស្ថិតនៅបរិវេណប្រាសាទតានៃ។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើ ចាប់ពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ រហូតដល់ចប់ភ្លាវកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ជៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ៤ កើត ខែ ចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ១០ ខែ ៣ ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាត់ ឃុំអំពិល
ស្រុកប្រាសាទបាគង៍ រាជធានីសៀមរាប

អាជ្ញាធរដើម្បីការពារមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province





រូបភាពប្រចាំសប្តាហ៍ ប្រាសាទព្រះខ័ន ស្ថាបត្យកម្មសំណង់ជ៏អស្ចារ្យ ដែលភ្ជៀវទេសចរ ទាំងអស់អាចទៅទស្សនា រឺថតរូបទុកជាអនុស្សាវរីយ៍ ជាមួយក្បាច់ចម្លាក់ល្អឯក

ផ្សាយនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៤











សប្តាហ៍ទី២ នៃខែមេសា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា បានអនុញ្ញាតសំណើរសុំជួសជុលលំនៅដ្ឋានអ្នកស្រុកអង្គរចំនួន ៥០ករណី

ផ្សាយនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤

នៅសប្តាហ៍ទី២ នៃខែមេសា (ពីថ្ងៃទី៨ ដល់ថ្ងៃទី១២ ខែមេសា) ក្រុមការងារសហគមន៍ នៃនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ បានបន្តចុះពិនិត្យទីតាំងស្នើសុំជួសជុល និងសាងសង់តូចតាចរបស់ប្រជាពលរដ្ឋនៅ៥ស្រុក/ក្រុង សរុប៥០ ករណី។ ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ទទួលបានការអនុញ្ញាតរួមមាន៖

- ស្រុកប្រាសាទបាគង អនុញ្ញាតបានចំនួន៤ករណី
- ស្រុកអង្គរធំអនុញ្ញាតបានចំនួន ៥ ករណី
- ស្រុកពួកអនុញ្ញាតបានចំនួន១៦ករណី
- ក្រុងសៀមរាបអនុញ្ញាតបានចំនួន១៥ ករណី
- ស្រុកបន្ទាយស្រីអនុញ្ញាតបានចំនួន១០ករណី

ចំពោះប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតខាងលើ ក្រុមការងារបច្ចេកទេសបានជួយរៀបចំគំនូសប្លង់ ដែលមានស្តាបត្យកម្មបែបប្រពៃណីជូនពួកគាត់ផងដែរ។ រាល់ការស្នើសុំច្បាប់ គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឱ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕







រូបភាពប្រចាំសប្តាហ៍÷ ទិដ្ឋភាពនៅក្នុងបរិវេណ អតីតព្រះបរមរាជវាំង ក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤













ប្រជាពលរដ្ឋមកពីស្រុកព្រៃកប្បាស ខេត្តតាកែវ សប្បាយរីករាយ ក្រោយបានឃើញសារមន្ទីរតាំងបង្ហាញផលិតផលជាស្នាដៃរបស់គាត់បានបរិច្ចាគមក

ផ្សាយនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៤



នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ មានបងប្អូនប្រជាពលរដ្ឋ បានធ្វើដំណើរពីស្រុកព្រៃកប្បាស ខេត្តតាកែវមកកម្សាន្តក្នុងខេត្តសៀមរាប ក្នុងឱកាសនោះ ពួកគាត់ក៏បានចូលមកកាន់សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ក្រុងសៀមរាប ដើម្បីទស្សនាសំពត់ហូលជាស្នាដៃរបស់ខ្លួន ដែលធ្លាប់បានបរិច្ចាគជូនមកកាន់សារមន្ទីរ។



អ្នកស្រី លី ណៃស្រ៊ីម និងអ្នកស្រី លី ស្រីមុំ ជាបងប្អូនបង្កើតនិងគ្នា រួមទាំងក្រុមគ្រួសារ មានទីលំនៅក្នុងស្រុកព្រៃកប្បាសខេត្តតាកែវបានធ្វើដំណើរមកកាន់ខេត្តសៀមរាប គោលបំណងសំខាន់ចង់ឃើញការដាក់តាំងបង្ហាញរបស់សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ីនូវស្នាដៃសំពត់ហូលជាមួង ជាស្នាដៃរបស់គាត់បានត្បាញដោយផ្ទាល់ដៃដោយទឹកចិត្តស្រឡាញ់ ចង់ថែរក្សាស្នាដៃកម្រទាំងនោះកុំឱ្យបាត់បង់ ទើបអ្នកស្រីសម្រេចចិត្តប្រគល់សមុច្ច័យទាំងនោះ មកកាន់សារមន្ទីរដើម្បីថែរក្សា និងអភិរក្សបន្តទុកឱ្យកូនចៅជំនាន់ក្រោយ។





អ្នកស្រី លី ណៃស្រីម បានបង្ហាញអារម្មណ៍រំភើបយ៉ាងក្រៃលែង ក្រោយពេលបានចូលមកទស្សនាសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី បានឃើញសំពត់ហូលរបស់អ្នកស្រីធ្លាប់ត្បាញដោយផ្ទាល់ដៃ ក្នុងសម័យលន់ណុលជាហូលក្បាច់គោមបាត់ដំបង ដោយប្រជុំយជីវិតលាក់ទុកក្នុងខ្នើយកើយកាលពីសម័យប៉ុលពត មកដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរជូនភ្ញៀវជាតិ អន្តរជាតិ ជាពិសេសកូនខ្មែរជំនាន់ក្រោយ បានឃើញ និងសិក្សាឈ្វេងយល់បន្ត។



សូមជម្រាបថា កាលពីឆ្នាំ២០២៣ បងប្អូនប្រជាពលរដ្ឋចំនួន២១គ្រួសារ រស់នៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ បានស្ម័គ្រចិត្តប្រគល់ក្រណាត់ហូល សំពត់ហូល អាវហូល និងសរសៃសូត្រគាធ ជូនមកកាន់សារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី ដោយសំពត់ហូលខ្លះមានអាយុកាលយូរឆ្នាំ ដោយខ្លះមានអាយុប្រមាណពី៤០ រហូតដល់៦០ឆ្នាំ ត្បាញឡើងដោយដៃ ជ្រលក់ល័ក្ខធម្មជាតិតាមក្បួនខ្នាតពីបុរាណ និងមានក្បាច់រចនាផ្សេងៗគ្នា យ៉ាងស្រស់ស្អាត៕

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទព្រៃមន្ទីរ សំណង់ឥដ្ឋមួយផ្សេងទៀត ស្ថិតក្នុងតំបន់រលួស ដែលមានអាយុកាលជាង១០០០ឆ្នាំ

ផ្សាយនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៤













ក្នុងសប្តាហ៍ទី៣ នៃខែមេសា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា បានបន្តចុះពិនិត្យទីតាំងស្នើសុំជួសជុល និងសាងសង់តូចតាចរបស់ប្រជាពលរដ្ឋអ្នកស្រុកអន្លង់ សរុបចំនួន១៤ករណី

ផ្សាយនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤

សប្តាហ៍ទី៣ នៃខែមេសា ឆ្នាំ២០២៤នេះ ក្រុមការងារបច្ចេកទេស នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យទីតាំងស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ និងសំណង់សាធារណៈផ្សេងៗ និងអនុញ្ញាតជូនដល់ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ចំនួន១៤ករណី។ ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ទទួលបានការអនុញ្ញាតរួមមាន៖

- ស្រុកពួកអនុញ្ញាតបាន ចំនួន ០៩ករណី
- ក្រុងសៀមរាបអនុញ្ញាតបានចំនួន ០៥ករណី

ចំពោះប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតខាងលើ ក្រុមការងារបច្ចេកទេសបានជួយរៀបចំគំនូសប្លង់ ដែលមានស្តាបត្យកម្មបែបប្រពៃណីជូនពួកគាត់ផងដែរ។ រាល់ការស្នើសុំច្បាប់ គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕





ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ចូលរួមកម្មវិធីសម្តែងក្បាច់គុនល្បុក្កតោ និងក្បាច់គុនសាវលីញ

ផ្សាយនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤នេះ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអញ្ជើញចូលរួមក្នុងកម្មវិធីសម្តែងក្បាច់គុនសាវលីញ និងក្បាច់គុនល្បុក្កតោនៅអង្គរ (When Shaolin Meets Bokator at Angkor) នៃយុទ្ធនាការ "ឆ្នាំនៃការផ្លាស់ប្តូរប្រជាជននិងប្រជាជនកម្ពុជា-ចិន២០២៤" ដែលរៀបចំនៅ





បរិវេណខាងជើងប្រាសាទបាយ័ន។ ព្រឹត្តិការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលទាំងពីរ ពិសេសតាមរយៈក្រសួងទេសចរណ៍កម្ពុជា និងរដ្ឋបាលខេត្តហឺណានក្នុងការពង្រឹង និងពង្រីកចំណងមិត្តភាពកម្ពុជា-ចិន ស្របតាមស្មារតី «មិត្តដែកថែប និងសហគមន៍វាសនារួមកម្ពុជា-ចិន ប្រកបដោយភាពស៊ីជម្រៅ និងភាពជាក់ស្តែង ក៏ដូចជាក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការត្បូងពេជ្ររវាងកម្ពុជា-ចិន ដែលផ្តោតលើវិស័យអាទិភាពចំនួន៦ ក្នុងនោះរួមបញ្ចូលទាំងការផ្លាស់ប្តូរប្រជាជន និងប្រជាជន។

សូមបញ្ជាក់ថា ក្នុងពិធីនេះដែរមានការអញ្ជើញចូលរួមពីតំណាងរដ្ឋបាលខេត្តសៀមរាប, ឯកឧត្តម HE XIONG អភិបាលក្រុងចឹងចូវនៃខេត្តហឺណាន និង**ឯកឧត្តម សុខ សូភេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍។ ក្រៅពីនោះក៏មានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីរាជការ និងប្រជាពលរដ្ឋសរុបប្រមាណមួយពាន់នាក់៕







ក្នុងសប្តាហ៍ទី៣ នៃខែមេសា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា បានបន្តចុះពិនិត្យទីតាំងស្នើសុំជួសជុល និងសាងសង់តូចតាចរបស់ប្រជាពលរដ្ឋអ្នកស្រុកអន្តរ សរុបចំនួន១២៤ករណី

ផ្សាយនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤



ក្នុងសប្តាហ៍ទី៣ ដោយចាប់ពីថ្ងៃ១៥ ដល់ថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៤កន្លងទៅ ក្រុមការងារបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យទីតាំងស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ សំណង់សាធារណៈផ្សេងៗ និងបានអនុញ្ញាតជូនដល់ប្រជាពលរដ្ឋ ដែលជាអ្នកស្រុកចាស់ បានសរុបចំនួន១២៤ករណី ក្នុងនោះអនុញ្ញាតដោយច្បាប់ធំ ចំនួន៣១ករណី និងអនុញ្ញាតដោយក្រុមការងារសហគមន៍ចំនួន៩៣ករណី។ ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ទទួលបានការអនុញ្ញាតរួមមាន៖

១. ក្រុងសៀមរាប ចំនួន៥៦ករណី
២. ស្រុកប្រាសាទបាគង ចំនួន១៥ករណី
៣. ស្រុកបន្ទាយស្រី ចំនួន២៦ករណី
៤. ស្រុកពួក ចំនួន១៣ករណី
៥. ស្រុកអង្គរធំ ចំនួន១៤ករណី

សូមបញ្ជាក់ផងដែរថា ក្នុងចំណោម ១២៤ករណី មាន៦៧ករណី បានសាងសង់ត្រឹមត្រូវតាមការអនុញ្ញាត និង ៥៦ករណី មិនទាន់សាងសង់នៅឡើយ។ ក្នុងនោះមានករណីសាងសង់ពុំត្រឹមត្រូវ តាមការអនុញ្ញាត ចំនួន ០១ករណី គឺ អ្នកស្រី លួស វាន នៅភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប។

ចំពោះករណីដែលប្រជាពលរដ្ឋសាងសង់ពុំត្រឹមត្រូវ តាមការអនុញ្ញាតក្រុមការងារបានពន្យល់ និងណែនាំឱ្យពួកគាត់កែប្រែឡើងវិញទៅតាមខ្លឹមសារ នៃការអនុញ្ញាត និងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយនឹងអាជ្ញាធរជាតិអប្សរា៕







វឌ្ឍនភាពការងារជួសជុលប្រាសាទជាម

ផ្សាយនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤



ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) តាមរយៈមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KCHF) កំពុងជួសជុលពង្រឹងគ្រឹះប្រាសាទជាម តាមបច្ចេកទេសអាណាស្ទីឡូសឱ្យមានភាពប្រសើរឡើងវិញ។



ស្ថាបត្យករកូរ៉េ ដែលកំពុងអនុវត្តគម្រោងជួសជុលប្រាសាទជាម លោក EO JINKYU ឱ្យដឹងថា នេះគឺជាដំណាក់កាលនៃការត្រូវពង្រឹងគ្រឹះនៃប្រាសាទ ដែលត្រូវរៀបខឿនទាំងបីស្រទាប់របស់ប្រាសាទឡើងវិញជាមុនសិន បន្ទាប់មក ទើបអាចរៀបចំផ្នែកខាងក្នុងនៃគ្រឹះ។ ក្នុងការរៀបចំគ្រឹះនេះ សម្រាប់កន្លែងណាដែលមានថ្មបាយក្រៀមចាស់ ដែលនៅល្អមានគុណភាពរឹងមាំ គឺត្រូវរក្សាទុកដដែល ប៉ុន្តែ សម្រាប់កន្លែងដែលមានថ្មបាយក្រៀមពុកផុយ អស់គុណភាព គឺត្រូវប្តូរជំនួសដោយថ្មបាយក្រៀមថ្មី។





លោក EO JINKYU ឱ្យដឹងទៀតថា ការជួសជុលប្រាសាទជម មានបញ្ហាលំបាកច្រើន ដោយសារស្ថានភាពប្រាសាទខូចខាតធ្ងន់ធ្ងរ ដូចជា ថ្មមានការខូចខាតច្រើន ទាមទារឱ្យជួសជុលឡើងវិញ។ ថ្មខ្លះជាប្រភេទថ្មប្រើប្រាស់ឡើងវិញដែលដូនតាបានយកពីប្រាសាទផ្សេងៗ ធ្វើឱ្យពិបាករកថ្មផ្គុំឡើងវិញ និងការពិបាកកំណត់ទីតាំងដើមនៃថ្មជាដើម។



បើទោះបីជាយ៉ាងណាក្តី ក្នុងរយៈពេល៧ខែចុងក្រោយនេះ ក្រុមការងារបានខិតខំប្រឹងប្រែងដំឡើងគ្រឹះថ្មីរបស់ប្រាសាទជមបាន៨០ភាគរយ ជួសជុលថ្មដែលខូចគុណភាព សម្រង់ប្លង់ថ្មនីមួយៗ បានផ្គុំហោជាង និងកំពូលផ្កាឈូកចេញជារូបរាង ឡើងវិញបានមួយចំនួន និងបានបញ្ចប់គូសប្លង់ រូបភាពទាំងបួនទិសហើយ។គម្រោងជួសជុលប្រាសាទជម បានចាប់ផ្តើមតាំងពីឆ្នាំ២០១៩ ហើយត្រូវបានផ្អាកមួយរយៈពេល ដោយសារតែការរីករាលដាលនៃជំងឺកូវីដ១៩។ ប៉ុន្តែកាលពីឆ្នាំ២០២១ គម្រោងជួសជុលបានចាប់ផ្តើមឡើងវិញ ហើយបន្តរហូតមកដល់បច្ចុប្បន្ន៕

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទនាគព័ន្ធ ត្រូវបានសាងសង់ឡើង ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ ជាប្រាំសាទកោះ ស្ថិតនៅក្នុងបារាយណ៍ ជ័យតដាក (បារាយណ៍ខាងជើង) ដូចជាប្រាសាទមេបុណ្យក្នុងបារាយណ៍ ជំនៃឡើតជែរ

ផ្សាយនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤











រូបភាពប្រចាំសប្តាហ៍៖ ថ្ងៃចាក់រស្មៀល នាប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤









ដំណាក់កាលជួសជុលខឿនព្រះលានជល់ដំរី ចុងក្រោយ

ផ្សាយនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤



អាជ្ញាធរជាតិអប្សរា សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) តាមរយៈមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េ (KCHF) រំពឹងថាការជួសជុលខឿនរបស់ព្រះលានជល់ដំរីអាចនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខ។ ការងារជួសជុលខឿនព្រះលានជល់ដំរីនេះ បែងចែកជាចំនួន២ទីតាំង គឺA ស្ថិតនៅផ្នែកខាងជើង ប្រវែង២០ម៉ែត្រ និងទីតាំងC នៅផ្នែកខាងត្បូង ប្រវែង១៥ម៉ែត្រ បានចាប់ផ្តើមតាំងពីចុងឆ្នាំ២០២១មក។





អ្នកបុរាណវិទ្យា និងជាក្រុមការងារបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា ប្រចាំការនៅការដ្ឋានជួសជុលព្រះលានជល់ជំរីទីតាំងA អ្នកស្រី សៀង សុផានី ឱ្យដឹងថាការងារដែលសម្រេចនៅទីតាំងA បានបញ្ចប់ការងារកំណាយស្រាវជ្រាវបែបបុរាណវិទ្យា និងជួសជុលសម្រាលថ្មបាយក្រៀមផ្នែកខាងលើដែលស្រុត ព្រមទាំងបានពង្រីកការជួសជុលកម្រាលនៅទិសខាងត្បូងប្រវែង៣ម៉ែត្របន្ថែមទៀតនូវផ្នែកដែលស្រុតបញ្ចៀសការហូរច្រោះដោយទឹកភ្លៀង និងជួសជុលពង្រឹងគ្រឹះ ហើយរៀបជញ្ជាំងថ្មកក់ផ្នែកខាងកើតនៃព្រះលានជល់ជំរីបានចំនួន៥រួត។



ចំណែក ស្ថាបត្យករ និងជាក្រុមការងារបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា ប្រចាំការនៅការដ្ឋានទីតាំងC លោក ព្រំ ទិត្យ ឆពណ្ណារិទ្ធ ឱ្យដឹងថា មកដល់បច្ចុប្បន្ន ក្រុមការងារបានជួសជុលពង្រឹង និងរៀបជញ្ជាំងដែលទ្រេតមកខាងមុខត្រឹមត្រូវតាមលំនាំដើមបាន៩០ភាគរយ។ រីឯផ្នែកកម្រាលខាងលើ កំពុងសិក្សារៀបចំប្រព័ន្ធរំដោះទឹកទៅតាមអនុសាសន៍របស់ក្រុមអ្នកជំនាញការអាយស៊ីស៊ី-អង្គរ។ ដូច្នេះការងារដែលនៅសេសសល់មានតែ ការរៀបចំប្រព័ន្ធរំដោះទឹក រៀបចំកម្រាលផ្នែកខាងលើឡើងវិញ និងបង្កាន់ដៃនាគជាដើម៕



យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់ នៃអាជ្ញាធរជាតិអប្សរា សូមប្រកាសគាំទ្រយ៉ាងពេញទំហឹង ចំពោះការអនុវត្តគម្រោងព្រែកជីកហ្វូណានតេជោ ដែលជាគម្រោងព្រែកជីកជាប្រវត្តិសាស្ត្រលើកទី១ នៅកម្ពុជា

ផ្សាយនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖.....✓.....

ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមប្រកាសជាឯឡារិកគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្ត "គម្រោងព្រែកជីកហ្វូណានតេជោ" ដែលជាព្រែកជីកប្រវត្តិសាស្ត្រលើកទី១នៅកម្ពុជា ក្រោមគំនិតផ្តួចផ្តើមប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងជា **ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**។ គម្រោងដែលនឹងតភ្ជាប់ផ្លូវទឹករវាងទន្លេទៅកាន់សមុទ្រកម្ពុជា ឆ្លងកាត់ខេត្តចំនួន ៤ គឺ ខេត្តកណ្តាល តាកែវ កំពត និងខេត្តកែប ដែលមានប្រវែង១៨០គីឡូមែត្រនេះ នឹងត្រូវអនុវត្តដោយរាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

គម្រោងព្រែកជីកហ្វូណានតេជោនេះ នឹងផ្តល់អត្ថប្រយោជន៍ដ៏មហាសាលជូនប្រជាជនកម្ពុជាដូចជា៖ ការដឹកជញ្ជូនតាមផ្លូវទឹក បង្កើតតំបន់ពាណិជ្ជកម្ម តំបន់សេដ្ឋកិច្ចពិសេស ពង្រីកតំបន់អភិវឌ្ឍន៍កសិកម្ម ធារាសាស្ត្រវារីវប្បកម្ម ជួយរំដោះទឹកជំនន់នារដូវវស្សា ជួយបង្កើនផលត្រីទឹកសាប និងជំរុញឱ្យមានការរីកចម្រើនផ្នែកអចលនទ្រព្យ និងការវិនិយោគ ព្រមទាំងបង្កើនការងារផ្សេងៗជាដើម។ល។ សក្ខីភាពនេះ ពិតជាបានសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់អំពីការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ** ចំពោះសុខទុក្ខ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវកតញ្ញុតាធម៌កោតសរសើរដោយស្មោះ និងសូមគាំទ្រយ៉ាងពេញទំហឹងឥតងាករ ចំពោះគំនិតផ្តួចផ្តើមប្រកបដោយឧត្តមគតិជាតិខ្ពស់របស់ **សម្តេចតេជោ** ក្នុងការអនុវត្ត "គម្រោងព្រែកជីកហ្វូណានតេជោ" ដើម្បីធានាបាននូវអត្ថប្រយោជន៍ជូនសង្គមជាតិ និងប្រជាជន។

ថ្ងៃចន្ទ ៦រោច ខែចេត្ត ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤

អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាំង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តរស្មីមាន

អាជ្ញាធរដើម្បីការការពារបណ្ដាយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

កិច្ចការអភិរក្សបេតិកភណ្ឌវប្បធម៌ ក៏ជាចំណែកដ៏ធំមួយក្នុងការអភិវឌ្ឍក្នុងមណ្ឌលដ្ឋានអង្គរផងដែរ

ផ្សាយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤











ក្នុងសប្ដាហ៍ទី៤ នៃខែមេសា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា បានបន្ដចុះពិនិត្យទីតាំងស្នើសុំជួសជុល និងសាងសង់តូចតាចរបស់ប្រជាពលរដ្ឋ អ្នកស្រុកអន្ដរ សរុបចំនួន៣៨ករណី

ផ្សាយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤



សប្ដាហ៍ទី៤ នៃខែមេសា ឆ្នាំ២០២៤នេះ ក្រុមការងារ សហគមន៍ នាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និង សហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យទីតាំង ស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ សំណង់សាធារណៈផ្សេងៗ និងបានអនុញ្ញាតជូនដល់ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ចំនួន៣៨ករណី។ ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ទទួលបានការអនុញ្ញាតរួមមាន៖

- ស្រុកបន្ទាយស្រី អនុញ្ញាតបាន៦ករណី
- ស្រុកប្រាសាទបាគង អនុញ្ញាតបាន៨ករណី
- ស្រុកស្វាយលើ អនុញ្ញាតបាន១ករណី
- ក្រុងសៀមរាប អនុញ្ញាតបាន១៧ករណី
- ស្រុកពួក អនុញ្ញាតបាន៨ករណី
- ស្រុកអង្គរធំ អនុញ្ញាតបាន២ករណី



ចំពោះប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតខាងលើ ក្រុមការងារបច្ចេកទេសបានជួយរៀបចំគំនូសប្លង់ ដែលមានស្តាបត្យកម្មបែបប្រពៃណីជូនពួកគាត់ផងដែរ។ រាល់ការស្នើសុំច្បាប់ គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឱ្យស្របតាមចំណុចបច្ចេកទេស ដែលមានការទទួលដឹងឮ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕



អាជ្ញាធរជាតិអប្សរា ប្រទះឃើញបំណែករូបព្រះពុទ្ធបដិមាធ្វើពីថ្មតក់ ចំនួនជាង១០០បំណែក នៅប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤



ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញបំណែករូបព្រះពុទ្ធបដិមាធ្វើពីថ្មភក់ប្រមាណជាង១០០បំណែក នៅក្នុងបរិវេណរបស់ប្រាសាទតាព្រហ្ម ខណៈពេលដែលជីកដីធ្វើកំណាយសម្រាប់ស្រាវជ្រាវ កាលពីពេលថ្មីៗ។

បំណែកបដិមាទាំងនោះ មានដូចជា រូបព្រះពុទ្ធគង់ភ្នែនប្រក់នាគ រូបលោកកេស្ងរៈ រូបព្រះពុទ្ធគង់ភ្នែនប្រក់នាគ សមាធិ រូបប្រាជ្ញាបារមិតា រូបព្រះកេសព្រះពុទ្ធប្រក់នាគ មួយកំណាត់ ដាច់ត្រឹមក បាល័ង្ស និងបំណែកដៃជើងជាដើម។

បុរាណវិទូ លោកស្រី នេត ស៊ីមន ឱ្យដឹងថា ដំបូងឡើយគឺក្រុមការងារបានទៅធ្វើការសម្អាតគំនរដី ដែលស្ថិតផ្នែកខាងត្បូង នៃកំពែងថ្មបាយក្រៀមរបស់រោងទងទី៣ នៃប្រាសាទតាព្រហ្ម ដើម្បីរៀបចំសម្រង់ប្លង់បំណែកថ្មដែលរាយប៉ាយ ព្រមទាំងមានការថតរូប ចុះបញ្ជីចូលទៅក្នុងប្លង់រួមរបស់ប្រាសាទឱ្យមានសណ្តាប់ធ្នាប់ ដោយសារតែនៅទីនោះ មានថ្មរាយប៉ាយច្រើន។ កំឡុងពេលសម្អាតក្រុមការងារ ក៏បានប្រទះឃើញបំណែករូបបដិមាជាច្រើននៅទីនោះ។



លោកស្រី ស៊ីមន មានប្រសាសន៍ទៀតថា ដោយសារតែក្រុមការងារប្រទះឃើញបំណែកបដិមាកប់នៅក្នុងដីដម្រៅពី១០ទៅ១៥សង់ទីម៉ែត្រ កាន់តែច្រើននោះ ក៏សម្រេចស្នើសុំយោបល់ពីថ្នាក់លើ ធ្វើរណ្តៅកំណាយ ដើម្បីស្រាវជ្រាវរកនៅក្រោមដីបន្ថែមទៀត។ នៅពេលជីកកាយដីជ្រៅបន្តិច ក៏ប្រទះឃើញបំណែករូបបដិមាកាន់តែច្រើន សរុបប្រហែលជាង១០០បំណែក។



រហូតមកដល់ពេលនេះ ក្រុមការងារមិនទាន់ដឹងច្បាស់នៅឡើយទេ ថាតើក្នុងដម្រៅដីចុះទៅក្រោមទៀតអាចនៅតែមានបដិមាដៃរឬក៏យ៉ាងណាឡើយ។ បច្ចុប្បន្ន ក្រុមការងារ កំពុងតែលើកយកបំណែករូបបដិមាជាច្រើនដែលគេបានប្រទះឃើញនោះ មកធ្វើការគូរប្លង់ បង់លេខ ព្រមទាំងវាស់វែងទំហំខ្នាតជាបណ្តោះអាសន្ន។

ក្រុមអ្នកជំនាញបុរាណវិទ្យាបានសន្និដ្ឋានថា បំណែកព្រះពុទ្ធបដិមាដែលគេប្រទះឃើញទាំងនោះ គឺស្ថិតក្នុងរចនាបថបាយ័ន។ បំណែករូបបដិមាដែលប្រទះឃើញខ្លះមានកម្ពស់ប្រហែលកន្លះម៉ែត្រ និងទំហំពី៤០ទៅ៥០សង់ទីម៉ែត្រ៕



ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែឧសភា

ប្រជាពលរដ្ឋរស់នៅក្នុងឃុំលាងដៃ ស្រុកអង្គរធំ នឹងប្រារព្ធធ្វើពិធីសុំទឹកភ្លៀងតាមទំនៀមទម្លាប់ប្រពៃណីរបស់អ្នកភូមិ នៅក្នុងបរិវេណប្រាសាទនាគព័ន្ធ កណ្តាលបារាយណ៍ជ័យតដាក ឬបារាយណ៍ខាងជើង នៅថ្ងៃទី២ ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤។

ដូច្នេះ សាធារណជនទេសចរជាតិ និងអន្តរជាតិ ប្រជាពលរដ្ឋជិតឆ្ងាយអាចចូលរួមតាមសទ្ធាជ្រះថ្លារៀងៗខ្លួន និងបានស្វែងយល់ពីជំនឿរបស់អ្នកស្រុកអង្គរដែលគោរពប្រតិបត្តិជាយូរលង់ណាស់មកហើយ៕

អ្នកស្រុកអង្គរ នឹងប្រារព្ធពិធីសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធ នៅថ្ងៃទី២-៣ ខាងមុខនេះ

ផ្សាយនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២៤







នៅក្នុងសប្តាហ៍ទី៤ ដោយចាប់ពីថ្ងៃ២២ ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤កន្លងទៅ ក្រុមការងារបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យទីតាំងស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ សំណង់សាធារណៈផ្សេងៗ និងបានអនុញ្ញាតជូនដល់ប្រជាពលរដ្ឋ ដែលជាអ្នកស្រុកចាស់ បានសរុបចំនួន២០៤ករណី។ ប្រជាពលរដ្ឋដែលជាអ្នកស្រុកចាស់ ទទួលបានការអនុញ្ញាតរួមមាន៖

១. ក្រុងសៀមរាបចំនួន ២៥ករណី
២. ស្រុកប្រាសាទបាគងចំនួន ២៧ករណី
៣. ស្រុកបន្ទាយស្រីចំនួន ៤១ករណី
៤. ស្រុកពួកចំនួន ៧១ករណី
៥. ស្រុកអង្គរធំចំនួន ៣៣ករណី
៦. ស្រុកស្វាយលើ ០៧ករណី

ក្នុងសប្តាហ៍ទី៤ នៃខែមេសា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេសដោយពុំគិតប្រាក់កម្រៃ ក្នុងដំណើរការសាងសង់លំនៅដ្ឋានក៏ដូចជាសំណង់ឧបសម្ព័ន្ធផ្សេងៗទៀត ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរ និងតំបន់ជុំវិញទៀត ស្ថិតក្រោមការគ្រប់គ្រង របស់អាជ្ញាធរជាតិអប្សរា ដែលទទួលបានការអនុញ្ញាតមានចំនួន ២០៤ករណី ដូចខាងក្រោម៖

ផ្សាយនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤







សូមបញ្ជាក់ផងដែរថា ក្នុងចំណោម ២០៤ករណី មាន១២១ករណី បានសាងសង់ត្រឹមត្រូវតាមការអនុញ្ញាត និងចំនួន៧៨ករណី មិនទាន់សាងសង់នៅឡើយ។ ក្នុងនោះមានករណីសាងសង់ពុំត្រឹមត្រូវ តាមការអនុញ្ញាត ចំនួន០៥ករណី។ ចំពោះករណីដែលប្រជាពលរដ្ឋសាងសង់ពុំត្រឹមត្រូវ តាមការអនុញ្ញាតក្រុមការងារបានពន្យល់ និងណែនាំឱ្យពួកគាត់កែប្រែឡើងវិញទៅតាមខ្លឹមសារនៃការអនុញ្ញាត និងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយនឹងអាជ្ញាធរជាតិអប្សរា៕



ពិធីសុំទឹកភ្លៀងរបស់អ្នកស្រុកអង្គរធំនៅប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៤

អ្នកឃុំលាងដៃ ស្រុកអង្គរធំ បានប្រារព្ធពិធីសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធ ក្នុងបំណងបន់ឱ្យមានភ្លៀងធ្លាក់ធាប់ៗ ស្របពេលរដូវកាលធ្វើស្រែចម្ការចូលដល់ តែនៅពុំទាន់មានភ្លៀងនៅឡើយ។ កិច្ចពិធីនេះធ្វើរយៈពេលមួយយប់ពីរថ្ងៃ ដោយរសៀលថ្ងៃទី១ មានពិធីប្រុងពាលីពិធីបួងសួង ពិធីបញ្ជាន់រូប និងពិធីសូត្រមន្ត។ លុះដល់ព្រឹកស្អែក មានពិធីប្រគេនចង្ហាន់ព្រះសង្ឃ ពិធីរាប់បាត្រ និងពិធីប្រទក្សិណ៣ជុំដើម្បីចាក់ទឹកចូលក្នុងទ ដើម្បីបង្ហូរចេញពីអាងធំចូលទៅអាងតូចតាមទិសទាំង៤។ កំឡុងពេលដើរប្រទក្សិណនោះក៏មានការចាក់ និងជះទឹកដាក់គ្នាយ៉ាងអធិកអធម ដែលជាការនិមិត្តថាមានភ្លៀងធ្លាក់មកមែន។

ចំពោះគ្រឿងរណ្តាប់នៅក្នុងពិធីនេះរួមមាន បាយសីស្លាធម៌ ក្បាលជ្រូក ទៀន ធូប បាយ សម្ល បង្អែម ផ្លែឈើ និងភេសជ្ជៈ។ អ្នកភូមិខ្លះ បានវេចខ្ចប់ម្ហូបអាហារ និងមកជាលក្ខណៈគ្រួសារដើម្បីចូលរួមក្នុងពិធី ប្រពៃណីមួយនេះ។ ពួកគេបង្ហាញទឹកមុខរីករាយឥតឧបមា និងរំពឹងថាភ្លៀងនឹងធាប់បង្អុរធាប់ៗ ក្រោយពិធីសុំទឹកភ្លៀងនេះចប់សព្វគ្រប់។











ពិធីនៅឆ្នាំនេះ មានប្រជាពលរដ្ឋចូលរួមច្រើន ក្នុងនោះមានអ្នកភូមិលាងដៃ ភូមិសំរោង ភូមិភ្នុង ស្រុកអង្គរធំ និងមានអ្នកក្រៅពីតំបន់ក្បែរនោះចូលរួមផងដែរ។ ពិធីនេះសបញ្ជាក់ថា កសិកម្មនៅតែជាវិស័យយ៉ាងសំខាន់របស់អ្នកស្រុក ទោះជាវិស័យទេសចរណ៍កំពុងរីកចម្រើនក៏ដោយ។ អ្នកស្រុកធ្វើស្រែចម្ការនៅពឹងជាសង្ឃឹមលើទឹកភ្លៀងនៅឡើយ។ ជាពិសេសនាឆ្នាំនេះ ការរាំងស្ងួតនិងកម្តៅចេះតែបន្តច្រើនអាទិត្យទៀត អ្នកស្រុករឹតតែចូលរួមប្រារព្ធពិធីសុំទឹកភ្លៀងនេះ យ៉ាងច្រើនកុះករ។ ជាទូទៅប្រជាពលរដ្ឋរស់នៅតំបន់អង្គរ តែងប្រារព្ធពិធីនេះរៀងរាល់ឆ្នាំពីដូនតាមក តាមរបៀបមានទម្រង់ផ្សេងៗទៅតាមតំបន់ ដែលពួកគេរស់នៅ៕







រូបភាពប្រចាំសប្តាហ៍ ៥ បក្សីចាំក្រុង សំណង់ប្រាសាទរាងសាជីតូចប្រលឹង ដែលទេសចរអាចទស្សនា និងថ្តិតរូបភាពយ៉ាងស្រស់ស្អាត ដោយមិនចំណាយពេលយូរ

ផ្សាយនៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០២៤







រូបភាពប្រចាំសប្តាហ៍÷ប្រាសាទបី សំណង់ឥដ្ឋសតវត្សរ៍ទី១០ កន្លែងល្អសម្រាប់អ្នកចូលចិត្តទស្សនាប្រាសាទមិនសូវអ៊ូអរ

ផ្សាយនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៤





ក្រុមការងារភ្នាក់ងារទេសចរ រួមគ្នាថែទាំបរិស្ថានជាប្រចាំ នៅប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២៤

ដើម្បីបរិស្ថានស្រស់ស្អាតជាប្រចាំ ក្រុមការងារភ្នាក់ងារទេសចររបស់អាជ្ញាធរជាតិអប្សរា ប្រចាំការនៅប្រាសាទបេងមាលា បានរួមគ្នាបោសសម្អាតសំរាមថង់ប្លាស្ទិក ដប កំប៉ុងកេសដ្ឋ:ផ្សេងៗ ដែលនាំឱ្យបាត់បង់សោភ័ណភាពទាំងក្នុង និងក្រៅប្រាសាទជាដើម។







ការទុកដាក់សំរាមបានត្រឹមត្រូវ គឺជាការចូលរួមថែរក្សាបរិស្ថានជាមួយអាជ្ញាធរជាតិអប្សរា។ ដូច្នេះ អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់សាធារណជន ភ្ញៀវទេសចរ ប្រជាពលពលរដ្ឋ និងអ្នកលក់ដូរគ្រប់ៗគ្នានៅជុំវិញតំបន់នេះ សូមចូលរួមថែរក្សាបរិស្ថានទាំងអស់គ្នា ដើម្បីរមណីយដ្ឋានយើងគ្មានសំរាម ដែលជាការលើកតម្លៃយ៉ាងខ្ពស់ និងទាក់ទាញភ្ញៀវទេសចរមកទស្សនាម្តងហើយម្តងទៀត៕





អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលស្តីពីៈ ការផ្ទេរចំណេះដឹង និងជំនាញដល់អ្នកបន្តវេន ក្នុងការងារអភិរក្ស និងជួសជុលប្រាសាទ

ផ្សាយនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២៤ នានាយកដ្ឋាន សណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា មានបើកវគ្គបណ្តុះបណ្តាលស្តីពីៈ ការផ្ទេរចំណេះដឹង និងជំនាញដល់អ្នកបន្តវេន ក្នុងការងារអភិរក្ស និងជួសជុលប្រាសាទ ស្ថិតក្រោមអធិបតីភាព **ឯកឧត្តម ឡុច កុសល** អគ្គនាយករង តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោកអ៊ឹម សុខរិទ្ធ ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ រួមទាំងសិក្ខាកាមសរុបចំនួន២៥រូប ជាមន្ត្រី-បុគ្គលិកភ្នាក់ងារទេសចរ និងភ្នាក់ងារសណ្តាប់ធ្នាប់ នៃអាជ្ញាធរជាតិអប្សរា ដែលកំពុងបំពេញ ការងារអភិរក្ស និងជួសជុលប្រាសាទក្នុងតំបន់អង្គរ។

ឯកឧត្តម ឡុច កុសល អគ្គនាយករងអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ក្នុងឱកាសនោះថា វគ្គបណ្តុះបណ្តាលនេះពិតជាសារៈសំខាន់ខ្លាំងណាស់ ក្នុងការបង្កើនសមត្ថភាពការគ្រប់គ្រងការងារប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក៏ដូចជាផ្តល់ចំណេះដឹងបន្ថែមដល់ភ្នាក់ងារ និងអ្នកគ្រប់គ្រងនៅតាមគោលដៅប្រាសាទនានា។ ធ្វើយ៉ាងណាធានាបាននូវកិច្ចការពារ ការងារអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរប្រកបដោយនិរន្តរភាព។

ឯកឧត្តម អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានជំរុញណែនាំឱ្យសិក្ខាកាមទាំងអស់ ត្រូវខិតខំរៀនសូត្របន្ថែមនូវចំណេះដឹង ដែលអាជ្ញាធរជាតិអប្សរាបានផ្តល់ជូនដើម្បីចូលរួមចំណែកក្នុងកិច្ចការងារថែរក្សា និងគ្រប់គ្រងរមណីយដ្ឋានអង្គរ ឱ្យកាន់តែមានប្រសិទ្ធភាពល្អថែមទៀត។

សូមជម្រាបផងដែរថា វគ្គបណ្តុះបណ្តាលស្តីពីៈ ការផ្ទេរចំណេះដឹង និងជំនាញដល់អ្នកបន្តវេន ក្នុងការងារអភិរក្ស និងជួសជុលប្រាសាទ មានរយៈពេល៧ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី០៧ រហូតដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤៕



សេចក្តីជូនដំណឹង
ស្តីពីការកាប់ជកហូតដើមឈើនិងកាត់ក្រីមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗក្នុងមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៤.៣៦៩/.៤ប.ស.៥៧៣
/២៦

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ជកហូតដើមឈើនិងកាត់ក្រីមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ក្រៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ ទេសចរណ៍ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងតាមបរិវណប្រាសាទក្នុងតំបន់មណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយ អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរា នឹងកាត់ជកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ក្រីមែកឈើចំនួន០៦ដើម (ដើមឈើទាល៤ដើម ដើមស្រឡៅ១ដើម ដើមពង្រ១ដើម) ស្ថិតនៅបរិវណប្រាសាទសូព្រ៉ត្រ។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន០៣ដើម (កាត់ជកហូតដើមក្រឡាញ់១ដើម ដើមវល្លីតាលីង១ដើម កាត់ក្រីដើមស្នូល១ដើម) ស្ថិតនៅបរិវណខាងមុខប្រាសាទតាសោម។
- កាត់ជកហូតដើមឈើទាលចំនួន១៤ដើម ស្ថិតនៅបរិវណខ្លោងទ្វារខ្មោច។
- កាត់ជកហូតដើមឈើទាលចំនួន៧ដើម ស្ថិតនៅបរិវណខ្លោងទ្វារជ័យ។
- កាត់ជកហូតដើមឈើទាលចំនួន១ដើមស្ថិតនៅបរិវណប្រាសាទបាយ័នមុខខាងកើតស្រះទឹកខាងជើង។
- កាត់ជកហូត និងកាត់ក្រីដើមឈើចំនួន១០ដើម (កាត់ជកហូតដើមល្បៀង១ដើម ដើមឈើទាល១ដើម ដើមខ្នារ១ដើម កាត់ក្រីដើមឈើទាល៣ដើម ដើមខ្នារ១ដើម ដើមត្រសេក១ដើម ដើមចំបក់១ដើម ដើមស្នូល១ដើម) ស្ថិតនៅក្នុងបរិវណប្រាសាទតានៃ។
- កាត់ជកហូតដើមឈើ២ដើម (ដើមស្លែង១ដើម និងដើមក្រសាំង១ដើម) ស្ថិតនៅបរិវណមុខប្រាសាទបាយ័ន ស្រះទឹកខាងត្បូង។
- កាត់ក្រីដើមឈើចំនួន២៣ដើម (ដើមឈើទាល១៨ដើម ដើមស្នាយ២ដើម ដើមអង្គាញ់២ដើម ដើមស្លែង១ដើម) ចាប់ពីខ្លោងទ្វារទន្លេអ៊ុំ រហូតដល់ប្រាសាទព្រហ្មកិល។
- កាត់ក្រីដើមឈើចំនួន៧ដើម (ដើមឈើទាល៣ដើម ដើមស្នាយ៣ដើម ដើមពោធ៌១ដើម) ស្ថិតនៅបរិវណវត្តទេពប្រណម។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ក្រៀវជាតិ អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១ កើត ខែពិភាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបន្ទាត់ ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរា និងសាលាស្រុកបន្ទាយស្រី បង្កើនកិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងតំបន់រមណីយដ្ឋានអង្គរឱ្យមានប្រសិទ្ធភាព

ផ្សាយនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤





នៅព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា ជួបពិភាក្សាជាមួយសាលាស្រុកបន្ទាយស្រី អធិការដ្ឋាននគរបាលស្រុក បញ្ជាការដ្ឋានកងរាជអាវុធហត្ថស្រុក និងអាជ្ញាធរឃុំរុនតាឯក ក្នុងគោលបំណងបង្កើនកិច្ចសហការបន្ថែមទៀតលើការផ្តល់សេវាកម្មផ្សេងៗពាក់ព័ន្ធនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ជាពិសេស អំពីការសាងសង់ សំណង់ និងការប្រើប្រាស់ដីធ្លី នៅក្នុងតំបន់អង្គរឱ្យបានសមស្រប។

ក្នុងកិច្ចពិភាក្សានេះដែរ អាជ្ញាធរជាតិអប្សរា ក៏បានពន្យល់បទដ្ឋានគតិយុត្តច្បាប់ដល់អាជ្ញាធរស្រុកបន្ទាយស្រី សមត្ថកិច្ចពាក់ព័ន្ធ និងអាជ្ញាធរឃុំរុនតាឯក ដើម្បីធ្វើការផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងលក្ខណៈបច្ចេកទេសមួយចំនួនដូចជា៖



១.អាចជួសជុលផ្ទះ ដែលចាស់ទ្រុឌទ្រោម ឱ្យទៅជាល្អឡើងវិញ

២.អាចសុំច្បាប់អនុញ្ញាតរុះរើផ្ទះចាស់ ដើម្បីធ្វើផ្ទះថ្មី ប៉ុន្តែត្រូវធ្វើសំណង់ទៅតាមលក្ខណៈជាផ្ទះខ្មែរ

៣.អាចពង្រីកខ្នងផ្ទះបាន ប្រសិនបើផ្ទះចាស់ មានសភាពតូចចង្អៀត

៤.អាចធ្វើស្រែ ឬចម្ការ នៅលើដីដែលគាត់កំពុងអាស្រ័យផលនោះបានជាធម្មតា

៥.អាចផ្ទេរកម្មសិទ្ធិផ្ទះឬដីបន្តទៅឱ្យកូនៗបាន និងអាចលក់ផ្ទះឬក៏ដីទៅឱ្យអ្នកភូមិជាមួយគ្នាបាន លើកលែងតែអ្នកដែលមកពីចម្ងាយ៕







ការស្រាវជ្រាវនៅព្រែកស្រមោច

ផ្សាយនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤

ជាយូរមកហើយ អ្នកស្រាវជ្រាវ និងអ្នកស្រុកមួយចំនួន យល់ថាព្រែកស្រមោចដែលជា ព្រែកជីកបុរាណ មានប្រភពចាប់ពីភ្នំគូលែនចុះរហូតដល់កំពង់ឃ្លាំង ជាប់មាត់ទន្លេសាប ហើយពីមុនមកក៏ពុំទាន់មានការសិក្សាទាំងផ្នែកបុរាណវិទ្យា ផ្នែកវិស្វកម្ម ព្រមទាំងផ្នែកធារាសាស្ត្រនៅឡើយទេ។ ប៉ុន្តែ កន្លងមកក៏ធ្លាប់មានដៃរការសិក្សាពីសហគមន៍មនុស្សតាមបណ្តោយព្រែកជីក និងអត្ថបទខ្លីៗទាក់ទងផ្សេងទៀតដៃរដែលបានចុះផ្សាយក្នុងបណ្តាណាព័ត៌មានវប្បធម៌ខ្មែរ។



ព្រែកស្រមោចពីកំពង់ឃ្លាំងជាប់មាត់ទន្លេសាប

(BULLETIN ÉCONOMIQUE DE L'INDOC HINE, 1941)

លោក ទិន ទីណា អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ ដែលជាប្រធានគម្រោង បានផ្តល់នូវសំណួរមួយចំនួនដូចជា តើគេជីកព្រែកដ៏ធំនេះដើម្បីទាញយកទឹកប្រើប្រាស់? បើដូច្នេះ ហេតុអ្វី ក៏ទទឹង ធំម្ល៉េះ? ដើម្បីដឹកជញ្ជូនភាជន៍ ពីកន្លែងផលិត នៅលើភ្នំគូលែន ចុះ មកទន្លេ សាប? ឬ មួយ មាន តួនាទីជា ផ្លូវ ដឹកថ្មពីអូរថ្មដាប់ដែល ជា កន្លែង ដាប់ យកថ្មទៅកសាង ប្រាសាទ នៅ អង្គរ? ចម្ងល់ ទាំង នេះ ហើយដែលក្រុម ស្រាវជ្រាវ ត្រូវធ្វើការស្វែងយល់ថា តើព្រែក ជីក បុរាណ នេះ មាន ប្រភព ពីណាទៅដល់ត្រឹមណា? មានតួនាទីអ្វីឱ្យប្រាកដ?

ក្រុមស្រាវជ្រាវបានប្រាស់រូបថតពីលើអាកាស ដែលបោះពុម្ពក្នុងឆ្នាំ១៩៤១ និងរូបភាពពីលើអាកាសតាមរយៈ Google Earth បានបង្ហាញថា ព្រែកស្រមោចសណ្តោកតាមទិសខាងជើងទៅត្បូង ចេញពីភូមិសាស្ត្រឃុំកំពង់ឃ្លាំងជាប់មាត់ទន្លេសាប កាត់តាមផ្លូវជាតិលេខ៦ ត្រង់ភូមិថ្នល់ចែក ឃុំដំដែក ឡើងទៅដល់ភូមិសំរោង ឃុំសំរោង ស្រុកសូទ្រនិគម។



ការស្រាវជ្រាវនៅដំណាក់កាលទី១បានបង្ហាញថាព្រែកជីកនេះលាតសន្ធឹងមិនដល់ភ្នំគូលែនទេ គឺនៅត្រឹមម្តុំវត្តសំរោងតែប៉ុណ្ណោះ ព្រោះពុំមានស្លាកស្នាមបន្តទៀតទេ។ ព្រែកជីកនេះមានប្រវែងសរុប២៣គីឡូម៉ែត្រ កន្លែងខ្លះមានទទឹងពី៣០០ម៉ែត្រ កន្លែងខ្លះមានទទឹង១៥០ម៉ែត្រ និងមានកម្ពស់ជាង៤ម៉ែត្រ។ក្រុមអ្នកស្រាវជ្រាវសន្និដ្ឋានថាប្រភពទឹកហូរចូលព្រែកនេះអាចមានប្រភព២ សំខាន់ៗ៖ ទី១ ប្រភពទឹកពីភ្នំគូលែនស្ថិតនៅខាងជើងវាលរាបអង្គរ រួចហូរចូលព្រែកជីកនេះ និងទី២ ប្រហែលទឹកឡើងមកពីទន្លេសាប ច្រាលចូលក្នុងព្រែក។

យើងពុំដឹងថាព្រែកជីកដ៏ធំនេះកសាងនៅសម័យណាទេ តែគេអាចសន្និដ្ឋានថា អាចកើតមុនរាជ្យព្រះបាទជ័យវរ្មន៉ទី៧ ឬប្រហែលអាចជាមុននោះយូរផង។ក្រោយមកប្រហែលជាព្រែកជីកនេះមានដំណើរការរអាក់រអួលនិងខូចខាតដោយអន្លើទើបក្នុងរាជ្យព្រះបាទ ជ័យវរ្មន៉ទី៧បានធ្វើផ្លូវមានទាំងស្ពានមួយចំនួនដែលសព្វថ្ងៃនេះក្លាយមកជាផ្លូវជាតិ លេខ៦ កាត់ព្រែកជីកឲ្យដាច់ជាពីរផ្នែកនៅត្រង់ចំណុច "ថ្នល់ចែក" ម្តុំភូមិថ្នល់ចែក ឃុំដុំដែក ស្រុកសូទ្រនិគម។ អ្នកស្រុករស់នៅតាមទំនប់ព្រែកជីកមួយចំនួននៅចាំតៗគ្នាថា ព្រែកស្រមោច ឬផ្លូវសំពៅនេះជាផ្លូវទឹកបុរាណមួយដែលមានសំពៅចរាចរចុះឡើងចន្លោះ ពីទន្លេសាប ទៅដល់ភ្នំគូលែន និងជាផ្លូវដឹកជញ្ជូនថ្មទៅសាងសង់ប្រាសាទនៅអង្គរដែរ។

នៅក្នុងឆ្នាំ២០២៤នេះ ក្រុមស្រាវជ្រាវបានបន្តធ្វើកំណាយនៅទីតាំងភូមិថ្មី ឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម ក្នុងបំណងស្វែងយល់បន្ថែម ពីព្រែកស្រមោច និងស្វែងយល់ពីការតាំងទីរបស់ប្រជាជន និងពេលវេលាដែលពួកគេរស់នៅទីនេះ។ ក្នុងពេលធ្វើកំណាយនេះ យើងបានរកឃើញឃើញ កុលាលភាជន៍ខ្លះៗដូចជាកុលាលភាជផុយ ភាជន៍មានលាបទឹកថ្នាំពណ៌ក្រហម (Red slip) ជាភាជន៍ផលិតនៅចុងសម័យមុនអង្គរ ឬដើមសម័យអង្គរ។





អគ្គនាយកអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាជាមួយមន្ត្រីទទួលបន្ទុកនៃការវាយតម្លៃគម្រោងនៃភ្នាក់ងារថាមពលនុយក្លេអ៊ែរអន្តរជាតិ

ផ្សាយនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៤

នៅព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានទទួលជួបមន្ត្រីទទួលបន្ទុកនៃការវាយតម្លៃគម្រោងនៃភ្នាក់ងារថាមពលនុយក្លេអ៊ែរអន្តរជាតិ ដឹកនាំដោយអ្នកស្រី Barbara Torggler ប្រធានផ្នែកវាយតម្លៃកម្មវិធីនៃការិយាល័យសេវាត្រួតពិនិត្យផ្ទៃក្នុងរបស់ IAEA ដើម្បីពិភាក្សាការងារទាក់ទងនឹងលទ្ធភាពចូលរួមចំណែកក្នុងកិច្ចការងារអភិរក្ស ថែរក្សាសម្បត្តិបេតិកភណ្ឌវប្បធម៌នៅរមណីយដ្ឋានអង្គរ។









រូបភាពប្រចាំសប្តាហ៍៖ ចម្លាក់ល្អវិចិត្រ នៃប្រាសាទតាព្រហ្មកិល ប្រាសាទនេះត្រូវបានសាងពីថ្មតក់ នៅចុងសតវត្សរ៍ទី១២ ដែលជា «ហោបន់ស្រន់» របស់មន្ទីរពេទ្យបាលរោគ មួយក្នុងចំណោមបួននៅជុំវិញក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤











ក្រុមការងារពិនិត្យ និងតាមដានការសាងសង់របស់ពលរដ្ឋ ដែលជាអ្នកស្រុកចាស់ ក្នុងតំបន់រមណីយដ្ឋានអង្គរក្រោយទទួលបានការអនុញ្ញាត

ផ្សាយនៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៤

ក្នុងសប្តាហ៍ទី១ ថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី០៥ នៃខែឧសភា ឆ្នាំ២០២៤ ក្រុមការងារពិនិត្យ និងតាមដានការសាងសង់នៃនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេសដោយពុំគិតប្រាក់កម្រៃ ក្នុងដំណើរការសាងសង់លំនៅដ្ឋាន ក៏ដូចជាសំណង់ឧបសម្ព័ន្ធផ្សេងៗទៀត ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរ និងតំបន់ដទៃទៀតស្ថិតក្រោមការគ្រប់គ្រង របស់អាជ្ញាធរជាតិអប្សរា បានចំនួន ១៤៧ករណី ដែលធ្លាប់ទទួលបានការអនុញ្ញាតកន្លងមក ដូចខាងក្រោម៖

១. ក្រុងសៀមរាប ចំនួន៤២ករណី
២. ស្រុកប្រាសាទបាគង ចំនួន១២ករណី
៣. ស្រុកបន្ទាយស្រី ចំនួន៣០ករណី
៤. ស្រុកពួក ចំនួន៣១ករណី
៥. ស្រុកអង្គរធំ ចំនួន២៧ករណី
៦. ស្រុកស្វាយលើ ចំនួន០៥ករណី

សូមបញ្ជាក់ជូនផងដែរថា ក្នុងចំណោម ១៤៧ករណី មាន៨៩ករណី សាងសង់ត្រឹមត្រូវតាមការអនុញ្ញាត មាន ៥៧ករណី មិនទាន់សាងសង់នៅឡើយ និងសាងសង់ពុំត្រឹមត្រូវតាមការអនុញ្ញាត មាន ០១ករណី មានឈ្មោះ លន់ រ៉ាវី នៅភូមិសណ្តាន់ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ។

ករណីដែលប្រជាពលរដ្ឋសាងសង់ពុំត្រឹមត្រូវតាមការអនុញ្ញាត ក្រុមការងារបានសម្របសម្រួលឱ្យពួកគាត់កែប្រែ ឡើងវិញទៅតាមខ្លឹមសារ នៃការអនុញ្ញាត និងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយនឹងអាជ្ញាធរជាតិអប្សរា៕



រូបភាពប្រចាំសប្តាហ៍ ទិដ្ឋភាពខ្លោងទ្វារជីឆ្លាំងជ៍ធំស្តឹមស្ពៃ ដែលជាប្រកទ្វារខាងជើងនៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤













ភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា ប្រគល់ទូរស័ព្ទ ជូនម្ចាស់ដើម ដែលបានភ្លេចនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤



ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា ប្រចាំគោលដៅនៅប្រាសាទអង្គរវត្ត បានប្រទះឃើញទូរស័ព្ទចំនួនមួយគ្រឿងរបស់ភ្ញៀវទេសចរជាតិដែលបានភ្លេចនៅចំណុចបណ្ណាល័យខាងជើងនៃប្រាសាទអង្គរវត្ត និងបានប្រគល់ជូនម្ចាស់ដើមវិញ ក្រោយពីពិនិត្យឃើញថាពិតជារបស់គាត់ពិតមែន៕







នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤ ទិដ្ឋភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ យ៉ាងច្រើនកុះករចូលមកទស្សនាប្រាសាទអង្គរវត្ត តាំងពីព្រឹកព្រលឹមដើម្បីគយគន់ថ្ងៃរះ នៅប្រាសាទអង្គរ ថតថ្ពិតរូបភាព និងទស្សនាស្ថាបត្យកម្មដ៏អច្ឆរិយៈមួយនេះ មិនដែលរំលង មុននឹងបន្តដំណើរទៅទស្សនាទីតាំងផ្សេងៗបន្តទៀត

ផ្សាយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា ប្រគល់លិខិតថ្លែងអំណរគុណ សប្បុរសជនអ្នកបរិច្ចាគសមុច្ច័យ ជូនសារមន្ទីរចំនួនពីរក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤

សប្បុរសជន ចំនួន១៩រូប ដែលកន្លងមក បានស្ម័គ្រចិត្ត បរិច្ចាគសមុច្ច័យ មួយចំនួន ជូនមកកាន់សារមន្ទីរ វាយនភណ្ឌប្រពៃណីអាស៊ី និងសារមន្ទីរព្រះនរោត្តម សីហនុ-អង្គរ ដើម្បីថែរក្សាទុក និងដាក់តាំងបង្ហាញនៅក្នុង សារមន្ទីរ បានទទួលលិខិតថ្លែងអំណរគុណពីអាជ្ញាធរជាតិ អប្សរា។





អ្នកស្រី តូច រដ្ឋា អាយុ៦០ឆ្នាំ និងអ្នកស្រី គង់ សុភ័ក្រ ប្រជាពលរដ្ឋរស់នៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ដែលបានបរិច្ចាគសំពត់ហូល ជូនសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ីបានឱ្យដឹងថា ពួកគាត់សប្បាយរីករាយ ក្រោយពេលបានប្រគល់សំពត់ហូល ជារបស់មានតម្លៃក្នុងគ្រួសារ ថែរក្សាទុកជាយូរមកហើយ ជូនមកកាន់សារមន្ទីរ ដោយមានជំនឿថា សារមន្ទីរអាចថែរក្សាវត្ថុមានតម្លៃទាំងនោះ បន្តទុកឱ្យកូនខ្មែរជំនាន់ក្រោយ បានឃើញនិងស្គាល់នូវសំពត់ ជាស្នាដៃរបស់ចាស់ៗពីដើម ដែលត្បាញដោយផ្ទាល់ដៃ។ ក្នុងពេលអញ្ជើញមកទទួលលិខិតថ្លែងអំណរគុណ ពីអាជ្ញាធរជាតិអប្សរា អ្នកស្រី រួមទាំងបងប្អូនសប្បុរសជនដទៃទៀត សប្បាយរីករាយ ដែលបានឃើញសារមន្ទីរតាំងបង្ហាញនូវសមិទ្ធផលដែលពួកគាត់បានប្រគល់មក ជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិបានទស្សនា។



លោក សែន គឹមស៊ុន នាយកស្តីទីសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី នៃអាជ្ញាធជាតិអប្សរា មានប្រសាសន៍ថា សមុច្ច័យទទួលបានពីសប្បុរសជន ទាំងនៅក្នុងខេត្តនិងបណ្តាខេត្តនានា សរុបចំនួន២១សមុច្ច័យ មានជាប្រភេទ ហូល អន្លូញ ស៊ីង សំពត់ចរបាប់ អាវកុតត្រង់ និងប្រភេទសម្លៀកបំពាក់របស់បងប្អូនជនជាតិដើមភាគតិចរស់នៅខេត្តរតនគិរី ដោយសមុច្ច័យទាំងនោះ មានអាយុកាលចន្លោះពី១០ឆ្នាំទៅ៥០ឆ្នាំ ភាគច្រើនជារបស់ត្បាញដោយដៃ។





សារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី ពិតជាមានសេចក្តីរីករាយយ៉ាងក្រៃលែង ចំពោះបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលបានស្ម័គ្រចិត្តបរិច្ចាគសមុច្ច័យ មកកាន់សារមន្ទីរ។ ទាំងនេះជាការបង្ហាញឱ្យឃើញនូវការស្រឡាញ់ ចូលរួមថែរក្សាអត្តសញ្ញាណរបស់ជាតិខ្មែរ ព្រោះថាបើសិនទុកនៅក្នុងផ្ទះ មិនបានថែរក្សាឱ្យបានត្រឹមត្រូវ សមុច្ច័យទាំងនោះនិងមានការបាត់បង់។ លោកបញ្ជាក់ថា ក្រោយទទួលបានការបរិច្ចាគពីសប្បុរសជន សារមន្ទីរបានយកសមុច្ច័យទាំងនោះមកថែរក្សា ជួសជុល និងដាក់តាំងពិព័រណ៍ ជូនសាធារណៈជនបានទស្សនានិងឈ្វេងយល់៕

សារលិខិតថ្វាយព្រះពរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រពៃថ្ងៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃព្រះរាជពិធីបម្រើនព្រះជន្មវស្សាគម្រប់៧១ យាងចូល៧២ ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអង្គារ ៧កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៤ ខាងមុខនេះ

ផ្សាយនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤




ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ.ពាសប/អប.សជ៨
២៤

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ
ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

បពិត្រព្រះករុណាថ្លៃវិសេសជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លា ប្រកបដោយសេចក្តីសោមនស្សរីករាយ នៃព្រះរាជពិធីបម្រើនព្រះជន្ម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត គម្រប់ព្រះជន្ម៧១ព្រះវស្សា យាងចូល ៧២ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអង្គារ ៧កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៤ តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ កងកា និងគ្រួសារនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្ញុំព្រះបង្គំ ជាខ្ញុំផ្ទាល់ សូមព្រះបរមរាជានុញ្ញាតអភិវន្ទន៍ និងក្រាបថ្វាយបង្គំទូលព្រះបរមរាជសក្ការៈ ក្រាបបង្គំទូលថ្វាយនូវព្រះពរជ័យ សាធុការពរជ័យ ជាវរសួស្តី សិរីមង្គលា វិបុលសុខ មហាប្រសើរគ្រប់ប្រការ និងសូមលើកហត្ថប្រណមបួងសួងគុណព្រះរតនត្រ័យវែងឆ្ងាយ ឬទ្ធិអានុភាពនៃព្រះបារមីនៃទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ ព្រះបារមីនៃជួងព្រះវិញ្ញាណក្ខន្ធ អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសព្រះបារមីព្រះករុណា ព្រះមហាវីរក្សត្រ ព្រះអាជ្ញាបិតា ព្រះបរមរតនកោដ្ឋ សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលព្រោះព្រាំ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ខ្លាំងក្លា ព្រះបញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ទិព្វព្រះសុភមង្គល ដើម្បីតង់ប្រថាប់នៅជាម្ចាស់ជំនួញត្រជាក់ត្រជុំ សម្បូរសប្បាយរង់រឿង នៃមាតុភូមិអង្គរដ៏បវរថ្លៃថ្នូរ ទិព្វប្រជានុកម្ស្រស់ខ្មែរគ្រប់រូបតរៀងទៅ។

ឱកាសនេះដែរ ខ្ញុំព្រះបង្គំយើងខ្ញុំ សូមសម្តែងថ្វាយនូវកតញ្ញូតាធម៌ ដ៏ជ្រាលជ្រៅបំផុត ចំពោះព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ដែលព្រះអង្គតែងតែយកអស់ព្រះរាជហឫទ័យ និងព្រះកាយពល គិតគូរដោទីបំផុតចំពោះសុខទុក្ខរបស់ប្រជារាស្ត្រទុំាងនគរ ដោយព្រះរាជហឫទ័យសប្បុរសប្រពៃថ្លៃថ្លាបំផុត។

សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះមេត្តាប្រោសព្រះរាជទានទោស។

ថ្ងៃ ... ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
សូមក្រាបបង្គំទូលថ្វាយនៅថ្ងៃអង្គារ ថ្ងៃទី..១៤.. ខែឧសភា ឆ្នាំ២០២៤

អគ្គនាយក

ហង់ ភៅ



សម្រស់ខ្លោងជ័យរបស់ខ្លោងទ្វារក្រុងអង្គរ ក្រោមដំណក់ទឹកភ្លៀង

ផ្សាយនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤

សម្រស់ខ្លោងជ័យរបស់ខ្លោងទ្វារក្រុងអង្គរ ក្រោមដំណក់ទឹកភ្លៀងដំបូងនារដូវវស្សាក្នុងដើមឆ្នាំ២០២៤។ តើបងប្អូនទាំងអស់គ្នានឹករលឹក រង់ចាំភ្លៀងធ្លាក់យូរប៉ុណ្ណា និងចង់មកទស្សនាប្រាសាទក្រោមដំណក់ភ្លៀង ដែលមានសម្រស់ស្រស់ស្អាតម្យ៉ាង ខុសពីពេលធម្មតាយ៉ាងណាដែរ? សូមភ្ញៀវទេសចរជាតិ និងអន្តរជាតិធ្វើដំណើរ និងទស្សនាដោយមានការប្រុងប្រយ័ត្ន ព្រមទាំងគោរពទៅតាមក្រមប្រតិបត្តិអង្គរ ដើម្បីជៀសវាងគ្រោះថ្នាក់ និងរក្សាសណ្តាប់ធ្នាប់ល្អនៅក្នុងរមណីយដ្ឋានអង្គរ៕







ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារ និងពលករនៃអាជ្ញាធរជាតិអប្សរា គាំទ្រពេញទំហឹងចំពោះគម្រោងព្រែកជីកហ្វូណនតេជោ ដែលនឹងនាំមកនូវផលប្រយោជន៍ជាប្រវត្តិសាស្ត្រដ៏ល់ប្រជាជាតិកម្ពុជា

ផ្សាយនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖.....

ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្នាំទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមប្រកាសជាឯឡាវិកគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្ត "គម្រោងព្រែកជីកហ្វូណនតេជោ" ដែលជាព្រែកជីកប្រវត្តិសាស្ត្រលើកទី១នៅកម្ពុជា ក្រោមគំនិតផ្ទូចផ្តើមប្រកបដោយចក្ខុវិស័យវៃងឆ្លាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយកដ្ឋមន្ត្រី** និងជា **ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**។ គម្រោងដែលនឹងតភ្ជាប់ផ្ទុំទឹកជាងទន្លេទៅកាន់សមុទ្រកម្ពុជា ឆ្លងកាត់ខេត្តចំនួន ៤ គឺ ខេត្តកណ្តាល តាកែវ កំពត និងខេត្តកែប ដែលមានប្រវែង១៨០គីឡូម៉ែត្រនេះ នឹងត្រូវអនុវត្តដោយរាជរដ្ឋាភិបាលអាណត្តិទី៧ ក្រោមការដឹកនាំដ៏ស្វាហាប់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយកដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

គម្រោងព្រែកជីកហ្វូណនតេជោនេះ នឹងផ្តល់អត្ថប្រយោជន៍ដ៏មហាសាលជូនប្រជាជនកម្ពុជាជូចជា៖ ការដឹកជញ្ជូនតាមផ្ទូវទឹក បង្កើតតំបន់ពាណិជ្ជកម្ម តំបន់សេដ្ឋកិច្ចពិសេស ពង្រីកតំបន់អភិវឌ្ឍន៍កសិកម្ម ជារាសាស្ត្រវារីវប្បកម្ម ជួយរំដោះទឹកជំនន់នារដូវវស្សា ជួយបង្កើនផលត្រីទឹកសាប និងជំរុញឱ្យមានការវិកចម្រើនផ្នែកអចលនទ្រព្យ និងការវិនិយោគ ព្រមទាំងបង្កើនការងារផ្សេងៗជាដើម។ល។ សក្ខីភាពនេះ ពិតជាបានសបញ្ជាក់ឱ្យឃើញកាន់តែច្បាស់អំពីការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ** ចំពោះសុខទុក្ខ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា។

ជាច្បីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវកតញ្ញុតាធម៌ភាតសរសើរដោយស្មោះ និងសូមគាំទ្រយ៉ាងពេញទំហឹងតាងាកង ចំពោះគំនិតផ្ទូចផ្តើមប្រកបដោយឯត្តមគតិជាតិខ្ពស់របស់ **សម្តេចតេជោ** ក្នុងការអនុវត្ត "គម្រោងព្រែកជីកហ្វូណនតេជោ" ដើម្បីជានាបាននូវអត្ថប្រយោជន៍ជូនសង្គមជាតិ និងប្រជាជន។

ថ្ងៃចន្ទ ៦រោច ខែចេត្រ ឆ្នាំពេង ឆស័ក ព.ស.២៥៦៧
គេប្រិមកុម ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤

អ្នកនាយក

ហាង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាជ្ញាធរជាតិអប្សរា
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel-Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bung Kong Village, Angel Commune,
Prasat Bakong District, Siem Reap Province





ក្រុមការងារស្រាវជ្រាវ ប្រទះឃើញព្រះកេសទេវតា ក្នុងកំណាយស្រាវជ្រាវ នៅខ្លោងទ្វារជ័យ

ផ្សាយនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤

កន្លងទៅថ្មីៗនេះ ក្រុមការងារកំណាយស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា បានប្រទះឃើញព្រះកេសទេវតាចំនួនមួយ ដែលបានកប់ក្នុងរណ្តៅកំណាយនៅខ្លោងទ្វារជ័យ នៃក្រុងអង្គរធំ។

កាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារស្រាវជ្រាវនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា បានប្រទះឃើញព្រះកេសទេវតាមួយកប់ក្នុងរណ្តៅកំណាយស្រាវជ្រាវ នៅបាតគ្រឹះខាងផ្នែកទេវតាទាញព្រ័ត្រ នៃខ្លោងទ្វារជ័យ។



លោក អន សុភាព បុរាណវិទូ ដែលកំពុងធ្វើកំណាយនៅខ្លោងទ្វារជ័យបានបញ្ជាក់ថា ជាងពីរសប្តាហ៍មកហើយ ដែលក្រុមការងារបស់លោកបាននិងកំពុងធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យា នៅខ្លោងទ្វារជ័យនេះ។ លោកបញ្ជាក់ថា ការងារនេះធ្វើឡើងក្នុងបំណងពិនិត្យមើលរចនាសម្ព័ន្ធបាតគ្រឹះ ចម្លាក់កូរសមុទ្រទឹកដោះ ដើម្បីរៀបចំបង្ក្រប់ឯកសារក្នុងគម្រោងជួសជុលចំណុចនេះឡើងវិញ។

តាមការលើកឡើងរបស់លោក អន សុភាព ជាការចែដន្យក្នុងពេលក្រុមការងារលោកកំពុងកំណាយនោះ ក៏បានប្រទះឃើញព្រះកេសមួយនៅស្អាត កប់ក្នុងរណ្តៅជើងគ្រឹះទេវតាទាញព្រ័ត្រតែម្តង។ ក្រោយការសិក្សា និងពិនិត្យ អ្នកជំនាញសន្និដ្ឋានថា ព្រះកេសនោះបានបាក់ធ្លាក់ពីរូបទេវតា នៅចំណុចលេខទី២៣ បើរាប់ពីជួរខាងមុខមក។ ព្រះកេសធ្វើពីថ្មភក់នេះមានបណ្តោយ ២០ស.ម ទទឹង១១ស.ម និងកម្ពស់ ១២ស.ម។



ក្រោយកំណាយស្រាវជ្រាវបានមួយផ្នែកធំ អ្នកជំនាញបានសន្និដ្ឋានថា គ្រឹះចម្លាក់កូរសមុទ្រទឹកដោះ នៅខ្លោងទ្វារជ័យនេះនៅមានភាពមាំល្អ ព្រោះធ្លាប់បានជួសជុលម្តងនៅសម័យកណ្តាល និងសម័យបារាំង។ យ៉ាងណា លោក អន សុភាព បញ្ជាក់ថា តាមការឱ្យយោបល់ពីអ្នកពាក់ព័ន្ធ គេត្រូវកំណាយស្រាវជ្រាវនៅផ្នែកខាងលើបន្ថែមទៀត មើលស្ថានភាពតួស្ពានទាំងមូល ដើម្បីមើលស្ថានភាពជួសជុលនៅពេលនោះឱ្យបានល្អិតល្អន់ មុននឹងមានគម្រោងជួសជុលចម្លាក់កូរសមុទ្រទឹកដោះ នាពេលខាងមុខ៕



ក្រុមការងារពិនិត្យ និងតាមដានការសាងសង់របស់ពលរដ្ឋ ដែលជាអ្នកស្រុកចាស់ ក្នុងតំបន់រមណីយដ្ឋានអង្គរ ក្រោយទទួលបានការអនុញ្ញាត បានចំនួន២៣២ករណី

ផ្សាយនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤

នៅក្នុងសប្តាហ៍ទី២ នៃខែឧសភា ឆ្នាំ២០២៤នេះ ក្រុមការងារពិនិត្យ និងតាមដានការសាងសង់របស់ពលរដ្ឋ ដែលជាអ្នកស្រុកចាស់ បានចុះពិនិត្យ និងផ្តល់លក្ខណៈបច្ចេកទេស នូវសំណង់ដែលបានការអនុញ្ញាត កន្លងមក ចំនួន៧៩ករណី និងការជួសជុលតូចតាច ដោយក្រុមការងារសហគមន៍ ចំនួន ១៥៣ករណី ដែលស្ថិតក្នុងភូមិសាស្ត្រ ដូចខាងក្រោម៖

១. ក្រុងសៀមរាប ចំនួន៦៧ករណី
២. ស្រុកប្រាសាទបាគង ចំនួន៣៤ករណី
៣. ស្រុកបន្ទាយស្រី ចំនួន៣៦ករណី
៤. ស្រុកពួក ចំនួន៥៨ករណី
៥. ស្រុកអង្គរធំ ចំនួន៣៧ករណី



នៅក្នុងចំណោម ២៣២ករណី មាន១៥៥ករណី សាងសង់ និងជួសជុលត្រឹមត្រូវ តាមការអនុញ្ញាត មាន៧៦ករណី មិនទាន់សាងសង់ និង ជួសជុលនៅឡើយ និង មាន០១ករណី សាងសង់ និងជួសជុលពុំត្រឹមត្រូវតាមការអនុញ្ញាត។



ករណីដែលប្រជាពលរដ្ឋសាងសង់ពុំត្រឹមត្រូវតាមការអនុញ្ញាត ក្រុមការងារបានសម្របសម្រួលឱ្យពួកគាត់កែប្រែឡើងវិញ ឬត្រូវបញ្ឈប់ការសាងសង់តែម្តង។ ក្រុមការងារបច្ចេកទេស និងបន្តតាមដានការសាងសង់ និងជួសជុលរហូតដល់ការអនុញ្ញាតផុតសុពលភាព និងការសាងសង់រួចរាល់មួយរយភាគរយ។



សូមជ្រាបថា ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរ ដែលជាអ្នកស្រុកចាស់ ត្រូវទទួលបានការអនុញ្ញាតសាងសង់សំណង់នានាស្របតាមគោលការណ៍ច្បាប់ ដែលមានសុពលភាព០១ឆ្នាំ និងការងារជួសជុលតូចតាច (ដោយក្រុមការងារសហគមន៍) មានសុពលភាពរយៈពេល ០៣ខែ។ រាល់សំណង់នានា ដែលនៅមានសុពលភាពត្រូវបាននាយកដ្ឋានគ្រប់គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃជាប្រចាំ រហូតសំណង់ទាំងនោះ សង់រួចរាល់មួយរយភាគរយ៕



ក្រុមការងារស្រាវជ្រាវ ប្រទះឃើញព្រះកេសទេវតា ក្នុងកំណាយស្រាវជ្រាវ នៅខ្លោចទ្វារជ័យ

ផ្សាយនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៤

នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាជាតិអប្សរា បានរៀបចំធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្របុរាណតំបន់អង្គរដល់និស្សិតសិង្ហបុរី នៃសាកលវិទ្យាល័យជាតិសិង្ហបុរីចំនួន២៦នាក់ និស្សិតកម្ពុជា នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រ ចំនួន ១៤នាក់ និងសាស្ត្រាចារ្យសិង្ហបុរីចំនួន១នាក់ សរុបចំនួន៤១នាក់ នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ នៅសាលប្រជុំនាយកដ្ឋានសណ្តាប់ធ្នាប់។





លោក ឡៃ ប៉ូទី អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ មានប្រសាសន៍ថា បទបង្ហាញនេះបានលើកឡើងនូវដីរប្រវត្តិនៃតំបន់អង្គរ ចាប់ពីការរីកចម្រើនខ្ពង់ខ្ពស់ រហូតដល់សម័យកាលបោះបង់ចោលទីក្រុងអង្គរ ដែលនាំឱ្យមានកង្វះការជួសជុលថែទាំ ធ្វើឱ្យប្រព័ន្ធធារាសាស្ត្របុរាណរងការខូចខាត ឈប់ដំណើរការ។ លោក ឡៃ ប៉ូទី បន្ថែមថា ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ការងារជួសជុលស្តារប្រព័ន្ធធារាសាស្ត្របុរាណដែលអត់ដំណើរការជាង៥០០ឆ្នាំ ឱ្យមានដំណើរការឡើងវិញ និងអាចគ្រប់គ្រងចាត់ចែងទឹកបានប្រើប្រាស់គ្រប់គ្រាន់ពោល គឺនៅរដូវប្រាំងឱ្យមានទឹកជាប្រចាំ ហើយនៅរដូវវស្សា គឺការពារកុំឱ្យមានទឹកជំនន់ទាំងក្នុងតំបន់អង្គរ និងក្រុងសៀមរាបទាំងមូលដែរ។



លោក ឡៃ ប៉ូទី ឱ្យដឹងទៀតថា ការធ្វើបទបង្ហាញនេះ ពិតជាមានសារសំខាន់ណាស់ សម្រាប់ការចែករំលែក បទពិសោធន៍ការងារក្នុងតំបន់បេតិកភណ្ឌ និងចំណេះដឹងការគ្រប់គ្រងទឹក និងការស្តារប្រព័ន្ធធារាសាស្ត្របុរាណ នៅតំបន់អង្គរ ឱ្យមានដំណើរការឡើងវិញ ព្រោះថា ប្រទេសជិតខាងមានការចាប់អារម្មណ៍ខ្លាំងទៅលើកិច្ចការងារគ្រប់គ្រង អភិរក្សប្រព័ន្ធធារាសាស្ត្រនៅក្នុងតំបន់អង្គរយើង និងបានផ្សព្វផ្សាយនូវកេរដំណែលរបស់ជូនតាយើងនាសម័យអង្គរដែលមានភាពល្បីល្បាញឈានដល់កម្រិតកំពូលផ្នែកធារាសាស្ត្រ ដែលមានដូចជា បារាយណ៍ស្តុកទឹក ប្រព័ន្ធធារាសាស្ត្រខ្វាត់ខ្វែង។ នេះជាការចែករំលែកចំណេះដឹងដល់និស្សិតខ្មែរ និងនិស្សិតប្រទេសសិង្ហបុរី ឱ្យយល់ដឹងបច្ចេកវិទ្យាបុរាណរបស់ខ្មែរមានភាពទំនើបបែបណា បើធៀបទៅនឹងប្រទេសទូទាំងពិភពលោកក្នុងអំឡុង





សតវត្សរ៍ទី៩ ទី១០ ដល់សតវត្សរ៍ទី១៥ ក្នុងសម័យអង្គរ ដែលរុងរឿងលើគ្រប់វិស័យ ពិសេសការរៀបចំប្រព័ន្ធធារាសាស្ត្រ បើធៀបទៅបណ្តាតំបន់ផ្សេងៗ គឺចក្រភពខ្មែរមុនគេ។

បន្ទាប់ពីធ្វើបទបង្ហាញរួច អាជ្ញាធរជាតិអប្សរា បានដឹកនាំនិស្សិតទៅសិក្សាស្វែងយល់ដោយផ្ទាល់នូវប្រព័ន្ធធារាសាស្ត្រមួយចំនួនសំខាន់ៗនៅក្នុងតំបន់អង្គរ ដែលអាជ្ញាធរជាតិអប្សរា បានជួសជុល និងស្តារឡើងវិញ។

ស្វែងយល់ពីរបៀបចាត់ចែងប្រព័ន្ធទឹក ប្រភពទឹក បង្ហាញថា រដូវប្រាំងជារដូវរីងស្ងួតទូទាំងប្រទេស តែក្នុងតំបន់អង្គរអាចរក្សាទឹកបានជាប្រចាំ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ.អាជ្ញ/រប.សជ/

សេចក្តីជូនដំណឹង
ស្តីពី
ការបើកឱ្យវិញការទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូប នៃរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា បច្ចុប្បន្ន អាជ្ញាធរជាតិអប្សរាបានជួសជុលរួចរាល់នូវទីតាំងដែលមានហានិភ័យរបស់ប្រាសាទប្រែរូប។ ក្នុងន័យដើម្បីបន្ថែមបទពិសោធន៍ថ្មីជូនភ្ញៀវទេសចរជាតិ និងអន្តរជាតិ អាជ្ញាធរជាតិអប្សរា នឹងបើកឡើងវិញការទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូប នៃរមណីយដ្ឋានអង្គរ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

សេចក្តីជូនចាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែ.ពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
សៀមរាប ថ្ងៃទី ១៦ ខែ.ឧសភា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន ភូមិបន្ទាយ ឃុំក្រឹស
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរា និងស៊ុមចំនត់អគ្គី
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Koreng Village, Angkrl Commune,
Prasat Bakong District, Siem Reap Province

សេចក្តីជូនដំណឹង ស្តីពីការបើកឡើងវិញ ការទស្សនាថ្ងៃលិច នៅប្រាសាទប្រែរូប នៃរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤



អ្នកជំនាញជួសជុលនៅប្រាសាទជម ខិតខំស្វែងរកប្រភពដើមថ្ម ដែលជ្រុះធ្លាក់រាយប៉ាយ មកជួសជុលឡើងវិញ

ផ្សាយនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៤

ក្រុមការងារជួសជុលប្រាសាទជម បានបំពេញការងារ សម្រង់ប្លង់ ថតរូប រៀបចំចុះបញ្ជីថ្ម រាប់រយដុំ ដែលបានរលុះធ្លាក់រាយប៉ាយនៅលើដី និងបែងចែកទៅតាមប្រភេទថ្ម ដើម្បីស្វែងរកទីតាំងដើម ហើយនឹងរៀបចំជួសជុលប្រាសាទនេះឱ្យបានពេញលេញតាមលក្ខណៈដើមឡើងវិញ ដោយព្យាយាមប្រើប្រាស់ថ្មថ្មីតិចបំផុត។ បច្ចុប្បន្ន ក្រុមការងារកំពុងសាកល្បងផ្គុំថ្មទៅតាមលំនាំដើម បានចំនួនជាង២០០ដុំ ក្នុងចំណោមថ្មប្រមាណ៧០០ដុំ ដែលបន្តស្វែងរកទីតាំងដើម។

ស្ថាបត្យករនៃអាជ្ញាធរជាតិអប្សរា លោក ថៃ យ៉ាម៉ង់ ដែលកំពុងរៀបចំផ្គុំសាកល្បងថ្មនៅបរិវេណខាងជើងប្រាសាទ បានឱ្យដឹងថា ចំនួនថ្មរាប់រយដុំទាំងអស់នេះ កាលមុនរៀបចំជួសជុល គឺស្ថិតនៅក្នុងបរិវេណប្រាសាទ ខ្លះកប់ក្នុងដី និងខ្លះទៀតនៅគរលើគ្នា។ ក្រោយមកក្រុមការងារបានថតរូប ចុះបញ្ជី សម្រង់ប្លង់ និងរើថ្មទាំងនេះទៅដាក់នៅខាងក្រៅបរិវេណប្រាសាទ ដើម្បីងាយស្រួលបំពេញការងារ។ ជាមួយគ្នានេះដែរ ក្រុមការងារក៏បានកំណត់អត្តសញ្ញាណ និងវាស់វែងដុំថ្មនីមួយៗ ព្រមទាំងបានបែងចែកទៅតាមប្រភេទដូចជាថ្មហោជាង ថ្មដំបូល ថ្មខឿន និងថ្មជញ្ជាំងជាដើម មុននឹងសាកល្បងផ្គុំទៅតាមបច្ចេកទេសនិងទម្រង់របស់ថ្មនីមួយៗនៃប្រាសាទ។



លោក ថៃ យ៉ាម៉ង់ បញ្ជាក់ទៀតថា មកដល់ពេលនេះ ក្រុមការងារបានរកឃើញថ្ម និងបានផ្គុំសាកល្បងត្រូវតាមលំនាំដើមរបស់រចនាសម្ពន្ធនៃប្រាសាទ ក្នុងនោះមានហោជាងទាំង៤ទិស និងថ្មកំពូលប្រាសាទមានរាងជាផ្កាឈូក ថ្មខឿន ថ្មជញ្ជាំង ថ្មកំពូលជាដើម។

ទោះបីមានការលំបាកយ៉ាងណាក្តី ក្រុមការងារនៅតែបន្តខិតខំប្រឹងប្រែងស្វែងរកថ្មដែលជ្រុះធ្លាក់លាយឡំគ្នាទាំងនេះ។ ចំពោះបញ្ហាដែលថ្មខ្លះពុកផុយ ខ្លះបាក់បែក និងខ្លះទៀតសឹករិចរិលរលុបនូវក្បាច់ធ្វើឱ្យពិបាកបែងចែកប្រភេទ និងពិបាកកំណត់ប្រភពនៃទីតាំងដើមគឺក្រុមការងារត្រូវការចំណាយពេលវេលាមួយសមស្រប ដើម្បីជួសជុលនិងស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយ។ ការព្យាយាមរបស់អ្នកជួសជុល និងអភិរក្សជំនាន់ថ្មីនេះ ដើម្បីការពារនិងលើកតម្លៃប្រាសាទជម ដែលជាកេរដូនតាខ្មែរឱ្យបាននូវលក្ខណៈដើមឡើងវិញ និងគង់វង្សបានយូរអង្វែងតទៅទៀត៕





រូបភាពប្រចាំសប្តាហ៍៖
ទិដ្ឋភាពប្រាសាទប្រែរូបពីលើអាកាស

ផ្សាយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤





ប្រាសាទប្រែរូប ទីទស្សនាថ្មៃលិចដ៏ទាក់ទាញមួយទៀត នៅតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤



ក្រៅពីប្រាសាទភ្នំបាខែង នៅក្នុងរមណីយដ្ឋានអង្គរ មានកន្លែងទស្សនាថ្ងៃលិចមួយចំនួនទៀត ដែលភ្ញៀវទេសចរអាចទៅទស្សនាបាន រួមមាន ខ្លោងទ្វារទន្លេអុំ ស្រះស្រង់ និងប្រាសាទប្រែរូបជាដើម។ កាលពីពេលថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានបើកឱ្យចូលទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូបឡើងវិញ បន្ទាប់ពីបិទមួយរយៈដោយសារការងារជួសជុលមួយចំនួន។ ក្នុងន័យនេះ សាធារណជន ក៏ដូចជាភ្ញៀវទេសចរអាចចូលទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូបបាន ដែលមានទស្សនីយភាពដ៏ស្រស់ស្អាត សូប់ស្ងាត់ និងប្លែកអារម្មណ៍៕



នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារភ្នាក់ងារទេសចរប្រចាំតាមដៅប្រាសាទអង្គវត្ត និងប្រាសាទភ្នំបាខែង បានប្រទះឃើញកាមេរ៉ាចំនួនមួយគ្រឿង ម៉ាក Canon នៅចំណុចលើបន្ទប់ ខាងក្រោយលោកយាយសួស និងបានសហការជាមួយអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់អណ្តើយដ្ឋានអង្គរ ប្រគល់ជូនម្ចាស់ដើមវិញ ដែលជាភ្ញៀវទេសចរជាតិ ក្រោយពីពិនិត្យឃើញថាពិតជាម្ចាស់ពិតប្រាកដមែន

ផ្សាយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤







រូបភាពប្រចាំសប្តាហ៍៖ សម្រស់ដ៏ល្អឯករបស់ប្រាសាទចៅសាយទេវតា ដែលទាក់ក្បែកទេសចរចូលទស្សនាមិនដែលរំលង

ផ្សាយនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤









ទិដ្ឋភាពស្រះស្រង់នាព្រឹកព្រលឹម ថ្ងៃទី១៩ ឧសភា ២០២៤

ផ្សាយនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤





វត្តព្រះឥន្ទទេព ក្នុងបរិវេណអតីតនៃក្រុងអង្គរធំ បំបួសកុលបុត្រ កុលធីតាចំនួន៥៤០រូប

ផ្សាយនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ នៅវត្តព្រះឥន្ទទេព នៅក្នុងបរិវេណនៃអតីតក្រុងអង្គរធំ បានប្រារព្ធធ្វើពិធីបុណ្យពិសាខបូជា ដោយក្នុងនោះមានកោរសក់ បួងសក់ បំបួសកុលបុត្រ កុលធីតាខ្មែរ ចំនួន៥៤០រូប ចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៤ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ ក្នុងបំណងជួយអប់រំសីលធម៌ ចរិយាធម៌ និងលើកកម្ពស់វិស័យព្រះពុទ្ធសាសនាដល់យុវជនខ្មែរទាំងឡាយណាដែលចង់ស្វែងយល់អំពីព្រះធម៌ក្នុងព្រះពុទ្ធសាសនា និងអប់រំផ្លូវចិត្ត ផ្លូវកាយ សម្រាប់បំភ្លឺផ្លូវទៅអនាគត។



ពិធីកោរសក់ បួងសក់ បំបួសកុលបុត្រ កុលធីតា ចំនួន៥៤០រូបនេះ ក្រោមព្រះអធិបតីភាព **ព្រះសុមង្គលសិលាចារ្យ អគ្គាភរោ ជុំ គឹមឡេង** ជាព្រះមេគណខេត្តសៀមរាប និងជាប្រធានក្រុមប្រឹក្សាកិច្ចការវត្តអារាមនៅឧទ្យានអង្គរ ព្រះមេគណខេត្តសៀមរាប **លោកជំទាវ ញ៉ែម សាខន ស ខេង** និង **លោកជំទាវ កែ សួនសុគី ស សុខា** និងលោក ង៉ូវ សេងកាក់ អភិបាលរងខេត្តសៀមរាប ព្រមទាំងពុទ្ធបរិស័ទមកពីច្រើនមជ្ឈដ្ឋាន។



ពិធីបុណ្យពិសាខបូជា គឺជាពិធីបុណ្យរំឭកនូវព្រឹត្តិការណ៍ធំៗចំនួនបី នាសម័យកាលរបស់ព្រះសម្មាសម្ពុទ្ធសមណគោតម គឺថ្ងៃដែលព្រះអង្គទ្រង់ប្រសូត បានត្រាស់ដឹង និងបរិនិព្វាន។ ព្រឹត្តិការណ៍ទាំងបីនេះ គឺកើតឡើងនៅចំថ្ងៃ ១៥កើតពេញបូណ៌មី ដែលមានព្រះចន្ទពេញវង់ ក្នុងខែពិសាខដូចគ្នា ខុសតែឆ្នាំប៉ុណ្ណោះ។ នៅថ្ងៃពុធ១៥កើត ខែពិសាខ ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤នេះ គឺជាទិវាមួយដែលពុទ្ធសាសនិកជននៅក្នុងប្រទេសកម្ពុជា និងនៅទូទាំងសកលលោកតែងនាំគ្នាប្រារព្ធពិធីបុណ្យដ៏សំខាន់មួយនេះ គឺ «ពិសាខបូជា»។។



ការចោលសំរាមពាសវាលពាសកាល នៅតែជាបញ្ហានៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៤



សព្វថ្ងៃនេះ បើទោះក្រុមការងារផ្នែកបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា បានខិតខំយកចិត្តទុកដាក់សម្អាត និងប្រមូលសំរាមបានល្អប្រសើរយ៉ាងណាក៏ដោយ ក៏នៅតែមានភ្ញៀវទេសចរមួយចំនួនបោះសំរាមចោលពាសវាលពាសកាលដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាពរមណីយដ្ឋានអង្គរ។ អាជ្ញាធរជាតិអប្សរា អំពាវនាវដល់ភ្ញៀវទេសចរទាំងអស់សូមប្រកាន់ខ្ជាប់នូវអនាម័យ ទុកដាក់សំរាមនៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ រួមគ្នាលើកតម្លៃរមណីយដ្ឋានអង្គរនៃយើងគ្រប់ៗគ្នា។







អាជ្ញាធរជាតិអប្សរា កំពុងជួសជុលរានហាល និងបង្គាន់ដៃនាគ នៅប្រាសាទបន្ទាយសំរែ

ផ្សាយនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

ក្រុមអ្នកបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងចាប់ផ្តើមជួសជុលរានហាល និងបង្គាន់ដៃនាគ នៅប៉ែកខាងកើតនៃជ្រុងខាងលិចឆៀងខាងជើង របស់ប្រាសាទបន្ទាយសំរែ។

គម្រោងជួសជុលនេះ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ជាមួយនិងស្ថាប័នGIZ នៃប្រទេសអាល្លឺម៉ង់។អ្នកជំនាញអភិរក្សថ្ម នៃនាយកដ្ឋានអភិរក្សប្រាសាទនិងបុរាណវិទ្យា លោក ឡុង ណារី ឱ្យដឹងថា បច្ចុប្បន្នរានហាល នៅប៉ែកខាងកើត នៃជ្រុងខាងលិច ឆៀងខាងជើងរបស់ប្រាសាទបន្ទាយសំរែ ចាំបាច់ត្រូវពង្រឹងគ្រឹះ និងរចនាសម្ពន្ធឱ្យរឹងមាំឡើងវិញ ពីព្រោះ គ្រឹះរបស់រានហាលនេះ កន្លែងខ្លះទ្រុឌទ្រោមខ្លាំង កន្លែងខ្លះប្រេះបែកថ្មធ្វើឱ្យរចនាសម្ពន្ធ មិនរឹងមាំ។



ចំណែកឯ បង្គាន់ដៃនាគនៅផ្នែកខាងលើរបស់រានហាលវិញ ក្រុមអ្នកបច្ចេកទេសកំពុងជួសជុលឡើងវិញទៅតាមអ្វីដែលអាចធ្វើទៅបាន។

លោក ឡុង ណារី មានបញ្ជាក់ទៀតថា បច្ចុប្បន្ន ក្រុមការងារបានរើថ្ម បង្គាន់ដៃនាគខ្លះ ដែលបានរលំ និងផ្ទាំងថ្មខ្លះ បានក្រៀកញែកចេញពីគ្នា រួចហើយ ព្យាយាមរុញចូលគ្នាឡើងវិញ។ ក្នុងការជួសជុល បង្គាន់ដៃនាគនេះដែរ គឺបានប្រើការប្រភេទ Fiber Glass ដើម្បីបិទភ្ជាប់ថ្មដែលបែកឡើងវិញ ព្រមទាំងប្រើសរសៃដែកថែប ដើម្បីតភ្ជាប់តំណថ្ម និងជួយទ្រទម្ងន់ថ្មខ្លះផង។ ចំពោះបង្គាន់ដៃចាស់ខ្លះ ដែលបែករកបំណែកមិនឃើញ គឺក្រុមការងារបាន ប្រើថ្មថ្មីមកបិទបំពេញ ចំណែកកន្លែងខ្លះដែលបាត់ថ្ម គឺត្រូវយកថ្មថ្មីមកឆ្លាក់ហើយដាក់ជំនួស។



បច្ចុប្បន្ននេះ រានហាល និងបង្គាន់ដៃនាគ នៅប៉ែកខាងកើតនៃជ្រុងខាងលិចឆៀងខាងជើងរបស់ប្រាសាទបន្ទាយសំរែ មានថ្មខូចខាតជាច្រើនប្រភេទ ដោយកន្លែងខ្លះថ្មបានបែកពីលើ កន្លែងខ្លះបែកពីក្រោម កន្លែងខ្លះបែកពីចំហៀង និងកន្លែងខ្លះទៀតថ្ម មានសភាពពុកផុយ ដែលទាមទារឱ្យអ្នកបច្ចេកទេសត្រូវធ្វើការព្យាបាល និងដកជាតិអំបិលចេញពីថ្ម មុននឹងយកដាក់ទៅតាមកន្លែងដើមឡើងវិញ៕



ការនិយមផលិត និងប្រើប្រាស់ធូបខ្មែរ ក្នុងកិច្ចពិធីនានារបស់អ្នកស្រុកអង្គរ

ផ្សាយនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤

បច្ចុប្បន្ននេះ ធូបខ្មែរនៅមានការនិយមប្រើប្រាស់តាមវត្តអារាម និងក្នុងកិច្ចពិធីនានានៅក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ ពិសេសអ្នកស្រុកអង្គរ ដែលធូបទាំងនេះត្រូវបានផលិតដោយអ្នកស្រុកអង្គរផ្ទាល់ ហើយយកវត្ថុធាតុដើមក្នុងតំបន់មកផលិត និងមានគុណភាពល្អ ហើយភាគច្រើនធ្វើឡើងដោយមនុស្សមានវ័យចំណាស់ប៉ុណ្ណោះ។







ការគាំទ្រដោយប្រើប្រាស់ធូបខ្មែរ គឺប្រៀបបានដាការថែរក្សាចំណេះដឹង និងជំនាញបន្តដល់កូនចៅជំនាន់ក្រោយ ដែលមនុស្សនៅក្នុងតំបន់អង្គរ តែងតែចែករំលែកពីមួយជំនាន់ទៅមួយជំនាន់មិនឱ្យបាត់បង់ ទើបនៅតំបន់អង្គរមានវប្បធម៌សម្បុរបែបនៅរស់ក្នុងជីវភាពប្រចាំថ្ងៃរបស់ប្រជាជនក្នុងភូមិស្រុក។

ក្រុមការងារស្រាវជ្រាវនៃអាជ្ញាធរជាតិអប្សរា តែងតែខិតខំចងក្រងប្រមូលនូវទំនៀមទម្លាប់ប្រពៃណីក្នុងតំបន់អង្គរមកផ្សព្វផ្សាយ និងសូមគាំទ្រចំពោះការថែរក្សាមរតកវប្បធម៌ទាំងនេះឱ្យមានភាពរស់រវើក ថែមទាំងលើកទឹកចិត្តឱ្យប្រជាជនខ្មែរ ងាកមកគាំទ្រផលិតផលខ្មែរ ដើម្បីលើកស្ទួយជីវភាពប្រជាជនផង និងការអភិរក្សផង៕

អាជ្ញាធរជាតិអប្សរា រៀបចំសិក្ខាសាលាផ្ទៃក្នុង ស្តីពីៈ ដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថាន ដើម្បីតំបន់អង្គរ

ផ្សាយនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤



កាលពីព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ នាសាលសន្និសីទអង្គរ អាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាផ្ទៃក្នុងស្តីពីៈ ដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ ជូនដល់មន្ត្រី-បុគ្គលិក មកពីនាយកដ្ឋាននានា សរុបចំនួន១០០នាក់។ សិក្ខាសាលានេះ មានគោលបំណង ដើម្បីផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់សៀវភៅប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ យល់ដឹងពីសកម្មភាពរបស់នាយកដ្ឋាននីមួយៗ ឈ្វេងយល់ និងចូលរួមការពារបរិស្ថាន ក្នុងតំបន់អង្គរ។

ឯកឧត្តម សុខ លក្ខិណា អ្នកតំណាងគ្រប់គ្រងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ក្នុងសិក្ខាសាលា នាឱកាសនោះថា សិក្ខាសាលានេះពិតជាមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការងារគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់អង្គរ ជាពិសេសអនុវត្តនូវគោលនយោបាយ និងចក្ខុវិស័យច្បាស់លាស់ ដែលអាជ្ញាធរជាតិអប្សរាបានដាក់ចេញ រួមមានៈ កិច្ចការពារថែរក្សាទេសភាព វប្បធម៌ បរិស្ថាន និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ ការអនុវត្តច្បាប់ និងជំរុញការកែលម្អ ដោយផ្អែកតាមគោលនយោបាយនានាជាដើម។ ឯកឧត្តម បានជំរុញណែនាំដល់សិក្ខាកាមទាំងអស់ សូមយកចិត្តទុកដាក់សិក្សា ស្តាប់ការធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលានេះ ដើម្បីទទួលបានបទពិសោធន៍ល្អៗយកទៅអនុវត្តន៍ ក្នុងការងារប្រចាំថ្ងៃ។

សូមបញ្ជាក់ដែរថា អាជ្ញាធរជាតិអប្សរា តែងតែបានរៀបចំសិក្ខាសាលាស្តីពីៈ ដំណើរការអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានដើម្បីតំបន់អង្គរ ដល់មន្ត្រី-បុគ្គលិក ជាទៀងទាត់ ៤ដងក្នុងមួយឆ្នាំ។ ដើម្បីឱ្យមន្ត្រី-បុគ្គលិកគ្រប់ៗរូបបានចូលរួមអនុវត្តប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ដើម្បីជួយថែរក្សា ការពារមរតក និងបរិស្ថានអង្គរឱ្យបានគង់វង្ស៕







នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ នាទីស្នាក់ការ សហជីពអន្តរសង្កាត់គ្រប់គ្រងទឹក នៃជ្រលងប៊ីយ៉ែវ (SIAVB) ប្រទេសបារាំង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារជាមួយ លោក Jean-Michel Bordes អគ្គនាយក SIAVB និងលោក Jacques Bellier ប្រធានសមាគម AGERA និងមន្ត្រីបច្ចេកទេសរបស់ស្ថាប័នផ្សេងៗ នៃគម្រោង«ប្រព័ន្ធជំនួយស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរ (SDGERA)» ដើម្បីពិនិត្យលើកិច្ចការបច្ចេកទេសក្នុងការត្រៀមយកស្ថានីយគ្រប់គ្រងទឹកដោយស្វ័យប្រវត្តិទៅដំឡើងនៅរមណីយដ្ឋានអង្គរ ចំនួន៦ស្ថានីយ នាខែមិថុនា ខាងមុខនេះ។

អាជ្ញាធរជាតិអប្សរា នឹងដំឡើងស្ថានីយគ្រប់គ្រងទឹកស្វ័យប្រវត្តិ នៅរមណីយដ្ឋានអង្គរ ដោយសហការជាមួយសហជីពអន្តរសង្ឋាត់គ្រប់គ្រងទឹក នៃជ្រលងប៊ីយ៉ែវ ប្រទេសបារាំង

ផ្សាយនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤





សូមរំលឹកឡើងវិញថា កាលពីខែវិច្ឆិកា ឆ្នាំ២០២៣ **លោកជំទាវ បណ្ឌិតសភាចារ្យ គឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្ប: និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានដឹកនាំគណ:ប្រតិភូអញ្ជើញចូលរួមការសម្ពោធសាកល្បងនៃស្ថានីយនេះ នៅទីស្នាក់ការ SIAVB។ ក្នុងពេលនេះ ជាលទ្ធផលស្ថានីយដែលបានដំឡើងសាកល្បងនៅ SIAVB នាពេលនោះ ទទួលបានលទ្ធផលប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា និងសហជីពអន្តរសង្កាត់ជ្រលងប៊ីយ៉ែវ (SIAVB) បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការវិមជ្ឈការនៅក្នុងគម្រោងប្រព័ន្ធជំនួយស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរ (SDGERA) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២២។

អ្នកភូមិចំណុះជើងវត្តអាធ្វា រៀបចំពិធីបុណ្យឆាន់ដា និងពិសាខបូជា នៅទួលតាមឿង តាមទំនៀមបុរាណ

ផ្សាយនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤



រយៈពេល៣ថ្ងៃ ២យប់ ចាប់ពីថ្ងៃទី២១ ខែឧសភា ដល់ទី២៣ ខែឧសភា ឆ្នាំ២០២៤ អ្នកភូមិជើងវត្តអាធ្វា រៀបចំពិធីបុណ្យឆាន់ដា និងពិសាខបូជា នៅទួលតាមឿង តាមទំនៀមបុរាណដែលតែងតែប្រារព្ធធ្វើឡើង ក្នុងគោលបំណងឧទ្ទិសកុសល់ដល់បុព្វការីជនទាំង៧សន្តាន ផ្តាច់កម្មផ្តាច់ពៀរសុំសេចក្តីសុខដោយប្រារព្ធក្លាប់នូវពិធីបុណ្យពិសាខបូជាផង។



លោកព្រឹទ្ធាចារ្យ ម៉ក់ សារ៉ែម អាយុ៧៧ឆ្នាំ រៀបរាប់ឱ្យដឹងថា វិធីបុណ្យនេះបានបន្តធ្វើឡើងតាមទំនៀមទម្លាប់បុរាណរៀងមក ដោយធ្វើឡើងនៅទួលតាមឿង និងកំណត់យកថ្ងៃពេញបូរណ៌មី ខែពិសាខបូជាមានចំនួន៣ថ្ងៃ ២យប់។ លោកបានបន្តថា កិច្ចពិធីមាននៅក្នុងថ្ងៃទី១ គឺឡើងរោង រៀបចំគ្រឿងរណ្តាប់ គ្រឿងសក្ការបូជាផ្សេងៗសម្រាប់ប្រើប្រាស់។ នាពេលរសៀលធ្វើកិច្ចពិធីបួងសួង បើកព្រះនេត្រព្រះ និងចម្រើនព្រះបរិត្ត។ ថ្ងៃទី២ ព្រឹកឡើងរៀបចំពិធីឆ្លង រួមមានឆ្លងព្រះ ឆ្លងភ្នំខ្សាច់ និងទេសនាអានិសង្សភ្នំខ្សាច់។ លុះល្ងាចឡើងរៀបចំសូត្រមន្ត ឆាន់ដា ទក្ខិណានុប្បទានជូនដល់ជូនតា ដែលអនិច្ចកម្មទៅ។ មិនថាតែញាតិ ឬអញ្ញាតិដែលអនិច្ចកម្មទាំងប៉ុន្មាន ដូចជាអ្នកបានតស៊ូក្នុងកិច្ចការពារប្រទេសជាតិក៏មកទទួលអនុមោទនាបានដូចគ្នា។ ថ្ងៃទី៣ ព្រឹកឡើង ឆាន់ដាឆ្លង ផ្សឹកភ្នំខ្សាច់ និងរាប់បាត្រជាកិច្ចនៃការបង្ហើយបុណ្យ។



ក្នុងកម្មពិធីនេះ មានភាពអធិកអធមក្រៃលែង។ ប្រជាពលរដ្ឋប្រុស-ស្រី ចាស់-ក្មេង ចំណុះជើងវត្តអាធ្វា រួមមាន ភូមិក្រសាំងរលើង ភូមិទ្រាក ភូមិដូនវង ភូមិធំ ភូមិកក្រាញ់ ភូមិស្ពានជ្រៅ មករៀបចំធ្វើរោងបុណ្យ រៀបចំគ្រឿងសក្ការបូជា ធ្វើចង្ហាន់ប្រគេនព្រះសង្ឃ ម្ហូបអាហារសម្រាប់ទទួលភ្ញៀវ ដែលមកចូលរួមក្នុងពិធីបុណ្យ និងធ្វើកិច្ចនៅក្នុងពិធីតាមសទ្ធាជ្រះថ្លាយ៉ាងច្រើនកុះករ ដែលជាទំនៀមរបស់អ្នកភូមិចំណុះវត្តអធ្វាតែងតែមូលមាត់គ្នាប្រារព្ធជារៀងរាល់ឆ្នាំមិនដែលអាក់ខានឡើយ៕



អង្គរ និងវែរសៃ (Versailles ប្រទេសបារាំង) ពង្រឹងកិច្ចសហប្រតិបត្តិការលើគម្រោង SDGERA

ផ្សាយនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ បានជួបពិភាក្សាការងារជាមួយលោក François De Mazières អភិបាលក្រុងវែរសៃ និងជាប្រធានឧទ្យានវែរសៃ (Versailles Grand Parc) នៅសាលាក្រុងវែរសៃ ប្រទេសបារាំង ដោយមានការចូលរួមពីលោក Francisque Vigouroux ប្រធាន SIAVB និងជាប្រធានសមាគមចៅសង្កាត់នៃតំបន់ Essonne លោក Jean-Michel Bordes អគ្គនាយកសហជីពអន្តរសង្កាត់គ្រប់គ្រងទឹក នៃជ្រលងប៊ីយ៉ែវ (SIAVB) និងលោក Jacques Bellier ប្រធានសមាគម AGERA និងសមាជិកបច្ចេកទេសមួយចំនួនទៀត ដូចជាលោកស្រី Béatrice Delgado លោក Manuel Pluvinage លោក Pascal Thévenot និងលោក Srun Kim Ang។

ប្រធានបទសំខាន់ៗនៃកិច្ចពិភាក្សាបានផ្តោតទៅលើការគាំទ្រនិងឧបត្ថម្ភរបស់សាលាក្រុងវែរសៃមកលើគម្រោងប្រព័ន្ធជំនួយស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរ (SDGERA) និងកិច្ចសហប្រតិបត្តិការនាថ្ងៃអនាគតរវាងស្ថាប័នទាំងពីរ៕



ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋនៅក្នុងឧទ្យានអង្គរ បានចំនួន៧៧ករណី និងសម្រេចអនុញ្ញាតបានចំនួន៧៧ករណី

ផ្សាយនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់ឧទ្យានអង្គរ តែងតែទទួលបាននូវការយកចិត្តទុកដាក់ អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះ ក្នុងការងារជួសជុលតូចតាចនូវលំនៅដ្ឋាន ក៏ដូចជាសំណង់ឧបម្ភ័ន្ធមាន របង ដំបូល ជញ្ជាំង សសរពុក២ជើម បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តង។ តាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំ ដោយក្រុមការងារសហគមន៍ នាយកដ្ឋានគ្រប់គ្រង់ដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែង ក្នុងសប្តាហ៍ទី២ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារសហគមន៍ បានចុះពិនិត្យសំណើ បានចំនួន៧៧ករណី និងសម្រេចអនុញ្ញាត បានចំនួនទាំង៧៧ករណី ទៅតាមបណ្តាស្រុក/ក្រុងទាំង៥ដូចខាងក្រោម៖

- ស្រុកពួក អនុញ្ញាតបាន ២៧ករណី
- ស្រុកបន្ទាយស្រី អនុញ្ញាតបាន១៣ករណី
- ស្រុកសៀមរាប អនុញ្ញាតបាន២០ករណី
- ស្រុកប្រាសាទបាគង អនុញ្ញាតបាន ៥ករណី
- ស្រុកអង្គរធំ អនុញ្ញាតបាន ១២ករណី



សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕





អាជ្ញាធរជាតិអប្សរា និងអង្គការ GIZ សម្ពោធគម្រោងចម្រោះទឹកស្អាតនៅប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤



នាព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា និងអង្គការ GIZ បានរៀបចំកម្មវិធីសម្ពោធ និងប្រគល់ជូនប្រព័ន្ធចម្រោះទឹកស្អាត នៅបរិវេណខាងមុខប្រាសាទបន្ទាយស្រី ក្នុងបំណងកាត់បន្ថយ កាកសំណល់ និងការបំពុលដោយសំរាមប្លាស្ទិកនៅតំបន់រមណីយដ្ឋានអង្គរ។

គម្រោងចម្រោះទឹកស្អាតនេះទទួលបានពីអង្គការ GIZ ដែលបានបំពាក់ម៉ាស៊ីនចម្រោះទឹកស្អាត ចំនួន២ទីតាំងនៅប្រាសាទបន្ទាយស្រី គឺទី១នៅក្នុងទីលានបដិសណ្ឋារកិច្ច និងទី២ នៅសាលបកស្រាយព័ត៌មានប្រាសាទបន្ទាយស្រី ក្នុងបំណងកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងការបំពុលដោយកាកសំណល់ប្លាស្ទិកនៅក្នុងបរិវេណប្រាសាទ។ មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរា បុគ្គលិកគ្រឹះស្ថានអង្គរ សមត្ថកិច្ចពាក់ព័ន្ធអ្នកលក់ដូរ និងភ្ញៀវទេសចរ អាចប្រើប្រាស់ទឹកស្អាតទាំងនោះបានដោយឥតគិតថ្លៃ ដោយគ្រាន់តែយកដបទឹកច្រកនៅតាមធុងចម្រោះខាងលើ។

លោក Frank Jattke ប្រធានក្រុមកាងារអាស៊ានប្រចាំប្រទេសកម្ពុជា នៃទីភ្នាក់ងារសហប្រតិបត្តិការ អាល្លឺម៉ង់ (GIZ) លើកឡើងថា នេះជាគម្រោងសាកល្បងដែល GIZ សហការជាមួយអាជ្ញាធរជាតិអប្សរា បំពាក់ឧបករណ៍ចម្រោះទឹកស្អាតប្រើប្រាស់នៅប្រាសាទបន្ទាយស្រីនេះ។ លោកបន្តថា ឧបករណ៍នេះមានសារសំខាន់ណាស់ ក្នុងការរួមចំណែកការកាត់បន្ថយការប្រើប្រាស់ដបប្លាស្ទិក ដែលកំពុងបង្កគ្រោះថ្នាក់ដល់ភពផែនដី ព្រោះវាមិនងាយរលាយឡើយ។ លោក Frank បន្ថែមថា ក្នុងរាល់មួយវិនាទី មានប្លាស្ទិកមួយលានដបដែលបានចរាចរលក់ និងកែច្នៃឡើងវិញ ដូច្នេះយើងត្រូវធ្វើការរួមគ្នា ចូលរួមក្នុងយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ដែលជាជំហានទី១ ដោយជំនួសដបទឹក ឬសម្ភារណាដែលប្រើប្រាស់បានយូរ និងងាយរលាយ។





មន្ត្រីអង្គការ GIZ លោក Frank រំពឹងថា គម្រោងទឹកស្អាតខាងលើនឹងទទួលបានជោគជ័យ ហើយក្នុងនោះ GIZ មានគម្រោងបន្តសហការជាមួយអាជ្ញាធរជាតិអប្សរា ឬរដ្ឋបាលខេត្ត ក្នុងការដំឡើងឧបករណ៍ចម្រោះទឹកស្អាតនេះនៅតាមប្រាសាទ ឬក្នុងទីក្រុង ដើម្បីងាយស្រួលដល់ភ្ញៀវទេសចរ ឬអ្នកពាក់ព័ន្ធ ប្រើប្រាស់ដោយឥតគិតថ្លៃ និងកាត់បន្ថយការបំពុលប្លាស្ទិក។



ឯកឧត្តម ឡុច កុសល អគ្គនាយករង និងជាតំណាង**ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណដល់អង្គការ GIZ ដែលសហការជាមួយអាជ្ញាធរជាតិអប្សរា ដំឡើងឧបករណ៍ចម្រោះទឹកស្អាតនៅពេលនេះ។ ឯកឧត្តមរំពឹងថា គម្រោងនេះនឹងទទួលបានជោគជ័យ និងមានការគាំទ្រពីមន្ត្រី-បុគ្គលិកអាជ្ញាធរ អ្នកលក់ដូរ កម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ពិសេសភ្ញៀវទេសចរដែលមកកម្សាន្តនៅប្រាសាទបន្ទាយស្រី។

ជាមួយគ្នានេះ **ឯកឧត្តម ឡុច កុសល** ក៏បានវ៉ែកដល់ការងាររបស់អាជ្ញាធរជាតិអប្សរា ដែលតែងតែយកចិត្តទុកដាក់ខ្ពស់លើការកាត់បន្ថយការបំពុលដោយសំរាមប្លាស្ទិកនៅតំបន់ប្រាសាទ ដូចជាមានការរៀបចំទុកដាក់ធុងសំរាម មានភ្នាក់ងារសម្អាត និងកែច្នៃសំរាមទាំងនោះឡើងវិញឱ្យអស់លទ្ធភាព។

បន្ថែមពីនេះ **ឯកឧត្តម ឡុច កុសល** សំណូមពរឱ្យអ្នកពាក់ព័ន្ធ ពិសេសអ្នកលក់ដូរ សូមចូលរួមសហការ និងញែកសំរាមឱ្យបានត្រឹមត្រូវ ដើម្បីងាយស្រួលដល់ការប្រមូលឱ្យកាន់តែមានប្រសិទ្ធិភាព។ ជាមួយគ្នានេះ ឯកឧត្តមក៏សង្ឃឹមថា GIZ នឹងបន្តជ្រោមជ្រែងកិច្ចសហការខាងលើនេះ នៅតាមប្រាសាទនានាបន្ថែមទៀត ក្នុងគោលដៅធ្វើយ៉ាងណាឱ្យតំបន់ប្រាសាទលែងមានការបំពុលដោយ សំរាមប្លាស្ទិក៕







រូបភាពប្រចាំសប្តាហ៍ ÷ ប្រាសាទលាក់នាង ជា«ហោបន់ស្រន់» របស់មន្ទីរព្យាបាលរោគ ដែលត្រូវបានកសាង នៅចុងសតវត្សរ៍ទី១២

ផ្សាយនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៤





រូបភាពប្រចាំសប្តាហ៍៖ ចម្លាក់ខ្លោចទ្វារព្រហ្មមុខបួនដ៏អស្ចារ្យ និងរូបទេពអប្សរដ៏ស្រស់ស្អាតជាច្រើនទម្រង់ នៅប្រាសាទតាសោម

ផ្សាយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤









អគ្គនាយកអាជ្ញាធរជាតិអប្សរា ជួបពិភាក្សាជាមួយប្រធាន SIAAP ក្នុងការជាកឱ្យដំណើរការគម្រោងប្រព័ន្ធដំឡូយស្វ័យប្រវត្តិគ្រប់គ្រងទឹកក្នុងតំបន់សៀមរាបអង្គរ (SDGERA)

ផ្សាយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤





នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាជាមួយលោក François Marie Didier ប្រធានសហជីព SIAAP (SyndicatInter départemental pour l'Assainissement de l'Agglomeration Parisien) ដោយមានការចូលរួមពីលោក Francisque Vigouroux ប្រធានសហជីពអន្តរសង្កាត់គ្រប់គ្រងទឹកនៃជ្រលងប៊ីវ៉ៃយ៉ែវ (SIAVB) លោក Jean-MichelBordes អគ្គនាយក SIAVB និងលោក Kim Srun Ang អនុប្រធានសមាគម AGERA ដើម្បីពិភាក្សាជាមួយសហជីព SIAAPក្នុងចូលរួមគាំទ្របន្តទៀតក្នុងគម្រោង SDGERA ធ្វើយ៉ាងណាអាចដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិក្នុងការគ្រប់គ្រងទឹកនៅរមណីយដ្ឋានអង្គរបានជោគជ័យក្នុងពេលដ៏ខ្លីខាងមុខនេះ។

សូមបញ្ជាក់ថា សហជីព SIAAP ក៏ធ្លាប់បានចូលរួមចំណែកយ៉ាងសំខាន់ជាមួយអាជ្ញាធរជាតិអប្សរានាពេលកន្លងមក ក្នុងគម្រោងមួយចំនួនក្នុងក្រុងសៀមរាប និងក្នុងការសិក្សាធ្វើប្រព័ន្ធចម្រោះទឹកកខ្វក់គំរូនៅក្នុងតំបន់អង្គរ ក្នុងក្របខ័ណ្ឌនៃគម្រោង PAAGERA និងនៅក្នុងក្រុងសៀមរាបកន្លងមកដែរ៕





ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០២៤ ក្រុមការងារឆ្នាក់ចារទេសចរ របស់អាជ្ញាធរជាតិអប្សរា ប្រចាំតំបន់ដៅប្រាសាទអង្គរវត្ត បានប្រទះឃើញទ្វារស័ព្ទដៃ ចំនួន១គ្រឿង ដែលភ្ញៀវទេសចរ បានភ្លេចនៅចំណុចច្រកចេញ

ផ្សាយនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤



ក្រោយពីរក្សាទុក ដើម្បីកុំឱ្យមានការបាត់បង់ ក្រុមការងារក៏បានប្រគល់ជូន ទៅម្ចាស់ដើមវិញ ដែលជាភ្ញៀវ ទេសចរជនជាតិបែលហ្សិក បន្ទាប់ពីពិនិត្យឃើញថា ពិតជារបស់គាត់ពិតប្រាកដមែន

អាជ្ញាធរជាតិអប្សរាបណ្តុះដើមស្នោត រាំង ស្តៅ និងអំពិល ជាំតាមជើងទំនប់ និងបារាយណ៍

ផ្សាយនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤





ក្រៅពីដើមឈើប្រណិត និងដើមឈើលម្អ ក្នុងនោះអាជ្ញាធរជាតិអប្សរា ក៏បាននិងកំពុងបណ្តុះប្រភេទ រុក្ខជាតិស្នោត ដើមរាំង ដើមស្តៅ និងដើមអំពិលផងដែរដើម្បីតុរុក្ខជាតិទាំងនេះមានភាពធន់នឹងទឹក និងអាកាសធាតុដែលអាចឱ្យគេយកទៅជាំដុះនៅជើងទំនប់ និងទីទំនាបលិចទឹកបាន។

លោក ញ៉ែម រស្មី មន្ត្រីបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ បានឱ្យដឹងថា ច្រើនឆ្នាំមកហើយ ដែលអាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមបណ្តុះរុក្ខជាតិស្នោត និងដើមរាំង ជាដើម ដើម្បីទុកជាំនៅតាមជើងទំនប់បុរាណ ទំនប់ធ្វើថ្មី និងតាមបារាយណ៍ជាដើម ព្រោះរុក្ខជាតិទាំងនោះ ងាយស្រួលថែរក្សា ហើយធន់នឹងអាកាសធាតុ។ តួយ៉ាងដូចជាដើមរាំង រុក្ខជាតិនេះមានភាព លូតលាស់លឿនពេលជាំនៅតាមជើងទំនប់ជិតទឹក ហើយវាក៏អាចរស់នៅក្នុងទឹករយៈពេលយូរដល់ទៅ ៦ខែ ឬលើសនេះក៏មានដោយមិនបារម្ភខ្លាចងាប់ឡើយ។ ជាក់ស្តែង តាមការបញ្ជាក់ពីលោក ញ៉ែម រស្មី អាជ្ញាធរជាតិអប្សរា បានជាំដើមរាំង និងស្នោតជិត២ពាន់ដើមនៅម្តុំសំណង់ទ្វារទឹកតាសោម ដែលបច្ចុប្បន្នពួកវាមានភាពលូតលាត់ល្អ និងមានអាយុចន្លោះ ៥ឆ្នាំ ទៅ១០ឆ្នាំ។

ក្រៅពីជួយការពារជើងទំនប់មិនឱ្យហូរច្រោះដី ក្នុងនោះប្រភេទរុក្ខជាតិខាងលើ ក៏មានអត្ថប្រយោជន៍សម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋផងដែរ។ ដូចជាដើមរាំង ដើមស្តៅ និងដើមអំពិល ពលរដ្ឋអាចអាស្រ័យផលដោយបេះធ្វើជាបន្លែសម្រាប់បរិភោគ សម្រាប់លក់ និងធ្វើជាឱសថផងដែរ។ លោក ញ៉ែម រស្មី បញ្ជាក់ថា ការបង្កើនការជាំស្នោត ជាផ្នែកមួយជួយលើកកម្ពស់រុក្ខជាតិតំណាងជាតិ និងរួមចំណែកអភិរក្សរុក្ខជាតិនេះកុំឱ្យបាត់បង់ផង។

ស្ថានីយបណ្តុះកូនឈើក្រាំងក្រូច ជាទីតាំងដែលអាជ្ញាធរជាតិអប្សរាប្រើប្រាស់សម្រាប់បណ្តុះប្រភេទ ដើមស្នោត ដើមរាំង ដើមស្តៅ ដើមអំពិល និងដើមរុក្ខជាតិដទៃទៀត សរុប១៥ប្រភេទ។

គួរបញ្ជាក់ថា គិតចាប់ពីឆ្នាំ២០១៤មក អាជ្ញាធរជាតិអប្សរាបានជាំដើមរាំងសរុបប្រមាណ៣ម៉ឺនដើម និងដើមស្នោតប្រមាណ៥៣ន់ដើម។ ចំនួននេះមិនរាប់បញ្ចូលការជាំរុក្ខជាតិផ្សេងៗទៀតទេ។ តាមរបាយការណ៍ ក្នុងឆ្នាំ២០២៣ កន្លងទៅ អាជ្ញាធរជាតិអប្សរាបានជាំកូនឈើក្នុងឧទ្យានអង្គរជិត៣ម៉ឺនដើម និងជាង២លានដើមគិតពីឆ្នាំ២០០៤មក៕

សិក្ខាកាម សិក្សាវគ្គបណ្តុះបណ្តាលជំនាញអភិរក្សថ្ម ចុះអនុវត្តការណាយកំបោរបាយអសម្រាប់ជួសជុល និងពង្រឹងថ្ម

ផ្សាយនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៤





សិក្ខាកាមជំនាន់ទី២ ចំនួន២០នាក់ ជាមន្ត្រី-បុគ្គលិក របស់អាជ្ញាធរជាតិអប្សរា ដែលសិក្សាវគ្គបណ្តុះបណ្តាលជំនាញផ្នែកអភិរក្សថ្មប្រាសាទ ពេលនេះបានឈានមកដល់វគ្គផលិតកំបោរបាយអដើម្បីជួសជុលពង្រឹងថ្មប្រាសាទ និងចុះអនុវត្តផ្ទាល់នៅប្រាសាទបន្ទាយសំរែ។



កញ្ញា Helen JACOBSEN អ្នកជំនាញអភិរក្ស និងជាគ្រូបង្គោលអភិរក្សថ្ម ឱ្យដឹងថា វគ្គបណ្តុះបណ្តាលដែលមានចំនួន១៣វគ្គនោះ បានឈានដល់វគ្គ១០ហើយ និងនៅសល់តែ២វគ្គទៀត ហើយនឹងមានការប្រលងបញ្ចប់នៅវគ្គ១៣។ ក្នុងវគ្គ១០នេះ សិក្ខាកាមសិក្សាពីទ្រឹស្តី និងការប្រើប្រាស់បាយអ។ កញ្ញា Helen បន្ថែមទៀតថា ដំបូងគឺឱ្យសិក្ខាកាមស្គាល់ពីអ្វីជាបាយអកំបោរ អ្វីជាបាយអកំបោរសើម បាយអស៊ីម៉ងត៍ ការញ៉ើឈ្មោល Epoxy សម្រាប់តភ្ជាប់ថ្ម និងថ្នាំ Ethyl Silicate សម្រាប់លាយជាមួយបាយអ។ បន្ទាប់មកតម្រូវឱ្យសិក្ខាកាមចុះអនុវត្តផ្ទាល់ជាមួយថ្មប្រាសាទដែលរងការខូចខាត ពុកផុយ ស្នាមប្រេះ ការព្យាបាល ការការពារដម្រាបទឹក និងបច្ចេកទេសប្រើបាយអតាមស្ថានភាពខុសៗគ្នាពីកន្លែងមួយទៅកន្លែងមួយក្នុងការងារជួសជុលអភិរក្ស។

បន្ទាប់ពីសិក្ខាកាមបានសិក្សាទ្រឹស្តី និងអនុវត្តនៅក្នុងការដ្ឋានដោយផ្ទាល់ សិក្ខាកាមទាំងអស់ទទួលបានចំណេះដឹងកាន់តែទូលំទូលាយ និងអាចផលិតបាយអសម្រាប់ជួសជុល ពង្រឹងថ្មដោយមានជំនាញច្បាស់លាស់។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលស្តីពីការអភិរក្សថ្មប្រាសាទ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ គឺជាកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា ជាមួយស្ថាប័ន GIZ នៃប្រទេសអាល្លឺម៉ង់ ដែលចាប់ផ្តើមតាំងពីពាក់កណ្តាលឆ្នាំ២០២២មក៕

ក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បើកកិច្ចប្រជុំអាណត្តិទី៦ លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវ បណ្ឌិតសភាចារ្យ គឿន សកុណា

ផ្សាយនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤











នៅព្រឹកថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤ នាសាលប្រជុំព្រះវិហារ ទីស្តីការក្រសួងវប្បធម៌និងវិចិត្រសិល្ប: **លោកជំទាវបណ្ឌិតសភាចារ្យ គឿន សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្ប: និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អណត្តិទី៦ លើកទី១ ដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធ ឯកឧត្តម អគ្គនាយកអាជ្ញាធរជាតិអប្សរា ឯកឧត្តម អគ្គនាយកគ្រឹះស្ថានអង្គរ លោកអភិបាលរងនៃគណ: អភិបាលខេត្តសៀមរាបតំណាងឯកឧត្តមអភិបាលខេត្តសៀមរាប ឯកឧត្តម អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា លោកប្រធាននាយកដ្ឋាន លោក លោកស្រី ជាមន្ត្រីជំនាញជាច្រើនរូប។ កិច្ចប្រជុំបានផ្តោតទៅលើការងារដែលអាជ្ញាធរជាតិអប្សរាសម្រេចបាននាឆ្នាំ២០២៣ ពិនិត្យលើវឌ្ឍនភាពការងារនិងបញ្ហាប្រឈមឆ្នាំ២០២៤ ព្រមទាំងផ្តល់នូវដំណោះស្រាយគន្លឹះដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពការងាររបស់អាជ្ញាធរជាតិអប្សរាទាំងមូល។









សិស្សានុសិស្សមកពីសាលារៀនចំនួន៣ ក្នុងតំបន់អង្គរទទួលបានការបូបរៀន ពីអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤

នាបរិវេណសាលាបឋមសិក្សាគោកគ្រើល ស្ថិតនៅក្នុងឃុំលាងដៃ ស្រុកអង្គរធំ នៅព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរា សហការជាមួយស្ថាប័នជានាគុណភាពជប៉ុន Japan Quality Assurance (JQA) បានប្រារព្ធកម្មវិធីសងទៅសង្គម ដោយមានចែកកាបូបសិក្សា ដល់សិស្សពូកែ និងសិស្សក្រីក្រ ចំនួន៥០នាក់ មកពីសាលារៀនចំនួន៣ ស្ថិតក្នុងតំបន់អង្គរ មានសាលាបឋមសិក្សាត្រពាំងស្វាយ សាលាបឋមសិក្សាដូនឌី និងសាលាបឋមសិក្សាគោកគ្រើល។ អញ្ជើញចូលរួមក្នុងឱកាសនោះមាន **ឯកឧត្តម សុខ លក្ខិណា** តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា លោក ភ័ន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ព្រមទាំងមន្ត្រី បុគ្គលិកអាជ្ញាធរជាតិអប្សរា លោកនាយកសាលាបឋមសិក្សាទាំង៣ លោកគ្រូ អ្នកគ្រូ អាជ្ញាធរក្នុងតំបន់ និងសិស្សានុសិស្សផងដែរ។



ចំពោះការផ្តល់កាបូបរៀនដល់សិស្សពូកែ និងសិស្សក្រីក្រ នៅក្នុងសាលាបឋមសិក្សាទាំង៣នេះ គឺជារង្វាន់លើកទឹកចិត្តក្នុងការខិតខំសិក្សារៀនសូត្រ និងសកម្មភាពរបស់ក្មួយៗ សិស្សានុសិស្សដែលជាក្រុមការងារបរិស្ថានរបស់សាលារៀន។

សូមជម្រាបថា សកម្មភាពទាំងនេះមិនមែនជាលើកដំបូងទេ ដែលអាជ្ញាធរជាតិអប្សរា បានរៀបចំពិធីចែកសម្ភារសិក្សា ព្រមទាំងកង់ជាដើមដល់សិស្សានុសិស្ស ស្ថិតក្នុងតំបន់រមណីយដ្ឋានអង្គរ៕





សិក្ខាកាម៦០នាក់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាល តួនាទីអ្នកគ្រប់គ្រងប្រាសាទ ជំនាន់ទី៣

ផ្សាយនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤





នៅព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៤នេះ សិក្ខាកាមដែលជាមន្ត្រី បុគ្គលិក និងពលករនៅតាមប្រាសាទ ក្នុងរមណីយដ្ឋានអង្គរសរុប ៦០នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី «តួនាទីអ្នកគ្រប់គ្រងប្រាសាទ» ជំនាន់ទី៣ ដែលធ្វើឡើងនៅនាយកដ្ឋានសណ្តាប់ធ្នាប់។

វគ្គបណ្តុះបណ្តាលខាងលើនេះធ្វើឡើងរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។ នេះជាវគ្គបណ្តុះបណ្តាលរយៈពេលខ្លី ដែលអាជ្ញាធរជាតិអប្សរាធ្វើឡើងក្នុងគោលដៅ ចែករំលែកចំណេះដឹងបន្ថែមដុំវិញការងារនៅក្នុងរមណីយដ្ឋានអង្គរ ដើម្បីបង្កើនសមត្ថភាពក្នុងការគ្រប់គ្រងការងារប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងធានាបាននូវវិធានការណ៍នានាក្នុងការទប់ស្កាត់រាល់សកម្មភាពមិនគប្បីមួយចំនួន ដែលប្រព្រឹត្តិឡើងដោយភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ។

សូមជម្រាបថា ការបណ្តុះបណ្តាលខាងលើនេះផ្តោតសំខាន់លើការងារមួយចំនួនដូចជា ស្វែងយល់ពីផែនទីហានិភ័យរបស់ប្រាសាទ ករណីហាមឃាត់ និងណែនាំភ្ញៀវថតរូបភាព ការរៀបចំសណ្តាប់ធ្នាប់ ការគ្រប់គ្រងទឹក ការគ្រប់គ្រងហានិភ័យដើមឈើ និងតួនាទីអ្នកគ្រប់គ្រងប្រាសាទ និងការកិច្ចដាដើម។ល។



អាជ្ញាធរជាតិអប្សរា រៀបចំបង្កើតសហគមន៍បម្រើសេវា ឱ្យអ្នកទេសចរអាចជិះទូកកម្សាន្ត នៅបារាយណ៍ជយតដាក

ផ្សាយនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤



អាជ្ញាធរជាតិអប្សរាកំពុងរៀបចំសហគមន៍សាមគ្គីមួយ ដើម្បីឱ្យបម្រើសេវាដល់អ្នកទេសចរជិះទូកលេងកម្សាន្តនៅបារាយណ៍ជយតដាក(បារាយណ៍ខាងជើង ឬបារាយណ៍នាគព័ន្ធ)។

លោក ទេស សុធី អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌ ឱ្យដឹងថា គោលបំណងនៃការបង្កើតសហគមន៍នេះ គឺដើម្បីអភិវឌ្ឍន៍ទេសចរណ៍នៅបារាយណ៍ជយតាដាកផង ដើម្បីបង្កើតការងារក្នុងសហគមន៍សម្រាប់ប្រជាពលរដ្ឋរស់នៅភូមិភ្លង់ និងភូមិលាងដៃរបស់ឃុំលាងដៃ។

អាជ្ញាធរជាតិអប្សរា រៀបចំជាវេន់ទស្សនាជិះទូកមើលសត្វព្រៃ និងសត្វស្លាបដ៏កម្រផ្សេងៗ ព្រមទាំងអាចផ្តិតយករូបភាពដ៏ស្រស់ត្រកាល ហើយអ្វីដែលពិសេសនោះ គឺទេសភាពថ្ងៃរៀបលិច។



អាជ្ញាធរជាតិអប្សរា បានរៀបចំគម្រោងបង្កើតសហគមន៍បម្រើសេវាទេសចរជិះទូកកម្សាន្តនៅបារាយណ៍ជយតាដាក តាំងតែពីឆ្នាំ២០១៧មក ក៏ប៉ុន្តែ គម្រោងនេះ បានខកខានដោយសារតែជំងឺកូវីដរាតត្បាត។ នៅដើមឆ្នាំ២០២២ អាជ្ញាធរជាតិអប្សរាបានផ្តួចផ្តើមរៀបចំគម្រោងដំណើរការទស្សនាចរ នៅបារាយណ៍ជយតាដាកនោះឡើងវិញ ដោយមានការគាំទ្រពីស្ថាប័នGIZ និងអង្គការយូណេស្កូ។ បារាយណ៍ជយតាដាក រួមទាំងប្រាសាទព្រះខ័ន សាងឡើងក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ នៅពេលទេសចរបានជិះទូកនៅក្នុងបារាយណ៍ហាក់បីដូចជានាំអារម្មណ៍បានទៅកាន់អតីតកាលដ៏រុងរឿងនាសម័យអង្គរ និងមានលក្ខណៈពិសេសខុសប្លែកពីទីតាំងផ្សេងៗ។

សូមភ្ញៀវទេសចរជាតិ និងអន្តរជាតិ ចូលរួមជិះទូកកម្សាន្តនៅបារាយណ៍ជយតាដាក ដែលជាផលិតផលទេសចរណ៍មួយថ្មី ដែលនឹងផ្តល់បទពិសោធន៍ល្អ ជាមួយបរិយាកាសខ្យល់បរិសុទ្ធ វារីជាតិ សម្បូរបែប សត្វព្រៃផ្សេងៗ ប្រាសាទនៅកណ្តាលបារាយណ៍ អមដោយទេសភាពវប្បធម៌សេវាកម្មល្អ សុវត្ថិភាពផ្តល់ឱ្យទេសចរមិនខកបំណងនោះឡើយ៕

សូមជម្រាបថា ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមានបំណងចង់ជិះទូកកម្សាន្តនៅបារាយណ៍ជយតដាក នេះអាចធ្វើការជាវសំបុត្របានតាមរយៈលេខទូរស័ព្ទ ០៩២ ៦៥ ៣៥ ១០ !



និស្សិតនៃសាកលវិទ្យាល័យន័រតុន ធ្វើទស្សនកិច្ចសិក្សា នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរ

ផ្សាយនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤





នៅរសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យន័រតុន សរុបចំនួនជិត១០០នាក់ បានធ្វើទស្សនកិច្ចសិក្សា ដើម្បីស្វែងយល់ និងធ្វើការស្រាវជ្រាវលើប្រធានបទ «បេសកកម្ម និងការកិច្ចរបស់អាជ្ញាធរជាតិអប្សរ» នៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរ។ នៅក្នុងឱកាសទទួលដំណើរទស្សនកិច្ចនោះ លោក ម៉ុក គន្ធី អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក តំណាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរ បានដឹកនាំក្រុមការងារជំនាញនៃអាជ្ញាធរជាតិអប្សរ ជួបសំណេះសំណាល និងធ្វើបទបង្ហាញស្តីពីបេសកកម្ម និងការកិច្ចរបស់អាជ្ញាធរជាតិអប្សរ៕







ក្រុមការងារសហគមន៍ បន្តចុះពិនិត្យសំណើពលរដ្ឋ ដែលកំពុងរស់នៅក្នុងឧទ្យានអង្គរ បានចំនួន៤៧ករណី និងសម្រេចអនុញ្ញាត បានចំនួន៤៧ករណី

ផ្សាយនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងឧទ្យានអង្គរត្រូវបានទទួលនូវការយកចិត្តទុកដាក់អំពីសំណាក់អាជ្ញាធរជាតិអប្សរា ដោយមានការអនុគ្រោះក្នុងការជួសជុលតូចតាចនូវលំនៅដ្ឋានក៏ដូចជាសំណង់ឧបត្ថម្ភសម្ព័ន្ធមាន របង ដំបូលជញ្ជាំង សសរពុក បង្គន់អនាម័យ រោងគោ ទ្រុងមាន់ និងទ្រុងជ្រូកជាដើម នៅលើទីតាំងកំពុងរស់នៅផ្ទាល់តែម្តង តាមរយៈការចុះពិនិត្យ និងសម្រេចជាប្រចាំដោយក្រុមការងារសហគមន៍នាយកដ្ឋានគ្រប់គ្រង់ដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរា។ ជាក់ស្តែងក្នុងសប្តាហ៍ទី៤(ទី២០ ដល់ទី២៤)នៃខែឧសភា ក្រុមការងារសហគមន៍បានចុះពិនិត្យសំណើបានចំនួន៤៧ករណី និងសម្រេចអនុញ្ញាតបានចំនួន៤៧ករណី ទៅតាមបណ្តាលស្រុក/ក្រុងទាំង៥ ដូចខាងក្រោម៖

- ស្រុកបន្ទាយស្រីអនុញ្ញាតបាន ១២ករណី
- ស្រុកប្រាសាទបាគងអនុញ្ញាតបាន ២ករណី
- ស្រុកពួកអនុញ្ញាតបាន ១៤ករណី
- ក្រុងសៀមរាបអនុញ្ញាតបាន ១៦ករណី
- ស្រុកអង្គរធំអនុញ្ញាតបាន ៣ករណី

សូមជម្រាបថា រាល់ការដាក់ពាក្យស្នើសុំច្បាប់ និងការអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។ ជាមួយគ្នានេះ ក្រុមការងារសង្កេតឃើញថា ក៏មានអ្នកដែលទទួលបានការអនុញ្ញាតហើយ ប៉ុន្តែពុំបានអនុវត្តត្រឹមត្រូវ ស្របនឹងការអនុញ្ញាតនោះឡើយ។

ដូច្នេះអាជ្ញាធរជាតិអប្សរា សង្ឃឹមថាបងប្អូនប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតឱ្យជួសជុលលំនៅដ្ឋានត្រូវអនុវត្តឲ្យស្របតាមចំណុចបច្ចេកទេសដែលមានការទទួលដឹងឮ ពីអាជ្ញាធរមូលដ្ឋាន និងទទួលស្គាល់ដោយអាជ្ញាធរជាតិអប្សរា៕







អគ្គនាយកអាជ្ញាធរជាតិអប្សរាទទួលជួបឯកឧត្តម ឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ីប្រចាំកម្ពុជា

ផ្សាយនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤

កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដោយអគ្គនាយករង និងមន្ត្រីជំនាញ បានជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា នាមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។ គោលបំណងសំខាន់នៃជំនួបនោះខាងលើ ដើម្បីពិភាក្សាការងារសំដៅពង្រីកកិច្ចសហការទៅលើកិច្ចការងារថែរក្សាបេតិកភណ្ឌ និងបង្កើននូវទំនាក់ទំនងទ្វេភាគីទៅថ្ងៃអនាគត។





សូមបញ្ជាក់ថា តាំងពីឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ២០០០ រដ្ឋាភិបាលឥណ្ឌូនេស៊ី បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងដំណើរការជួសជុលប្រាសាទនៅក្នុងតំបន់រមណីយដ្ឋានអង្គរផងដែរ៕





ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមិថុនា



រូបភាពប្រចាំសប្តាហ៍ៈ ប្រាសាទបន្ទាយស្រី ជាមួយនិងក្បូរក្បាច់ចម្លាក់ដ៏អស្ចារ្យ ដែលផុសពីផ្ទាំងថ្មតក់ពណ៌ផ្តាល្យូកកម្រមាន ដែលទស្សនីយភាពនេះ បានជិតជាប់ក្លុងក្រអៅបេះដូងភ្ឿៀវទេសចរគ្រប់ៗរូប

ផ្សាយនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤







រមណីយដ្ឋានអង្គរសូមស្វាគមន៍ ភត្តិមានកំពូលអ្នកប្រដាល់ពិភពលោក

លោក Manny Pacquiao

ផ្សាយនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤





អាជ្ញាធរជាតិអប្សរា ចាប់ផ្តើមកាត់បន្ថយសំណល់ប្លាស្ទិក ក្នុងតំបន់អង្គរ តាមរយៈការចែកដបទឹក ជូនមន្ត្រី-បុគ្គលិកប្រចាំការ នៅប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌នៃអាជ្ញាធរជាតិអប្សរា នាំយកដបទឹកចំនួន៥០ ចែកជូនដល់ភ្នាក់ងារទេសចរ ភ្នាក់ងារសណ្តាប់ធ្នាប់ បុគ្គលិកនិងកម្មករនៃមណ្ឌលបដិសណ្ឋារកិច្ចចំនួន៥០នាក់ នៅប្រាសាទបន្ទាយស្រី សម្រាប់ច្រកទឹកពិសារប្រចាំថ្ងៃ ក្នុងបំណងរួមគ្នាកាត់បន្ថយការប្រើប្រាស់ដបប្លាស្ទិកផ្សេងៗ និងលើកកម្ពស់បរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរឱ្យកាន់តែប្រសើរ។



លោក ចាន់ សំណាង ប្រធានគ្រប់គ្រងរួមនៃភ្នាក់ងារទេសចរ ឱ្យដឹងថា ការចែកជូនដបទឹកនេះ គឺចង់លើកទឹកចិត្តដល់មន្ត្រី-បុគ្គលិករបស់អាជ្ញាធរជាតិអប្សរា ដែលប្រចាំការនៅប្រាសាទបន្ទាយស្រី ដើម្បីធ្វើជាគំរូក្នុងការច្រកទឹកពីម៉ាស៊ីនចម្រុះទឹកស្អាត ដែលមានដាក់ឱ្យប្រើប្រាស់ និងបញ្ឈប់នូវការប្រើដបប្លាស្ទិកជាបន្តទៀត។





លោកស្រី ឈឹម រដ្ឋនា ប្រធានក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទបន្ទាយស្រី បានបង្ហាញសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង បន្ទាប់ពីទទួលបានដបទឹកថ្មី។ ក្នុងនាមជាប្រធានភ្នាក់ងារទេសចរនៅប្រាសាទបន្ទាយស្រី អ្នកស្រី ឈឹម រដ្ឋនា សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំនៃអាជ្ញាធរជាតិអប្សរា ក៏ដូចជាអង្គការGIZដែលបានផ្តល់នូវដបទឹក ក្នុងគោលបំណងរួមគ្នាដើម្បីកម្ពុជាគ្មានប្លាស្ទិក។



សូមបញ្ជាក់ថា កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ អាជ្ញាធរជាតិអប្សរា និងអង្គការ GIZ បានរៀបចំកម្មវិធីសម្ពោធប្រព័ន្ធចម្រោះទឹកស្អាត នៅបរិវេណខាងមុខប្រាសាទបន្ទាយស្រី ដើម្បីជូនដល់មន្ត្រី-បុគ្គលិក អាជ្ញាធរ អ្នកលក់ដូរ កម្លាំងសមត្ថកិច្ចពាក់ព័ន្ធពិសេសភ្ញៀវទេសចរ ដែលទៅកម្សាន្តនៅប្រាសាទបន្ទាយស្រីអាចពិសារ ក្នុងបំណងជួយកាត់បន្ថយ កាកសំណល់និងការបំពុលបរិស្ថានដោយសំណល់ប្លាស្ទិកនៅតំបន់រមណីយដ្ឋានអង្គរ៕



រូបភាពប្រចាំសប្តាហ៍÷ ខ្លោចទ្វារព្រហ្មមុខបួន និងចម្លាក់ទ្វារបាលដ៏រស់រវើក ដៅប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤







លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត អញ្ជើញចូលរួមអនុវត្តយោគៈនិងសមាធិ នៅបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤



ព្រឹកថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤ មូលនិធិគន្ធបុប្ផាកម្ពុជា បានរៀបចំកម្មវិធីធ្វើយោគៈ និងសមាធិនៅបរិវេណប្រាសាទអង្គរវត្ត ដោយមានការចូលរួមពី**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** ដែលជាប្រធានកិត្តិយសនៃមូលនិធិ ព្រមទាំងសមាជិក សមាជិកាប្រមាណ១០០នាក់។



លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត មានប្រសាសន៍ថា នេះជាលើកទីមួយដែលមូលនិធិគន្ធបុប្ផាកម្ពុជាបានរៀបចំកម្មវិធីយោគៈ និងសមាធិនៅប្រាសាទអង្គរវត្តដែលជាទីសក្ការគោរពបូជារបស់ប្រជាជនខ្មែរយើង។ កម្មវិធីនេះ មានគោលបំណងបួងសួងសុំសេចក្តីសុខ ចូលរួមកម្មវិធីមនុស្សធម៌ដើម្បីអែងគ្គាសថវិកាជួយដល់កុមារកម្ពុជាក្រោមមូលនិធិគន្ធបុប្ផាកម្ពុជា និងកម្មវិធីអប់រំសុខភាពផ្លូវចិត្ត សុខភាពផ្លូវកាយ សូប់អារម្មណ៍ដែលជំរុញឱ្យមនុស្សស្រឡាញ់សុខសន្តិភាព។





លោកជំទាវបណ្ឌិត ក៏បានថ្លែងអំណរគុណដល់មូលនិធិគន្ធបុប្ផាកម្ពុជា ដែលបានរៀបចំកម្មវិធីដ៏មានសារសំខាន់នេះឡើង និងសូមអរគុណដល់សប្បុរសជនទាំងអស់ដែលបានចូលរួមជាថវិកាដល់មូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីគាំទ្រដល់ដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផាដែលទទួលពិនិត្យ និងព្យាបាលកុមារដោយឥតគិតថ្លៃ មិនរើសអើង ក្នុងស្មារតី«ខ្មែរជួយខ្មែរ»ដើម្បីភាពញញឹមរបស់កុមារដែលជាអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា៕





អាជ្ញាធរជាតិអប្សរា សហការជាមួយក្រសួងយុត្តិធម៌ និងក្រុមកីឡាសេនាយុត្តិធម៌ បន្តដាំស្មៅ និងកូនឈើនៅបរិវេណជុំវិញប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤

នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៤ ឆ្លៀតឱកាសក្នុងកម្មវិធីជិះកង់អង្គរ លើកទី២ ដើម្បីរំអង្គាសថវិកាដោយស្ម័គ្រចិត្តរបស់មន្ត្រីរាជការ និងអ្នកវិជ្ជាជីវៈក្នុងវិស័យយុត្តិធម៌ ព្រមទាំងសប្បុរសជនប្រមាណជាង៣០០នាក់របស់ក្រសួងយុត្តិធម៌ និងក្រុមកីឡាសេនាយុត្តិធម៌ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ **ឯកឧត្តម កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ចូលរួមដាំកូនឈើចម្រុះចំនួន៣២០ដើម និងស្មៅចំនួន៦០០ម៉ែត្រការ៉េ នៅបរិវេណខាងត្បូងកសិន្ទប្រាសាទអង្គរវត្ត។

ការងារនេះធ្វើឡើងក្នុងយុទ្ធនាការដាំដើមឈើ និងស្មៅដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក ដើម្បីបន្សល់ទុកជាស្នាដៃការងារសង្គម និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផងដែរ៕





ប្រាសាទអង្គរវត្តជាប់លេខ១លើពិភពលោក ជាកន្លែងទស្សនាព្រះអាទិត្យរះល្អបំផុត

ផ្សាយនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៤





«ប្រាសាទអង្គរវត្ត» ជាប់ជាទីតាំងដ៏ល្អបំផុតលេខ១លើពិភពលោក សម្រាប់ទស្សនាព្រះអាទិត្យរះ។



យោងតាមគេហទំព័រ Mornings.co.uk ដែលប្រមូលទិន្នន័យ និងស្វែងរកពាក្យគន្លឹះ «ថ្ងៃរះ» នៅក្នុងប្រទេសប្រមាណ៧២ប្រទេសនៅជុំវិញពិភពលោក ក្នុងនោះប្រាសាទអង្គរវត្តរបស់ប្រទេសកម្ពុជា ជាប់ជាទីតាំងដែលទទួលបានការលើកឡើងច្រើនជាងគេ និងត្រូវបានចាត់ទុកថា «ជាកន្លែងដែលល្អបំផុតសម្រាប់ការទស្សនាព្រះអាទិត្យរះ» ។







អាជ្ញាធរជាតិអប្សរា កំពុងជួសជុលពង្រឹងគ្រឹះប្រាង្គលេខ៥ របស់ប្រាសាទបាគង

ផ្សាយនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៤

ក្រុមអ្នកបច្ចេកទេសនៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលពង្រឹងគ្រឹះតួប្រាង្គលេខទី៥ របស់ប្រាសាទបាគងដែលមានសភាពទ្រុឌទ្រោម និងមានហានិភ័យឱ្យរឹងមាំឡើងវិញ។

ប្រធានអភិរក្សតំបន់រលួស នៃអាជ្ញាធរជាតិអប្សរា លោក សារាយ គឹមហួល ឱ្យដឹងថា ស្ថានភាពរបស់ប្រាង្គលេខ៥ នៃប្រាសាទបាគងមានហានិភ័យខ្លាំង ជាពិសេស ជញ្ជាំងប្រាង្គពីគ្រឹះរហូតដល់កំពូល។

លោក សារាយ គឹមហួល បញ្ជាក់ទៀតថា ដោយសារតែភាពប្រឈមនិងគ្រោះថ្នាក់ច្រើន ទើបអាជ្ញាធរជាតិអប្សរាធ្វើការជួសជុលពង្រឹងរចនាសម្ព័ន្ធប្រាង្គលេខ៥ នៃប្រាសាទបាគងឡើងវិញ ដោយត្រូវពង្រឹងរចនាសម្ព័ន្ធឥដ្ឋ ជញ្ជាំង តួប្រាង្គ និងបិទស្នាមប្រេះនៅតាមជញ្ជាំង ដើម្បីការពារជម្រាបទឹក។

ប្រាង្គលេខ៥ នៃប្រាសាទបាគង បានរងការខូចខាតដោយសារកត្តាអាយុកាល អាកាសធាតុ និងឫសឈើតូចធំចាក់ចូលប្រាង្គ៕











ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា ធ្វើការជួសជុល ពង្រឹងជើងក្រោម ប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៤

នេះ គឺជាផ្នែកមួយ នៃកិច្ចការអភិរក្ស ដែលអាជ្ញាធរជាតិអប្សរា បានអនុវត្តជាប្រចាំ ដើម្បីថែរក្សាប្រាសាទលលៃ ជាទីសក្តារឱ្យនៅឈរវឹងមាំយូរអង្វែងបន្តទៀត។

សូមបញ្ជាក់ថា ប្រាសាទលលៃត្រូវបាន សាងឡើងក្នុងសតវត្សរ៍ទី៩ ដើម្បីឧទ្ទិសថ្វាយព្រះតសូរ។

ក្រុមអ្នកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងធ្វើការជួសជុល ពង្រឹងរចនាសម្ពន្ធផ្នែកខាងក្រោមជុំវិញតួនិរតី និងតួពាយ័ព្យប្រាសាទលលៃ ដែលមានសភាពទ្រុឌទ្រោមខ្លាំង។

ការងារជួសជុលនេះ ក្រុមអ្នកបច្ចេកទេស បានប្រមូលបំណែកឥដ្ឋដែលបាក់បែក និងពុកផុយមកធ្វើការពង្រឹង និងរៀបផ្ទុំតាមទីតាំងដើមឡើងវិញ ព្រមទាំង បិទបាយអតាមចន្លោះប្រហោង ដើម្បីការពារជម្រាបទឹក និងពពួកសត្វល្អិតផ្សេងៗ។





ក្រុមការងារបច្ចេកទេសបន្តចុះពិនិត្យទីតាំងស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ និងសំណង់សាធារណៈផ្សេងៗ សរុបចំនួន១៩ករណី

ផ្សាយនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៤

កំឡុងសប្តាហ៍ទី៤ នៃខែឧសភា ឆ្នាំ២០២៤នេះ (ចាប់ពីថ្ងៃទី២៧ដល់ថ្ងៃទី៣១ ខែឧសភា) ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងដីធ្លី បេតិកភណ្ឌក្រុង និងសហគមន៍ បានបន្តចុះពិនិត្យទីតាំងស្នើសុំសាងសង់លំនៅដ្ឋានប្រជាពលរដ្ឋ និងសំណង់សាធារណៈផ្សេងៗ សរុបចំនួន១៩ករណី។ ក្នុងរយៈពេលមួយសប្តាហ៍នេះ នាយកដ្ឋានបានអនុញ្ញាតចំនួន០៨ករណី ជូនដល់ប្រជាពលរដ្ឋ ដែលជាអ្នកស្រុកចាស់ ដែលទីតាំងស្នើសុំពួកគាត់មានសំណង់នៅក្នុងទិន្នន័យរូបភាពពីលើអាកាសឆ្នាំ២០០៤ (បានចុះពិនិត្យកន្លងមក)។ ទីតាំងដែលបានអនុញ្ញាតនោះរួមមាន៖





- ស្រុកបន្ទាយស្រី មាន៣ករណី
- ស្រុកប្រាសាទបាគងមាន១ករណី
- ស្រុកពួក មាន២ករណី
- ក្រុងសៀមរាប មាន១ករណី
- ស្រុកអង្គរធំ មាន១ករណី



សូមបញ្ជាក់ថា ចំពោះប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាតខាងលើ ក្រុមការងារបច្ចេកទេសបានជួយរៀបចំគំនូសប្លង់ ដែលមានស្តាបត្យកម្មបែបប្រពៃណីជូនផងដែរ។ ហើយរាល់ការដាក់ពាក្យស្នើសុំច្បាប់ ចុះពិនិត្យ គូរប្លង់ និងអនុញ្ញាត គឺពុំតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ។

អាជ្ញាធរជាតិអប្សរា សូមសំណូមពរដល់ប្រជាពលរដ្ឋដែលទទួលបានការអនុញ្ញាត សូមសាងសង់ឱ្យស្របតាមលក្ខណៈបច្ចេកទេស និងប្លង់ស្តាបត្យកម្មដែលភ្ជាប់ជាមួយលិខិតអនុញ្ញាតផងដែរ៕







កូនឈើចម្រុះចំនួន៤,១០៥ដើម ត្រូវបានអាជ្ញាធរជាតិអប្សរា ចែកចាយពីថ្ងៃទី១៦ ខែឧសភា ដល់ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤

ពីពាក់កណ្តាលខែឧសភា ដល់ដើមខែមិថុនា ឆ្នាំ២០២៤នេះ អាជ្ញាធរជាតិអប្សរាបានចែកចាយ កូនឈើចម្រុះសរុប ៤,១០៥ដើម តាមស្ថាប័ន វត្តអារាម និងដល់ប្រជាពលរដ្ឋទូទៅ ដែលបានដាក់ពាក្យស្នើ យកទៅដាំនៅទីតាំងផ្សេងៗ។ កូនឈើដែលចែកចាយទាំងនោះរួមមាន៖

- ផ្តល់កូនឈើចម្រុះជូនតំណាងវិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា ចំនួន៥៥៥ដើម ដើម្បីយកទៅដាំលម្អបន្ថែមក្នុងបរិវេណវិទ្យាស្ថាន ស្ថិតក្នុងភូមិអន្លង់ក្ងាន សង្កាត់ឃ្ជួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ កូនឈើទាំងនោះរួមមាន គ្រញូង១២៥ដើម ធ្នង់១២៥ដើម បេង១២៥ដើម គគីរ៥០ដើម កកោះ៥០ដើម រំដួល៥០ដើម និងផ្កាពុល៣០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ហេង ណារី ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ ចំនួន១០០ដើម ដើម្បីយកទៅដាំនៅភ្នំប្រសិទ្ធ៏។ កូនឈើទាំងនោះរួមមាន គ្រញូង២៥ដើម ធ្នង់២៥ដើម ច្រេស២៥ដើម និងបេង២៥ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ឡៃ សុភ័ស្ត ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០ដើម ដើម្បីយកទៅដាំនៅខេត្តតាកែវ។ កូនឈើទាំងនោះរួមមាន គ្រញូង២០ដើម ធ្នង់១០ដើម ច្រេស១០ដើម និងបេង១០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក ម៉ៅ ហាត់ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន២០០ដើម ដើម្បីយកទៅដាំនៅភូមិខ្ទីង ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់៥០ដើម បេង៥០ដើម កកោះ៥០ដើម និងលឿងរាជ៥០ដើម។

- ប្រគេទកូនឈើចម្រុះជូនតំណាងព្រះគ្រូចៅអធិការ វត្តមុនធាយលាងវនារាម ចំនួន៤០០ដើម ដើម្បីយកទៅដាំលំអក្នុងបរិវេណវត្ត ស្ថិតក្នុងភូមិគោកស្រុក ឃុំរ៉ាវិន ស្រុករ៉ាវិន ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ឈើទាល១០០ដើម គ្រញូង១០០ដើម ធ្នង់៥០ដើម បេង៥០ដើម ក្ងោក៥០ដើម និងរំដួល៥០ដើម។



- ប្រគេទកូនឈើចម្រុះជូនតំណាងព្រះភិក្ខុ ប៉ុង ផាន់ ចំនួន១,៣០០ដើម ដើម្បីយកទៅដាំលម្អក្នុងបរិវេណវត្ត និក្រោធារាម ស្ថិតក្នុងភូមិធាំធា ឃុំតាងអុង ស្រុកចំការលើ ខេត្តកំពង់ចាម។ កូនឈើទាំងនោះរួមមានគ្រញូង៣០០ដើម ធ្នង់២០០ដើម បេង២០០ដើម ឈើទាល២០០ដើម គគីរ២០០ដើម ផ្ទៀក១០០ដើម និងរំដួល១០០ដើម។

- ផ្តល់កូនធ្នង់ចំនួន១០០ដើម ជូនលោក ចាន់ សេងឡា អគ្គនាយករដ្ឋាការទឹកស្ទ័យតសៀមរាប ដើម្បីយកទៅដាំ នៅបរិវេណក្រុងរុនតាឯក តេជោសែននៃខេត្តសៀមរាប។

- ផ្តល់កូនឈើចម្រុះជូនលោក ស៊ន់ កាន់ តំណាងគណៈកម្មការវត្តរាជបូណ៍ ចំនួន៨០០ដើម ដើម្បីយកទៅដាំលម្អក្នុងបរិវេណពុទ្ធមណ្ឌលវិបស្សនាអន្តរជាតិនៃកម្ពុជា ស្ថិតនៅភូមិបំពេញរាជ្យ ឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម ធ្នង់១០០ដើម បេង១០០ដើម ឈើទាល១០០ដើម គគីរ១០០ដើម សែដា១០០ដើម និងក្វោក១០០ដើម។

- ផ្តល់កូនឈើចម្រុះជូនលោក អាំ ចំរើន ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន២០០ដើម ដើម្បីយកទៅដាំខេត្តកណ្តាល។ កូនឈើទាំងនោះរួមមាន គ្រញូង៧០ដើម បេង៧០ដើម និងធ្នង់៦០ដើម។
- ផ្តល់កូនឈើចម្រុះជូនលោក ឈុំ រឺ តំណាងវិទ្យាល័យបាយ័ន ចំនួន៤០០ដើម ដើម្បីយកទៅដាំបន្ថែមក្នុងបរិវេណ វិទ្យាល័យ ស្ថិតនៅភូមិគោកបេង សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់១០០ដើម បេង១០០ដើម រំដួល១៥០ដើម និងឥន្ទនេល៥០ដើម។





អ្នកជំនាញអាជ្ញាធរជាតិអប្សរា ជួសជុលខឿនជណ្តើរ និងបង្កាន់ដៃនាគ នៅជាន់ផ្ទាល់ដីរបស់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២៤



ក្រុមអ្នកជំនាញរបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងជួសជុលខឿនជណ្តើរ និងបង្កាន់ដៃនាគជាន់ផ្ទាល់ដី ផ្នែកខាងលិចនៃជណ្តើរខាងត្បូងរបស់ប្រាសាទអង្គរវត្ត ឱ្យមានភាពរឹងមាំ និងសោភ័ណភាពឡើងវិញ។



លោក សយ សុការិន្ទ បុរាណវិទូ និងជាភ្នាក់ងារអភិរក្សប្រាសាទអង្គរវត្ត ឱ្យដឹងថា បង្កាន់ដៃនាគ និងជើងទម្រធ្វើអំពីថ្មកក់ប្រវែង២២ម៉ែត្រ នៅផ្នែកខាងលិច នៃជណ្តើរផ្នែកខាងត្បូងរបស់ប្រាសាទអង្គរវត្ត បានរងការខូចខាតដោយសារកត្តាអាយុកាល ទឹកភ្លៀងហូរច្រោះ បណ្តាលឱ្យថ្មខឿនញែកចេញពីគ្នា និងធ្វើឱ្យទ្រេតខ្លាំងប្រឈមនឹងការដួលរលំ។



លោក សុការិន្ទ បន្ថែមទៀតថា ដើម្បីជួសជុលបង្កាន់ដៃនាគ ជើងទម្រនាគ ឱ្យបានល្អរឹងមាំ និងមានសោភ័ណភាពឡើងវិញ ក្រុមការងារត្រូវលើកបង្កាន់ដៃ និងក្បាលនាគរុះរើផ្នែងថ្ម ដែលជាខឿននៃបង្កាន់ដៃនាគចេញ រួចហើយសម្អាតកម្ទេចដីឱ្យស្អាត។ បន្ទាប់មក ក្រុមការងារត្រូវរៀបចំពង្រឹងគ្រឹះ ដោយបន្ថែមល្បាយដី រៀបថ្មឱ្យអិបចូលគ្នា ជួសជុលខ្លួននាគ ឬផ្លាក់ថ្មថ្មីជំនួសវិញ ព្រមទាំងជួសជុលជើងទម្រនាគ ឱ្យមានភាពរឹងមាំសិន ទើបរៀបចំដាក់បញ្ចូលតាមកន្លែងដើមវិញ។



សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាទើបតែបញ្ចប់ការជួសជុលបង្កាន់ដៃនាគនៅជាន់ផ្ទាល់ដី នាផ្នែកខាងកើតនៃជណ្តើរខាងត្បូងរបស់ប្រាសាទអង្គរវត្ត ជាស្ថាពរកាលពីចុងឆ្នាំ២០២៣កន្លងមក៕





រូបភាពប្រចាំសប្តាហ៍÷
ប្រាសាទអូរក្អែក សំណង់ឥដ្ឋកសាងនៅសតវត្សរ៍ទី៩ ស្ថិតក្នុងអតីតរាជធានីហរិហរាល័យ

ផ្សាយនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៤







ក្រុមការងារទឹកកំពុងជួសជុលពង្រឹងកែលម្អសំណង់ទ្វារទឹកសំខាន់ៗក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៤



ស្របពេលដែលរដូវវស្សាចូលមកដល់ ក្រុមការងារគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា ក៏កំពុងមមាញឹកណាស់ដែរ ពិសេសគឺការជួសជុលកែលម្អ និងត្រួតពិនិត្យទ្វារទឹកសំខាន់ៗ ដើម្បីធានាថា អាចដំណើរការបានល្អពេលមានទឹកច្រើន។



លោក ញ៉ែម រស្មី មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ក្រុមការងារនាយកដ្ឋានតែងតែចុះត្រួតពិនិត្យសំណង់ទ្វារទឹកនានាជាប្រចាំ ជាពិសេសមុនរដូវវស្សាមកដល់ ក្រុមការងារបស់លោកតែងចុះពិនិត្យ មើលដុំមេកានិចទ្វារទឹក ថាតើវាដំណើរការបានល្អឬយ៉ាងណា ដើម្បីឱ្យប្រាកដថា ពេលមានទឹកច្រើនវាមិនមានបញ្ហាចោទជាយថាហេតុ។ ក្រៅពីនេះ ក៏មានការពិនិត្យតាមដើងទ្វារទឹកផងដែរ ទ្វារទឹកណាខូចខាតខ្លាំង គឺក្រុមការងារអាជ្ញាធរជាតិអប្សរា រៀបចំជួសជុលឡើងវិញ និងឱ្យទាន់ពេលវេលា។



សូមបញ្ជាក់ថា សំណង់ទ្វារទឹកតូចធំសំខាន់ៗនៅក្នុងតំបន់រមណីដ្ឋានអង្គរមានសរុបជាង ២០០កន្លែង។ សំណង់ទាំងនោះត្រូវបានរៀបចំឡើងដើម្បីបញ្ជៀស និងគ្រប់គ្រងទឹកកុំឱ្យជន់លិចតំបន់ប្រាសាទនារដូវវស្សា និងក្រុងសៀមរាប និងងាយស្រួលបញ្ចូលទឹកទៅអាងស្តុកទឹក ឬបារាយណ៍សំខាន់ៗក្នុងតំបន់អង្គរ៕

រូបភាពប្រចាំសប្តាហ៍៖ ប្រាសាទក្តីស្វរ កសាងនៅចុងសតវត្សរ៍ទី៩ ក្បែរប្រាសាទបន្ទាយក្តី ប៉ុន្តែមិនសូវមានអ្នកស្គាល់

ផ្សាយនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៤











គាំទ្រជិះទូកកម្សាន្តនៅបារាយណ៍ជយតដាក ជាការលើកកម្ពស់ជីវភាពពលរដ្ឋ និងការអភិវឌ្ឍន៍ក្នុងសហគមន៍ជុំវិញបារាយណ៍ប្រវត្តិសាស្ត្រមួយនេះ

ផ្សាយនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤



សហគមន៍សាមគ្គីដើម្បីអភិវឌ្ឍន៍ទេសចរណ៍ដែលបម្រើសេវាទេសចរជិះទូកកម្សាន្តនៅបារាយណ៍ជយតដាក ឬបារាយណ៍នាគព័ន្ធ អំពាវនាវដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មកជិះទូកកម្សាន្តទស្សនាប្រាសាទនាគព័ន្ធ ស្ថិតនៅលើកោះកណ្តាលបារាយណ៍ ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ធម្មជាតិបែបប្រវត្តិសាស្ត្រ និងផ្តល់ការងារដល់ប្រជាជន រួមទាំងអភិវឌ្ឍន៍ក្នុងសហគមន៍ជុំវិញបារាយណ៍ប្រវត្តិសាស្ត្រមួយនេះបានកាន់តែល្អប្រសើរ។





អ្នកចែវទូកម្នាក់ទៀត រស់នៅភូមិលាងដៃ ឃុំលាងដៃ ដែលជាជនពិការជើងម្ខាងផង លោក សឿន សុភាព បង្ហាញអារម្មណ៍សប្បាយចិត្តដែលសហគមន៍ផ្តល់ការងារឱ្យលោកធ្វើជាអ្នកចែវទូក។ លោកបន្តថា ការគាំទ្រជិះទូកកម្សាន្តរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិពិតជាសំខាន់ណាស់ដើម្បីឱ្យពលរដ្ឋនៅជុំវិញបារាយណ៍នេះមានការងារធ្វើ។ ជាពិសេសជនពិការដូចជារូបលោក ដែលពិបាកស្វែងរកការងារធ្វើនៅឆ្ងាយផ្ទះ។

លោក អ៊ា នាង ជាអ្នកភូមិសំរោង ឃុំលាងដៃ ក្នុងចំណោមអ្នកបម្រើសេវាចែវទូក របស់សហគមន៍បារាយណ៍ជយតដាក បានឱ្យដឹងថា ភ្ញៀវទេសចរនឹងទទួលបានអារម្មណ៍សប្បាយប្លែកជាមួយនឹងធម្មជាតិផ្សេងៗដែលលាក់ខ្លួននៅក្នុងបារាយណ៍បុរាណមួយនេះ លើសពីការជើរឆ្លងស្ពាន។ ការងារចែវទូកដឹកភ្ញៀវទេសចរ មួយផ្នែកបានផ្តល់ឱ្យលោកមានចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសារ និងមួយផ្នែកទៀតសម្រាប់អភិវឌ្ឍន៍ក្នុងសហគមន៍ផង។

អាជ្ញាធរជាតិអប្សរា សហការជាមួយវិស័យឯកជន បន្តដាំកូនឈើនៅខាងលិចប្រាសាទព្រហ្មកិល

ផ្សាយនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤



កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២៤ ឆ្លៀតឱកាសក្នុងកម្មវិធីបោះដំរំយុវជនប្រចាំឆ្នាំ ក្រុមហ៊ុនDHLCambodia រួមជាមួយអង្គការបង្រៀនដើម្បីកម្ពុជា ព្រមទាំងលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សមកពីវិទ្យាល័យនានាក្នុងខេត្តកណ្តាល និងរាជធានីភ្នំពេញ ចំនួន៤៥នាក់ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ចូលរួមដាំកូនឈើចម្រុះចំនួន៥០០ដើម នៅបរិវេណខាងលិចប្រាសាទព្រហ្មកិល ក្នុងយុទ្ធនាការដាំដើមឈើ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក សម្រាប់បន្សល់ទុកជាស្នាដៃការងារសង្គម និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផង។





អ្នកជំនាញអាជ្ញាធរជាតិអប្សរា ធ្វើកំណាយស្រាវជ្រាវស្ពានហាលខាងកើតប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤



ក្រុមការងារបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរា កំពុងធ្វើកំណាយស្រាវជ្រាវទិន្នន័យបុរាណវិទ្យាទៅលើរចនាសម្ពន្ធរបស់ស្ពានហាលផ្នែកខាងកើតនៃប្រាសាទបេងមាលា ដើម្បីឈានទៅដល់គម្រោងជួសជុលនៅពេលខាងមុខ។

លោក ពុទ្ធ សុទ្ធ មន្ត្រីបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា ដែលបានដឹកនាំធ្វើកំណាយឱ្យដឹងថា ក្រុមការងារបានចាប់ផ្តើមធ្វើកំណាយស្រាវជ្រាវនៅលើស្ពានហាលនេះ គឺដើម្បីពិនិត្យលទ្ធភាពក្នុងការជួសជុលរចនាសម្ពន្ធស្ពានហាលខាងកើតប្រាសាទបេងមាលាឡើងវិញ។





សូមបញ្ជាក់ថា គម្រោងជួសជុលស្ពានហាលខាងកើតប្រាសាទបេងមាលា ស្ថិតក្រោមមូលនិធិនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង៕

លោក ពុទ្ធ សុទ្ធ ឱ្យដឹងទៀតថា ពេលកំណាយបកស្រទាប់ដីខាងលើឃើញថា កម្រាលស្ពានហាលផ្នែកខាងកើតនៃប្រាសាទបេងមាលាមានការស្រុតខ្លាំងដោយកន្លែង គ្រឹះក៏ចុះខ្សោយ និងហែកចេញពីគ្នា ធ្វើឱ្យគ្រឿងបង្គុំរបស់រចនាសម្ពន្ធស្ពានហាលមួយចំនួនមានដូចជា សសរបង្គាន់ដៃនាគ ខ្លួននាគ ក្បាលនាគ បាក់ជាច្រើនបំណែក ធ្លាក់ចូលក្នុងកសិន្ទ និងខ្លះទៀតកប់ក្នុងដី ដែលបណ្តាលមកពីកត្តាអាយុកាល និងធម្មជាតិ។







អ្នកជំនាញកំណត់អត្តសញ្ញាណថ្ម ប្រាសាទភ្នំខែង ដែលធ្លាក់រាយប៉ាយ ដើម្បីជួសជុលប្រាសាទឡើងវិញ

ផ្សាយនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៤

នៅការដ្ឋានជួសជុលប្រាសាទភ្នំបាខែង ក្រុមអ្នកជំនាញស្វែងរកថ្មប្រមាណ១០នាក់ រួមគ្នាប្រឹងប្រែងស្វែងរកថ្មទាំងនៅតាមបរិវេណប្រាសាទ និងនៅក្នុងព្រៃនៃជម្រាលភ្នំ ដើម្បីយកថ្មដែលចល័ចខុសពីតាំងដើមទាំងនោះមកជួសជុល និងរៀបចំផ្គុំនៅទីតាំងដើមឡើងវិញ។

លោក អ៊ុម ណារិទ្ធ ប្រធានក្រុមការងាររកថ្ម នៅការដ្ឋានជួសជុលប្រាសាទភ្នំបាក់ខែងឱ្យដឹងថា ការងារស្វែងរកថ្មដែលរលុះធ្លាក់រាយប៉ាយជុំវិញប្រាសាទភ្នំបាខែង មានបីប្រភេទ ក្នុងនោះមានថ្មជញ្ជាំងប្រាសាទកណ្តាល (ប្រាង្គពីរ៉ាមីត) ថ្មតួប៉មប្រាសាទតូចៗតាមថ្នាក់នីមួយៗ និងថ្មខឿនប្រាសាទឥដ្ឋ និងត្រូវកំណត់អត្តសញ្ញាណ រួមទាំងបែងចែកប្រភេទថ្មតាមរចនាសម្ព័ន្ធប្រាសាទ ក្រោយពីរកឃើញ។ ក្រៅពីនេះ ក្រុមការងារត្រូវប្រមូលថ្មនៅជម្រាលភ្នំដែលត្រូវបានគេប្រមូលយកមករក្សាទុកក្នុង៤សម័កាលចាប់តាំងពីសម័យបារាំង គឺយកតែថ្មណាដែលមិនមានក្បាច់ឬមិនអាចកំណាត់អត្តសញ្ញាណបាន យកទៅប្រើប្រាស់ជំនួសថ្មដែលបាត់បង់ប៉ុណ្ណោះ។ អ្នកជំនាញរូបនេះបន្តថា ក្រុមការងារបានខិតខំអស់ពីលទ្ធភាពក្នុងការស្វែងរកថ្មមកដាក់ទីតាំងដើមវិញ ហើយក្នុងចំណោមទាំងនោះ មានថ្មតួប៉មប្រាសាទតូចៗខ្លះ ដែលបានរលុះធ្លាក់សល់ពី៥០ទៅ៦០ដុំ ហើយក្រុមការងារបានរកឃើញប្រមាណ៧០ទៅ៨០ភាគរយ បានមកផ្គុំឡើងវិញ។

លោក សំ ធើត ជាអ្នកជំនាញរកថ្មម្នាក់ក្នុងចំណោមក្រុមការងាររកថ្ម មានប្រសាសន៍ថា លោកពិតជាមានមោទកភាពដែលបានចូលរួមជួសជុលប្រាសាទបុរាណភ្នំបាខែងនេះ។ តាមរយៈបទពិសោធន៍ជាង១០ឆ្នាំធ្វើការជួសជុលនៅប្រាសាទ ធ្វើឱ្យលោកស្គាល់ប្រភេទថ្មនីមួយៗដែលរលុះធ្លាក់ចេញពីទីតាំងដើម។ លោក ធើត បញ្ជាក់ថា ការងារនេះជោគជ័យ គឺការសហការល្អនៅក្នុងក្រុម បើទោះបីការងារនេះមានភាពស្មុគស្មាញខ្លាំង។ រីឯការរើជញ្ជូនថ្មពីគំនរនៅជម្រាលភ្នំវិញ ក៏ត្រូវការពេលវេលាយូរ ដើម្បីធ្វើតាមបច្ចេកទេសត្រឹមត្រូវ គឺអាចជញ្ជូនបានតែពី៣ទៅ៤ដុំក្នុងមួយថ្ងៃ៕







ក្រុមហ៊ុន WAKODO Cambodia
ចូលរួមដាំកូនឈើនៅបរិវេណ
ខាងមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងបុគ្គលិកក្រុមហ៊ុន WAKODO Cambodia ចំនួន១៣នាក់ បានសហការជាមួយអាជ្ញាធរជាតិអប្សរា ចូលរួមដាំកូនឈើចម្រុះចំនួន៥០ដើម និងស្មៅចំនួន១០០ម៉ែត្រការ៉ែ នៅបរិវេណអតីតផ្សារយាងធំ ស្ថិតនៅខាងជើងធៀងខាងលិចប្រាសាទអង្គរវត្ត។ ការងារនេះជាផ្នែកមួយនៃយុទ្ធនាការដាំដើមឈើ ដើម្បីអភិរក្សរមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក សម្រាប់បន្សល់ទុកជាស្នាដៃការងារសង្គម និងទុកជាអនុស្សាវរីយ៍នៃការចងចាំក្នុងរមណីយដ្ឋានអង្គរផង។





សម្រស់រុក្ខវិថីព្រះសីហនុ

ផ្សាយនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤



មុននឹងទៅដល់ប្រាសាទបុរាណនានានៅក្នុងរមណីយដ្ឋានអង្គរ អ្នកដំណើរ ឬទេសចរទាំងឡាយ ដែលធ្វើដំណើរលើកំណាត់ផ្លូវនៃរុក្ខវិថីព្រះសីហនុ ឆ្ពោះទៅកាន់រមណីយដ្ឋានអង្គរ នឹងទទួលបាននូវអារម្មណ៍ស្រស់ស្រាយជាមួយនិងធម្មជាតិ ព្រៃប្រឹក្សាលាស់ត្រួយបញ្ចេញពណ៌ខៀវខ្ចីនៅអមសងខាងផ្លូវគ្រប់រដូវកាល រួមជាមួយការយកចិត្តទុកដាក់ដាំកូនឈើបន្ថែមថ្មីៗ និងបោសសម្អាតថែទាំបរិស្ថានស្អាតជាប្រចាំរបស់ក្រុមការងារបរិស្ថាននៃអាជ្ញាធរជាតិអប្សរា។



សូមអ្នកដំណើរទាំងអស់គ្នាមេត្តាកុំបោះសំរាមគ្រប់ប្រភេទលើដងផ្លូវដែលនាំឱ្យប៉ះពាល់ដល់សោភ័ណភាពបរិស្ថាននិងអនាម័យនៃរមណីយដ្ឋានអង្គរ។



អាជ្ញាធរជាតិអប្សរាបង្កើនដាំដើមស្នោត ស្ថេរតាមទំនប់បុរាណ ឬមាត់ប្រឡាយនានា ដើម្បីថែរក្សាដើមស្នោតជាតំណាងអត្តសញ្ញាណរបស់ខ្មែរ

ផ្សាយនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

នាយកដ្ឋានគ្រប់គ្រងទឹក ព្រៃឈើ និងហេដ្ឋារចនាសម្ព័ន្ធ នៃអាជ្ញាធរជាតិអប្សរា ក្នុងមួយឆ្នាំៗ បានបណ្តុះនិងដាំកូនឈើពូជប្រណិតៗរាប់ម៉ឺនដើម ដើម្បីដាំដុះឡើងវិញក្នុងតំបន់រមណីយដ្ឋានអង្គរ។ ក្រៅពីឈើប្រណិតៗអាជ្ញាធរជាតិអប្សរាក៏បានគិតគូ ចំពោះការដាំដុះនូវប្រភេទដើមឈើលម្ហឬដើមឈើហូបផ្លែផ្សេងៗ ជាក់ស្តែង ស្នោតជាដើមឈើមួយតំណាងអត្តសញ្ញាណរបស់ខ្មែរ ក៏បានដាំដុះឡើងវិញផងដែរ។







លោកញ៉ែមរស្មីមន្ត្រីបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងទឹកព្រៃឈើនិងហេដ្ឋារចនាសម្ព័ន្ធនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ដើមស្នោតក្រៅពីជាឈើបុរាណមានអាយុកាលដ៏យូរលង់ ជាអត្តសញ្ញាណរបស់ខ្មែរ ក៏មានការប្រើប្រាស់ច្រើនសម្បូរបែបក្នុងជីវភាពរស់នៅប្រចាំថ្ងៃ តាំងពីដើមរហូតដល់ស្លឹក ដោយបងប្អូនប្រជាពលរដ្ឋអាចយកមកកែច្នៃជារបស់របរប្រើប្រាស់ឬវត្ថុអនុស្សាវរីយ៍ផ្សេងៗលក់ឱ្យទេសចរ ចំណែកផ្លែស្នោត និងទឹកស្នោត សម្រាប់ធ្វើនំលក់ជាដើម។ តម្រូវការប្រើប្រាស់ដើមស្នោត បានកើនឡើងជាប្រចាំ ជាហេតុអាចប្រឈមនិងការបាត់បង់ដើមឈើ ជាអត្តសញ្ញាណមួយនេះ បើសិនមិនមានការដាំដុះឡើងវិញនោះ។





លោក ញ៉ែម រស្មី បញ្ជាក់ថា អនុវត្តតាមទស្សនវិស័យ និងការគិតគូរវែង ឆ្ងាយរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា មកដល់បច្ចុប្បន្ននេះដើមត្នោត ដែលបានដាំដុះរួច និងកំពុងលូតលាស់យ៉ាងល្អប្រសើរ លើដីនៃឧទ្យានអង្គរ មានចំនួនប្រមាណ ៥,០០០ដើមរួចមកហើយ។ ខណៈក្រុមការងារក៏កំពុងបណ្តុះ នៅតាមស្ថានីយបណ្តុះកូនឈើនានា មានប្រមាណជាង២,០០០ដើមបន្ថែម ដើម្បីត្រៀមដាំដុះនៅតាមទីតាំងក្បែរមាត់ប្រឡាយ និងទំនប់បុរាណ នារដូវវស្សាខាងមុខនេះ។



នៅពេលដើមត្នោតដែលបានដាំដុះក្នុងពេលកន្លងមក លូតលាស់ហើយអាចអាស្រ័យផលបាន បងប្អូនប្រជាពលរដ្ឋនៅក្បែរៗនោះអាចអាស្រ័យផល តាមរយៈការបេះផ្លែ និងទឹកត្នោត យកទៅទ្រទ្រង់ជីវភាពប្រចាំថ្ងៃបាន ប៉ុន្តែអាជ្ញាធរជាតិអប្សរាសូមសំណូមពរបងប្អូនមិនត្រូវកាប់ដើមត្នោតទាំងនោះជាដាច់ខាត ព្រោះថាដើមឈើទាំងនោះ ទម្រាំដាំដុះឱ្យធំលូតលាស់ផ្តល់ផលមកវិញ ចំណាយពេលមិនតិចជាង២០ឆ្នាំឡើយ៕

ក្រុមភ្នាក់ងារទេសចរ កំពុងជាំស្មៅឡើងវិញ នៅខាងមុខប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៤



ក្រុមភ្នាក់ងារទេសចរប្រចាំប្រាសាទបន្ទាយក្តីកំពុងតែមមាញឹកក្នុងការងារជាំស្មៅឡើងវិញ នាបរិវេណខាងមុខប្រាសាទបន្ទាយក្តី ដើម្បីលើកកម្ពស់ភាពបៃតងនៅទីនោះ។





បន្ទាប់ពីស្មៅបានជាំរួចរាល់ ទីនោះនឹងមានទេសភាពបៃតងស្រស់បំព្រងយ៉ាងស្រស់ស្អាត។







រូបភាពប្រចាំសប្តាហ៍៖ ទីតាំងសំខាន់ៗមួយចំនួននៃប្រាសាទតាព្រហ្ម ដែលទេសចរជាតិ និងអន្តជាតិ និយមថ្តឹករូបភាពទុកជាអនុស្សាវរីយ៍

ផ្សាយនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤









អាជ្ញាធរជាតិអប្សរា ជួសជុល អភិរក្សប្រាសាទបាតជុំ ជំណាក់កាលទី៥

ផ្សាយនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤

ក្រុមការងាររបស់នាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បន្តការងារជួសជុលប្រាង្គកណ្តាលនៃប្រាសាទបាតជុំ ក្នុងជំណាក់កាលទី៥។ ការងារជួសជុលនេះ បានចាប់ផ្តើមតាំងតែពីពាក់កណ្តាលខែឧសភា ឆ្នាំ២០២៤។



កញ្ញា ដយ ពេជ្រដីវ៉ា វិស្វករនៃអាជ្ញាធរជាតិអប្សរា និងជាអ្នកគ្រប់គ្រងការដ្ឋានជួសជុលនៅប្រាសាទបាតជុំ ឱ្យដឹងថា បច្ចុប្បន្នក្រុមការងារកំពុងជួសជុលតួប៉មកណ្តាលផ្នែកខាងលើនៃប្រាសាទបាតជុំដោយជួសជុលនៅជ្រុងខាងជើង និងទិសអាគ្នেយ៍កន្លែងដែលមានហានិភ័យខ្លាំងជាមុនសិន និងបន្តជួសជុលកន្លែងខូចខាតផ្សេងៗរហូតដល់កំពូលប្រាសាទ ដើម្បីឱ្យរចនាសម្ព្ធន្ធឥដ្ឋមានភាពរឹងមាំឡើងវិញ និងទប់ស្កាត់ការហូរជ្រាបទឹកជាបន្តទៀត។









វិស្វករដដែលបន្តទៀតថា មុនជួសជុល ប្រាសាទបាតដុំ មានសភាពទ្រុឌទ្រោម និងគ្រោះថ្នាក់ខ្លាំង ដោយនៅផ្នែកខ្លះឥដ្ឋហែកចេញពីគ្នា ជញ្ជាំងឥដ្ឋពុកផុយ រលុះធ្លាក់ និងផ្នែកខ្លះទៀតនៃតួប៉មបានផ្លាស់ប្តូរទ្រង់ទ្រាយ ដែលទាមទារឱ្យមានការជួសជុលពង្រឹងជាបន្ទាន់។

ប្រាសាទបាតដុំ កសាងឡើងនៅពាក់កណ្តាលសតវត្សទី១០ ដោយមន្ត្រីជាន់ខ្ពស់ក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ ដើម្បីឧទ្ទិសដល់ពុទសាសនាមហាយាន។ ប្រាសាទនេះ កសាងនៅលើខឿនថ្មបាយក្រៀមពីរថ្នាក់ដែលមានតួប៉មសង់ពីឥដ្ឋចំនួន បី និងមានសិលាចារឹកចំនួន៦ផ្ទាំង។ ផ្នែកខ្លះនៃស្ថាបត្យកម្ម លម្អដោយថ្មកក់ដូចជាផ្តែរ សុំទ្វារ និងជើងខឿននៃតួប៉មទាំងបី។

ការងារជួសជុលមកដល់ដំណាក់កាលទី៥នេះ តួប៉មប្រាសាទទាំងបី នឹងមានភាពរឹងមាំជាងមុន ដោយពុំចាំបាច់ទល់ទ្រនៅតាមតួប៉មទាំងបីជាបន្តទៀតនោះទេ។ ប្រាសាទនេះ នឹងបានបង្ហាញសោភ័ណភាពឡើងវិញ គង់វង្សបានយូរអង្វែងទៅអនាគត ហើយភ្ញៀវទេសចរ ក៏នឹងអាចចូលទស្សនាស្វែងយល់នៅតាមតួប៉មនីមួយៗបានដោយសុវត្ថិភាព៕

រូបភាពប្រចាំសប្តាហ៍ៈ
ប្រាសាទបន្ទាយសំរែ៉ ក្រោមផ្ទៃមេឃខៀវស្រងាត់

ផ្សាយនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៤











សារលិខិតថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ក្នុងឱកាសដ៏ឧត្តុង្គឧត្តមប្រពៃថ្លៃថ្លា នៃព្រះរាជពិធីចម្រើនព្រះជន្ម គម្រប់ព្រះជន្ម៨៨ យាងចូល៨៩ព្រះវស្សា ដែលនឹងប្រព្រឹត្តទៅនាថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤











ការសម្អាតរុក្ខជាតិតាមប្រាសាទ ក្នុងតំបន់អង្គរបស់អាជ្ញាធរជាតិអប្សរា កាន់តែមមាញឹកក្នុងរដូវវស្សា

ផ្សាយនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤

នាដើមរដូវវស្សា ដែលមានភ្លៀងធ្លាក់ជាបន្តបន្ទាប់នេះ ក្រុមការងារសម្អាតរុក្ខជាតិតាមប្រាសាទនៃនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យារបស់អាជ្ញាធរជាតិអប្សរា កាន់តែមមាញឹកក្នុងការកាត់សម្អាតដើមរុក្ខជាតិ ឬស្មៅដុះនៅតាមប្រាសាទទាំងក្នុង និងក្រៅតំបន់អង្គរ ដើម្បីកាត់បន្ថយហានិភ័យដល់ប្រាង្គប្រាសាទ។

លោក ងិន ធី អ្នកគ្រប់គ្រងការងារសម្អាតរុក្ខជាតិតាមប្រាសាទ បានឱ្យដឹងនៅក្នុងពេលដឹកនាំក្រុមការងារចុះសម្អាតនៅប្រាសាទតាកែវថា ការកាត់សម្អាតរុក្ខជាតិ និងស្មៅនៅតាមប្រាសាទ គឺដើម្បីចៀសវាងកុំឱ្យវាបង្កផលប៉ះពាល់ដល់រចនាសម្ពន្ធរបស់ប្រាសាទ ទាំងប្រាសាទថ្មភក់ និងប្រាសាទឥដ្ឋ។ ជាពិសេសរដូវវស្សា គឺក្រុមការងារកាន់តែមមាញឹកសម្អាតនៅគ្រប់ប្រាសាទទាំងអស់ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរាទាំងក្នុង និងក្រៅតំបន់អង្គរ។ លោក ងិន ធី បន្តថា ក្នុងឆ្នាំនេះ ថ្វីត្បិតតែអាកាសធាតុក្តៅខ្លាំង ធ្វើឱ្យស្មៅមិនសូវមានដុះក៏ប៉ុន្តែចំពោះរុក្ខជាតិនៅតែដុះលូតលាស់ធម្មតា និងដុះកាន់តែច្រើននៅពេលរដូវភ្លៀង។ បញ្ហានេះ ទាមទារឱ្យមានការសម្អាតជាប្រចាំ ដើម្បីសោភ័ណភាពរបស់ប្រាសាទបុរាណផងនិងជៀសវាងការប៉ះពាល់ដល់ប្រាង្គប្រាសាទ និងរចនាសម្ពន្ធផ្សេងៗរបស់ប្រាសាទផង។

លោក ងិន ធី បញ្ជាក់ថា ការងារសម្អាតនេះ អាចរំខានដល់ទេសចរក្នុងរយៈពេលខ្លី ហើយលោកក៏សំណូមពរដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលបានទស្សនាប្រាសាទនានា ស្របពេលក្រុមការងារសម្អាតកំពុងបំពេញការងារមេត្តាកុំចូលទៅជិត ចៀសវាងគ្រោះថ្នាក់កើតឡើងដោយប្រការណាមួយជាយថាហេតុ។ ម្យ៉ាងទៀត សូមចូលរួមថែរក្សាបរិស្ថាននៅក្នុងរមណីយដ្ឋានអង្គរទាំងអស់គ្នា ដើម្បីលើកម្ពស់បរិស្ថាន និងតម្លៃជាសកលរបស់បេតិកភណ្ឌពិភពលោក។

សារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី បានទទួលសមុច្ច័យជា សំពត់ហូល និងជាមួង មានអាយុកាលយូរឆ្នាំពីប្រជាពលរដ្ឋចំនួន២៧គ្រួសារ រស់នៅស្រុកព្រៃកប្បាស ខេត្តតាកែវ

ផ្សាយនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤







កាលពីពេលថ្មីៗនេះ ក្រុមការងារសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី បានធ្វើដំណើរទៅកាន់ស្រុកព្រៃកប្បាស នៃទឹកដីខេត្តតាកែវ ដើម្បីទទួលសមុច្ច័យសរុបចំនួន៤៤ ពីប្រជាពលរដ្ឋចំនួន២៧គ្រួសារ មានដូចជា៖ ហូលពិតាន ចំនួន០៣ សំពតហូលចំនួន១៧ សំពត់ផាមួងលាត ចំនួន០៥ សំពត់អន្លូញចំនួន០៤ អាវផាមួង ចំនួន០៤ អាវហូលចំនួន០៥ កន្សែងហូលពានាចំនួន០២ កាបូបហូលចំនួន០២ ក្រណាត់ហូល ចំនួន០១ ក្រមាសូត្រ ចំនួន០១។

ចំពោះសមុច្ច័យចំនួន៤៤សមុច្ច័យ មានដូចជា ហូលពិតាន សំពត់ហូល អាវផាមួង និងក្រណាត់ហូល ជាដើម ដែលបងប្អូនប្រជាពលរដ្ឋចំនួន២៧គ្រួសារ រស់នៅក្នុងស្រុកព្រៃកប្បាស ខេត្តតាកែវ បានប្រគល់ជូន យកមករក្សាទុកក្នុងសារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី ដើម្បីតាំងបង្ហាញជូនសាធារណៈបានទស្សនា និងសិក្សាស្វែងយល់។

សូមជម្រាបថា សារមន្ទីរវាយនកណ្តាប្រពៃណីអាស៊ី មានទីតាំងស្ថិតនៅភូមិបឹងដូនប៉ា តាមបណ្តោយផ្លូវ៦០ម៉ែត្រ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ សារមន្ទីរបើកឱ្យសាធារណជនបានចូលទស្សនា ចាប់ពីថ្ងៃពុធ ដល់ថ្ងៃចន្ទ ពីម៉ោង៨និង៣០នាទីព្រឹក ដល់ម៉ោង៤ល្ងាច៕









សប្តាហ៍ទី២នៃខែមិថុនានេះក្រុមការងារពិនិត្យនិងតាមដានការសាងសង់ក្រោយទទួលបានការអនុញ្ញាត នាពេលកន្លងមកបានចំនួន ៦០ករណី និងការជួសជុលតូចតាចដោយក្រុមការងារសហគមន៍ ចំនួន ១៥៤ករណី

ផ្សាយនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤

ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរពីយូរមកហើយត្រូវបានទទួលការអនុញ្ញាតសាងសង់សំណង់នានាស្របតាមគោលការណ៍ច្បាប់ ដែលមានសុពលភាព០១ឆ្នាំ និងការងារជួសជុលតូចតាច(ដោយក្រុមការងារសហគមន៍) មានសុពលភាពរយះពេល ០៣ខែ។ រាល់សំណង់នានាដែលនៅមានសុពលភាពត្រូវបាននាយកដ្ឋានគ្រប់ គ្រងដីធ្លីបេតិកភណ្ឌក្រុង និងសហគមន៍ នៃអាជ្ញាធរជាតិអប្សរាបានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃជាប្រចាំ រហូតសំណង់ទាំង នោះសង់រួចរាល់មួយរយភាគរយ។

ជាក់ស្តែងក្នុងសប្តាហ៍ទី២ នៃខែមិថុនា ឆ្នាំ២០២៤ នេះមន្ត្រី-បុគ្គលិកជំនាញ បានចុះពិនិត្យ និងផ្តល់លក្ខណៈបច្ចេកទេសនូវសំណង់ដែលបានការអនុញ្ញាត កន្លងមកចំនួន ៦០ករណី និងការជួសជុលតូចតាចដោយក្រុមការងារសហគមន៍ ចំនួន ១៥៤ករណី ដែលស្ថិតក្នុងភូមិសាស្ត្រ ដូចខាងក្រោម៖

១. ក្រុងសៀមរាបចំនួន ៦៤ករណី
២. ស្រុកប្រាសាទបាគងចំនួន ១១ករណី
៣. ស្រុកបន្ទាយស្រីចំនួន ៦៣ករណី
៤. ស្រុកពួកចំនួន ៤២ករណី
៥. ស្រុកអង្គរធំចំនួន ២៧ករណី
៦. ស្រុកស្វាយលើ ០៧ករណី



សូមបញ្ជាក់ជូនផងដែរថា ក្នុងចំណោម ២១៤ករណី មាន ១៥៣ករណី កំពុងតែសាងសង់ ជួសជុលត្រឹមត្រូវតាមការអនុញ្ញាត និងមាន ៦១ករណី មិនទាន់សាងសង់។ ក្រុមការងារបច្ចេកទេស និងបន្តតាមដានការសាងសង់ និងជួសជុលរហូតដល់ការ អនុញ្ញាតផុតសុពលភាព និងការសាងសង់រួចរាល់មួយរយភាគរយ។



រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពស្រស់ស្អាតនៃធម្មជាតិ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៤













ព្រះវិហារចំណាស់អាយុជាង១០០ឆ្នាំ ក្លុងវត្តជំណាក់ ជាសម្បត្តិបេតិកភណ្ឌជាតិ កំពុងធឡូលបាន ការជួសជុល អតិរក្ស

ផ្សាយនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៤



ទីអារាមព្រះពុទ្ធសាសនាមួយនេះ ស្ថិតនៅតាមបណ្តោយស្ទឹងសៀមរាប ក្នុងក្រុងសៀមរាប ខេត្តសៀមរាប។ សំណង់ព្រះវិហារនៃអារាមនេះ តាមភស្តុតាងបានចារិកនៅលើជញ្ជាំងនៃសំណង់ក៏ដូចជាថេរដីកាព្រះគ្រូចៅអធិការបានបញ្ជាក់ ព.ស ២៤៦២ ដែលអាចជាឆ្នាំនៃការកសាង។ ពុទ្ធសាសនិក ជំនាន់មុន បានកសាងឡើង សម្រាប់បូជាដល់ព្រះរតនៈត្រ័យនៃព្រះពុទ្ធសាសនា ដែលក្នុងព្រះវិហារមានព្រះពុទ្ធរូបធំមួយព្រះអង្គ ហៅថាព្រះជីគង់ជាអធិបតី។

ព្រះវិហារត្រូវបានសាងសង់ឡើង នៅលើខឿនមួយជាន់ និងមានទទឹង១៥.៤ម បណ្តោយ៣៧ម ដែលសង់អំពីបេតុង និង ឈើផងដែរ។ ដោយហេតុ អាយុកាល និងបញ្ហាមួយចំនួនទៀត ជំបូលនៃព្រះវិហារមានការខូចខាត ធ្លុះធ្លាយ ដោយអន្លើ ដែលធ្វើឱ្យទឹកជ្រាបចូលដល់ខាងក្នុងវិហារ។ មិនតែប៉ុណ្ណោះ រចនាសម្ព័ន្ធនានា គ្រឿងបង្គំដំបូល សរសរ គ្រឹះ ក៏ចាស់មួយចំនួន ទ្រុឌទ្រោម ពុកផុយ ដែលតម្រូវឱ្យមានការជួសជុល ជាបន្ទាន់។ ជាហេតុពេលនេះ អាជ្ញាធរជាតិអប្សរាបានប្រើប្រាស់ទាំងបច្ចេកទេស និងថវិកា ដើម្បីជួសជុលសំណង់ ពិសិដ្ឋមួយនេះ ដោយគម្រោងជួសជុលបានចាប់ផ្តើមដំណើរការ ហើយគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤ខាងមុខនេះ។

ការជួសជុលនេះនឹងរួមចំណែកថែរក្សាកេរដំណែល នឹងតម្លៃគ្រប់យ៉ាង នៃស្ថាបត្យកម្មដ៏ចំណាស់នេះ បានបំពេញតួនាទីរបស់ខ្លួនជាបន្ត និងសម្រាប់ពុទ្ធសាសនិកចូលបំពេញបុណ្យកុសល្យ ក៏ដូចជាព្រះសង្ឃបំពេញកិច្ចវត្តតទៅ។

រូបភាពប្រចាំសប្តាហ៍៖ ទិដ្ឋភាពគួរឱ្យគយគន់ នៃប្រាសាទកណ្តាលស្រះស្រង់

ផ្សាយនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៤







ក្រុមការងារបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា ប្រចាំគោលដៅនៅអតីតក្រុងអង្គរធំ បន្តសកម្មភាពកាត់សម្ពាតស្មៅនៅក្នុងបរិវេណក្រុងអង្គរធំយ៉ាងមមាញ្ចឹក និងយកចិត្តទុកដាក់ ដើម្បីរក្សាឱ្យបានន្ទវសោភ័ណភាពស្រស់ស្ពាតគ្រប់ពេលវេលា ខណៈដែលមានស្មៅ រួមទាំងរុក្ខជាតិនានាជុះលូតលាស់កាន់តែលឿន និងច្រើននាពេលភ្លៀងធ្លាក់ញ្ចឹកញ្ចាប់នៅក្នុងរដូវវស្សា

ផ្សាយនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៤







កូនឈើចម្រុះចំនួន៥,៧៤០ដើម ត្រូវបានអាជ្ញាធរជាតិអប្សរា បន្តចែកចាយពីថ្ងៃទី០៦ ខែមិថុនា ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤

ផ្សាយនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤

អាជ្ញាធរជាតិអប្សរា បានបន្តចែកចាយកូនឈើចម្រុះសរុប ៥,៧៤០ដើមបន្ថែមទៀតទៅដល់ស្ថាប័នរដ្ឋ ឯកជន ព្រះសង្ឃ និងប្រជាពលរដ្ឋទូទៅ ដើម្បីយកទៅដាំនៅទីតាំងផ្សេងៗ។ កូនឈើដែលបានផ្តល់ជូនទាំងនោះរួមមាន៖





ពលរដ្ឋស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រគល់ហូលពិតាន ជូនសារមន្ទីរ វាយនភណ្ឌប្រពៃណីអាស៊ី ដើម្បីចូលរួមផ្សព្វផ្សាយឱ្យកូនខ្មែរបានស្គាល់

ផ្សាយនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤



ចំនួន៣ផ្ទាំង ពីពលរដ្ឋដែលជាអ្នកតម្បាញសូត្រនៅស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីពាក់កណ្តាលខែមិថុនា ឆ្នាំ២០២៤។ ហូលពិតាននេះ មានក្បាច់គោមសាច់រឿងព្រះវេស្សន្តរជាតក ដែលស្នាដៃពោរពេញដោយសិល្បៈ និងជំនាញយ៉ាងប៉ិនប្រសប់។ ប្រជាពលរដ្ឋ ដែលបរិច្ចាគហូលពិតាន មានបំណងចូលរួមផ្សព្វផ្សាយពីតួនាទីហូលពិតាននៅក្នុងសង្គមខ្មែរ ទៅកាន់សាធារណជន ព្រមទាំងបណ្តុះផ្នត់គំនិតស្រឡាញ់ និងជួយថែរក្សាឱ្យបានយូរអង្វែងតទៅមុខទៀត។

យាយ លឹម មៀច អាយុ៩១ឆ្នាំ ជាអ្នកភូមិត្រពាំងស្តុក ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ឱ្យដឹងថា គាត់ចេះជំនាញត្បាញហូលតាំងពីអាយុ២០ឆ្នាំ ហើយក៏អាចត្បាញហូលពិតានផង។ ថ្វីត្បិតតែសព្វថ្ងៃ គាត់មានវ័យជរាមិនអាចត្បាញបាន ក៏ប៉ុន្តែគាត់បរិច្ចាគហូលពិតានចំនួន១ផ្ទាំង ដែលជាស្នាដៃចុងក្រោយសម្រាប់ជាទាន មកដល់សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ដើម្បីអភិរក្ស និងតាំងបង្ហាញដល់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ លោកយាយ លឹម មៀច បង្ហាញទឹកចិត្តត្រេកអរជាខ្លាំង ក្នុងការធ្វើអំណោយហូលពិតានដល់សារមន្ទីរ ដោយលោកយាយចង់ឱ្យកូនខ្មែរជំនាន់ក្រោយបានស្គាល់ និងជួយថែរក្សាកុំឱ្យបាត់បង់។





អ្នកស្រី គង់ សុភ័ក្រ មន្ត្រីអភិរក្សវាយនកណ្ដៀនៃសារមន្ទីរវាយនកណ្ដៀប្រពៃណីអាស៊ី ឱ្យដឹងថា ថ្មីៗនេះសារមន្ទីរទទួលបានសមុច្ច័យចំនួន៤៤ ពីប្រជាពលរដ្ឋ២៧គ្រួសារ រស់នៅខេត្តតាកែវ។ ក្នុងចំណោមនោះ មានហូលពិតានចំនួន៣ ហើយហូលពិតាននេះមានតួនាទីសំខាន់ដូចជារូបព្រះបត់ដៃរ ដែលពួកគាត់ត្បាញសម្រាប់តាំងនៅទីសក្ការៈ ឬវត្តអារាម និងមានអ្នកជាវដើម្បីប្រគេនព្រះសង្ឃជាដើម។ ស្នាដៃសិល្បៈត្បាញហូលពិតានរបស់អ្នកខេត្តតាកែវ គឺមានជាច្រើនជំនាន់មកហើយ ដែលផ្ទេរជំនាញនេះបន្តគ្នារហូតមកដល់សព្វថ្ងៃ។ អ្នកស្រី គង់ សុភ័ក្រ ពន្យល់ថា បច្ចុប្បន្ននេះ កូនខ្មែរជំនាន់ក្រោយ មិនសូវស្គាល់ហូលពិតាននេះទេ គឺស្គាល់តែហូលដែលគេត្បាញសម្រាប់កាត់ជាសម្លៀកបំពាក់តែប៉ុណ្ណោះ។

សូមបញ្ជាក់ថា នៅសារមន្ទីរវាយនកណ្ដៀប្រពៃណីអាស៊ីក្រៅពីតាំងបង្ហាញសម្លៀកបំពាក់សហសម័យ និងឧបករណ៍តម្បាញមកពីបណ្ដាប្រទេសចំនួន៥ ដែលរស់នៅតាមដងទន្លេមេគង្គ និងទន្លេគង្គារ ក៏មានការអភិរក្ស និងតាំងបង្ហាញជាអចិន្ត្រៃយ៍នូវហូលពិតានចំនួន៦ផ្ទាំង មានក្បាច់គោមសាច់រឿងពុទ្ធប្រវត្តិ ក្បាច់គោមសត្វហង្ស និងក្បាច់គោមសត្វនាគជាដើម៕







ការងារសម្អាតបរិស្ថាន រួមគ្នាលើកតម្កើរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤

ក្រុមការងារបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា ប្រមាណជិត៣០នាក់ កំពុងមមាញឹកកាត់សម្អាតស្មៅ និងរុក្ខជាតិតូចៗនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ដើម្បីរក្សាឱ្យបានសោភ័ណភាពស្រស់ស្អាតគ្រប់ពេលវេលា។ ការសម្អាតនោះទៀតសោត គឺត្រូវប្រើប្រាស់ឧបករណ៍សម្អាតទៅតាមស្ថានភាពដី ទីតាំង និងស្មៅ ឬរុក្ខជាតិទាំងនោះ ដើម្បីឱ្យការសម្អាតមានប្រសិទ្ធិភាព។







បើទោះបីមានការសម្អាតជាប្រចាំ ក៏មានឃើញការទុកដាក់សំរាមមិនបានត្រឹមត្រូវនៅឡើយ។ ដូច្នេះ អាជ្ញាធរជាតិអប្សរាសូមអំពាវនាវដល់សារធារណជន ភ្ញៀវទេសចរជាតិ និងអន្តរជាតិ មេត្តាចូលរួមថែរក្សាបរិស្ថាន និងអនាម័យល្អនៅក្នុងរមណីយដ្ឋានអង្គរទាំងអស់គ្នា ចៀសវាង ការជើរជាន់ស្មៅនៅកន្លែងហាមឃាត់ ចោលសំរាមពាសវាលពាសកាលដែលនាំឱ្យបាត់បង់សណ្ដាប់ធ្នាប់ល្អ និងការខិតខំរបស់អាជ្ញាធរជាតិអប្សរា៕







បច្ចុប្បន្ន ជណ្តើរ មានការបាក់ស្រុត ដោយសារកត្តាយុកាល រុក្ខជាតិដុះចាក់ចូលគ្រឹះ ធ្វើឱ្យរចនាសម្ព័ន្ធសំណង់រងការពុកផុយ ទឹកដែលហូរនាំដីខ្សាច់ខាងក្នុងសំណង់ចេញទៅក្រៅ ធ្វើឱ្យថ្មរមៀលចេញពីទីតាំងដើម ជាហេតុធ្វើឱ្យជណ្តើរបាត់លំនឹង។ ចំណែកឯ កម្រាលវិញ ក៏មានទឹកហូរលិចពីលើកម្រាលចុះទៅក្រោមថ្ម ធ្វើឱ្យចំណុចមួយនៃជ្រុងអាគ្នេយ៍ បានបាក់ស្រុត ធ្លាក់ចូលទឹកទាំងស្រុងធ្វើឱ្យបាត់លំនឹង។

ជណ្តើរ និងកម្រាលជុំវិញដំបូលទឹក ភាគខាងកើត ខាងជើង និងខាងលិច របស់ប្រាសាទនាគព័ន្ធ កំពុងដំណើរការជួសជុល

ផ្សាយនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤





ក្រុមអ្នកបច្ចេកទេសនាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យា នៃអាជ្ញាធរជាតិអប្សរាអនុវត្តន៍គម្រោងជួសជុលជណ្តើរ និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងកើត ខាងជើង និងខាងលិចរបស់ប្រាសាទនាគព័ន្ធ ដែលកំពុងទទួលរងការខូចខាតធ្ងន់ធ្ងរឱ្យប្រសើរឡើងវិញ។

លោក ជា សារិទ្ធ បុរាណវិទូ នៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ការជួសជុលចាប់ដំណើរការតាំងពីដើមខែឧសភា ឆ្នាំ២០២៤ ដោយផ្តោតទៅលើការងារសំខាន់ៗមួយចំនួនដូចជា ការជួសជុលពង្រឹងជណ្តើរខាងលិចនៃស្រះខាងកើត និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងកើត ជួសជុលជណ្តើរខាងត្បូងនៃស្រះខាងជើង និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងជើង ជួសជុលជណ្តើរខាងកើតនៃស្រះខាងលិច និងកម្រាលជុំវិញដំបូលទបង្ហូរទឹកខាងលិច។

លោក សារិទ្ធ បញ្ជាក់ទៀត វិធីសាស្ត្រនៃការជួសជុល គឺធ្វើទៅតាមផ្នែកណាដែលរងការខូចខាត និងទ្រុឌទ្រោមខ្លាំង តែប៉ុណ្ណោះ បន្ទាប់ត្រូវជួសជុលពង្រឹងគ្រឹះដីខ្សាច់ ដីច្រាំងស្រះ ទម្រជណ្តើរ និងទម្រកម្រាល នឹងត្រូវរៀបផ្គុំជណ្តើរ និងកម្រាលឡើងវិញ៕









សម្រស់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤

ប្រាសាទអង្គរវត្ត ពេលដែលទេសចរទាំងឡាយបានមកទស្សនាហើយ តែងតែត្រូវបានគេកោតស្ងប់ស្ងែងភាពសម្បើមនៃសំណង់ស្ថាបត្យកម្មដ៏ល្អឯក រួមជាមួយក្បាច់លម្អចម្លាក់ទេវកថា និងចម្លាក់ទេពអប្សរនៅលើជញ្ជាំង ហាក់បីដូចជាកំពុងញញឹមស្វាគមន៍ភ្ញៀវទេសចរចម្រុះជាតិសាសន៍មកពីជុំវិញពិភពលោក តាំងពីឈានជើងចូលដល់ខ្លោងទ្វារ រហូតដល់ប្រាង្គកំពូលប្រាសាទ។





សេចក្តីជូនដំណឹង
ស្តីពីការកាប់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ឃជ/អប.សជណ
២៤

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើនិងកាត់ក្រឹមែកឈើ
មានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ និងទីតាំងសំខាន់ៗ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភណភាពនៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិអប្សរានឹងកាត់ដកហូតដើមឈើ និងកាត់ក្រឹមែកឈើ នៅតាមទីតាំងនានាដូចខាងក្រោម៖

- កាត់ក្រឹមែកឈើចំនួន០៨ដើម (ដើមសង្កែ០៣ដើម ដើមកន្សែង០២ដើម ដើមវល្លិ៍តាលើង០១ដើម ដើមខ្នាស់០១ដើម និងដើមក្រគង០១ដើម) ស្ថិតនៅបរិវេណប្រាសាទបន្ទាយក្តីមុខខាងកើត។
- កាត់ដកហូត និងកាត់ក្រឹដើមឈើចំនួន០៨ដើម (កាត់ដកហូតដើមឈើទាល១ដើម កាត់ក្រឹដើមឈើទាល៥ដើម ដើមចាម១ដើម ដើមឆ្នូក១ដើម) ស្ថិតនៅបរិវេណចំណតខាងលិចប្រាសាទព្រះខ័ន។
- កាត់ដកហូត និងកាត់ក្រឹដើមឈើចំនួន២៧ដើម (កាត់ដកហូតដើមពង្រ១ដើម កាត់ក្រឹដើមឈើទាល១៨ដើម ដើមស្រឡៅ២ដើម ដើមស្វាយ២ដើម ដើមស្លែង១ដើម ដើមក្រឹង១ដើម ដើមត្រគង១ដើម ដើមចាម១ដើម) ស្ថិតនៅបរិវេណខាងក្បែងទីលានដល់ដំរី(ភូមិខ្ចី)។
- កាត់ដកហូតដើមឈើទាលចំនួន១ដើម ស្ថិតនៅបរិវេណប្រាសាទចាយ័ន ស្រះទឹកខាងជើង។
- កាត់ដកហូតដើមឈើចំនួន០៦ដើម (ដើមពង្រ២ដើម ដើមស្វាយ១ដើម ដើមត្រែក្រឹម១ដើម ដើមអង្គោល ១ដើម ដើមក្រលៅ១ដើម) ស្ថិតនៅបរិវេណប្រាសាទកីមានអាកាស។
- កាត់ដកហូតដើមឈើទាលងាប់ចំនួន០២ដើម ស្ថិតនៅបរិវេណក្បែរគសិន្ធទឹកភូមិនគរក្រៅ។
- កាត់ដកហូត និងកាត់ក្រឹដើមឈើចំនួន០៣ដើម (កាត់ដកហូតដើមឈើទាល១ដើម ដើមសិរមាន់១ដើម កាត់ក្រឹដើមឈើទាល១ដើម) ស្ថិតនៅភូមិថ្នល់បណ្តោយ ឃុំព្រះដាក ស្រុកបន្ទាយស្រី ខេត្តសៀមរាប។
- កាត់ក្រឹមែកស្តង់ចំនួន០១ដើម ស្ថិតនៅបរិវេណប្រាសាទតាព្រហ្មខាងក្បែង។
- កាត់ក្រឹដើមឈើចំនួន២១ដើម (ដើមស្នួល១ដើម ដើមស្រឡៅ១ដើម ដើមម្លាក់ព្រៃ២ដើម ដើមចាម២ដើម ដើមអំពិល៣ដើម ដើមឈើទាលពីរដើម ដើមស្វាយ៨ដើម ដើមអង្គោល២ដើម ដើមពង្រ១ដើម ដើមក្រសាំង១ដើម និងឫស្សី១គុម្ព) ស្ថិតនៅបរិវេណសារមន្ទីរកុលគាជន៍អង្គរភូមិតានី។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៤ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៦ រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អគារបញ្ជាការ តូចប៊ីបង្គោលី ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដឹកនាំដោយលោកជំទាវ និងលោកបណ្ឌិត
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Koeng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ ជួសជុលជណ្តើរឈើចំនួន៩ទីតាំង នៅរួតទី២ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍របស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ និងវប្បធម៌នៃអាជ្ញាធរជាតិអប្សរា ជួសជុលពង្រឹងជណ្តើរឈើមានចំនួន៩ទីតាំង ស្ថិតនៅរួតទី២ របស់ប្រាសាទអង្គរវត្ត ដែលរៀបចំធ្វើឡើងសម្រាប់ឱ្យភ្ញៀវទេសចរដើរឡើង-ចុះ ជំនួសឱ្យការជាន់ជណ្តើរថ្មដោយផ្ទាល់ ដើម្បីកាត់បន្ថយសំណឹក និងសុវត្ថិភាពភ្ញៀវទេសចរផង។





ការជណ្តើរឈើទាំងនេះ រងការខូចខាតដោយសារអាកាសធាតុ និងអាយុកាល។ ក្រុមការងារផ្លាស់ប្តូរផ្នែកដែលខូចខាត ជួសជុលពង្រឹងឱ្យរឹងមាំឡើងវិញ ដោយប្តូរកូនគីង្គក់ និងមេក្រោមរបស់កាំជណ្តើរដែលពុកមួយចំនួន។ ការថែទាំជាប្រចាំនេះ ដើម្បីសោភ័ណភាព និងសុវត្ថិភាពភ្ញៀវទេសចរឡើង-ចុះ ឆ្លងកាត់ទៅទស្សនារួតបាកន្តរាប់រយនាក់ជារៀងរាល់ថ្ងៃ៕





ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង០៩:១៩នាទីព្រឹក ក្រុមការងារភ្នាក់ងារទេសចរប្រចាំគោលដៅប្រាសាទអង្គរវត្ត បានប្រទះឃើញកាបូបស្ពាយក្រោយពណ៌ខៀវមួយនៅចំណុចរួតទីពីខាងជើង លុះដល់វេលាម៉ោង០៩:៤៩នាទី មានភ្ញៀវទេសចរជនជាតិអាមេរិកម្នាក់ភេទប្រុស អាយុ៤៥ឆ្នាំ បានមករកកាបូបដែលបានបាត់ដោយពិនិត្យឃើញថាពិតជារបស់គាត់ពិតប្រាកដមែនក្រុមការងារទេសចរ សហការនគរបាលការពារបេតិកភណ្ឌ និងនគរបាលទេសចរណ៍ ធ្វើការប្រគល់ជូនគាត់វិញ។

ភ្នាក់ងារទេសចរ សហការជាមួយនគរបាលការពារបេតិកភណ្ឌ និងនគរបាលទេសចរណ៍ ប្រគល់សម្ភារជូនភ្ញៀវទេសចរដែលភ្លេចម្តុំៗ

ផ្សាយនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤



ជារឿយៗ ភ្នាក់ងារទេសចរតែងតែរើសបាននូវសម្ភារឬបស់របរមួយចំនួនដែលភ្ញៀវទេសចរបានជ្រុះ ឬភ្លេចនៅតាមប្រាសាទនានា ហើយសហការជាមួយនគរបាលការពារបេតិកភណ្ឌ នគរបាលទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់ ក្នុងការស្វែងរកម្ចាស់សម្ភារឬបស់របរទាំងនោះ ជូនទៅម្ចាស់ដើមវិញ។





ភ្នាក់ងារទេសចរ និងក្រុមការងារសណ្តាប់ធ្នាប់
នៃអាជ្ញាធរជាតិអប្សរា បានជួយសង្គ្រោះបឋម
និងសម្ភតរបួសជង់ភ្នៀវទេសចរចំនួន២នាក់
ដែលជួលម៉ូតូ បង្កឱ្យមានរបួសស្រាល
កំឡុងពេលជិះដើរកម្សាន្តនៅតំបន់រមណីយដ្ឋានអង្គរ

ការជួយសង្គ្រោះនេះនាពេលម៉ោងប្រមាណ១រសៀល
ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ នៅចំណុចប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤



ភ្នាក់ងារទេសចរបានប្រគល់ទូរសព្ទដូនភ្ញៀវទេសចរវិញ បន្ទាប់ពីភ្លេចនៅតាមប្រាសាទ

ផ្សាយនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤



នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ នេះ ក្រុមភ្នាក់ងារទេសចរប្រចាំតាមគោលដៅប្រាសាទ បានប្រទះឃើញ និងប្រគល់ទូរសព្ទ ជូនភ្ញៀវទេសចរវិញ បន្ទាប់ពីពួកគេបានភ្លេចកំឡុងពេលចូលទស្សនា នៅក្នុងបរិវេណប្រាសាទ។





ករណីទី១ កើតឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ នេះ នៅវេលាម៉ោង៣:៣៩នាទី ក្រុមការងារភ្នាក់ងារទេសចរប្រាសាទអង្គរវត្ត បានប្រទះឃើញទូរសព្ទដៃ១គ្រឿងម៉ាក Vivo ពណ៌ខ្មៅ នៅចំណុចមាត់ស្រះទឹកខាងលិចធៀងខាងជើងចំណុចព្រះរយព្រះពាន់។ មួយសន្ទុះក្រោយមកម្ចាស់ទូរសព្ទដៃខាងលើ បានត្រលប់មករកវិញ ក្រុមការងារក៏បានប្រគល់ជូនគាត់វិញភ្លាមៗតែម្តង។



ករណីទី២ នាវេលាម៉ោង ០៥:១៣នាទី មានភ្ញៀវជាតិម្នាក់បានរើសបានទូរសព្ទដៃ១គ្រឿង ម៉ាក SAMSUNG នៅប្រាសាទនាគព័ន្ធ និងបានយកមកប្រគល់ជូនភ្នាក់ងារទេសចរ ដើម្បីស្វែងរកម្ចាស់ដើមមកទទួលវិញផងដែរ។ លុះដល់ម៉ោង០៥:២៦នាទី ម្ចាស់ទូរសព្ទដៃបានត្រលប់មករកវិញ ក្រុមភ្នាក់ងារទេសចរសហការជាមួយភ្នាក់ងារសណ្តាប់ធ្នាប់ បានប្រគល់ជូនម្ចាស់វិញផងដែរ៕





ក្រុមការងារភ្នាក់ងារទេសចរ និងក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ រួមគ្នាថែរក្សាសោភ័ណភាពប្រាសាទ តាមគោលដៅរៀងៗខ្លួន

ផ្សាយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤

ក្រុមការងារភ្នាក់ងារទេសចរ និងក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ របស់អាជ្ញាធរជាតិអប្សរាដែលប្រចាំការតាមគោលដៅនីមួយៗ នៅក្នុងរមណីយដ្ឋានអង្គរបានសហការរួមគ្នាសម្អាតកំណកដី និងគ្រឿងបរិក្ខារទេសចរណ៍ផ្សេងៗ។ ក្នុងកំឡុងរដូវភ្លៀងធ្លាក់នេះដែរ ក្រុមការងារខាងលើ បានយកចិត្តទុកដាក់សម្អាត និងរៀបចំបរិវេណប្រាសាទ ចំពោះទីតាំងដែលមានទឹកដក់ និងដាំស្មៅបង្កើតភាពបៃតង ជាដើម ដែលជាផ្នែកមួយរក្សាបាន នូវសោភ័ណភាព និងតម្លៃប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរ។





សេចក្តីប្រកាសព័ត៌មាន ទាក់ទងនិងការបង្ហោះក្លុងបណ្តាញសង្គមមួយចំនួន ដោយបានធ្វើការបំប្លែងព័ត៌មានថាក្រុមការងារទប់ស្កាត់សំណង់ខុសច្បាប់ របស់អាជ្ញាធរជាតិអប្សរា ចុះរុះរើផ្លូវបេតុងរបស់ប្រជាពលរដ្ឋនៅភូមិជ្រៃ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប

ពាក់ព័ន្ធករណីនេះ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនសាធារណជន មេត្តាជ្រាបជូចខាងក្រោម

ផ្សាយនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ៤៩៤/ឆ.ស.ប.ក
២៤

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនសាធារណជនទាំងអស់ មេត្តាជ្រាបថា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ មានការបង្ហោះក្នុងបណ្តាញទំនាក់ទំនងសង្គមមួយចំនួន ដោយបានធ្វើការបំប្លែងព័ត៌មានថា ក្រុមការងារទប់ស្កាត់សំណង់ខុសច្បាប់របស់អាជ្ញាធរជាតិអប្សរា ចុះរុះរើផ្លូវបេតុងរបស់ប្រជាពលរដ្ឋនៅភូមិជ្រៃ សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប។ ពាក់ព័ន្ធករណីនេះ អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនសាធារណជន មេត្តាជ្រាបដូចខាងក្រោម៖

១/ ផ្លូវបេតុងខាងលើនេះ គឺត្រូវបានបុគ្គលឈ្មោះ ភឿន សុភាព ភេទប្រុស អាយុ៥១ឆ្នាំ មុខរបរជាមន្ត្រីនគរបាល ឋានន្តរសក្តិ វរៈសេនីយ៍ទោ ស្ថិតនៅក្នុងភូមិជ្រៃ សង្កាត់ទឹកវិល ក្រុង/ខេត្តសៀមរាប លួចសាងសង់ថ្មីៗនេះ អមដោយការកឥដ្ឋធ្វើស្តាន និងជីកស្រះខុសច្បាប់ កៀកជាប់នឹងប្រាសាទកោះហូរ ក្នុងដីទំនេរមួយកន្លែងនៃតំបន់ការពារទី១ របស់រមណីយដ្ឋានអង្គរ។ ក្រុមការងារអាជ្ញាធរជាតិអប្សរាបានចុះរុះរើ ក្រោយពីបានអនុវត្តរួចរាល់នូវនីតិវិធីពាក់ព័ន្ធនឹងសំណង់ខុសច្បាប់នេះ។ ជារួម ផ្លូវបេតុងខាងលើនេះ គឺជាផ្លូវឯកជន មិនមែនសម្រាប់ប្រើប្រាស់ទូទៅរបស់ប្រជាពលរដ្ឋទេ។

២/ អាជ្ញាធរជាតិអប្សរាអំពាវនាវដល់ប្រជាពលរដ្ឋ សូមមេត្តាកុំចូលរួមការពារនូវសកម្មភាពខុសច្បាប់ដែលបាននឹងកំពុងធ្វើឱ្យប៉ះពាល់ដល់តម្លៃបេតិកភណ្ឌ ព្រលឹងជាតិខ្មែរ។

៣/ ជាវិធានបន្ត អាជ្ញាធរជាតិអប្សរានឹងបន្តសហការជាមួយរដ្ឋបាលខេត្តសៀមរាប និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ជាប្រឈមនានា ហើយនឹងបន្តអនុវត្តនូវវិធានការច្បាប់ជាធរមាន ក៏ដូចជារៀបចំសំណើទៅស្ថាប័នគ្រប់គ្រងបុគ្គលខាងលើ ដើម្បីអនុវត្តវិធានការរដ្ឋបាល និងវិធានច្បាប់នានា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ មេត្តាជ្រាប និងសូមបញ្ឈប់ការចែកចាយបន្តនូវព័ត៌មានដែលមានចរឹតបំផ្លើសការពិត ក៏ដូចជាញុះញង់ឱ្យមានកំហឹងក្នុងសង្គម តាមការគួរ។

ថ្ងៃសុក្រ ៧ៗ៣ ខែ ដេឋ្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
សៀមរាប ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២៤
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋានៈ ភូមិបន្ទាត់ ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរជាតិអប្សរា
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province







រូបភាពប្រចាំសប្តាហ៍៖
សម្រស់ប្រាសាទអង្គរវត្តពេលព្រឹកព្រលឹម

ផ្សាយនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤







រូបភាពប្រចាំសប្តាហ៍៖
ប្រាសាទក្រខ៉ាន់ សំណង់ឥដ្ឋ ដែលមានក្បូរក្បាច់ចម្លាក់ច្បាស់ៗ លើជញ្ជាំងឥដ្ឋគួរឱ្យចង់គយគន់

ផ្សាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤







សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យស្វាយរៀង ធ្វើទស្សនកិច្ចសិក្សា នៅក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤







ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤ សាស្ត្រាចារ្យ សាកលវិទ្យាធិការ និងនិស្សិត សរុបចំនួន១៣៧នាក់ នៃសាកលវិទ្យាល័យស្វាយរៀងបានធ្វើទស្សនកិច្ចសិក្សាមកកាន់រមណីយដ្ឋានអង្គរ គោលបំណងដើម្បីសិក្សាស្វែងយល់អំពីការដឹកនាំ គ្រប់គ្រង និងដំណើរការនៃអាជ្ញាធរជាតិអប្សរា។

ប្រធានបទសំខាន់ៗ ដែលមន្ត្រីជំនាញអាជ្ញាធរជាតិអប្សរាបានធ្វើបទបង្ហាញនៅក្នុងឱកាសទទួលដំណើរទស្សនកិច្ច និងសម្របសម្រួលកម្មវិធីខាងលើជូនដល់សាស្ត្រាចារ្យ សាកលវិទ្យាធិការ និងក្រុមនិស្សិត មានដូចជា៖ សាវតារបស់អាជ្ញាធរជាតិអប្សរា រចនាសម្ព័ន្ធនៃអាជ្ញាធរជាតិអប្សរា តួនាទី ភារកិច្ចនៃអាជ្ញាធរជាតិអប្សរា លទ្ធផលដែលអាជ្ញាធរជាតិអប្សរាសម្រេចបាន និងបញ្ហាប្រឈមដែលអាជ្ញាធរជាតិអប្សរាជួបប្រទះ និងដំណោះស្រាយជាដើម៕









គ្រប់គ្រងដោយ

ឯកឧត្តម ឡុង កុសល

អគ្គនាយករងអាជ្ញាធរជាតិអប្សរា

លោក អ៊ឹម សុខរិទ្ធី

ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ

រចនា

លោក រ៉ុង អង្គូរែល

លោក ធោម មករា



កិច្ចការពារបេតិកណ្ឌវប្បធម៌
ជាតារកិច្ចរបស់ក្មួនខ្ញុំរគ្រប់ៗរូប



មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្តល់សេវាសាធារណៈតាមយន្តការច្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្ម អំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្គោងយុអំពិល ស្រុកប្រាសាទបាគងខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (តាមបណ្តោយផ្លូវហ្សាលដីហ្គោលឆ្ពោះទៅប្រាសាទអង្គរវត្ត)
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសេវាគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

លេខទំនាក់ទំនង

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

ម៉ោងបំពេញការងារ

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ចងក្រងដោយនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ
ឆ្នាំ២០២៣